សុខ សុគ្គាល សាស្ត្រាចារ្យបរិញ្ញាទស្សនវិជ្ជា

# ទស្សនវិជ្ជា

## សំនួរ ចំលើយ អត្ថាធិប្បាយ



### ថ្នាក់បញ្ចប់

www.elibraryofcambodia.org

សុខ សុត្ថាល
បរិញ្ញាបត្រអក្សរវិជ្ជា

# ទស្សនវិជ្ជា

សំណួរចំលើយ អត្ថាធិប្បាយ

## ថ្នាក់បញ្ចប់

ការផ្សាយរបស់
បណ្ណាគារ សមភាព - ប៉ារីស

www.elibraryofcambodia.org

www.elibraryofcambodia.org

# ទស្សនៈអ្នកនិពន្ធ

ដើម្បីឆ្លើយតបនឹងសំណូមពរ នៃ អស់លោកអ្នកមាន , មាន សាស្ត្រាចារ្យ , និស្សិត និង សិស្សានុសិស្សភាគច្រើន ដែលនិយម "ទស្សនវិជ្ជា", ម្យ៉ាងទៀតដើម្បីបំពេញ បំណងប្អូនសិស្សានុសិស្ស ថ្នាក់បញ្ចប់ដែលកំពុងស្រេកឃ្លាននូវ " អាហារទស្សនវិជ្ជា " ដើម្បី ប្រលងយកសញ្ញាបត្រ មធ្យមសិក្សាភាគទី ២ នៅចំណោចឆ្នាំរបស់ខ្លួន ទោះបីមានភារកិច្ចដ៏មមាញឹកក្នុងមុខក្រសួង និងក្នុងជីវភាពយ៉ាង ណាក្ដី, ក៏ខ្ញុំនៅតែខិតខំ - ព្យាយាម, ចងក្រង " ទស្សនវិជ្ជាថ្នាក់បញ្ចប់ សំណួរ ចំលើយ អត្ថាធិប្បាយ" នេះ, ដោយបានកើតមានជារូប រាងឡើង ។

និយមន័យ និង ឧត្តមគតិខ្លះ ដែលអស់លោក-លោកស្រីដែលជា អ្នកនិពន្ធទស្សនវិជ្ជា ក្នុងកម្មវិធីខេមរយានកម្ម នៃក្រសួងអប់រំជាតិបាន រៀបចំពីមុនមកហើយ ។ ដែលខ្ញុំពិនិត្យទៅ ឃើញថាត្រឹមត្រូវល្អឥត ខ្ចោះ, ក៏ត្រូវខ្ញុំស្រង់ឧត្តមគតិទាំងនោះខ្លះមកជូនជាថ្មីម្ដងទៀត ។ ក្រៅ ពីនេះ, ទស្សននិយមដែលខ្ញុំបានលើកយកមកបង្ហាញ និងពន្យល់ក្នុង សៀវភៅនេះ, ក៏មិនសុទ្ធតែកើតមកពីគោលគំនិតខ្លួនឯងឡើយ តែជា ទស្សនរបស់ " វចនានុក្រម - សកល " មានវចនានុក្រមឡារូស (LAROUSSE) និងរ៉ូប៊ែរ (Robert) ថ្មីជាដើម ។

www.elibraryofcambodia.org

រីឯគំរូ ឧទាហរណ៍ ដែលខ្ញុំលើកយកមកដាក់នៅក្នុងសៀវភៅនេះ ភាគច្រើន ខ្ញុំដកស្រង់ចេញពីគំនិតរបស់លោកបណ្ឌិត "ប៉ូល-ហ្វុលគីយេ" (Paul Foulquié) និងបណ្ឌិត "អាឡាំង-ដានីយេលូ" (Alain Danielou)

សូមបញ្ជាក់ថា , អ្នកនិពន្ធទស្សនវិជ្ជាដ៏ល្បីទាំងពីររូបនេះ សុទ្ធតែជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យផ្នែកអក្សរសាស្ត្រ-ទស្សនវិជ្ជា, ស្នាដៃគំនិតរបស់លោក បានទទួលការនិយមនិងសរសើរពីសកលលោកច្រើន ។

ទោះជាយ៉ាងនេះក្តី, ក៏យើងពុំបានអួតអាងថាជាវិញ្ញូជនមួយរូបណាឡើយ, គឺគ្រាន់តែ សិស្សានុសិស្សជាក់លាក់ដែលនិយម "សច្ចៈក្នុងទស្សនវិជ្ជា" , អាចបើកយកមកធ្វើជាមេរៀន សំរាប់បើកផ្លូវទៅកាន់ជោគជ័យបាន ។

អ្នកនិពន្ធ

www.elibraryofcambodia.org

# បញ្ជីអត្ថបទ

## សំណួរ - ចំលើយ


| | ទំព័រ |
|---|---|
| 1 - អ្វីជាទស្សនវិជ្ជា | 9 |
| 2 - បញ្ញា | 18 |
| 3 - ការបង្កើតថ្មី | 28 |
| 4 - ល្បិចទូទៅនៃគំនិត | 36 |
| 5 - ស្បទ់និងគំនិតស្បទ់ | 44 |
| 6 - គណិតវិទ្យា | 53 |
| 7 - ស្បង់រូបធាតុនិងវិធីពិសោធន៍ | 62 |
| 8 - ជីវវិទ្យា | 73 |
| 9 - មនុស្សវិទ្យា | 80 |
| 10 - សង្គមវិទ្យា | 97 |
| 11 - ទំនោរនៃធម្មជាតិមនុស្ស | 110 |
| 12 - ឆន្ទៈ | 115 |
| 13 - គោលករណីយកិច្ចនិងកុសល | 119 |
| 14 - សីលញ្ញាណ | 129 |
| 15 - ទំនួលខុសត្រូវនិងវិបាកវិនិច្ឆ័យ | 135 |
| 16 - ជីវិតផ្ទាល់ខ្លួនគុណធម៌ | 145 |
| 17 - សិទ្ធិនិងច្បាប់ | 154 |
| 18 - គ្រួសារ | 157 |
| 19 - យុត្តិធម៌និងការគោរពបុគ្គល សប្បុរសធម៌ | 165 |
| 20 - បញ្ហាសេដ្ឋកិច្ច | 171 |
| 21 - បញ្ហានយោបាយប្រជាជាតិ មាតុប្រទេស | 181 |


www.elibraryofcambodia.org

## អត្ថាធិប្បាយ 187


ប្រធានទី ១- ទស្សនវិជ្ជានិងវិទ្យាសាស្ត្រ 188

ប្រធានទី២- គណិតវិទ្យា និងពិសោធន៍ 193

ប្រធានទី៣- គណិតវិទ្យានិងសច្ចៈ 198

ប្រធានទី៤- សារៈសំខាន់នៃទស្សនវិជ្ជា 201

ប្រធានទី៥- គណិតវិទ្យាជាឧបករណ៍របស់សាស្ត្រ 204

ប្រធានទី៦- ការណ៍ (fait) និងទ្រឹស្តី 208

ប្រធានទី៧- សាស្ត្រអំពីសីលវិជ្ជានិងសាស្ត្រធម្មជាតិ. 211

ប្រធានទី៨- វិជ្ជាឯកទេសនៃសាស្ត្រនិងវិប្បធម៌ទូទៅ 213

ប្រធានទី៩- តក្កវិជ្ជាជាសីលវិជ្ជានៃគំនិត 218

ប្រធានទី១០- ទំនាក់ទំនងនៃជីវិតសីលវិជ្ជានិងសុភមង្គល 222


www.elibraryofcambodia.org

## ១– អ្វីជាទស្សនវិជ្ជា ?

1 - អ្វីជាទស្សនវិជ្ជា ?

ទស្សនវិជ្ជា គឺ ស្នេហាគតិបណ្ឌិត ។

2 - នរណាជាអ្នកអោយនិយមន័យដូចខាងលើនេះ ?

លោក ពីតាករ (Pythagore), អ្នកទស្សនវិជ្ជាក្រិច ។

3 - ចុះចំណែក លោក សូក្រាត (Socrate) យល់យ៉ាងណាដែរចំពោះពាក្យ " ទស្សនវិជ្ជា " នេះ ?

លោកសូក្រាតយល់ថា « ទស្សនវិជ្ជា » គឺ ចង់បានគតិបណ្ឌិត ព្រោះមនុស្សខ្វះគតិបណ្ឌិត ។

4 - នរណាខ្លះដែលជឿថា មនុស្សមានគតិបណ្ឌិតរួចហើយ ពោលគឺចំណេះជាសាកល ?

ពួក " សូភីស " (Sophiste) អ្នកទស្សនវិជ្ជាមួយក្រុមដែលប្រឆាំងនឹងគំនិតរបស់សូក្រាត ។

5- តើលោកសូក្រាត បានបញ្ជាក់សំដីអ្វីខ្លះទៅលើន័យថា មនុស្សគ្មានចំណេះជាសាកល ?

លោក សូក្រាតបានពោលថា ៖ « ខ្ញុំដឹងតែមួយមុខគឺខ្ញុំគ្មានចេះអ្វីទាំងអស់ » ។

(Je ne sais qu'une chose= c'estque je ne sais rien)



www.elibraryofcambodia.org

6- តើអ្វីទៅដែលហៅថា គតិបណ្ឌិតនោះ?

គឺការយកបញ្ហាទៅវិនិច្ឆ័យឲ្យបាន ត្រឹមត្រូវទៅលើបញ្ហាទាំងឡាយខាងបញ្ហាមនុស្សជាដើម តែត្រូវមាន លក្ខណៈប្រកបទៅដោយវិចារណញ្ញាណ នៃអាកប្បកិរិយា គឺការចេះប្រមាណនូវកំលាំងចំណង់របស់ខ្លួន ជាមួយនិងអំណាចត្រួតត្រាលើខ្លួនឯង ។

7- លោកសូក្រាតបានពោលយ៉ាងដូចម្ដេច ចំពោះការពិចារណារបស់មនុស្សតាមរបៀបទស្សនវិជ្ជា ?

លោកសូក្រាតពោលថា ការពិចារណាតាមបែបទស្សនវិជ្ជា គឺ ហាត់ស្លាប់ - ព្រោះសូក្រាតពិចារណាលើន័យរបស់ជីវិត ។

8- ចុះសិស្សថ្នាក់បញ្ចប់ត្រូវពិចារណា ទៅលើអ្វី ?

សិស្សថ្នាក់បញ្ចប់ត្រូវពិចារណាទៅលើកម្មវត្ថុនៃការសិក្សារបស់គេដូចជា :

១- ឧបករណ៍គំនិតដែលជាផលនៃពិសោធន៍របស់មនុស្សពីខាងមុន ។

២- ស្បង់និងវិវត្តន៍របស់ស្បង់ ។

9- តើយើងត្រូវពិចារណាអ្វីខ្លះជាបឋម ?

យើងត្រូវពិចារណាលើខ្លួនយើងជាមុន , បន្ទាប់មកទើបយើងចាប់ពិចារណា លើអ្វីៗដែលនៅជុំវិញខ្លួនយើង ។

10- កម្មវត្ថុនៃទស្សនវិជ្ជា បើពោលដោយសង្ខេបចែកជាប៉ុន្មានពួកធំៗ ?



www.elibraryofcambodia.org

កម្មវត្ថុនៃទស្សនវិជ្ជា ចែកជាបួនពួកធំៗ គឺ:

១- ចិត្តវិជ្ជា - ( Psychologie )

២- តក្កវិជ្ជា - ( Logique )

៣- សីលវិជ្ជា - ( Morale )

៤- បរមត្ថវិជ្ជា - ( Métaphysique )

11 - តើសព្វថ្ងៃផ្នែកដ៏ធំទាំងបួនរបស់ទស្សនវិជ្ជាស្ថិតនៅនិរន្តរទេ ?

សព្វថ្ងៃផ្នែកទាំងបួននៃទស្សនវិជ្ជាពុំស្ថិតនៅជានិរន្តរទៀតទេ បានបង្រួមមកជាពីរចំណែកវិញគឺ: ពុទ្ធិនិងអំពើ

12 - អ្វីទៅហៅថាពុទ្ធិ ?

ពុទ្ធិ (Connaissance) គឺការចេះដឹងដែលជាលទ្ធផលនៃការសិក្សាពីមុខវិជ្ជាច្រើនយ៉ាង ដូចជា ចិត្តវិទ្យា - តក្កវិជ្ជា សីលវិជ្ជា និងបរមត្ថវិជ្ជា ។

13 - អ្វីទៅហៅថាអំពើ ?

អំពើគឺអ្វីដែលមនុស្សធ្វើ ហើយបានលទ្ធផលមកពីគ្រប់វិស័យ ដូចជាវិស័យឧស្សាហកម្ម-សិល្បៈ សីលវិជ្ជា-សង្គមវិទ្យា។ល។

14 - គំនិតទស្សនវិជ្ជាមានលក្ខណៈពិសេសប៉ុន្មាន ?

គំនិតទស្សនវិជ្ជាមានលក្ខណៈពិសេសពីរ គឺ:

១ - គំនិតរិះគិត

២ - គំនិតកល្បស្រ័យ

15 - អ្វីទៅហៅថា គំនិតរិះគិត ?

គំនិតរិះគិត គឺ គំនិតដែលបានពិចារណាត្រឹមត្រូវរួចហើយ ។

www.elibraryofcambodia.org

ខ្វះញាណ ” (Science sans conscience) ចំណោះ ទៅតែលោកិយទាំងមូល កំពុងតែភិតភ័យខ្លាចបាក់បង់រូបកាយរបស់ខ្លួនទៅវិញថែមទៀតផង ។ ព្រោះថា បើកំលាំងអាតូមិច (Atomique) បានសម្លាប់មនុស្សក្នុង១វិនាទីអស់ដប់ពាន់នាក់, កំលាំងគ្រាប់បែកអ៊ីដ្រូសែន (Hydrogène) និងគុណចំនួនមនុស្សស្លាប់ក្នុងមួយវិនាទីនិងមួយរយ ។ ដូច្នេះគេត្រូវការទស្សនវិជ្ជាសាសនិច្ច ដើម្បីទប់កម្លាំងបៀនបៀន ដែលផ្តោតទៅរកការវិនាសនេះ ។

23- អ្នកយល់យ៉ាងណាដែរ ចំពោះការសិក្សាទស្សនវិជ្ជា នៅថ្នាក់បញ្ចប់ ។

ការសិក្សាទស្សនវិជ្ជានៅថ្នាក់បញ្ចប់ គឺការបើកផ្លូវឬត្រួសត្រាយផ្លូវជាលើកដំបូងសម្រាប់សិស្ស ។ ព្រោះថាសិស្សអាចបានដឹងនិងស្គាល់ផ្នែកនានាទាំងឡាយច្បាស់លាស់នៃទស្សនវិជ្ជាផង និងត្រួសត្រាយការឈានចាប់នូវមុខវិជ្ជាធំៗទាំងឡាយទៀតនៅក្នុងសិក្សាជាន់ខ្ពស់ជាពន្ធវិទ្យា (Ethnologie) មនុស្សធម្មជាតិវិទ្យា (Anthropologie) ជាដើម ។ល។ ដែលមានទំនាក់ទំនងជាច្រើនជាមួយនឹងទស្សនវិជ្ជា ។

24. មានមតិខ្លះយល់ថា ៖

“ការសិក្សាទស្សនវិជ្ជា គឺការពិចារណាទៅលើខ្លួនឯងផងនិងទៅលើអ្វីៗដែលនៅជុំវិញខ្លួនឯងផង„ តើអ្នកយល់យ៉ាងដូចម្តេចចំពោះទស្សនៈខាងលើនេះ ?



www.elibraryofcambodia.org

សូក្រាតបានពោលថា ៖
« សិក្សាទស្សនវិជ្ជា គឺ ហាត់ស្លាប់ » តើយើងត្រូវយកគំនិតពិចារណារបស់សូក្រាតមកប្រៀបធៀបនឹងវិគ្គទី១នៃសិក្ខាទស្សនវិជ្ជានេះបានឬទេ ?
លោកសូក្រាតបានពោលដូចព្រះពុទ្ធដែរ គឺ ត្រូវយកចិត្តទុកដាក់នឹងខ្លួនឯងសិនទើប, ទៅពិចារណាលើអ្នកដទៃ ។
ព្រះពុទ្ធជឿថា កម្មផល, និងប្រវត្តិនៃវាលវដ្តសង្សារកើតមានបានអាស្រ័យការមានរូបជាបច្ច័យ ។ ដូច្នេះបើមានរូបហើយ, បញ្ហាច្បាស់ជាស្ថិតនៅលើរូបនេះជាបឋម ។
ព្រះពុទ្ធពុំគ្រាន់តែប្រាប់យើងឲ្យយកចិត្តទុកដាក់នឹងខ្លួនយើងប៉ុណ្ណោះទេ, តែលោកបានបញ្ជាក់ថែមទៀតថា រូបនេះឯងជាប្រភពនៃជីវិត ។ ឧទាហរណ៍ = ទុក្ខកើតមកពីមានរូប-គឺមានរូបត្រូវតែមានទុក្ខ ។ ដូច្នេះបើមានទុក្ខហើយ ហេតុអ្វីក៏ពិចារណា រកហេតុនៃទុក្ខនេះនៅឯណាទៅវិញ ?
ត្រូវគ្នានឹងទស្សនៈរបស់សូក្រាត ដែលយល់ដូចព្រះពុទ្ធដែរ « សិក្សាទស្សនវិជ្ជាគឺហាត់ស្លាប់ » (Philosopher c'est apprendre à mourrir) ។ ក្នុងន័យនេះ សូក្រាតបានបញ្ជាក់ថា បើចង់ចាប់ពិចារណាពីហេតុការណ៍ទាំងឡាយដទៃណាមួយគេត្រូវចាប់ពិចារណាជាបឋមនូវជីវិត ពោល គឺ រាងកាយរបស់យើងជាមុនសិន ។ ក្នុងការស្វែងរកជំហុងសជាតិ ព្រះពុទ្ធពុំបានខានបន្ទូលប្រាប់ឲ្យយើងទៅពិចារណាលើព្រះនិព្វាន - ព្រះព្រហ្មឬឋានទេវលោកឯណាទេ តែត្រង់បានផ្ដាំឲ្យពិចារណាលក្ខណៈតែក្នុងខ្លួនយើងតែប៉ុណ្ណោះ ។



www.elibraryofcambodia.org

ដូច្នេះយើងឃើញថាវត្ថុទី១នៃបដិទានលើនេះ ពុំនទួល យកដំណោះស្រាយអ្វីបន្តិចឡើយ ។

ក្នុងវត្ថុទី២ ដែលបានថ្លែងថា ត្រូវតែមានការលើអ្វីៗដែលនៅជុំវិញខ្លួនយើងនោះ, បង្គួលឲ្យឃើញច្បាស់ថា ការវិលមនុស្សបានឆ្លងពីទីមួយទៅទីមួយទៀត ពោលគឺពីក្នុងពោះម្តាយមកក្នុងសង្គម ។

មនុស្សនេះឯងក៏ត្រូវតែទាក់ទងបញ្ហាមួយ គឺ សង្គមមនុស្ស ហើយដែលមានលក្ខណៈខុសពីបញ្ហាអត្ត ដោយគិតប្រកែកបាន ។ ការប្រលាក់ប្រល្ហូសជាមួយបញ្ហាសង្គម ព្រោះមនុស្សចូលខ្លួនទៅក្នុងសង្គម ដូច្នេះទោះបីញាណ ឬ អញ្ញាណក៏ដោយ មនុស្សត្រូវតែនាំគ្នាដោះស្រាយបញ្ហាទាំងឡាយនោះ ជាមួយអ្នកឯទៀតដែលជាសមាជិកនៃសង្គមនោះ ។

បើគ្រាន់តែយោលទៅលើសីលវិជ្ជា Morale មួយខ្សែ ប៉ុណ្ណោះយើងក៏ហាក់ដូចជាគ្រប់គ្រាន់ណាស់ ចំពោះវត្ថុទី ២ នៃបដិទានលើនេះ ។ ឧទាហរណ៍: ស្រុកកំពុងអត់បាយ ទំនិញសារពើមានតែលធិតល់ទីង ព្រមទាំងពុំអាចមានកំលាំងផ្ទប់អោយល្មមបាន ប្រៀបដូចទឹកជាក់មកលើទីទាប បើមនុស្សគិតពីអាត្មានិយមបើឡើងរស់ស្រួលតែឯង ឃើញថាវាមានគក្កភាពណាស់ចំពោះបុគ្គល ។ បើយើងអាចរស់នៅតែឯកឯងបានក្នុងសង្គមនោះវាជាការប្រសើរណាស់ ។ ក៏ប៉ុន្តែ ក្រែងនៅជុំវិញយើងមាន «បុគ្គល» របស់អ្នកដទៃពុំអនុញ្ញាតឲ្យយើងរស់ដោយសុខវិតម្នាក់ឯងបាន ។ ដូច្នេះយើងត្រូវ សំរុះសំរួល ជាមួយបញ្ហាទាំងឡាយដែលទាក់ទងឡើងនោះ



www.elibraryofcambodia.org

គ្រឿងយន្តទំនើបលោះហើរទៅដល់ឋានព្រះច័ន្ទ ព្រមទាំងយកថ្មឋានព្រះចន្ទបានវិលមកវិញផង ។ គេបានឃើញ។ មនុស្សបង្កើតគ្រឿងប្រហារយ៉ាងឃោរឃៅ ហើយមានកំលាំងមហិមាដូចជាកំលាំងអាតូមិកនិងកម្លាំងគ្រាប់បែកអ៊ីដ្រូសែនគេបានឃើញមនុស្សចេះបង្កើតមនុស្សយន្ត (Robot) ដើរដោយកំលាំងអេឡិចត្រូនិច ។ ឃើញថាកំលាំងបញ្ញារបស់មនុស្សមានកំរិត ស្ទើរនឹងហួសវិស័យនឹងនឹកដល់ ។ ទោះជាយ៉ាងនេះក្តី យើងក៏នៅតែឃើញថាមនុស្សពុំទាន់ផុតលក្ខណៈល្ងី (Idiotie) របស់ខ្លួននៅឡើយ ព្រោះមនុស្សពុំចេះទ្រទ្រង់រាងកាយរបស់ខ្លួនឲ្យរួចចាកពីការវិនាសបាត់ទៅនៃរូបហើយមនុស្សក៏ពុំអាចជៀសរួចអំពីសេចក្តីស្លាប់ ដែលមានលើមនុស្សគ្រប់រូបបានឡើយ ។ តែថាសេចក្តីស្លាប់ចុះវាជារបស់ដែលហួសនឹងគិតបាន ចុះបើមនុស្សចេះយកបញ្ញាមកប្រើយ៉ាងដូច្នេះ ហេតុអ្វីក៏មនុស្សមិនសាកល្បងធ្វើគ្រឿងយន្ត សម្រាប់ផលិតកំណាព្យ (La poésie) ដែលក៏ធ្លាប់ធ្វើបានរួចទៅហើយនោះផង?

ដូច្នេះ បញ្ញាមនុស្សបច្ចុប្បន្នពុំទាន់ឲ្យគេហៅថា «ជាពុទ្ធិសត្ថៈសាកល»នៅឡើយទេ ។

37- ដើម្បីវាស់បញ្ញារបស់ក្មេង. អ្នកប្រាជ្ញឈ្មោះប៊ីណេ (Binet) និង ស៊ីម៉ុង (Simon) បានរកមធ្យោបាយយ៉ាងណា ដើម្បីឲ្យដឹងថាក្មេងនោះមានបញ្ញាឬគ្មានបញ្ញា ?

អ្នកប្រាជ្ញទាំងពីរនេះបានយកអាយុបញ្ញា (âge mental) ទៅចែកនឹងអាយុពិត (âge réel) ហើយលទ្ធផលដែលបានមក



www.elibraryofcambodia.org

គេហៅថា „ លទ្ធបញ្ញា ” ។ បើលទ្ធបញ្ញាច្រើនជាងឯកត. (Unité) អ្នកប្រាជ្ញបានសំគាល់ថា ក្មេងនោះមានបញ្ញាខ្ពស់ ។ បើតិចជាងឯកតា, គេយល់ឃើញថា ក្មេងនោះមានបញ្ញាទាប ឬ អតិបញ្ញា ។

38 - តើវិធីវាស់បញ្ញារបស់លោកប៊ីណេ និងស៊ីម៉ុងត្រឹមត្រូវទាំងអស់ទៅលើបញ្ញារបស់មនុស្សខ្លួនទៅឬទេ ?

វិធីវាស់បញ្ញារបស់អ្នកប្រាជ្ញទាំងពីរនេះពុំត្រូវចំពោះមនុស្សទាំងអស់បានឡើយ ព្រោះអនុគមន៍នៃបញ្ញានិងពុទ្ធិរបស់មនុស្សនូវកល្បិតនៅក្នុងលក្ខណៈអរូបី ។ ហេតុដូច្នេះហើយបានជាបច្ចុប្បន្នកាលក្តី អតីតកាលក្តី គេពិតជាវាស់បញ្ញាមនុស្សដោយដាក់វិញ្ញាសាឲ្យមនុស្សដោះស្រាយជាចាំបាច់ ។

39 - លោក "កាលម៉ាក់" ( Karl marx ) និយាយថា៖ ភាពខុសគ្នារវាងស្ថាបត្យករដែលគ្មានថ្វីដៃសោះ និងសត្វឃ្មុំដែលពូកែ, នៅត្រង់ហេតុថា ស្ថាបត្យករមានប្លង់ផ្ទះនៅក្នុងក្បាលមុននឹងចាប់សង់ ។ តើអ្នកយល់យ៉ាងណាចំពោះសំដីខាងលើនេះ? ចូរពិភាក្សា ។

ស្ថាបត្យករ គឺមនុស្សដែលផលិតនូវស្នាដៃផ្សេងៗ តាមមុខវិជ្ជារបស់ខ្លួន គឺ ស្ថាបត្យកម្ម ។ សំណង់ទាំងឡាយអាចកើតជារូបរាងបានអាស្រ័យការគូរវាស់តាមមុខវិជ្ជានៃស្ថាបត្យករនោះ។ មុននឹងសាងនូវសំណង់អ្វីមួយ ស្ថាបត្យករបានគិតពិចារណារាវរកទេពកោសល្យតាមឧបនិស្ស័យរបស់ខ្លួន, ហើយឧប-



www.elibraryofcambodia.org

និស្ស័យនេះតែងទាក់ទងទៅនឹងសម្បទាបញ្ញា ពិសេស សំរាប់ស្ថាបត្យករនោះឯង ។

ចំណែកសត្វឃ្មុំកាលណាវាចាប់ធ្វើសំបុក, វាពុំមានការគិតពិចារណា ហើយគ្មានរូបភាពសំណង់នៅក្នុងក្បាលវាដូចមនុស្សឡើយ ។ គឺកាលណាវាបានជ្រើសរើសបន្ទំល្អមនឹងធ្វើសំបុកហើយ ឃ្មុំក៏ចាប់ផ្ដុំគ្នាពាក់ពួនហើយរចនាសម្ពន្ធទំលាប់ ក៏ធ្លាំងសភាវគតិឃ្មុំឲ្យបញ្ចេញក្រមួនជាសំណង់ភ្លាមៗសំរាប់ក្សាក្បាលទឹក ។ ដូច្នេះឃ្មុំគ្មានរូបភាពនៃសំបុករបស់វានៅក្នុងក្បាលដូចមនុស្ស ឬ ស្ថាបត្យករឡើយ ។ បើដូច្នេះហេតុដូចម្ដេចក៏ (karl - marx) បានប្រៀបប្រដូចស្ថាបត្យករគ្មានថ្វីដៃទៅនឹងឃ្មុំ ?

យើងជឿថា គឺកាលម៉ាក់ចង់ប្រដូច ស្ថាបត្យករ និង សំបុកឃ្មុំនេះតែម្ដង គោលគឺគ្រឿងសំណង់ដែលជាស្នាដៃរបស់ស្ថាបត្យករគ្មានថ្វីដៃប្រដូចបាននឹងសំបុកឃ្មុំនោះពិត ។ ឯចំណែកស្ថាបត្យករនោះឯងក៏ត្រូវកាលម៉ាក់ប្រដូចទៅនឹងឃ្មុំ , ព្រោះ « មនុស្សឃ្មុំ » នោះ ខុសទៅនឹង « សត្វឃ្មុំ » តែត្រង់ខ្លួនមាន « រូបភាពនៃសំណង់គំរូ » នៅក្នុងក្បាលខ្លួនមុននឹងចាប់គូរវាល ឬ សាងសំណង់នោះតែប៉ុណ្ណោះ ។

40 - គេច្រើនពោលថា សង់សាក់រូស្សូ (J. J. Rousseau) មានចំណូលចិត្តទៅនឹង “ រុក្ខវិទ្យា ” ដោយសារគាត់មានការស្រលាញ់ធម្មជាតិ និងការរំភើបសប្បាយដែលធម្មជាតិបានផ្ដល់ដល់គាត់ ។ តើអ្នកយល់យ៉ាង



www.elibraryofcambodia.org

ដូចម្តេចចំពោះសំដីរបស់អ្នកទស្សនវិជ្ជានេះ ?

ដើម្បីវិនិច្ឆ័យលើសំដីរបស់លោករូសូ គប្បីយើងរំឭកពីសកម្មភាពនិងខ្សែជីវិតខ្លះ ៗ របស់អ្នកទស្សនវិជ្ជានេះសិន ។

លោករូសូ កើតនៅក្រុងហ្សឺណែវ (GENÈVE) ប្រទេសស្វីស (SUISSE) មាតារបស់លោកបានទទួលមរណភាពនៅថ្ងៃកំណើតរបស់លោកតែម្តងគឺថ្ងៃទី ២៨ មិថុនា ១៧១២ ដប់ឆ្នាំក្រោយមក, ឪពុកលោករូសូ ដែលមានកង្វល់ក្នុងជីវិតក៏សម្រេចចិត្តដើរចោលស្រុក ។ ពេលនោះលោករូសូក៏ស្ថិតនៅក្រោមការបីបាច់រក្សារបស់អ្នកគង្វាលសត្វម្នាក់ឈ្មោះ ឡំប៊ែរស៊ីយេ (Lambercier) ។ ពីរឆ្នាំក្រោយមករូសូត្រូវគេបញ្ជូនទៅបំរើជាងចំលាក់ម្នាក់ បន្ទាប់មកគាត់ក៏ចាប់ដើរផ្សងព្រេងរហូត ។ ដំបូងគាត់បានត្រូវស្រីមេម៉ាយម្នាក់ឈ្មោះវ៉ារង់ (Mme de Waren) បញ្ជូនអោយទៅរស់នៅក្នុងកុមារសង្គ្រោះវិជ្ជកសាលាប្រូតិស្តង់ រួចចេញមកបំរើនៅក្នុងវិមានរបស់លោកស្រី «ទិវែរសិលីស» និង លោក „គូវ៉ុង (Gouvon) ។ ដោយ រូសូ មានរូបសម្បត្តិល្អពីធម្មជាតិ គាត់ក៏ត្រូវស្រីមេម៉ាយដែលជួយទុកម្តងនោះទទួលរក្សាគ្រាន់នឹងបំពេញកាមគុណប៉ុណ្ណោះ ។ ស្ថិតនៅក្នុងសភាពជា «កូនជីង», ដូច្នោះ, រូសូក៏មានការធុញនឹងជីវិតហើយក៏សំរេចចិត្តដើរទៅ ក្នុងព្រៃជិតស្លាប់ ។ តែមិនស្លាប់ រូសូត្រឡប់ទៅជាអ្នកទទួលទេពកោសល្យពីធម្មជាតិ ព្រោះមានកិលេសាធន៍សន្ធះ ។ លុះអាយុលោកបាន ៣០ ឆ្នាំ រូសូក៏បានត្រូវលោក «ឌឺម៉ុងតេគុយ» (M-De-Montegu) អគ្គរដ្ឋទូតបារាំងប្រចាំ



www.elibraryofcambodia.org

ក្រុងវីនីសទទួលយកធ្វើជាស្មៀន ។ តាំងពីថ្ងៃនោះមក រូសូក៏មានមុខមានមាត់ ហើយតាំងខ្លួនជាអ្នកសរសេររឿងពិតនៃបញ្ហាមនុស្ស ។ រូសូបានជួបនឹងលោក «វ៉ុលទែរ» (Voltaire) ហើយបានចងមេត្រីភាពនឹងគ្នា ។ លុះរូសូអាយុ ៣៤ ឆ្នាំ, គាត់បានយកស្រីអ្នកបោកអ៊ុតខោអាវម្នាក់ឈ្មោះ Thérèse ជាប្រពន្ធ ។ ក្រោយមកគេឃើញថារូសូបានកូន, ហើយកូននោះគាត់ពុំបានចិញ្ចឹមខ្លួនឯងទេ - តែគាត់បានយកទៅដាក់ក្នុង «កុមារសង្គ្រោះ» ។ បន្ទាប់មកគាត់ក៏បោះបង់ចោលនាងតេរ៉េស (Thérèse) នោះ ហើយរើងស៊ូងស្រែកខ្លួនទៀត ។

រូសូបានសរសេរអត្ថបទដែលស្តីពី « សិល្បៈនិងស្បង់ » ហេតុមានឈ្មោះបោះសំឡេង គឺអត្ថបទត្រូវសាលាបណ្ឌិតសភានៅឌីហ្សុង (Dijon) ផ្តល់រង្វាន់យ៉ាងច្រើន ។ តាំងពីពេលនោះមករូសូសរសេរពិសេសលើកិច្ចការរបស់មនុស្សដូចជាអត្ថបទឈ្មោះ «កំណើតនៃអសមភាព» (Origine de l' inégalité) និងអត្ថបទឈ្មោះ «អេមីល» (Emile) ដែលបណ្តាលឲ្យគេចាប់ខ្លួនគាត់យកទៅធ្វើទោស ។ តែរូសូបានដឹងមុនហើយក៏គេចខ្លួនទៅនៅស្វីសវិញ ។ ជីវភាពរស់នៅរបស់រូសូមានវិវឌ្ឍន៍ឆ្ងាយណាស់ តែយើងគ្រាន់តែបញ្ជាក់ថារូសូបានជួបនឹងបញ្ហាមនុស្សហេតុធ្វើឲ្យគាត់ស្អប់សង្គមនេះពេកក្រៃ ។ គាត់ស្លាប់នៅថ្ងៃទី ២ កក្កដា ១៧៧៨ ក្នុងវ័យអាយុ ៦៦ឆ្នាំ នៅគេហដ្ឋានលោកហ្ស៊ីរ៉ាដាំង (Girardin) ហើយសពរបស់គាត់ត្រូវគេនាំយកទៅកប់ស្ងាត់ៗ ទៅលើកោះមួយឆ្ងាយដាច់ពីគេ គឺ « កោះដើមស្រល់ » ។



www.elibraryofcambodia.org

១៦ឆ្នាំក្រោយមក , ទើបប្រជាជនបារាំងយល់ឃើញថា គំនិតរូស្សូជាគំនិតត្រូវ , ទើបគេនាំគ្នាទៅបង្វិលរកគាត់ពីកោះនោះមករក្សាក្នុងវិហារ« បង់តេអុង » រហូតដល់សព្វថ្ងៃនេះ។ ខ្សែជីវិតរូស្សូបានបញ្ជាក់ប្រាប់យើងថា , គាត់ជាមនុស្សដែលមានលក្ខណៈប្រកបដោយ «ត្រូវការចក្ខុការណ៍ន្ទះ» ។ ធ្លាប់ទទួលទុក្ខវេទនាជីវិតពីកុមារភាពព្រាត់ប្រាស , ក៏បានទទួលផ្លាស់មានចិត្តឆ្លង (Sympathie - contagion) ដូចអ្នកក្រុងផ្ដាសឡើយ , តែគាត់មានមនោគតិកំណើត (Imagination innée ញែកចេញពីសង្គមមនុស្សរហូតស្អប់សង្គមនេះថែមទៀតផង ។

គាត់បានដើរស្វែងរកនៅក្នុងព្រៃ- ទាត់ស៊ីន- លើភ្នំ ។ល។ ដើម្បីជៀសវាងពីបញ្ហាមនុស្ស.. តែគាត់ត្រឡប់ជាប្រទះនូវលទ្ធផលពិតក៏ផ្ទុយជាងដែលគេយល់ថា មានប្រយោជន៍សម្រាប់សត្វៈក្នុងចរនាគតិទិសស្ងប់ទៅវិញ ។ លុះរូស្សូបានឃើញធម្មជាតិទាំងឡាយនោះផ្តាយពីសោកសៅរួចហើយ ទើបគាត់ត្រឡប់មកពិនិត្យទ្រឹស្ដីរុក្ខវិទ្យា ដែលអ្នកឯកទេសធំទាន់ខ្ទុន គាត់បានបញ្ចេញគំនិតសំយោគ ប្រាប់ហេតុផលពិតទាស់វិជ្ជាទាំងនេះព្រមទាំងសរសេរបញ្ជាក់ពី សត្វៈវិទ្យាគាត់ធ្លាប់ជួបប្រទះផង ។

ផ្លូវថ្មីរូស្សូមានមនោគតិនិងទិសមានទំនោរតបធម្មជាតិផង ។ បុព្វហេតុក៏គាត់បានឆ្លាស់ចរនាសម្រេចនាពីសង្គម ហើយងាកទៅរកធម្មជាតិ ។ លុះបានលទ្ធផលពីការពិចារណានោះហើយ គាត់ក៏ចាប់ផ្ដើមផ្គុំប្រាប់ជាទ្រឹស្ដី ដែលមាន



www.elibraryofcambodia.org

លក្ខណៈជាមនោសញ្ចេតនាបញ្ហា នោះតាមសង្គមវិទ្យាវិត្តិវិស័យ ។ រូស្សូមានបញ្ហាក្នុងជីវិតកុំព្រមផ្សះផ្សារហើយថែមទាំងរត់ចូលទៅក្នុងធម្មជាតិ ។ ដូច្នេះក្រៅពីការស្រឡាញ់ធម្មជាតិ, ការរំភើបសប្បាយដែលធម្មជាតិផ្តល់ដល់គាត់នេះ: រូស្សូមានបញ្ហាជាបច្ច័យច្រើន ដូចបានរៀបរាប់មកហើយ សម្រាប់ញ៉ាំងអោយមានចំណូលចិត្តទៅនឹង «រុក្ខវិទ្យា» ។

* * *

...កាច ។

...គ្រឿងបណ្តាលអោយយើងមានភ្លាច

...ងទាំងឡាយ ( Cellules terminales ) ។
...ស្ថិតនៅចុង នៃសរីរាង្គទាំងក្នុងរបស់យើង
...នមុខងារចាំទទួលសម្ពស្សហើយបង្កើតជាភ្លាច

...ពីមានទាក់ទងនឹងខួរក្បាល ឬ ទេ ?



www.elibraryofcambodia.org

# ៣. ការបង្កើតថ្មី

41 - អ្វីទៅហៅថាការបង្កើតថ្មី ?

ការបង្កើតថ្មីគឺផលិតសំយោគថ្មីនៃគំនិត ឬរូបភាព ។ គឺផលិតការផ្គុំថ្មីមួយនៃមនោគតិចាស់ៗទាំងឡាយ ដើម្បីសម្រេចគោលដៅមួយ ។

42 - អ្វីទៅហៅថា ឥន្ទ្រិយារម្មណ៍ ( Sensation ) ?

ឥន្ទ្រិយារម្មណ៍ ជាអារម្មណ៍របស់ឥន្ទ្រិយ, ជាបាតុភូតចិត្តសរីរៈវិទ្យា ( Phénomène psycho - physiologique) ដែលកើតឡើងដោយរំញោចលើសរីរាង្គ ឥន្ទ្រិយមួយ ( Organe sensoriel ) ។

43 - តើឥន្ទ្រិយារម្មណ៍កើតមកពីអ្វី ?

ឥន្ទ្រិយារម្មណ៍កើតមកពីរំញោច ( Excitation ) ។

44 - តើរំញោចកើតមកពីអ្វី ?

រំញោច កើតមកពីការប៉ះទង្គិចគ្នារវាងសរីរាង្គឥន្ទ្រិយនិងវត្ថុ

nt ) ។

គាត់ត្រឡប់មកពិនិត្យទ្រឹស្តីរូបវិទ្យា នៃស៊ូ

គាត់បានបញ្ចេញគំនិតសំយោគ ប្រាប់ហេ

ទាំងនេះក្រោយទាំងសរសេរបញ្ជាក់ពី សន្ទុះនៃ

ne ) មានសមូល្យ

ប្រទះផង ។

ផ្ទុះរបស់បានបោះពុម្ពនិងបានទំនោរតម្លៃ ទកំដៅរញ្ជួយសំលេង

បុព្វហេតុគឺគាត់បានស្តាប់បទភ្លេងរកពីសត្វ

ទៅកេតម្មជាតិ ។ លុះបានទទួលពីការ រលផាតិជ្ជា, រស.

ហើយ គាត់ក៏ចាប់ផ្តើមចង្អុលប្រាប់ជាទ្រឹស្តី



www.elibraryofcambodia.org

46 - បើសិនជាយើងត្រូវខ្យល់ភ្លឹងធក់ តើឥន្ទ្រិយារម្មណ៍របស់យើងបានទទួលភ្ញាចអ្វី ?

បើខ្យល់ភ្លឹងធក់ ឥន្ទ្រិយារម្មណ៍របស់យើងទទួលភ្ញាចរងា និង ព្រោះអារម្មណ៍របស់យើងទទួលការញាក់ ; ស្ពឹកស្រយង់ ។

47 - បើសិនជាយើងលោកភ្លើង តើឥន្ទ្រិយារម្មណ៍របស់យើងបានទទួលភ្ញាចអ្វី ?

បើយើងលោកភ្លើង ឥន្ទ្រិយារម្មណ៍របស់យើងទទួលកំដៅ បណ្ដាលអោយយើងឈឺចាប់ ; រលាក, ផ្សា ។ យើងនឹងទទួលភ្ញាចរូបវិទ្យា ។

48 - បើសិនយើងទទួលទានម្ជូរ ឬ ស្តៅ តើឥន្ទ្រិយារម្មណ៍របស់យើងបានទទួលភ្ញាចអ្វី ?

បើសិនជាយើងទទួលទានម្ជូរ ឬ ស្តៅ យើងទទួលភ្ញាចគីមី ព្រោះអណ្ដាតយើងទទួលរសជាតិជូរ ឬ ចត់ បណ្ដាលអោយយើងស្រៀវមួយរំពេច ។

49 - តើអ្វីដែលជាគ្រឿងបណ្ដាលអោយយើងមានភ្ញាចនោះ?

គឺកោសិកាចុងទាំងឡាយ ( Cellules terminales ) ។ កោសិកានេះស្ថិតនៅចុង នៃសរីរាង្គទាំងក្នុងរបស់យើងទាំងអស់ , មានមុខងារចាំទទួលសម្ពស្សហើយបង្កើតជាភ្ញាចឡើង ។

50 - តើភ្ញាចទាំងពីមានទាក់ទងនឹងខួរក្បាល ឬ ទេ ?



www.elibraryofcambodia.org

## ៣. ការបង្កើតថ្មី

**41 - អ្វីទៅហៅថាការបង្កើតថ្មី ?**

ការបង្កើតថ្មីគឺផលិតសំណោតថ្មីនៃគំនិត ឬរូបភាព ។ គឺផលិតការផ្គុំថ្មីមួយនៃបទញ្ញាណចាស់ៗទាំងឡាយ ដើម្បីសំរេចគោលដៅមួយ ។

**42 - អ្វីទៅហៅថា ឥន្ទ្រិយារម្មណ៍ ( Sensation ) ?**

ឥន្ទ្រិយារម្មណ៍ ជាអារម្មណ៍របស់ឥន្ទ្រិយ, ជាបាតុភូតចិត្តសរីរវិទ្យា ( Phénomène psycho - physiologique) ដែលកើតឡើងដោយរំញោចលើសរីរាង្គ ឥន្ទ្រិយមួយ ( Organe sensoriel ) ។

**43 - តើឥន្ទ្រិយារម្មណ៍កើតមកពីអ្វី ?**

ឥន្ទ្រិយារម្មណ៍កើតមកពីមានរំញោច ( Excitation ) ។

**44 - តើរំញោចកើតមកពីអ្វី ?**

រំញោច កើតមកពីការប៉ះទង្គិចគ្នារវាងសរីរាង្គឥន្ទ្រិយនិងវត្ថុ

គាត់ត្រឡប់មកពិនិត្យទ្រឹស្តីរូបវិទ្យា នៃអ្ន nt ) ។

គាត់បានបញ្ចេញគំនិតសំណោត ប្រាប់គេ

ទាំងនេះក្រោយទៀតសរសេរបញ្ជាក់ពី សម្ភះនៃ

ប្រទះផង ។ e ) មានសម្ព័ន្ធ

ផ្ទេរសូល្យបានបង្ហាញពីពិសិដ្ឋមានទំនោរគេដា ។គំរោងស្អិតសំលេង

បុព្វហេតុដែលគាត់បានផ្តាច់ចរន្តអគ្គិសនីពីវត្ថុ

ទៅកេតុផាតិ ។ លុះបានលទ្ធផលពីការ ពិសោធន៍, រួច

ហើយ គាត់ក៏ចាប់ផ្តើមផ្តល់ប្រាប់ជាទ្រឹស្តី



www.elibraryofcambodia.org

46 - បើសិនជាយើងគ្រវីខ្សែភ្លើងឆក់ តើឥន្ទ្រិយារម្មណ៍របស់យើងបានទទួលភ្ញោចអ្វី ?

បើខ្សែភ្លើងឆក់ ឥន្ទ្រិយារម្មណ៍របស់យើងទទួលភ្ញោចមេកានិច ព្រោះអារម្មណ៍របស់យើងទទួលការញាក់ ; ស្ពឹកស្រយង់ ។

47 - បើសិនជាយើងរលាកភ្លើង តើឥន្ទ្រិយារម្មណ៍របស់យើងបានទទួលភ្ញោចអ្វី ?

បើយើងរលាកភ្លើង ឥន្ទ្រិយារម្មណ៍របស់យើងទទួលកំដៅ បណ្ដាលអោយយើងឈឺចាប់ ; ពើត, ផ្សា ។ យើងនឹងទទួលភ្ញោចរូបវិទ្យា ។

48 - បើសិនយើងទទួលទានម្ហូប ឬ ស្ករ តើឥន្ទ្រិយារម្មណ៍របស់យើងបានទទួលភ្ញោចអ្វី ?

បើសិនជាយើងទទួលទានម្ហូបឬស្ករ យើងទទួលភ្ញោចគីមី ព្រោះអណ្ដាតយើងទទួលរសជាតិផ្អែម ឬ ចត់ បណ្ដាលអោយយើងស្រៀវឬយរំភេច ។

49 - តើអ្វីដែលជាគ្រឿងបណ្ដាលអោយយើងមានភ្ញោចនោះ?

គឺកោសិកាចុងសរសៃប្រសាទ ( Cellules terminales ) ។ កោសិកានៅក្បែរចុង នៃសរីរាង្គទាំងក្នុងរបស់យើងទាំងអស់ , មានចុងសរសៃប្រសាទប្រសព្វស្របហើយបង្កើតជាភ្ញោចឡើង ។

50 - តើភ្ញោចទាំងពីរមានទាក់ទងនឹងខួរក្បាល ឬ ទេ ?



www.elibraryofcambodia.org

ភ្នែកទាំងបីមានទាក់ទងទៅខួរក្បាលជាពិសេសបំផុត ។

51 - ចុះបើភ្នែកទាំងបីមានទំនាក់ទំនងទៅនឹងខួរក្បាល តើមានអ្វីជាអ្នកនាំចរន្តទៅដល់ខួរក្បាល ?

អ្នកដែលនាំចរន្តទៅដល់ខួរក្បាល គឺ សរសៃប្រសាទ (Voie nerveuse) ។

52 - ចុះមនុស្សដែលមានសរីរាង្គ ប្រកបដោយសរសៃប្រសាទស្លាប់អាចចាត់ទុកថាមនុស្សនោះ មានឥន្ទ្រិយារម្មណ៍ឬទេ ?

មនុស្សមានសរីរាង្គប្រកបដោយសរសៃប្រសាទស្លាប់ , គេពុំអាចចាត់ទុកថាមានឥន្ទ្រិយារម្មណ៍ឡើយ ព្រោះមនុស្សនោះពុំទទួលនូវសម្ពស្សផ្សេងៗ ។ ហេតុនេះភ្នែកក៏កើតកើតមានដែរ ដែលគេហៅថាមានរ៉េផ្លិច (Réflexe) ។

53 - នៅពេលណាដែលគេសំគាល់ថា ឥន្ទ្រិយារម្មណ៍ជាការណ៍វេទនា (fait affectif) ?

គេសំគាល់ឥន្ទ្រិយារម្មណ៍ជាការណ៍វេទនា នៅពេលដែលឥន្ទ្រិយារម្មណ៍នោះ មានលក្ខណៈវេទនាអាចផ្តល់នូវការត្រេកត្រអាល , ការស្រយុតស្រយង់ចិត្ត , ឬការរន្ធត់ចិត្ត ។

54 - នៅពេលណាដែលគេសំគាល់ថា ឥន្ទ្រិយារម្មណ៍ជាការណ៍បញ្ញា (fait de connaissance)?

គេសំគាល់ឥន្ទ្រិយារម្មណ៍ជាការបញ្ញា នៅពេលដែលឥន្ទ្រិយារម្មណ៍ នោះទៅទាក់ទងនឹងវត្ថុមួយនៅខាងក្រៅចិត្តយើង ។



www.elibraryofcambodia.org

55- តើគេអាចជឿបានថា មនុស្សស្លាប់ដៃ, ស្លាប់ជើង អាចមានឥន្ទ្រិយារម្មណ៍ទេ? ហេតុអ្វី?

គេអាចជឿបានថាមនុស្សពិការនេះ អាចមានឥន្ទ្រិយារម្មណ៍បាន ប៉ុន្តែមានលក្ខណៈជាឥន្ទ្រិយារម្មណ៍ ដែលមានសភាពជារូបភាពនៅក្នុងអារម្មណ៍របស់ខ្លួនប៉ុណ្ណោះ ។

56- តើឥន្ទ្រិយារម្មណ៍ជារូបភាពមាន នៅក្នុងឥន្ទ្រិយណាច្រើនជាងគេ? ហេតុអ្វី?

ឥន្ទ្រិយារម្មណ៍ជារូបភាពមាននៅក្នុង ចក្ខុន្ទ្រិយនិងសោតិន្ទ្រិយច្រើនជាងគេ ព្រោះចក្ខុបានទទួលនូវរូបភាពជាយូរយារណាស់មកហើយ ។ ចក្ខុបានឃើញរូបភាពជាមនុស្សវារីយ៍ និងជាប់នៅក្នុងអារម្មណ៍ ពុំអាចនឹងលប់ទៅវិញដោយស្រួលៗឡើយ ។ ផ្ទុកភាពរូបភាពនោះ មានឥទ្ធិពលអាចបណ្តាលអោយមនុស្សសប្បាយរីករាយ, សើចឬយំផងក៏មាន ។ នេះពុំមែនបាននិយាថា មនុស្សនោះមានមនោគតិបង្កើតទេ (Imagination créatrice) តែមនុស្សនោះមានអារម្មណ៍ច្រកចេញដោយមនោគតិរំលឹកឡើងវិញ (Imagination reproductrice) ប៉ុណ្ណោះឯង ។ ម្យ៉ាងទៀតរូបភាពក៏មាននៅក្នុង សោតិន្ទ្រិយដែរ, ព្រោះសម្លេងអាចជិតជាប់នៅក្នុងអារម្មណ៍អស់យូរលង់ រហូតមនុស្សស្លាប់ទៅវិញឯងក៏មាន ។ សម្លេងជាមនុស្សវារីយ៍បង្កើតរូបភាព ក្នុងអារម្មណ៍បណ្តាលអោយគេយំសោក ឬសើចខ្ចាក់ខ្ចាំង ។ នេះជារូបភាពដែលស្ថិតនៅក្នុងទ្វារទាំងពីរនៃឥន្ទ្រិយរបស់



www.elibraryofcambodia.org

57 - ហេតុអ្វីបានជាមនុស្សអាចរំលឹកឡើងវិញ ឬស្គាល់ឡើងវិញនូវអតីតកាល ?

មនុស្សអាចរំលឹកឡើងវិញ ឬស្គាល់ឡើងវិញនូវអតីតកាល ព្រោះមនុស្សមានសំនឹក (mémoire) ។

58 - អ្នកប្រាជ្ញខ្លះបានចែងថា "សំនឹក (mémoire) ជាការណ៍ (fait) ដែលទាក់ទងទៅនឹងសរីរាង្គ" ; ឯចំណែកអ្នកប្រាជ្ញខ្លះទៀតយល់ថា "សំនឹកជាសក្តិមួយដែលទាក់ទងទៅនឹងចិត្តគំនិត" ។ តើអ្នកយល់យ៉ាងដូចម្តេចចំពោះមតិពីរប្លែកគ្នានេះ ?

ពួកអ្នករូបធាតុនិយម (matérialiste) យល់ថាសំនឹកទាក់ទងទៅនឹងសរីរាង្គ, ឯចំណែកពួកអ្នកគំនិតនិយមពោលអះអាងថា «សំនឹក» កើតមកពីសក្តិដែលទាក់ទងទៅនឹងចិត្តគំនិត ។ បញ្ហាដែលចោទឡើងឃើញថាមានតែមួយគឺការកើតមាននៃ «សំនឹក» ។ ឯចំណែកគោលយល់ និង សន្និដ្ឋានរបស់ពួកអ្នកប្រាជ្ញឃើញថាខុសគ្នា ។ អ្នកមួយយល់ថា បើគ្មានទំនាក់ទំនងរវាងសរីរាង្គទេ, សំនឹកក៏ពុំអាចកើតមានបានដែរ អ្នកមួយយល់ផ្សេងថា , បើសិនជាគ្មានទំនាក់ទំនងរវាងចិត្តគំនិតទេ «សំនឹក» ច្បាស់ជាពុំអាចកើតឡើយ ។ ដើម្បីវិនិច្ឆ័យលើទស្សនៈទាំងពីរនេះ គប្បីយើងពិនិត្យគំនិតអ្នកប្រាជ្ញទាំងនេះមួយម្តងសិន ៖

តើសរីរាង្គបានបង្កើតសំនឹកមែនឬទេ? សរីរាង្គជាការប្រមូលផ្តុំនិងជាអ្នកបង្កើតជីវិត ហោយវិញ្ញាណរីឯវិញ្ញាណជាគន្លងផ្ទុកនូវ



www.elibraryofcambodia.org

អារម្មណ៍ទាំងឡាយ ។ នៅក្នុង អារម្មណ៍ការនោះចំណងក៏មានមនោសញ្ចេតនា ។ មនោសញ្ចេតនាណាក៏ដូចគ្នា « លំនឹក » ដែលជាប្រភពនៃការវិវត្តន៍នោះដែរ ។ ដូច្នេះយើងឃើញថា សរីរាង្គជាអ្នកដើមកំណើត « លំនឹក » ។ ទ្រឹស្ដីរបស់អ្នករូបធាតុនិយមប្រកបដោយសុភនិច្ឆ័យដែរ ព្រោះបើសិនជាគ្មានសរីរាង្គកាលណាឡើយនឹងមានវិញ្ញាណ បើសិនជាគ្មានវិញ្ញាណ ម្ដេចឡើយនឹងមានអារម្មណ៍ ។ បើសិនគ្មានអារម្មណ៍កាលណាឡើយនឹងមានមនោសញ្ចេតនា, ហើយបើគ្មានមនោសញ្ចេតនា, តើមាន « លំនឹក » កើតមក ?

ចូរយើងត្រលប់មកមើលទ្រឹស្ដីរបស់អ្នកគំនិតនិយមខ្លះវិញ, តើមានលក្ខណៈយ៉ាងណាដែលចំពោះពាក្យថា ៖
« លំនឹកកើតមកពីទំនាក់ទំនងរវាងសក្តិនឹងចិត្តគំនិត »

ដោយពុំបាច់យកសក្ខីភាពវិធីយក៏គ្រាន់តែលើកយកចិត្តគំនិតដែលប្រាំងមកពិនិត្យក៏យើងអាចឆ្លើយបានថា ទស្សនៈនេះត្រូវសាបយកទុក្ខទុកតិចមួយភាគធំប្រេសចទៅហើយ ។ ព្រោះថាចិត្តគំនិតក៏ស្ថិតនៅក្នុងមនោសញ្ចេតនាដែរ ។ ចិត្តគំនិតបានចូលទៅជ្រកនៅក្នុងខួរក្បាល ដែលជាទីតាំងយ៉ាងធំនៃអារម្មណ៍ ។ ដូច្នេះ “ លំនឹក » កិតជាកើតមកពីទំនាក់ទំនង « ចិត្តនិងសក្តិ » នេះផង, និងសរីរាង្គកាយផង ។ សារូបសេចក្តីមកឃើញក៏ដោយពោលថា ទាក់ទងនឹងខួរក្បាលសុទ្ធតែមានលក្ខណៈជាវិជ្ជមាន នៅលើចំណោទទាំងលើនេះទាំងអស់ ។

59 - អ្វីទៅហៅថាមនោគតិ ?

មនោគតិ គឺ ជា សក្តិ សំរាប់នឹកគិតដោយរូបភាព ។



www.elibraryofcambodia.org

60 - អ្វីទៅហៅថាមនោគតិរំលឹកឡើងវិញ? (Imagination reproductrice)

ដែលហៅថាមនោគតិរំលឹកឡើងវិញគឺ មនោគតិដែលធ្វើអោយរូបភាពនៃព្រឹត្តិការណ៍មួយ ដែលកន្លងផុតទៅហើយ លេចចេញមកវិញ, ហើយប្រកបដោយលក្ខណៈហាក់ដូចជារូបភាពបច្ចុប្បន្ន ។

61 - អ្វីទៅដែលហៅថាមនោគតិបង្កើត? (Imagination créatrice )

មនោគតិបង្កើតគឺ មនោគតិដែលចាប់យករូបភាពទាំងឡាយដែលមាននៅក្នុងសតិ ដើម្បីយកមកធ្វើសំយោគអោយបានជារូបភាពថ្មី ។

62 - តើមនោគតិបង្កើតចែកជាប៉ុន្មានសណ្ឋាន? គឺអ្វីខ្លះ?

មនោគតិបង្កើតចែកជាបីសណ្ឋាន គឺ:

១- សណ្ឋានឈឺ,

២- សណ្ឋានថ្នាក់ទាប,

៣- សណ្ឋានថ្នាក់ខ្ពស់ ។

63 - ចុះការយល់សប្តិ ជាមនោគតិបង្កើតក្នុងសណ្ឋានអ្វី?

ការយល់សប្តិជាមនោគតិបង្កើតក្នុងសណ្ឋានថ្នាក់ទាប ។ ព្រោះការយល់សប្តិ ជាសំណាញ់រូបភាពប្រកបដោយលក្ខណៈវិក្ខិត្តវិស័យភាពនៅពេលដែលលង់ក្នុងដំណេក ។

64 ចុះនៅពេលយល់សប្តិ តើសរីរាង្គឥន្ទ្រិយមានដើរឬទេ?

នៅពេលយល់សប្តិ សរីរាង្គឥន្ទ្រិយឥតដើរទេ ។



www.elibraryofcambodia.org

65 - បើនៅពេលយល់សប្តិ សរីរាង្គឥន្ទ្រិយឥតដើរទេ ហេតុអ្វីក៏មានសំណង់រូបភាព ? តើសំណង់រូបភាពនោះមកពីណា ?

នៅពេលយល់សប្តិ សរីរាង្គឥន្ទ្រិយបានឈប់សម្រាកតែមានព្រលឹងវិញ្ញាណប្រក្រតី - ពេលគឺសរីរាង្គឥន្ទ្រិយមានមុខងារផ្សេងទៀតជាមួយអារម្មណ៍ក្នុងការបង្កើតសំណង់រូបភាព គឺមានលក្ខណៈជារូបភាពប្រត្យក្សផងជារូបភាពមនោគតិផង ។

66 - អ្វីទៅហៅថាការស្រវើស្រវាយ ? ( Rêveries )

ការស្រវើស្រវាយគឺជាសភាពអកម្មមួយនៃចិត្តដែលរង់ចាំទទួលនូវរូបភាពទាំងអស់កើតមានឡើង, ហើយរូបភាពទាំងឡាយដែលកើតចេញ សុទ្ធតែតាមរបៀបបណ្តុំគំនិតទាំងអស់ (Association des idées) ។

*

* *



www.elibraryofcambodia.org

# ៤- ល្បិចផ្លូវនៃគំនិត

67 - អ្វីទៅហៅថា "វិចារ"

វិចារគឺជាតំណជាប់តគ្នានៃគំនិតជាច្រើន ដើម្បីទៅដល់សន្និដ្ឋានមួយ ។

68 - តើគេអាចចាត់ទុកវិចារថា ជាចំណងរបស់គំនិតបានឬទេ ?

វិចារចងគំនិតជាច្រើនដើម្បីអោយដល់សន្និដ្ឋានមួយ, ដូច្នេះគេអាចចាត់ទុកវិចារថាជាចំណងនៃគំនិតបាន ។

69 - តើអំពើសំខាន់របស់គំនិតមានប៉ុន្មាន ?

អំពើសំខាន់ៗរបស់គំនិតមានបីគឺ,

១- បញ្ញត្តិ (concept)

២- វិនិច្ឆ័យ (Jugement)

៣- វិចារ (Raisonnement)

70 - អ្វីទៅហៅថាបញ្ញត្តិ?

បញ្ញត្តិជាន័យរបស់ពាក្យមួយ, ជាអ្វីដែលគេនឹកឃើញ កាលណាគេប្រើពាក្យមួយ ។

71 - តើមានបញ្ញត្តិជារូបីទេ ?

បញ្ញត្តិទាំងអស់សុទ្ធតែអរូបី ដូច្នេះគ្មានបញ្ញត្តិរូបីទេ ។

72 - ហេតុអ្វីក៏បញ្ញត្តិសុទ្ធតែអរូបី ?

បញ្ញត្តិទាំងអស់សុទ្ធតែអរូបី ព្រោះបញ្ញត្តិជាអំពើរបស់គំនិត ហើយគំនិតសុទ្ធតែអរូបី ។



www.elibraryofcambodia.org

73- អ្វីទៅហៅថាវិនិច្ឆ័យ ?

វិនិច្ឆ័យជាអំពើមួយរបស់គំនិត ដែលកំណត់អោយលក្ខណៈទៅបញ្ញត្តិ ។ ជាចំណងដែលចងបញ្ញត្តិពីរ ឬបញ្ញត្តិជាច្រើនអោយជាប់គ្នា ។

74- វិចារជាអ្វី ?

វិចារជាការប្រមូលផ្តុំនូវវិនិច្ឆ័យពីរ ឬវិនិច្ឆ័យជាច្រើន ។

75- អ្វីទៅហៅថាអនុមានវិញ្ញក ?

អនុមានវិញ្ញកគឺជាវិចារដែលវិញ្ញក សន្និដ្ឋានចេញពីគោលការណ៍ទូទៅ ។ គណិតជាគំរូនៃអនុមានវិញ្ញកមួយដែរ ។

ឧទាហរណ៍ : មនុស្សទាំងអស់សុទ្ធតែត្រូវស្លាប់
សូក្រាតជាមនុស្សម្នាក់ ដូច្នេះសូក្រាតត្រូវតែស្លាប់ដែរ ។

76- តើគេចែកអនុមានវិញ្ញកជាប៉ុន្មានបែប ? គឺអ្វីខ្លះ ?

គេចែកអនុមានវិញ្ញកជាពីរបែបគឺ :

១- អនុមានវិញ្ញកតាមរូបរាង (déduction formelle)

២- អនុមានវិញ្ញកគណិតវិទ្យា (déduction mathématique)

77- តើគេអាចហៅអនុមានវិញ្ញកតាមរូបរាងថាជាអនុមានវិញ្ញកវិភាគបានឬទេ ?

គេអាចហៅអនុមានវិញ្ញកតាមរូបរាងថាជាអនុមានវិញ្ញកវិភាគបាន (déduction analytique)



www.elibraryofcambodia.org

78- តើអនុមានវិញកគណិតវិទ្យា អាចហៅថាអនុមានវិញកសំយោគ (déduction synthétique) បានឬទេ?

យើងនឹងថា គណិតវិទ្យាជាស្នូលដែលរៀនពីចំនួនហើយ អនុមានវិញកសំយោគក៏មានគោលវត្ថុជាចំនួនដែរ, ដូច្នេះយើងអាចហៅអនុមានវិញកគណិតវិទ្យាថា ជាអនុមានវិញកសំយោគបានដែរ ។

79- ក្រៅពីគណិតវិទ្យា តើមានស្នូលណាខ្លះដែលត្រូវការប្រើអនុមានវិញក? ហេតុអ្វី?

ក្រៅពីគណិតវិទ្យា គេត្រូវការអនុមានវិញក នៅប្រើក្នុងស្នូលពិសោធ។ ព្រោះស្នូលពិសោធត្រូវការគោលច្បាប់គណនាដូចគណិតវិទ្យាដែរ ។

80- អ្វីទៅហៅថាអនុមានរូម?

អនុមានរូមជាវិធានដែលចេញពីការពិសោធជាច្រើន ដើម្បីរួមអោយបានជាច្បាប់ទូទៅមួយ ។

81- តើអនុមានរូមមានគោលដៅយ៉ាងដូចម្ដេច? ចូរលើកឧទាហរណ៍ ។

អនុមានរូមមានគោលដៅចង់ជ្រើសរើសលក្ខណៈរួមមួយ ។ ហេតុដូច្នេះហើយបានជាអនុមានរូម ទំរូវប្រមូលយកការសង្កេតជាច្រើនមកពិនិត្យ ។

ឧទាហរណ៍ៈ ខ្ញុំសង្កេតឃើញឪពុកមិត្តខ្ញុំស្លាប់

មិត្តខ្ញុំក៏ស្លាប់

— ឪពុកខ្ញុំក៏ស្លាប់



www.elibraryofcambodia.org

១- ជាផលដែលបានមកដោយគិតប្រឹង, ជាផលដែលអាចបំភ្លឺយើងអោយជួបប្រទះនឹងវិបត្តិផ្សេងៗ ព្រោះយើងពុំបានពិចារណាក្រោយទាំងពុំបានពិនិត្យវាជាថ្មីបានផង ។

២- អន្តរញ្ញាណឥន្ទ្រិយច្រើនជឿតាមឥន្ទ្រិយរបស់យើង, ថ្វីដ្បិតតែយើងនឹងថា អន្តរញ្ញាណជាការស្គាល់និងយល់ដោយគ្មានអ្នកកណ្ដាលក្ដី ក៏យើងនៅតែពុំរួចពីកំហុសខ្លះ ដោយហេតុថាល្បិចគំនិតគេៈ កំពុងវិចារជានិច្ច ហើយជាឧបករណ៍នាំវិចារអោយដើរផ្លូវខុសផងក៏សឹងមាន ។

* * *



www.elibraryofcambodia.org

# ស្យង់និងគំនិតស្យង់

## 96 - អ្វីទៅហៅថាស្យង់ ?

ស្យង់ជារបកគំហើញនៃទំនាក់ទំនងដែលមានក្នុង កថ : ជាការពិតទំ ដើម្បីពន្យល់និងស្គាល់អ្វីដែលមាន ។

## 97 - អ្វីទៅហៅថាតិចនិច ?

តិចនិចជាការរៀបចំដាក់លាក់ដើម្បីបង្កើតលទ្ធផល ដែលគេយល់ថាមានប្រយោជន៍ ។ តិចនិចគាំទ្រទៅលើអ្វីដែលមានប្រយោជន៍ ហើយជាអ្នកបំពេញសេចក្ដីត្រូវការទាំងអស់របស់មនុស្ស ។ តិចនិចចាំបង្កើតអ្វីដែលយើងប្រាថ្នាចង់អោយមាន ហើយដែលមិនទាន់មាននៅឡើយ ។

## 98 - តើស្យង់មានលក្ខណៈគំនិតយ៉ាងដូចម្ដេច ?

គំនិតស្យង់ មិនទទួលស្គាល់អ្វីដោយខ្វាក់ភ្នែកទាំងទេ ។ ស្យង់មិនរាថយចំពោះការពិភាក្សាទាំងឡាយ - ព្រោះស្យង់មានលក្ខណៈជាគំនិតរិះគិត (Esprit critique) តែងពិភាក្សាលើគំនិតផ្ទាល់របស់ខ្លួនវិញទៀតផង ។ ស្យង់មានលក្ខណៈជាគំនិតសកល (Esprit universel) កាលណាស្យង់កើតចេញពីវិចារណញ្ញាណ ជាគំនិតជាក់ច្បាស់ ដែលផ្ទុយស្រលះពីលក្ខណៈប្រហាក់ប្រហែលនៃគំនិតសាមញ្ញ ។

## 99 - អ្នកប្រាជ្ញឈ្មោះអ្វីដែលបាន បំបែកស្យង់ជាប្រាំមួយផ្នែក ? តើអ្វីខ្លះ ?



www.elibraryofcambodia.org

លោកអូគុស្តកុងបានបំបែកស្យង់ជាប្រាំមួយផ្នែកគឺ ៖

១- គណិតវិទ្យា

២- តារាវិទ្យា

៣- រូបវិទ្យា

៤- គីមី

៥- ជីវវិទ្យា

៦- សង្គមវិទ្យា ៕

100- គេបានពោលថា " ស្យង់ " បានត្រូវឃ្លាតចេញពីទស្សនវិជ្ជាដោយការរីកចំរើននៃពុទ្ធិរបស់អ្នកប្រាជ្ញទាំងឡាយ ។ ចូររៀបរាប់ឈ្មោះអ្នកប្រាជ្ញវិទ្យាសាស្ត្រ និងមុខវិជ្ជារបស់អ្នកប្រាជ្ញទាំងនោះដែលអ្នកបានដឹង?

ដោយសារមនុស្សមានបំណងចង់រកប្រយោជន៍ជាតិ ដើម្បីកំរូវទៅតាមសេចក្ដីត្រូវការរបស់ខ្លួន ហើយមនុស្សបង្កើតស្យង់ឡើង ។ ក្នុងចំណោមអ្នកប្រាជ្ញទាំងឡាយដែលមានជំនឿនិងនិន្នាការគតិពិចារណា ( Tendance réfléchie ) បានពុះពារនូវសេចក្ដីព្យាយាមទាំងចំណាយកំលាំងកាយចិត្តរបស់ខ្លួន, ដើម្បីការស្រាវជ្រាវរកនៃសច្ចៈ ( Origine de la vérité ) ក្នុងមាគ៌ារបស់ស្យង់ ។ រីឯអ្នកប្រាជ្ញទាំងនោះគេសង្កេតឃើញ

— លោក ញូតុន និង ទ្រឹស្ដី មេកានិចរបស់លោក

— លោក អឺក្លីត និង ទ្រឹស្ដី គណិតវិទ្យា

— លោក ការប៊ែល និង ទ្រឹស្ដី រូបវិទ្យា



www.elibraryofcambodia.org

— លោក ឡាំសៀ និង ស្រ្ដី គីមី
— លោក ឡាម៉ាក់ និង ស្រ្ដី ជីវវិទ្យា
— លោក កុង និង ស្រ្ដី សង្គមវិទ្យាជំនើប ។ល។

101 - អ្នកយល់ដូចម្ដេចចំពោះ មតិមួយដែលបានពោលថា ៖ " ទស្សនវិជ្ជាជាការពិចារណា មិនមែនជាការប្រមូលចំណេះទាំងអស់ទេ " ។ ចូរវិភាគវែកញែកនិងអោយយោបល់ចំពោះមតិខាងលើនេះ ។

ទស្សនវិជ្ជា គឺ ស្នេហាគតិបណ្ឌិត, នេះជានិយមន័យដែលគេបានបកប្រែតាមភាសារបស់ក្រិចថា "ភី ឡូ សូភីយ៉ា" (PHILOSOPHIA) ។

ពាក្យថា "ស្នេហា" គឺចូលចិត្ត, ស្រឡាញ់និងចង់បាន ។ តើអ្នកទស្សនវិជ្ជាស្រឡាញ់និងចង់បានអ្វី? ឆ្លើយថាអ្នកទស្សនវិជ្ជាស្រឡាញ់នូវគតិប្រាជ្ញ, នោះបីក្នុងវិស័យណាក៏ដោយ ។ ដូច្នេះដើម្បីអោយបាននូវគតិប្រាជ្ញ, អ្នកទស្សនវិជ្ជាបានប្រើបរិយាសវែកញែកនានានិងបញ្ហារបស់ខ្លួនស្រាវជ្រាវរក "ពុទ្ធិសច្ចៈ" ដោយប្រើជាចាំបាច់នូវការពិចារណា ។ ការពិចារណារកហេតុនិងផលទៅលើធម្មជាតិ និងវត្ថុនានាផ្សេងៗក្នុងធម្មជាតិជាកម្មវត្ថុរបស់អ្នកឯកទេស ។ ពិតមែនហើយ, ថាមនុស្សម្នាក់ៗពុំអាចប្រមូលយកវិជ្ជាឯកទេសទាំងអស់បានទេ ក៏ប៉ុន្តែគេអាចប្រមូលចំណេះជាច្រើនដាក់ទៅក្នុងគំនិតរបស់គេបាន ដែរអោយខួរក្បាលរបស់គេទទួលយកចំណេះនោះបាន ។



www.elibraryofcambodia.org

សព្វថ្ងៃនេះ វិទ្យាស្ថានពហុតិចនិចបានកើតមានឡើងស្ទើរតែគ្រប់អាណាប្រទេសទាំងអស់ ។ ការបង្កើតសាលាពហុតិចនិច (politechnique) នេះ ពុំមែនមានន័យថាត្រូវតែការពារមនុស្សពិចារណាយ៉ាងប៉ុណ្ណោះទេ, តែគេបានបង្កើតឡើងដើម្បីជ្រើសរើសមនុស្សទាំងឡាយណា ដែលមានខួរក្បាលអាចទទួលយកការប្រកបចំណេះជាគតិបណ្ឌិតនោះឯង ។ ដូច្នេះយើងអាចសន្និដ្ឋានបានថាចំណេះទាំងអស់ខាងស្យង់ក្ដី ពុំមែនស្យង់ក្ដី, តិចនិចក្ដី ពុំមែនតិចនិចក្ដី សុទ្ធតែប្រើការពិចារណាទាំងអស់ ។ ម្យ៉ាងទៀតយើងឃើញថា ព្រះពុទ្ធពុំគ្រាន់តែបូកចំណេះទាំងអស់ របស់មនុស្សប៉ុណ្ណោះទេ, តែព្រះពុទ្ធត្រាស់ដឹងដឹកសំលឹងធ្លុះត្រង់ណាបន្តិច អាស្រ័យការពិចារណានេះដែរ ។ ដូច្នេះមតិខាងលើនេះ ខុសស្រឡះពីគោលដៅពិតរបស់ន័យថា " ទស្សនវិជ្ជា ជាប្រភពនៃការពិចារណាទៅលើចំណេះទាំងអស់ក្នុងលោក និងក្រៅលោក" ។

ជាមួយគ្នានឹងការពិចារណានេះ លោក"ប៉ូលវ៉ាឡេរី(Paul Valery)"ក៏បានយល់ស្របនឹងខ្លួនគេ ខាងក្រោយនេះដែរ គឺ:" ខ្ញុំទុកជាអ្នកទស្សនវិជ្ជា នូវជនទាំងឡាយណាដែលខិតខំឲ្យស្វែងរកការឃើញសរុប (Vision globale) នូវចំណេះទាំងអស់របស់ខ្លួន ទោះបីជននោះមានចំណេះស្ទួចស្ដើងយ៉ាងណាក៏ដោយ លោកប៉ូលវ៉ាឡេរី បាននិយាយពីចំណេះសរុបដែលមនុស្សម្នាក់ៗ ខំប្រឹងប្រែងសិក្សាប្រមូលមកដាក់ក្នុងខួរក្បាល


www.elibraryofcambodia.org

ជីវិតគ្រឿងយន្តល័យប្រតិវត្តិនេះឲ្យមានរូបរាងឡើង ។ ដូច្នេះមតិដែលពោលមកខាងលើនេះ ជាសំយោគនៃទ្រឹស្តីគ្រូពិការគឺ ល្បង់ក៏ពឹងលើកិច្ចនិច , ដំណែលកិច្ចនិចក៏ពឹងលើស្បង់ដើម្បីញុំាងអោយសម្រេចនូវគោលបំណងរបស់ខ្លួន គ្រូនិងសេចក្តីប្រៀបប្រដូចមួយវគ្គដែលបានពោលថា ៖

« ស្បង់បានសង្គ្រោះជីវិតនៃទ្រឹស្តី ទស្សនវិជ្ជាជាអ្នកដឹកក្រោមសំណាងនោះ ដើម្បីវិលត្រឡប់មកពន្យាស់លាស់ , រីឯកិច្ចនិច ជាគ្រឹងនិងសាច់នៃសំណង់ទាំងមូល » ។

103- បើស្បង់និយមការផាក់លាក់, បើស្បង់មិនទទួលអ្វីទាំងឡាយដែលខ្វះភស្តុតាង តើស្បង់មានសច្ចៈដាច់ខាតឬទេ ? ហេតុអ្វី ?

ពិតមែនតែស្បង់និយមការផាក់, ពិតមែនតែស្បង់មិនទទួលស្គាល់អ្វីទាំងឡាយដែលខ្វះភស្តុតាង, ស្បង់ពុំមានសច្ចៈដាច់ខាតឡើយ ។ ព្រោះពុំមែនជាទ្រឹស្តីមួយដែលយើងទទួលពីអាទិទេពទេ ។ ដូច្នេះស្បង់មានសច្ចៈដែលអាចផ្លាស់ប្តូរបាន ។

104- តើស្បង់បានផ្តាច់ខ្លួនអោយដាច់ពីធម្មជាតិឬទេ ?

ស្បង់ពុំមានបំណងនឹងផ្តាច់ខ្លួនអោយចេញពីធម្មជាតិទេ ។ តែផ្ទុយទៅវិញ ស្បង់បានប្រើគ្រប់មធ្យោបាយទាំងអស់របស់ខ្លួនដើម្បីអោយបានវិតចូលទៅជិតធម្មជាតិ ។

105- បើជ្រើសរើសយកតែសំខាន់ៗ តើស្បង់មានប៉ុន្មានបែប ?



www.elibraryofcambodia.org

បើជ្រើសយកតែវិជ្ជាធំៗ លោកអូគុស្តកុង ( Auguste Comte) បានចែកស្យង់ជាប្រាំមួយបែបដូចតទៅនេះ ÷

១- គណិតវិទ្យា ( Mathématique)

២- តារាវិទ្យា ( Astronomie )

៣- រូបវិទ្យា ( Science physique)

៤- គីមី ( Chimie )

៥- ជីវវិទ្យា ( Biologie )

៦- សង្គមវិទ្យា ( Sociologie )

106- តើគេបានដឹងថា « រូបវិទ្យា » (Science physique) មានលក្ខណៈ ជាស្យង់ពិតប្រាកដនៅក្នុងសតវត្សទី ប៉ុន្មាន ?

រូបវិទ្យា ( Science physique ) បានទទួលលក្ខណៈជាស្យង់ពិតប្រាកដនៅក្នុងសតវត្សទី១៧ ។

107- ក្នុងសតវត្សទី១៧នេះ អ្នកប្រាជ្ញឈ្មោះអ្វីដែលបានធ្វើ រូបវិទ្យា អោយមានលក្ខណៈជាស្យង់ពិតប្រាកដ ?

អ្នកប្រាជ្ញដែលធ្វើ « រូបវិទ្យា » អោយមានលក្ខណៈពិតប្រាកដគឺលោក " កាលីលេ " និងលោក " ញូតុន » ( Galilée et Newton ) ។

108- តើស្យង់ "គីមី" បានទទួលលក្ខណៈជាស្យង់ពិតប្រាកដ នៅសតវត្សទីប៉ុន្មាន? ដោយអ្នកប្រាជ្ញឈ្មោះអ្វី?

ស្យង់ « គីមី » បានទទួលលក្ខណៈជាស្យង់ពិតប្រាកដនៅ សតវត្សទី១៨ដោយអ្នកប្រាជ្ញឈ្មោះ « ឡាវ៉ូស្យេ (Lavoisier)



www.elibraryofcambodia.org

109- បើស្យង់ទាំងឡាយសុទ្ធតែទទួលលក្ខណៈពិតរបស់ខ្លួនខុសពេលគ្នា, តើស្យង់ទាំងនោះបានពឹងផ្អែកគ្នាទៅវិញទៅមកដែរឬក៏ពឹងតែលើវិធានការផ្ទាល់ខ្លួន ?

ស្យង់ទាំងឡាយបានពឹងផ្អែកលើគ្នាទៅវិញទៅមក ដោយខានពុំបាន ។ ជាពិសេសគឺដំកូកស្យង់ដែលមានលក្ខណៈរូបីជាងគេ ។

110- តើណាដែលមានគំនិតទប់ភាពអសច្ចៈ របស់ស្យង់មុនគេ ?

លោកអូគុស្តកុង មានគំនិតទប់អសច្ចៈ គឺការអាចផ្លាស់ប្តូរនៃស្យង់ទាំងឡាយដោយបញ្ចូលស្យង់ទៅក្នុងសង្គមវិទ្យា ។

111- តើគំនិតរបស់លោកអូគុស្តកុង បានចៀសផុតពីការរិះគន់របស់អ្នកប្រាជ្ញនៅទៀតឬទេ ? ហេតុអ្វី ?

គំនិតរបស់លោកអូគុស្តកុងត្រូវទទួលការរិះគន់ពីសំណាក់អ្នកប្រាជ្ញនៅទៀតជាច្រើន ។ ព្រោះថា លោកពុំបានត្រិះរិះពីទំនាក់ទំនងរវាងស្យង់ទាំងឡាយនេះឲ្យច្បាស់ ។ ម្យ៉ាងទៀត លោកអូគុស្តកុង បានសន្និដ្ឋានចំណាត់ថ្នាក់នៃមុខវិជ្ជាខ្លះខុសនិងសច្ចៈ ដូចជា រូបវិទ្យានិង ស្យង់គីមី, លោកអូគុស្តកុងចែករាយដាច់ពីគ្នា ។ តាមពិតវិជ្ជាទាំងពីរនេះអាចមានទំនាក់ទំនងគ្នា, ព្រោះបើគេបានយកមុខវិជ្ជាទាំងពីរទៅប្រើក៏ឃើញថាការចេញជាស្យង់មួយថ្មីទៀត ដែលគេហៅថា "តារារូបវិទ្យា" (astrophysique) ។

*

* *



www.elibraryofcambodia.org

# ៦- គណិតវិទ្យា

112- អ្វីទៅហៅថា គណិតវិទ្យា?

គណិតវិទ្យា គឺជាវិជ្ជាដែលមានចែកផ្នែកច្រើនដូចជា, គណិតវិទ្យារូបី (mathématique concrète) គណិតវិទ្យាសុទ្ធសាធ (mathématique pure) និងគណិតវិទ្យាស្យង់លំដាប់ (science de l'ordre) ។

113- អ្វីទៅហៅថាគណិតវិទ្យារូបី?

ដែលហៅថាគណិតវិទ្យារូបី គឺគណិតវិទ្យាដែលសិក្សាពីទំហំទាំងឡាយមានទំហំនៃលំហនិងចលនាជាដើម ។

114- អ្វីទៅហៅថាគណិតវិទ្យាសុទ្ធសាធ?

ដែលហៅថាគណិតវិទ្យាសុទ្ធសាធ គឺស្យង់ដែលរៀនអំពីបរិមាណនិងអំពីទំហំរូបី (grandeurs concrètes) ។

115- អ្វីទៅហៅថាគណិតវិទ្យាស្យង់លំដាប់?

ដែលហៅថាគណិតវិទ្យាស្យង់លំដាប់ គឺគណិតវិទ្យាដែលសិក្សាពីលំដាប់ (l'ordre) ។

116- ដូច្នេះដើម្បីអោយងាយយល់ គេអាចសន្និដ្ឋានថា គណិតវិទ្យាជាអ្វី?

ដើម្បីអោយងាយយល់ គេអាចសន្និដ្ឋានបានយ៉ាងខ្លីថា គណិតវិទ្យាជាសញ្ញាណចំបង(notions fondamentales) បីធំៗដូចជា :

១- ទំហំ (grandeur)



www.elibraryofcambodia.org

២- បរិមាណ (quantité)

៣- លំដាប់ (l'ordre)

117 - ដូចម្តេះគណិតវិទ្យាមានសញ្ញាណកើតមកពីអ្វី ?

គណិតវិទ្យាមានសញ្ញាណកើតមកពីទ្រឹស្តីនិយមពីរគឺ :

១- ទ្រឹស្តីពិសោធន៍និយម (thèse empiriste)

២- ទ្រឹស្តីវិចារណញាណនិយម (thèse rationaliste)

118 - ចុះនរណាបញ្ជាក់ថាគណិតវិទ្យា មានសញ្ញាណមកពីទ្រឹស្តីពិសោធន៍និយម?

លោកចនស្ទ្វាតមីល (John-stuart-Mill) បានជឿថាគណិតវិទ្យាមានសញ្ញាណកើតមកពីពិសោធន៍ឥន្ទ្រិយ ។

119 - ដើម្បីការពារមតិឬទ្រឹស្តីរបស់ខ្លួន តើលោកចនស្ទ្វាតមីល បានលើកយកអំណាង (Argument) អ្វីខ្លះមកអធិប្បាយ ?

ដើម្បីការពារមតិឬទ្រឹស្តីរបស់ខ្លួន លោកចនស្ទ្វាតមីល បានលើកយកអំណាងបីមកបញ្ជាក់គឺ :

ទី១ - បញ្ជាក់ពីភាពដូចគ្នារវាងពិសោធន៍និងសញ្ញាណគណិតវិទ្យា ។

ទី២ - លើកយកសេចក្តីបញ្ជាក់របស់ចិត្តវិទ្យាដែលបានបញ្ជាក់ពីលក្ខណៈអរូបីរបស់ចំនួន ។

ទី៣ - ផ្អែកលើប្រវត្តិគណិតវិទ្យាដែលថាគណិតវិទ្យារូបីនោះ ថា បានចាប់កំណើតមកមុនគេ ។



www.elibraryofcambodia.org

120- ចុះចំណែកលោកប្លាតុង (Platon) ដែលជាអ្នកទស្សនវិជ្ជាយ៉ាងធំម្នាក់ដែរ, ហើយដែលធ្លាប់ពិចារណារកហេតុនិងផលលើបញ្ហាទាំងអស់នៅក្នុងធម្មជាតិតើលោក បានអោយយោបល់យ៉ាងដូចម្តេចដែរទៅលើបញ្ហាសញ្ញាណគណិតវិទ្យា ?

លោកប្លាតុងបានពោលថា «សញ្ញាណគណិតវិទ្យា» បានដាច់ស្រលះពី «ពិភពឥន្ទ្រិយ» (monde sensible) ហើយសញ្ញាណនោះឯងបានចាប់កំណើត នៅក្នុងពិភពមួយទៀតឈ្មោះហៅថា «ពិភពបញ្ញា» (monde intelligible) ។

121- ចុះចំណែកលោកដេកាត (Descartes) វិញ តើយល់យ៉ាងដូចម្តេចដែរចំពោះបញ្ហាសញ្ញាណគណិតវិទ្យា ?

ក្រោយដែលបានពិសោធរកហេតុផលយ៉ាងល្អិតល្អន់ លោកដេកាតអោយយោបល់ ចំពោះសញ្ញាណគណិតវិទ្យាថា: «ជាពូជតែសុទ្ធៈដែលមានដោយធម្មជាតិ នៅក្នុងវិញ្ញាណក្ខន្ធ (âme) ពោលគឺវត្ថុនេះកើតមាននៅក្នុងក្បាលមនុស្សតាំងពីកំណើតមក ។

122- តាមពិតគណិតវិទ្យាមានគោលការណ៍ (Principes) របស់ខ្លួនប៉ុន្មាន ? គឺអ្វីខ្លះ ?

បើរាប់យកតែគោលធំៗ គោលការណ៍គណិតវិទ្យាមានបីយ៉ាងគឺ:

១- អាក់ស្យូម (Axiome)

២- ប៉ូស្ទុយឡា (Postulat)



www.elibraryofcambodia.org

៣- និយមន័យ (définition)

**123-** អ្វីទៅហៅថា "អាក្សូម" ?

អាក្សូម គឺជាសំណើដែលមានលក្ខណៈច្បាស់លាស់ ដោយខ្លួនឯង ។

**124-** អ្វីទៅហៅថា "ប៉ូស្ទុយឡា" ?

ប៉ូស្ទុយឡាគឺជា «សំណើបុរាណ» មានលក្ខណៈ ខុសពីគ្រឹះនៃគណិតវិទ្យា ទុកសំរាប់សំរាយបញ្ជាក់ ។

**125-** អ្វីទៅហៅថា និយមន័យដែលជាគោលការណ៍នៃ គណិតវិទ្យា ?

និយមន័យដែលជាគោលការណ៍គណិតវិទ្យា គឺជាការពិពណ៌នាពីលក្ខណៈ «វត្ថុគណិត» តាមវិធីសាស្ត្រខុសពីបាណ រូបារម្មណ៍ ។

**126-** អ្វីទៅហៅថាវិធានគណិតវិទ្យា ?

(Qu'est-ce que le raisonnement mathématique?

ដែលហៅថាវិធានគណិតវិទ្យា គឺ វិធាននាំឲ្យយល់ការ ដែលគេច្រើនប្រើមានពីរគឺ :-

១- អនុមានវិញកសង់ (Déduction constructive)

២- វិធានតាមកំណើន (Raisonnement par récurrence) ។

**127-** អ្វីទៅហៅថាវិធានអនុមានវិញកសង់ ?

ដែលហៅថាវិធានអនុមានវិញកសង់ គឺវិធានដែលពឹងលើសំណើប្រតិទ្ធអាក្សូម ប្រកបដោយលក្ខណៈ សម្មតិកម្ម (Hypothétique) ។



www.elibraryofcambodia.org

128- អ្វីទៅហៅថាវិធានការយកំណើត ?

វិធានការយកំណើត គឺជាវិធីរោយតួទៅតួរណែនូវលសំរាយ បញ្ជាក់ពីរស់សម្ព័ន្ធ ។

129- តើគណិតវិទ្យា និង ស្យង់ពិសោធន៍មានលក្ខណៈខុសគ្នាយ៉ាងដូចម្តេចខ្លះ? ព្រោះអ្វី ?

គណិតវិទ្យាមានលក្ខណៈខុសស្រឡះពីស្យង់ពិសោធន៍ ត្រង់លក្ខណៈល្អិតល្អន់ពោលគឺ គណិតវិទ្យាពុំដឹងថយទៅរកការប្រហាក់ប្រហែលឡើយ ។ រីឯស្យង់ពិសោធន៍មានលក្ខណៈប្រហាក់ប្រហែលច្រើន ( Caractère approché ) ។

130- អ្វីទៅហៅថា " អាកស្យូម " ? ចូរអធិប្បាយបញ្ជាក់ពីមុខងារទាំងឡាយរបស់ " អាកស្យូម " នៅក្នុងសំណង់គណិតវិទ្យា ។

( វិញ្ញាសាក្រុងល៊ីល ខែមិថុនា ១៩៥០ )

នៅក្នុងគណិតវិទ្យាគេបានអោយនិយមន័យថា « អាកស្យូម » គឺជាសំណើដែលមានលក្ខណៈដោយខ្លួនឯង ។
ដើម្បីកន្សល់អោយបានច្បាស់លាស់ពីពាក្យរបស់គណិតវិទ្យានេះ គប្បីរំលឹកគ្រឿងការមើលទៅប្រវត្តិរបស់វាក្នុងគណិតវិទ្យាជាមុនសិន ។
« អាកស្យូម » ជាពាក្យមួយម៉ាត់ដែលអ្នកគណិតវិទ្យាយកពីភាសា « ក្រិច » មកប្រើ ។ ហើយអ្នកបង្កើតពាក្យនេះមុនគេ គឺលោកអឺគ្លីត ( Euclide ) ។ ពួកក្រិចបានមានគោលជ័យ



www.elibraryofcambodia.org

ក្នុងការស្រាវជ្រាវស្វែងរកគណិតវិទ្យា តាំងពីដូរគេបានរក ឃើញចំណេះខាងធរណីមាត្រម្ល៉េះ ។ គេបានរកឃើញពាក្យ គណិតវិទ្យាជាច្រើន ដែលត្រូវអ្នកប្រាជ្ញខាងមុខវិជ្ជានេះបាន យកធ្វើជាឧបករណ៍ សម្រាប់ធ្វើចំណោះស្រាយគណិតវិទ្យា ដូចជានិយមន័យទាំងឡាយ, ប៉ូស្ទុយឡា, អាក់ស្យូម និង ទ្រឹស្ដីបទជាដើម ។

យើងឃើញថា "និយមន័យ" ទាំងឡាយ សុទ្ធតែជាសំណើ បង្ហាញនូវលក្ខណៈសំខាន់ៗរបស់សញ្ញាណដូចជា: ចំនួន, ឯកតា, ចំណុច, បន្ទាត់, និងផ្ទៃ.. ។ ដូច្នេះឃើញថា "និយមន័យ" ដែលចេញខ្លួនមកបំរើគណិតវិទ្យានោះជា រូបធាតុ (Matières) ទាំងឡាយរបស់ការស្រាវជ្រាវរាវ រកដំណោះស្រាយ ។ ឯចំណែក «អាក់ស្យូម» និង «ប៉ូស្ទុយ ឡា» វិញគឺជារូបរាងនៃសំរាយបញ្ជាក់ប៉ុណ្ណោះ (Démon stration) ។

យើងឃើញទៀតថា ប៉ូស្ទុយឡា ក៏គឺជាសំណើគិតជាក់ លាក់ផងនិងពុំអាចធ្វើសំរាយបញ្ជាក់បានផង ។ ឧទាហរណ៍ ចំណុច (A) មួយនៅក្រៅបន្ទាត់ (D) គេអាចគូសបានបន្ទាត់ តែមួយស្របនឹង (D) ។

ឯចំណែក «អាក់ស្យូម» វិញមាននិយមន័យថា «ជា សំណើប្រកបដោយការជាក់លាក់ផង និងពុំបាច់ធ្វើសំរាយ បញ្ជាក់ឡើយ» ដូចជាថា៖ បរិមាណពីរដែលមាន តំលៃស្មើនឹងបរិមាណ ទី៣ ត្រូវមានតំលៃស្មើគ្នា ។ ឬក៏ថា ទាំងមូលធំជាងចំណែកមួយៗ ។ល។



www.elibraryofcambodia.org

ទោះបីយ៉ាងណាក៏ដោយ ក៏ «មាគស្យូម» បានជួបប្រទះនិងការពិបាករបស់ខ្លួនដែរ ។ អ្នកគណិតវិទ្យាបានប្រើ "សំណើ" ថ្មីមួយថា «មាគស្យូម ប៉ុស្ទុយឡា» គឺគេបានយកមាគស្យូមនិងប៉ុស្ទុយឡាយកប្រើជាមួយគ្នាតែម្តង ។ មូលហេតុដែលបណ្តាលអោយអ្នកប្រាជ្ញធរណីមាត្រ ប្រើសំណើថ្មីនេះ គឺគេចង់បង្កើតអំណោះស្រាយអោយប្រកបដោយ «ការជាក់លាក់ក្នុងន័យ» តែទោះជាយ៉ាងណាក៏ដោយ ក៏គេឃើញថា សំរាយបញ្ជាក់របស់គេត្រូវពឹងផ្អែកទាំងស្រុងទៅលើ រូបភាពធរណីមាត្រ ។ ដូច្នេះគេត្រូវរង់ចាំលោកដេកាត (Descart) ដើម្បីផ្តាច់ធរណីមាត្រពីមនោគតិ (Imagination) ។ ធរណីមាត្រដែលកុំប្រើទ្រឹស្តីលោកអឺគ្លីតបានលើកចំពីរយ៉ាងធំ បង្ហាញវិវត្តន៍នៃគណិតវិទ្យា ។

ឧទាហរណ៍ : ដូចជាទ្រឹស្តីរបស់លោក ឡូបាតឆេវស្គី (LOBATSCHEWSKY) ដែលបង្ហាញថា : ចំណុចក្រៅបន្ទាត់មួយ, គេអាចគូសបន្ទាត់ពីរស្របទៅនឹងបន្ទាត់នោះ ។ គេបានបង្ហាញនូវភាពពិតដោយផ្ទុយពីទ្រឹស្តីលោក «អឺគ្លីត» ។ នៅក្នុងឆ្នាំ ១៨៥១ លោករីម៉ាន់ (RIEMAN) បានបង្ហាញនូវទ្រឹស្តីវាងក្រោយនេះដែរ ។ លុះមកដល់សម័យក្រោយមកទៀត អ្នកគណិតវិទ្យាទាំងអស់តែងតែដើរតាមគន្លងនៃលោកទាំងពីរនេះគ្រប់គ្នា ។

តាំងពីពេលនោះមក ធរណីមាត្ររបស់លោកអឺគ្លីត ក៏ស្ថិតនៅលើតែកម្រិតនៃការសិក្សាដំបូង គឺថ្នាក់ទាបនៃការសិក្សាធរណីមាត្រប៉ុណ្ណោះ ។ ហើយមាគស្យូមក៏បានបាត់បង់



www.elibraryofcambodia.org

នូវលក្ខណៈសំខាន់របស់ខ្លួនដែរ ក៏អាកស្យូមបានក្លាយទៅត្រឹមតែ «សំណើដើម» (proposition première) ។ យើងឃើញថាអាកស្យូម បានផ្លាស់ប្តូរលក្ខណៈរបស់ខ្លួនទៅតាមកាលវេលានិងគំនិតរបស់អ្នកប្រាជ្ញ ។

តែអាកស្យូមមាននាទីរបស់ខ្លួនដដែលរហូតគឺឥតផ្លាស់ប្តូរឡើយ ។ អាកស្យូមនៅជាគ្រឿងសំខាន់របស់គណិតវិទ្យារវាងពួកក្រិចនិងលោកដេកាត ហើយវាក៏មានជញ្ជាំងកំសោតមួយដែលហាមាំងទ្រឹស្តី របស់ពួកគេទាំងនោះគឺ : លក្ខណៈជាក់លាក់ផ្សេងគ្នា ។ ឧទាហរណ៍ លោក ហ៊ិលបែរ (Hilbert) បានប្រមូលអាកស្យូមទាំងអស់ណាដែលសំខាន់ៗ មកបង្កើតធរណីមាត្រមួយ ។ អាកស្យូមទាំងនោះត្រូវលោករៀបជាប្រាំផ្នែក ហើយផ្នែកនិមួយៗសុទ្ធតែអាចជ្រើសរើសអាកស្យូមដើម្បីបង្កើតជាប្រព័ន្ធបាន ។

នៅសម័យបច្ចុប្បន្ន ដែលគណិតវិទ្យាវិវត្តទៅមុខជាលំដាប់ គេឃើញអាកស្យូមបង្កើតជាប្រព័ន្ធ«អាកស្យូមម៉ាទិច (AXIOMATIQUE) ។ ហេតុដូច្នេះហើយបានជាធរណីមាត្រក្រិចប្រកបដោយសច្ចៈដ៏ប្លែករបស់ខ្លួន បានត្រូវក្លាយទៅជា "សច្ចៈសំណុំ" (Vérités des ensembles) ។ ហើយសច្ចៈសំណុំនេះក៏ប្រកបដោយសោភ័ណ យ៉ាងប្រសើរ ក្នុងការប្រើប្រាស់បន្ទាត់និងវណ្ណ័យ ក្នុងការអោយទៅជារូបភាពរបស់ខ្លួន ។ យើងបានសង្កេតឃើញថាប្រវត្តិអាកស្យូមនៅក្នុងគណិតវិទ្យានិងនាទីរបស់វា មានសារៈសំខាន់ណាស់ចំពោះគណិតវិទ្យាទូទៅ ។ អាកស្យូមគឺជាសញ្ញាណជាក់លាក់ដែលមាន



www.elibraryofcambodia.org

ពីធរណីមាត្រលោកដេកាត ព្រោះទាំងផ្តាច់ដោយនៅដោយ
វិស្សុកធរណីមាត្រទំនើប ។
ចូរយល់ពិនិត្យ ទ្រឹស្ដីរបស់អ្នកប្រាជ្ញសិក្សាពីជាតិអង់គ្លេសម្នាក់
ឈ្មោះរូសែល( Russell ) ដែលពោលថា «គណិតវិទ្យាគឺ
ជាស្បង់ដែលគេពុំដឹងថាគេនិយាយពីអ្វី, និងជាស្បង់ដែលគេពុំ
ដឹងថាតើគេនិយាយនោះត្រូវឬខុសផង » ។ ការចំរើននៃរូប
វិទ្យាចំនើបអាស្រ័យគណិតវិទ្យាក្រៅទ្រឹស្ដី លោកមិត្តក
ដែលបានគិតគណនាយ៉ាងច្បាស់ពីភាពស្មុគ, បានសំរេចនូវ
គោលដៅត្រូវកន្លងយ៉ាងពេញចិត្តក្នុងការសិក្សាបញ្ជាក់ពីទ្រឹស្ដី
គណិតវិទ្យា ។

*
* *



www.elibraryofcambodia.org

# ៧- ស្យង់រូបធាតុនិងវិធីពិសោធន៍

## 131- អ្វីទៅហៅថាស្យង់រូបធាតុ ?

ដែលហៅថាស្យង់រូបធាតុ គឺស្យង់ដែលសិក្សាពីរូបធាតុទាំងអស់ដោយពឹងផ្អែកទាំងស្រុងទៅលើពិសោធន៍ ។

## 132- តើគេត្រូវពិសោធស្យង់រូបធាតុ ដោយប្រើវិធីយ៉ាងដូចម្តេចខ្លះ ?

គេត្រូវពិសោធស្យង់រូបធាតុ ដោយប្រើមធ្យោបាយបីយ៉ាងគឺ :

១- ធ្វើការសង្កេតពិនិត្យ (OBSERVATION)

២- ធ្វើសម្មតិកម្ម (HYPOTHESE)

៣- ធ្វើពិសោធន៍ (EXPERIMENTATION)

## 133- តើការសង្កេតពិនិត្យមានប៉ុន្មានបែប ?

អ្នកស្យង់និយម ឬអ្នកប្រាជ្ញបាន សំគាល់ឃើញថាការសង្កេតពិនិត្យមានពីរបែបគឺ :

១- ការសង្កេតពិនិត្យអកម្ម (observation passive)

២- ការសង្កេតពិនិត្យសកម្ម (observation active)

## 134- យ៉ាងដូចម្តេចទៅហៅថាការសង្កេតអកម្ម ?

ការសង្កេតអកម្ម គឺការសង្កេតពិនិត្យ កត់ត្រាទុកនូវការទាំងឡាយដែលប៉ះទង្គិចនឹងឥន្ទ្រិយគ្មានការរំប្រើង ។



www.elibraryofcambodia.org

144- តើគេអាចពោលថា សម្មតិកម្មខុសបានឬទេ ?

គេអាចពោលថាសម្មតិកម្មខុសបាន បើសិនជាសម្មតិកម្មនោះស្ថិតនៅជាឧបករណ៍មុនពិសោធ (A priori) ។

145- ដូច្នេះតើសម្មតិកម្មមានប្រយោជន៍សំរាប់ស្យង់ឬទេ ?

សម្មតិកម្មមានប្រយោជន៍សំរាប់ស្យង់ណាស់ព្រោះថាសម្មតិកម្មជាចំណុចដំបូងរបស់វិធីស្យង់ម៉្យាងទៀត បើសិនជាគ្មានសម្មតិកម្មទេរបកគំហើញច្បាស់ជាពុំអាចកើតមានឡើយ ។

146- អ្វីទៅហៅថាពិសោធន៍ ?

ពិសោធន៍គឺការយកសម្មតិកម្មទៅល្បងមើល, តើខុសឬត្រូវ ។

147- តើជាកត្តាណាខ្លះដែលអ្នកស្យង់និយមថាជាបានការ?

ជាកត្តាដែលអ្នកស្យង់និយមយកជាបានការនៅក្រោយពិសោធន៍ គឺជាកត្តាដែលត្រូវទៅតាមធម្មជាតិ ។

148- គេបានពោលថាស្យង់ មានច្បាប់របស់ខ្លួនត្រឹមត្រូវសំរាប់អនុវត្ត ។ តើស្យង់នោះជាអ្វី ?

ច្បាប់ស្យង់ គឺជាគំហើញជាក់លាក់របស់ស្យង់ដែលបញ្ជាក់ពីទំនាក់ទំនងឥតផ្លាស់ប្តូរនៃបាតុភូតទាំងឡាយរបស់ធម្មជាតិ ។

149- តើច្បាប់ស្យង់មានគុណសម្បត្តិយ៉ាងដូចម្តេចខ្លះ ?

ច្បាប់ស្យង់ មានបំណងនឹងស្វែងរករបៀបខាងក្នុង នៅក្រោមការប្រែប្រួលខាងក្រៅនៃការណ៍ ។ ច្បាប់នេះមានបំណងនឹងញែកអ្វីដែលជាខ្លឹម (essence) ចេញពីអ្វីដែលគ្មានន័យ អ្វីដែលឋិតថេរពីអ្វីដែលផ្លាស់ប្តូរ ។ ច្បាប់ស្យង់មានមុខងារត្រឹមតែតាមគ្រាដាច់ទៅកំណត់និយម (déterminisme) ។



www.elibraryofcambodia.org

ច្បាប់ស្យង់មានប្រយោជន៍ជាចាំបាច់ណាស់សំរាប់គំនិត និងជីវិតរាល់ថ្ងៃ ព្រោះច្បាប់នេះ អាចអោយយើងទាយទុកមុនបាននូវការណ៍ផ្សេងៗ ។ តែទោះជាយ៉ាងណាក៏ដោយក៏យើងសង្កេតឃើញថា, ច្បាប់ស្យង់គ្មានសមត្ថភាពនឹងកស្រាយអ្វីៗទាំងអស់បានទេ ដោយហេតុថាច្បាប់នេះគ្រាន់តែបង្ហាញនូវចំណង ដែលចងធាតុភូតទាំងឡាយ តែមិនអាចប្រាប់យើងអោយស្គាល់នូវអាថ៌កំបាំងនៃចំណងនេះបានទេ ។

150- ដោយសារការជាក់លាក់របស់ស្យង់ តើអ្នកប្រាជ្ញបានរកឃើញទ្រឹស្តីឈ្មោះអ្វី ?

ដោយសារការជាក់លាក់របស់ស្យង់, អ្នកប្រាជ្ញបានរកឃើញទ្រឹស្តីមួយថ្មីទៀតហៅថាទ្រឹស្តីកំណត់និយម (déterminisme) ។

151 - តើទ្រឹស្តីកំណត់និយមសិក្សាពីអ្វី ?

ទ្រឹស្តីកំណត់និយម សិក្សាពីការកំណត់យ៉ាងជាក់លាក់ ដែលមាននៅក្នុងភាវៈរស់និងក្នុងអង្គធាតុទាំងឡាយ ដែលគ្មានឥន្ទ្រិយ ។

152- តើបាតុភូតទាំងអស់នៅក្នុងធម្មជាតិ គេអាចសំគាល់បានដោយសារអ្វី ?

បាតុភូតទាំងអស់នៅក្នុងធម្មជាតិ, គេអាចសំគាល់បានដោយសារ ឥន្ទ្រិយរបស់យើងផ្ទាល់ខ្លួនផង ឬដោយសារ ឧបករណ៍ទាំងឡាយរបស់ស្យង់ផង ។



www.elibraryofcambodia.org

153- វិវត្តន៍របស់ស្យង់សព្វថ្ងៃ អាចអោយអ្នកប្រាជ្ញទាំងអស់ អស់ជំនឿទៅលើវាសនាឬទេ ? ព្រោះអ្វី ?

វិវត្តន៍របស់ស្យង់បានធ្វើអោយលោកសម័យថ្មីរីកចំរើនគ្រប់វិស័យ, គឺសង្គមកិច្ច, សេដ្ឋកិច្ច និងវិទ្យាសាស្ត្រ ។ គេឃើញមនុស្សហោះហើរដូចបក្សី ដោយធ្វើដំណើរបានទាន់ចិត្តតាមយន្តហោះប្រតិកម្មយ៉ាងទំនើបបំផុត ។ មនុស្សឈប់ប្រើខួរក្បាលដើម្បីគិតលេខដែលមានចំនួនច្រើនឥតគណនា ដោយប្រើម៉ាស៊ីនអេឡិចត្រូនិច ។ គេឃើញម៉ាស៊ីន អ័រឌីណាទ័រ (Ordinateur) បំរើមនុស្សបានយ៉ាងទាន់ចិត្ត ហើយមនុស្សបានទាញយកផលធម្មជាតិមកប្រើប្រាស់ បានស្ទើរតែគ្រប់វិស័យ ។ តែទោះជាយ៉ាងនេះក្តីក៏គេឃើញថា មានអ្នកប្រាជ្ញវិទ្យាសាស្ត្រភាគច្រើន, ក្រោយដែលខ្លួនអស់សមត្ថភាពក្នុងការទ្រទ្រង់ជីវិតមនុស្សអោយប្រកបដោយសុខភាពបានក៏, សម្រេចចិត្តតាមដានរកបាតុភូតផ្សេងៗដែលមាននៅក្នុងធម្មជាតិ ហើយដែលពិសេសនិយាយពីកំណត់និយម។ ក្រោយមកពួកអ្នកប្រាជ្ញទាំងនោះវិលត្រឡប់មកជឿលើគោលទ្រឹស្តីសាសនា ដែលបាននិយាយពីភាពប្រាកដប្រជានៃជីវិតសត្វលោក ។ ហើយគេក៏បានហៅទ្រឹស្តីនោះថាជាទ្រឹស្តីវាសនានិយម (Fatalisme) ។

154- ហេតុអ្វី បានជាអ្នកប្រាជ្ញនៅជឿទៅលើវាសនារបស់មនុស្ស ?

អ្នកប្រាជ្ញនៅជឿទៅលើវាសនារបស់មនុស្សព្រោះអ្នកប្រាជ្ញ



www.elibraryofcambodia.org

ពុំទាន់រកឃើញនូវហេតុនិងផល ដែលធ្លាក់ទៅលើមនុស្ស ម្នាក់ៗដោយវិធីសាស្ត្រច្បាស់ ។ មានសភាពអាចកំណត់ដែល ហួសវិស័យនិងកិច្ចការណាបាន ទើបពួកអ្នកប្រាជ្ញទាំងនោះវិល ត្រឡប់ទៅជឿគំនិតសាសនា ដែលបានកើតមានមកជាច្រើន សតវត្សមុនកំណើតរបស់គ្រិស្ត ។

155- អ្វីទៅហៅថាចៃដន្យ ( Le hasard )?

ចៃដន្យ គឺអ្វីដែលគ្មានទីដៅ, គ្មានដើមហេតុ ។
អ្នកប្រាជ្ញឈ្មោះគួរណូ (Cournot) ពោលថា ៖
« ចៃដន្យ គឺការជួបគ្នានៃបាតុភូតទាំងឡាយដែលកើតនៅក្នុង ជំពូកពីរខុសដាច់ឡែកពីគ្នា ក្នុងដំណើរហេតុផល »

156- ចូរអធិប្បាយរិះគន់ តាមបែបទស្សនវិជ្ជានូវសំដី របស់អ្នកប្រាជ្ញឈ្មោះស្ពីណូសា (Spinoza) ដែល បានពោលថា ៖ "ការអោយឈ្មោះហេតុមួយថាជាចៃ ដន្យ, គឺជាការទទួលស្គាល់នូវកង្វះនៃពុទ្ធិមនុស្ស"?

ដើម្បីរិះគន់ទ្រឹស្តីរបស់លោក ស្ពីណូសា, គប្បីយើង បង្ហាញនូវនិយមន័យរបស់ពាក្យថា « ចៃដន្យ » ជាមុនសិន ។ ពាក្យចៃដន្យ បើតាមនិយមន័យទូទៅពោលថា ៖ « អ្វី ដែលគ្មានទីដៅ » ឬ អ្វីដែលគ្មានដើមហេតុ ។ ដូច្នេះចៃដន្យ គ្មានវត្ថុបំណងត្រឹមត្រូវឡើយ ។ ហេតុការណ៍ទាំងឡាយ ដែលកើតឡើងដោយចៃដន្យ គឺជាហេតុការណ៍ដែលរកពុំ អាចស្មានត្រូវ ។ ប្រភពនៃហេតុការណ៍កើតពីចៃដន្យគ្មាន



www.elibraryofcambodia.org

អ្នកប្រាជ្ញណាម្នាក់អាចលើកយកអធិប្បាយ ឬ ពន្យល់តាមបែបរូបីក្នុងសួនបានឡើយ ។ រីឯអ្នកទស្សនវិជ្ជាលោកទៀតក៏គ្មានលទ្ធភាពនឹងប្រើមនោសញ្ចេតនារបស់ខ្លួន ឬ ក៏ប្រើវិចារណញ្ញាណរបស់ខ្លួន ដើម្បីតាមដានរកដើមកំណើតនៃចៃដន្យអោយឃើញស្រឡះជាក់លាក់បាន ។ ពួកគេទាំងឡាយដែលសុទ្ធសឹងតែជាអ្នកប្រាជ្ញល្បីៗ ខាងមនោគតិនិយមបានចុះចាញ់បញ្ហាចៃដន្យគ្រប់គ្នា ។ ទោះយ៉ាងនេះក្តី យើងនៅឃើញអ្នកប្រាជ្ញខ្លះ ខំបញ្ចេញគំនិតរបស់ខ្លួនដើម្បីស្រូបសាងការទើសទ្រែក ។ ឧទាហរណ៍អ្នកប្រាជ្ញឈ្មោះគួរណូ (Cournot) ដែលបានអោយនិយមន័យពាក្យចៃដន្យថា — ចៃដន្យ គឺ ជា « ការជួបគ្នានៃធាតុពួកទាំងឡាយដែលបិទនៅក្នុងពួកពីរខុស ដាច់ឡែកពីគ្នាក្នុងដំណើរហេតុផល (Causalite) ។ លោកគួរណូបានបញ្ជាក់ថែមទៀតថា ចៃដន្យ « គឺពុំដែលគេមិនអាចកំណត់បាន, គឺការជួបគ្នារវាងសេរីលក្ខណៈមួយ ទៅនឹងវត្ថុជាមួយនឹងសេរី (Série) លក្ខណៈទីពីរ, ហើយសេរីលក្ខណៈមួយនោះគោរពទៅតាមច្បាប់កំណត់និយមធាតុអាកាស ។ ចំណែកឯសេរីលក្ខណៈទីពីរគោរពទៅតាមច្បាប់កំណត់និយមចិត្តវិទ្យា ។

យើងបានឃើញថានិយមន័យ និងការវិភាគដែលលោកគួរណូ បានពន្យល់អោយយល់ឧបករណ៍ គ្រាន់តែជាការយកអរូបីទៅដោះស្រាយអរូបីប៉ុណ្ណោះ ។ ចំណែកភាពពិតប្រាកដរបស់ចិត្តនិងលើរឿងហៅថា ចៃដន្យនោះ ស្ថិតនៅក្នុងអាថ៌កំបាំង



www.elibraryofcambodia.org

ដំរីដល ។ យើងជឿថាបើអ្នកប្រាជ្ញឈប់មានះប្រកាន់យក
គំនិតស្បែកទាំងអស់, ហើយចាប់ភ្លឹកទៅលើទ្រឹស្ដីនិងក្បួន
ខ្នាតរបស់ „ហោរាសាស្ត្រ” ខ្លះនោះ ការដោះស្រាយ
បញ្ហាចៃដន្យ ប្រហែលជាអាចហុចលទ្ធផលក្នុងការស្រាវ
ជ្រាវគាប់ប្រសើរលើសតាមចំណង់របស់ខ្លួនបាន ។ ព្រោះថា
ឧទាហរណ៍ : គម្ពីរស្រុកចិនមួយសរសេរថា : កាលណោះ
ស្ដេចភុជង្គនាគ អង្គុយក្នុងវិមានរបស់ខ្លួន, ក៏គិតណែងកាយជា
មាណពម្នាក់ឡើងមកលេងឋានមនុស្សលោក ។ មកដល់មាត់
សមុទ្រក៏ជួបនឹងអ្នកនេសាទកំជិលម្នាក់កំពុង ដេកលើដុំថ្មមួយ
រង់ចាំផ្លែដូងក្រង់ធ្លាក់ចុះទៅដីក្រោម ។ ពេលនោះ ស្ដេច
ភុជង្គនាគបានក្លាយរូបជាមនុស្សម្នាក់ពោលទៅកាន់តានេសាទ
កំជិលនោះថា៖

– „អេ ជនកំជិល យើងឯងគិតតែគិតដេក, ធ្វើម្ដេចនឹងបានត្រី
ទៅស៊ី?”

– ស្ដេចភុជង្គនាគឮតានេសាទខ្ជិលនោះឆ្លើយទៅវិញថា :

– „អញចាំទៅដងរនាយហត់នឿយប្រយោជន៍ធ្វើអ្វី? បើហោរា
ទាយអោយអញរួចហើយ , ថា : ផ្លែដូងក្រង់នឹងអោយអញដងត្រី
បាន ឯងចាំមើលចុះរឿងនេះពិតឬក៏កុហក?” ។

កាលណោះស្ដេចភុជង្គនាគ លបចាំមើលរហូតដល់ផ្លែដូងក្រង់
តើអ្នកនេះដងត្រីបានតាមហោរាទាយឬទេ ?

លុះដល់ផ្លែដូងធ្លាក់, តានេសាទក៏ឱ្យម្នាលីថ្មីងទៅដងត្រី
វិញ។ គាត់ដងទីតមួយលើកស្រាប់តែបានត្រីពេញថ្នង់។ ស្ដេចភុ
ជង្គនាគឆ្ងល់នឹងហោរាទាយអស្ចារ្យនោះជាពន់ពេក ។ ជាមួយ



www.elibraryofcambodia.org

និងចំអស់ទេ ស្ដេចនាគក៏ខឹងនឹងអ្នកនេសាទដែលបានចាប់កូន
ទៅរបស់ខ្លួន, ក៏បញ្ចេញមហិទ្ធិឫទ្ធិបំបាក់ខ្នង អ្នកនេសាទនោះ
ទំលាក់ទៅក្នុងទឹកអស់វិញ ។ ពេលនោះ អ្នកនេសាទស្រាប់
តែស្ទុះសំពើលាន់រកង់ហើយនិយាយថា :

ឱ! ដូចពាក្យរបស់លោកហោរាទាយមែន ថា " នៅពេល
ថ្ងៃត្រង់អញត្រូវវង់ត្រីបានមួយខ្លួន, ក៏ប៉ុន្តែនៅពេលអញក៏ទាញ
លើកត្រីនោះ, ខ្លួនអញត្រូវធ្លាក់ ហើយរួចត្រីទៅក្នុងទឹកវិញ
អស់, បុព្វហេតុដោយមានពស់ម្នាក់បញ្ចេញឫទ្ធិរបស់វា
ឱ! ហោរានេះអាចទាយមើលឃើញប្រភពកំណើតខែជន្សាយមែន
ពិត » ។

រឿងក្នុងគម្ពីរមិនបានបំផុសជំនឿមួយដែលពោលពាក់ព័ន្ធទៅ
លើការទស្សន៍ទាយឬក្បួនហោរាសាស្ត្រ ។ បើតាមទស្សនៈ
វិជ្ជា រឿងទាំងនេះជាខែជន្សាយប៉ុណ្ណោះ, គឺថាខែជន្សាយបាន
បណ្ដាលអោយមានអ្នកនេសាទកំពិល ស្រដីសរសើរពេលថ្ងៃ
ត្រង់ដែលហ្វូងត្រីសមុទ្រមួយហ្វូង បានទាំងផ្លាបកៅហាលលើទឹ
ទឹកថៃក្បែរមាត់ច្រាំងហើយស្ដេចភុជង្គនាគ, មិនដឹងមកពីរឿងអ្វី
ក៏ស្រាប់តែខែជន្សាយ បណ្ដាលអោយកើតការអន្ទ្រាក់ចង់ចាកឹង
កំសាន្តនៅឋានមនុស្សលោក ។ ទីបំផុតខែជន្សាយបាននាំស្ដេច
ភុជង្គនាគអោយជួបនឹងតានេសាទកំពិលនោះ ទម្លាក់ទាល់តែ
បំផ្លាញផ្ទះរបស់គាត់ បណ្ដាលអោយត្រីដែលវង់បានដោយ
ខែជន្សាយទៅវិញដោយខែជន្សាយអស់គ្មានសល់ ។

ហេតុអ្វីក៏យើងហៅការកាលថារឿងនេះជារឿងខែជន្សាយ ?
យើងហៅការកាលដូច្នេះ ព្រោះយើងឃើញថាស្ដេចភុជង្គនាគ



www.elibraryofcambodia.org

កើតអស្ចារ្យដោយចៃដន្យ ។ បន្ទាប់មកស្តេចនាគក៏បានស្អប់និងអ្នកនេសាទដោយចៃដន្យ ហេតុទាល់តែបំផ្លាញផ្ទះរបស់គាត់ចោលថែមទៀតផង ។ យើងឃើញថារឿងនេះកើតឡើងដោយចៃដន្យទាំងអស់ ព្រោះថារឿងដែលកើតឡើងដោយគ្មានទីដៅនិងគ្មានដើមហេតុ ហើយដែលថារឿងដែលគេស្មានមិនត្រូវផង ។ ឧទាហរណ៍នៃគម្ពីរចិននិយាយពីហោរាចម្លែកគេ, បានបង្អួលអោយយើងឃើញស្ទើរទាយដែលអាចស្ទង់ពីដើមកំណើតនៃព្រឹត្តិការណ៍ ដែលគេចាត់ថាចៃដន្យនោះ ហេតុដល់ទីបញ្ចប់គ្រប់ចន្លោះបន្តិចឡើយ ។ ដូច្នេះចៃដន្យពុំមែនជារឿងចម្លែកឡើយ ។ តែជារឿងទាំងឡាយដែលកើតមានឡើងដូចព្រឹត្តិការណ៍ឯទៀតដែរ, តែខុសគ្នាត្រង់ថាព្រឹត្តិការណ៍ឯទៀតកើតឡើងដោយចេតនា ឯចំណែកចៃដន្យជារឿងដែលកើតឡើងដោយអចេតនា, ព្រោះអ្នកប្រព្រឹត្តធ្វើពុំបានគិតទុកជាមុនសោះ ។ តែរឿងរបស់ចៃដន្យមានកំណើតជាក់លាក់ ដែលវិចារណញ្ញាណរបស់មនុស្សពុំអាចសំរេចនូវ « ពុទ្ធិលក្ខណៈ » នេះបានឡើយ ។ មានតែព្រះពុទ្ធនៃប៉ុណ្ណោះ ដែលអាចមើលឃើញបច្ច័យដែលពួកផ្តុំជាកម្មហើយអន្ទោលតាមប្រាណរបស់អ្នកដែលប្រព្រឹត្តិ ។

ដោយមនុស្សពុំមែនមាន « ពុទ្ធិ » ប្រកបដោយការគ្រាប់ដឹងផលនូវរឿងរ៉ាវទាំងឡាយក្នុងលោកនិងក្រៅលោកដូចព្រះពុទ្ធ , បានជាលោកស្តីណា សារពាលថា ៖

« ការអោយឈ្មោះហេតុមួយថាជាចៃដន្យ , គឺការទទួលស្គាល់នូវកង្វះនៃពុទ្ធិមនុស្ស » ។

*
* *



www.elibraryofcambodia.org

# ៨-ជីវវិទ្យា

157 - អ្វីទៅហៅថាជីវវិទ្យា ?

ជីវវិទ្យាជាស្យង់ដែលសិក្សាពីជីវិតនៃមនុស្សសត្វនិង រុក្ខជាតិទាំងអស់នៅក្នុងលោក ។

158- ដូច្នេះគេអាចសន្និដ្ឋានថា ជីវវិទ្យាជាវិជ្ជាសមោធាន ដែលសិក្សាពី " ជីវិត " បានឬទេ ? ហេតុអ្វី ?

គេអាចសន្និដ្ឋានថា ជីវវិទ្យាជាវិជ្ជាសមោធានខាងការសិក្សាពីជីវិតបាន ព្រោះថាក្រៅពីការសិក្សាលើរូបធាតុទាំងឡាយដែលប្រកបដោយសរីរាង្គនិង ដែលជាទីតាំងនៃជីវិតនោះ,ជីវវិទ្យាបាននាំអោយសិក្សា លើវត្ថុធាតុទាំងឡាយក្នុងធម្មជាតិ ដែលប្រកបដោយសរីរាង្គតែពុំមានវិញ្ញាណឬជីវិតថែមទៀតផង ។

159- តើគេអាចស្គាល់ភាវៈរស់(être vivant) ដោយលក្ខណៈណាខ្លះ ? អ្វីហៅថាភាវៈរស់ ?

ភាវៈរស់គឺអ្វីដែលមានជីវិត ក៏ប៉ុន្តែដើម្បីសិក្សាពីជីវិតអោយបានច្បាស់លាស់ , អ្នកប្រាជ្ញខាងជីវវិទ្យាបានយកចិត្តទុកដាក់ជាពិសេស ទៅលើបញ្ហារបស់មនុស្សមុនអ្វីទាំងអស់ ។ មនុស្សជាសត្វ ដែលមានប្រាជ្ញាវិញ្ញាណ ភ្ជាប់ជាមួយនិងមនោសញ្ចេតនា ។ ដូច្នេះសិក្សាពីជីវិតមនុស្សជាមធ្យោបាយចាំបាច់បំផុតសម្រាប់ការស្គាល់ , ពិសោធន៍, និងវិភាគ ។ គេបានចាត់ទុកមនុស្សថាជា «ភាវៈរស់» (être vivant) ដែល



www.elibraryofcambodia.org

ប្រកបដោយលក្ខណៈពិសេសពោលគឺ ។ លក្ខណៈបុគ្គល (Caractère individuel) ខុសនិងសត្វឬក្រុមជាតិនានា ។

160- តើពិសោធន៍ ដែលអ្នកប្រាជ្ញជីវវិទ្យាចាប់យកមកធ្វើជាកម្មវត្ថុរបស់ខ្លួនមុនគេគឺអ្វី ? ហេតុអ្វី ?

អ្នកប្រាជ្ញជីវវិទ្យា បានលើកយកបញ្ហាសរីរាង្គរបស់ភាវៈរស់យកធ្វើជាកម្មវត្ថុរបស់ខ្លួនមុនគេ ។ ហើយបុព្វហេតុដែលបណ្ដាលអោយអ្នកប្រាជ្ញទាំងនោះលើកបញ្ហាសរីរាង្គយកធ្វើជាកម្មវត្ថុរបស់ខ្លួននោះគឺសរីរាង្គជាពិសោធន៍រូបីដែលផ្ដល់អោយគេនូវការសង្កេតពិនិត្យតាមបែបទស្សន៍និយមយ៉ាងច្បាស់ ។

161- ទស្សនៈដែលលើកយកការពិចារណារកហេតុពិតរបស់ជីវិតដោយធ្វើការសង្កេតពិនិត្យ ទៅលើសរីរាង្គទាំងឡាយរបស់ភាវៈរស់ តើអាចផ្ដល់ផលប្រយោជន៍អ្វីខ្លះក្នុងការសិក្សាពីជីវិត ?

ការស្រាវជ្រាវសិក្សាពីជីវិត ដោយផ្អែកទៅលើការពិនិត្យសង្កេតដែលធ្វើឡើងលើសរីរាង្គកាយរស់ភាវៈរបស់,មិនគ្រាន់តែផ្ដល់នូវសេចក្ដីចំរើន ដោយមានប្រត្យក្សនិយមប៉ុណ្ណោះ ទេតែបានជំរុញអ្នកប្រាជ្ញជីវវិទ្យាខ្លះ អោយហ៊ានធ្វើ វិភាគដោយប្រើការវះកាត់ទៅលើសរីរាង្គ ដើម្បីពិនិត្យមើលនាទីខាងក្នុងនៃភាវៈរស់នោះថែមទៀតផង ។ ការហ៊ានវះសរីរាង្គភាវៈរស់ដើម្បីពិនិត្យអោយប្រត្យក្ស, បានបង្កើតបញ្ហាមួយថ្មីទៀតដល់អ្នកស្រាវជ្រាវ, គឺបញ្ហាស្មុគស្មាញចាក់ស្រែះនៃសរី



www.elibraryofcambodia.org

រាង្គរបស់ភាវៈរស់ទៅតាមប្រភេទនិមួយៗរបស់ខ្លួន ។ ទីបំផុត ក្រោយដែលបានរកឃើញនូវភាពមិនដូចគ្នារវាងភាវៈរស់ក្នុងក្រុមនិមួយៗ រួចហើយ, អ្នកប្រាជ្ញក៏អនុម័តគំនិតការស្រាវជ្រាវរបស់ខ្លួនអោយនៅត្រឹមពាក់កណ្តាល, ពោលគឺគេបានប្រមូលការសិក្សាវិះកាត់លើសរីរាង្គរបស់ភាវៈរស់ទាំងអស់ ដោយប្រគល់កម្មវត្ថុដល់មុខវិជ្ជាថ្មីមួយទៀតដែលមានឈ្មោះថា: «សរីរវិទ្យា» (physiologie) ដែលជាផ្នែកសិក្សាអំពីមុខងារទាំងឡាយនៃជីវិត ។

162- តើសរីរវិទ្យាក្តី ជីវវិទ្យាក្តី មានពឹងផ្អែកទៅលើគណិតវិទ្យាឬ គីមី-រូបវិទ្យាឬទេ ?

ដោយសរីរវិទ្យាក្តី, ជីវវិទ្យាក្តី ត្រូវការចាំបាច់នូវភាពប្រាកដនិយម និងការស្ទង់ធាតុដែលទាក់ទងនឹងសីតុណ្ហភាព ទើបវិជ្ជាទាំងពីរនេះត្រូវការជាចាំបាច់នូវគណិតវិទ្យា និងគីមី-រូបវិទ្យា ។

163- ដូច្នេះជីវវិទ្យាដែលមានលក្ខណៈជាវិជ្ជាពិសោធពិតៗនោះ តើបានឆ្លងកាត់វិវត្តន៍អ្វីខ្លះ ?

មុននឹងបានក្លាយខ្លួនជាវិជ្ជាពិសោធពិតៗ, ជីវវិទ្យាបានឆ្លងកាត់តំណាក់ការណ៍នៃការសិក្សាជាច្រើនប្រភេទគួរកត់សំគាល់ដូចទៅនេះ:

ដំបូងការប្រមូលផ្តុំនូវលក្ខនិទ្ទេសជាតិជាពួកជាក្រុមបានញ៉ាំងការសិក្សាអោយក្លាយទៅជាវិជ្ជាមួយយ៉ាង ដែលសិក្សាពីសណ្ឋានផ្សេងៗរបស់ភាវៈរស់តាមពួក ។ ហើយការប្រមូលផ្តុំនិងចំណាត់ថ្នាក់ (classification) របស់ភាវៈរស់ទាំងនោះបាន



www.elibraryofcambodia.org

ក្លាយទៅជាក្បួនចងក្រងកិច្ចរៀងរបស់ធម្មជាតិ ដែលហៅថា "ប្រវត្តិធម្មជាតិ" (histoire naturelle) ។ ក្នុងសិក្សាពីចំណែកថ្នាក់របស់ធម្មជាតិ មិនគ្រាន់តែបង្ហាញនូវភាពដែលមានលក្ខណៈជាប្រព័ន្ធ (systèmes) ប៉ុណ្ណោះទេ, តែបានបង្កើតគំនិតប្រាកដនិយមតាមបែបស្យង់តិសោធន៍ ក្នុងរូបវិទ្យា (physique) ជាច្រើនទៀត ដែលកាលពីដើមស្ថិតនៅក្នុងជំនឿជាអច្ឆរិយៈក្រៅស្បង់រូបវិទ្យា (បរមត្ថវិជ្ជា : métaphysique) នៅឡើយ ។

យើងបានឃើញថា, ការស្រាវជ្រាវរូបធាតុរបស់ភាវៈរស់ ផ្តល់នូវចំណេះពិសោធន៍យ៉ាងទៀត គឺការយល់ឃើញដើមកំណើតនៃភាវៈរស់ទូវដែលបានផ្លាស់ប្តូរភេទនិងសរីរាង្គរបស់ខ្លួនពីកំណើតកើតមកជាសរីរាង្គថ្មី ដែលគេពុំអាចមើលស្គាល់បាន ។ ឧទាហរណ៍ : សត្វដង្កូវទឹកបានក្លាយទៅជាមូស ។ សត្វដង្កូវនាងបានក្លាយទៅជាមេអំបៅ ។ មនុស្សក្នុងកាលពីសម័យបុរេប្រវត្តិមានរូបរាងជាស្វា ។ល។
ការផ្លាស់ប្តូរភេទរបស់ភាវៈរស់ បានត្រូវអ្នកប្រាជ្ញទាំងឡាយហៅឈ្មោះថា (ប៉ែរលង់និយម) (Le transformisme)

**164- ក្រោយ ដែលបានបន្តការស្រាវជ្រាវទៅតាមជីវវិទ្យា តើអ្នកប្រាជ្ញ បានកត់សំគាល់សរីរាង្គកាយរបស់មនុស្សថាយ៉ាងដូចម្តេចខ្លះ ?**

បញ្ហា ដែលក្រសោបយកភាវៈរស់ទាំងអស់មកស្រាវជ្រាវ ពេលគឺធ្វើចំណែកថ្នាក់ទៅតាមប្រភេទនិងពួក, បន្ទាប់មកគឺការវះកាត់សរីរាង្គសត្វនិង មនុស្សដើម្បីសង្កេតពិនិត្យរោយ -



www.elibraryofcambodia.org

ឃើញលក្ខណៈពិតនៃធម្មជាតិ បានការពារអ្នកប្រាជ្ញរោយ បញ្ជាក់ថា ៖

« សរីរាង្គទាំងឡាយរបស់មនុស្សនិងសត្វ , សុទ្ធតែទំណុ ដោយស្រួល ដែលតែកលក្ខនិងមនុស្សជាច្រើនបែកពីរផាច់ពីគ្នា ។ ទី១គឺមជ្ឈដ្ឋានក្រៅ (Milieu extérieur) ចំណែកទី២ គឺមជ្ឈដ្ឋានក្នុង (Milieu intérieur) ។ អ្នកប្រាជ្ញបានពោលថា ៖ « ព្រំដែនក្រៅរបស់សារពាង្គកាយ គឺស្បែក ឬស្រោម ។ មជ្ឈដ្ឋានក្រៅមិនសូវមានឥទ្ធិពលលើសារពាង្គកាយទេ ។ រីឯមជ្ឈដ្ឋានក្នុងមានឥទ្ធិពលខ្លាំងក្លាណាស់ទៅលើសារពាង្គកាយ ព្រោះនៅព្រំដែនខាងក្នុងមានសុទ្ធតែធាតុផ្សំ (Composant) របស់ភាវៈរស់ , ហើយសុទ្ធតែនៅត្រាំក្នុងឈាមនិងទឹករងៃ ។

165- តើជីវវិទ្យាដែលទំពក្តការស្រាវជ្រាវរបស់ខ្លួន . ក្រោយទាំងបានលទ្ធផលគាប់ប្រសើរយ៉ាងដូច្នេះអាចឆ្លើយនឹងសំណួររបស់ "បរមត្ថវិជ្ជា" ពីបញ្ហា " ជីវិត " បាន ឬទេ ?

ថ្វីបើការស្រាវជ្រាវផ្នែកជីវវិទ្យា ប្រកបដោយលទ្ធផលគាប់ប្រសើរក្នុងធម្មជាតិយ៉ាងនេះក្តី , ក៏យើងឃើញថា « ជីវវិទ្យា កុំអាចឆ្លើយនឹងសំណួររបស់ « បរមត្ថវិជ្ជា » ពីបញ្ហាជីវិតបានឡើយ ។

166- តើ " បរមត្ថវិជ្ជា " សួរ " ជីវវិទ្យា " ដោយសំណួរយ៉ាងដូចម្តេច ?



www.elibraryofcambodia.org

« បរមត្ថវិជ្ជា » បានសួរ « ជីវវិទ្យា » ថា ៖

« តើអ្នកណាបង្កើតភ្នែកសំរាប់មើល ? បង្កើតមនោសញ្ចេតនា ឲ្យមនុស្សចេះយំ-សើច-សប្បាយរីករាយ និងខឹង ?

167- តើអ្នកប្រាជ្ញឈ្មោះអ្វី ដែលបានរករូបមន្តស្យង់ឃើញមុនគេក្នុងការស្រាវជ្រាវសរីរវិទ្យា ?

អ្នកប្រាជ្ញឈ្មោះក្លូតប៊ែណា (Claudes Bernard) បានរកឃើញរូបមន្តស្យង់មុនគេក្នុងការស្រាវជ្រាវពិសោធសរីរវិទ្យា ។

168- តើអ្នកប្រាជ្ញឈ្មោះអ្វីដែលរៀបថា « សរីរាង្គកាយរបស់មនុស្សនិងសត្វ » មានបែបដូចជាម៉ាស៊ីន ?

ដេកាត (Descartes) ។

169- តើនរណាដែលបានរកធាតុពិតទាំងអស់ នៃសរីរាង្គកាយរបស់មនុស្សនិងសត្វឃើញមុនគេ ?

ព្រះពុទ្ធសមណគោតមបានរកឃើញរូបមន្ត នៃការកកើតរាងកាយមនុស្សនិងសត្វទាំងអស់ឥតមានចន្លោះឡើយ ។ ឧទាហរណ៍ដូចជាព្រះអង្គទ្រង់បានបញ្ជាក់ ក្នុងព្រះគម្ពីរអភិធម្មថា ៖ រូបកើតមកពីសភាវៈទាំងឡាយ ៤ គឺកម្ម ១ - ចិត្ត ១ - ឧតុ ១ និងអាហារ ១ - ។ រីឯសំណួរថាតើក្នុងរូបនោះតើមានធាតុអ្វីខ្លះ ? ព្រះពុទ្ធក៏ទ្រង់មានពុទ្ធដីការួចមកហើយដែរ គឺ ទ្រង់បានបញ្ជាក់ឈ្មោះមួយឡើងហៅថា « មហាភូត » ដែលមានសំភារធាតុ ៤ គឺ ៖



www.elibraryofcambodia.org

១ - បឋវីធាតុ ( ធាតុដី )

២ - អាបោធាតុ ( ធាតុទឹក )

៣ - តេជោធាតុ ( ធាតុភ្លើង )

៤ - វាយោធាតុ ( ធាតុខ្យល់ ) ។

* * *



www.elibraryofcambodia.org

# ៩- មនុស្សវិទ្យា

(Sciences humaines)

170- អ្វីទៅហៅ ថាមនុស្សវិទ្យា?

វិជ្ជាដែលហៅថាមនុស្សវិទ្យា គឺវិជ្ជាទាំងឡាយដែលសិក្សាអំពីកិរិយាបថនិងអាកប្បកិរិយា (Comportement) មនុស្ស ។

171- ដើម្បីកុំអោយច្រលំនៅពេលសិក្សា, តើគេអាចចែកមនុស្សវិទ្យាជាប៉ុន្មានកង? តើអ្វីខ្លះ?

ដើម្បីកុំអោយច្រលំក្នុងការសិក្សាពីមនុស្សវិទ្យា អ្នកប្រាជ្ញសម័យថ្មីបានចែកការសិក្សាមនុស្សវិទ្យាជា៣កងដូចតទៅគឺ ៖

១ - ប្រវត្តិវិទ្យា (Histoire)
២ - សង្គមវិទ្យា (Sociologie)
៣ - ចិត្តវិទ្យា (Psychologie)

172- អ្វីទៅ ហៅថាប្រវត្តិវិទ្យា?

ប្រវត្តិវិទ្យា គឺការសិក្សាពីស្ទង់របស់មនុស្សដែលរស់នៅក្នុងសង្គមតាមសម័យអតីតកាល ។ ជារឿងរ៉ាវដែលចែងនិងស្តែងពីព្រឹត្តិការណ៍ពិតនៃជនជាតិណាមួយ ប្រកបដោយទីកន្លែងនិងការណ៍ជាក់លាក់ ។

173- លក្ខណៈសំខាន់ដែលធ្វើអោយគេចាប់អារម្មណ៍យ៉ាងខ្លាំងថាប្រវត្តិវិទ្យាជាស្ទង់ដែលប្លែកពីស្ទង់ដទៃ គឺអ្វី?



www.elibraryofcambodia.org

នៅក្នុងប្រវត្តិវិទ្យា លក្ខណៈសំខាន់ដែលធ្វើអោយចាប់អារម្មណ៍ជាងគេគឺ « ការណ៍ប្រវត្តិវិទ្យា » (Fait historique)

174- អ្វីទៅហៅថា " ការណ៍ប្រវត្តិវិទ្យា " ?

ដែលហៅថា « ការណ៍ប្រវត្តិវិទ្យា » គឺព្រឹត្តការណ៍ទាំងឡាយណាដែលមានលក្ខណៈជារូបី, បានប្រព្រឹត្តក្នុងគតិកាលកន្លងទៅតែម្តងគត់, ប្រកបដោយកាលនិងកន្លែងយ៉ាងជាក់លាក់, ហើយជាពិសេសជាការណ៍ទាក់ទងនឹងសង្គមមនុស្សនោះផង ។

ឧទាហរណ៍ៈ រូបទេសចរាទីឡើងវង់ទង់ផងគេ ។
ន្ទុះបាញ់ចេតិយធំនៅវត្តភ្នំបណ្តាលអោយព្រះជាតិ ។ ចិនកន្លាំងមកពីហុងកុង ដើរស្រោចកោញចរិទើណអតីតវាំងហើយដើរទាំងស្រោចស្រូចទៅផ្ទុតទឹកទន្លេចតុមុខ ។
ព្រឹត្តការណ៍ទាំងនេះ គេអាចបានកត់ទុកក្នុងប្រវត្តិកម្ពុជាវិតារបស់ខ្មែររួចហើយ ។ គឺជាព្រឹត្តិការណ៍ដែលមានកន្លងក្នុងប្រវត្តិសាស្ត្រប្រកបដោយកាលនិងកន្លែងជាក់លាក់ ។

175- បើពោលថា " ប្រវត្តិវិទ្យា " ជាស្បែងរបស់មនុស្ស, តើគេអាចធ្វើពិសោធន៍ទៅលើស្បែងនោះបានឬទេ?

គេពុំអាចធ្វើពិសោធន៍លើស្បែងប្រវត្តិវិទ្យាបានទេ ។ តែគេអាចវិនិច្ឆ័យ គេធាតុពិតរបស់ស្បែងនោះឃើញដោយវិធីមួយដែលគេអោយឈ្មោះថា « វិធីប្រវត្តិវិទ្យា » ។

176- ក្នុងការវិនិច្ឆ័យរកធាតុពិតនៃប្រវត្តិវិទ្យា តើគេអាចប្រើវិធីប៉ុន្មានយ៉ាង ? គឺវិធីអ្វីខ្លះ ?



www.elibraryofcambodia.org

មហាឫសីយថ្មានេះ , លោកឡេនីនបានអនុស្សាវរីយ៍កាតព្វកិច្ចដែន អាចនឹងធ្វើជាអ្នកលោកឡើយ ។ អាស្រ័យហេតុនេះ វិស័យភាពប្រវត្តិ-វិទ្យាដែលមានរូបមន្តគ្រប់គ្រាន់ , អ្នកស្រាវជ្រាវប្រវត្តិវិទ្យាប្រ-នេះបានចាកផុតពីការងងឹតងងល់គ្រប់យ៉ាង របស់មតិមហាជនក្នុងលោក ។ មិនតែប៉ុណ្ណោះលោកគំនិតដែលប្រកបដោយសកលភាពរបស់ប្រវត្តិវិទ្យា បានធ្វើអោយសមត្ថភាពលោកសីលធម៌ ស្ថិតនៅក្រៅការងងឹតគ្រប់កាល ទាំងពួងផង ។

181 - អ្វីហៅថាហេតុផលភាពនៃប្រវត្តិវិទ្យា ? ចូរលើកឧទាហរណ៍ប្រើ ?

ហេតុផលភាពនៃប្រវត្តិវិទ្យា គឺជាទំនាក់ទំនងនៃហេតុផលជាចាំបាច់ទាំងឡាយ ដែលបានចងក្រងពីបុព្វហេតុបង្កើតអោយមានការណ៍ប្រវត្តិវិទ្យា ។

ឧទាហរណ៍ : តើលោកវេជ្ជបណ្ឌិត កែវ - សង្គីម - និង លោកសាស្ត្រាចារ្យ ជាត់ - ជា ស្លាប់ដោយសារអ្វី ? តើហេតុផលភាពនៅត្រង់ណា ? ។

បើយើងចង់បង្ហាញព្រឹត្តិការណ៍ ជាក់លាក់ស្ដីពីមរណភាព របស់លោកទាំងពីរនេះ , យើងនៅសល់តែ នឹងហៅការបង្ហាញនូវ ហេតុផលភាពនៃប្រវត្តិវិទ្យានោះឡើយ ។ ព្រោះរឿងមរណៈភាព លោកទាំងពីរ បានត្រូវគេបញ្ចូលទៅក្នុងប្រវត្តិសាស្ត្រខ្មែររួចហើយ ។ តើហេតុផលភាពនៅត្រង់ណា ?

បើចង់បង្ហាញនូវហេតុផលភាពនៃមរណៈភាពលោកទាំងពីរ គេត្រូវឆ្លើយអោយរួចនូវចំលើយដូចតទៅនេះ :

ទី១ - ហេតុអ្វីក៏លោក កែវ សង្គីម និងលោក ជាត់ ជា ស្លាប់ ?



www.elibraryofcambodia.org

ទី២ - ហេតុអ្វីក៏មានព្រឹត្តិការណ៍នៅវិទ្យាល័យ ១៥ មីនា ?

ទី៣ - ហេតុអ្វីក៏មានការប៉ះទង្គិចគ្នា រវាងសិស្ស, បុគ្គលិកសិក្សាជាមួយនឹងរដ្ឋាភិបាល ?

ទី៤ - ហេតុអ្វីការបៀវត្សចាយពុំគ្រាន់ ? និងហេតុអ្វីបានជាទំនិញសព្វសារពើឡើងថ្លៃ ?

ទី៥ - ហេតុអ្វីក៏ប្រទេសខ្មែរមានសង្គ្រាម ? និងហេតុអ្វីក៏ខ្មែរត្រូវផ្លាស់នយោបាយ ?

បើយើង ឆ្លើយនូវសំណួរទាំងប្រាំ ខាងលើនេះពុំរួចទេ, ច្បាស់ជាយើងរកការណ៍ប្រវត្តិស្ដីពីបរណៈភាព លោកទាំងពីរនេះពុំឃើញឡើយ ។ បើយើងរកពុំឃើញហេតុជាក់លាក់នៃការណ៍ប្រ-វត្តិពុំឃើញ, តើយើងអាចរកហេតុផលភាពនៃប្រវត្តិឃើញឬទេ ? ខោះបើគេជឿថាប្រវត្តិវិទ្យាជាស្ពានសម្រាប់សិក្សាពីរឿងរ៉ាវទាំងឡាយរបស់មនុស្ស ឬ ជនជាតិណាមួយក៏ដោយ, ក៏គេពុំអាចធ្វើពិសោធន៍ដូចវិទ្យាដទៃទៀត ដើម្បីរកហេតុផលភាពរបស់វាអោយឃើញបានឡើយ ។ ព្រោះថាពេលរកទំនាក់ទំនងនៃការណ៍ប្រវត្តិជាក់លាក់ពុំឃើញ ពោលគឺទំនាក់ទំនងពីបាវចករទៅអ្នកបញ្ជាបាវចករ, ពីអ្នកបញ្ជាបាវចករទៅអ្នកប្រតិបត្តិ ។ល។ និង ។ល។

## 182 - អ្វីទៅហៅថាទស្សនវិជ្ជានៃប្រវត្តិវិទ្យា ?

( la philosophie de l' histoire)

ដែលហៅថាទស្សនវិជ្ជានៃប្រវត្តិវិទ្យា គឺការពិចារណាទាំង



www.elibraryofcambodia.org

ឡាយដែលជារូបធាតុ សំរាប់ប្រែក្រឡាប់ទាំងអស់ នៃវិវត្តន៍របស់មនុស្ស (évolution humaine) ។

183 - អ្វីទៅហៅថាវិវត្តន៍នៃប្រវត្តិវិទ្យា ?

(le devenir historique)

ដែលហៅថាវិវត្តន៍ប្រវត្តិវិទ្យា គឺការណ៍ប្រវត្តិវិទ្យា ដែលបណ្តាលមកពីចលនផង និងលំដាប់ឡាប់ដែលជាបុព្វហេតុនៃការណ៍នោះផង ។

184- គេបានពោលថា វិវត្តន៍ប្រវត្តិវិទ្យាមានលក្ខណៈជាកំណត់និយម (déterminisme) ផង, និងជាវាសនានិយម (fatalisme) ផង ។ តើអ្នកយល់យ៉ាងដូចម្តេចចំពោះបញ្ហាខាងលើនេះ ?

ចូរលើកឧទាហរណ៍មកពន្យល់ ?

គេបានពោលថា វិវត្តន៍ប្រវត្តិវិទ្យាមានលក្ខណៈជាកំណត់និយម :

តើវិវត្តន៍ប្រវត្តិវិទ្យាមានលក្ខណៈ ជាកំណត់និយមមែនឬទេ? ដើម្បីដោះស្រាយកិច្ចការខាងលើនេះ, គប្បីយើងយល់ន័យនៃពាក្យវិវត្តន៍នៃប្រវត្តិវិទ្យាជាមុនសិន ។

វិវត្តន៍នៃប្រវត្តិវិទ្យាជាការណ៍ប្រវត្តិវិទ្យា ដែលបណ្តាលមកពីចលនផង និងលំដាប់ឡាប់ដែលជាបុព្វហេតុនៃការណ៍នោះផង ។ តើនៅក្នុងការណ៍ប្រវត្តិវិទ្យាមាននិយាយពីកំណត់



www.elibraryofcambodia.org

និយមឬទេ ? បើមាន តើកំណត់និយមនោះកើតមកពីមនុស្ស ឬមួយកើតមកពីលំដាប់ច្បាប់ ? ឬមួយក៏ផ្ទុយគ្នាទៅវិញ ?

រឿងរ៉ាវទាំងឡាយដែលជាការណ៍ប្រវត្តិវិទ្យា នោះបើកើតមកអំពីមនុស្សក្តី, ឬកើតមកអំពីលំដាប់ច្បាប់ក្តី, ហេតុនៃការណ៍ទាំងនោះ ច្រើនតែមានលក្ខណៈជាកំណត់និយម (déterminisme) ។

យើងសាកល្បងពិចារណាលើព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្ររបស់នគរខ្មែរយើង ៖

មុនពេលរាជានិយមបានបាត់បង់ពីប្រទេសខ្មែរទៅ យើងបានសង្កេតឃើញព្រឹត្តិការណ៍ទាំងឡាយ ដែលបង្ហាញអោយយើងឃើញថា មានហេតុផលភាគច្រើនជាកត្តាប្រកាសវិវត្តន៍ពីរាជានិយមមកជាសាធារណរដ្ឋ ។ ឧទាហរណ៍ រូបមួយគួរយើងលើកយកមកបង្ហាញក្នុងពេលនេះបាន ៖ ១. បញ្ហារឿងក្លស់ ។ គេបានដឹងថាមុនព្រឹត្តិការណ៍ ១៨ មិនា ១៩៧០, នៅឱកាសបុណ្យជាតិលើកចុងក្រោយបង្អស់មួយ, ពេលកើតប្រមុខរដ្ឋដែលកំពុងតែដើរត្រួតពល ស្រាប់តែក្លស់បាក់ធ្លាក់ពីកំពស់ត្រឹមស្មើដូចគេយកកាំបិតមកកាត់ ។ អច្ឆរិយហេតុនេះជាប្រផ្នូលមួយគួរអោយពិចារណាដូចតទៅនេះ ៖

ទី១ - បើជាការបាក់ក្លស់ អតីតប្រមុខរដ្ឋកណ្តាលពិធីជាតិនេះ កើតឡើងដោយមនុស្សក៏ជាបញ្ហាមួយដែរ ។ គឺថាពេលនោះមានខ្យល់បក់មកយ៉ាងខ្លាំងពីទិសខាងកើត, វាយបំបាក់ក្លស់នោះ ។ ដូច្នេះ យើងអាចពោលថាព្រឹត្តិការណ៍នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រកើតឡើងដោយមនុស្ស ។



www.elibraryofcambodia.org

ទី២- បើថាការបាក់ក្ដួលនោះបណ្ដាលមកពីមានលំដាប់ច្បាប់ ដែលជាបុព្វហេតុនៃការណ៍ គឺយើងសំដៅទៅលើន័យថា ៖ ក្ដួលបាក់ដោយការធ្វេសប្រហែសរបស់គ្រូគ ដែលពុំបានពិនិត្យអោយហ្មត់ចត់មុននឹងជ្រើសរើសក្ដួលយកមកបាំង ។ ប្រហែសដោយពុំបានប្រុងប្រយ័ត្នមើលជើងខ្យល់ ដែលកំពុងបោកបក់មកលើក្ដួល បុគ្គលនោះឯងជាមនុស្សដែលពុំប្រសប់ខ្លួន៖ ការប្រសប់ក្នុងតួនាទីរបស់ខ្លួន ។ ម្យ៉ាងទៀតយើងអាចពោលថា ជាងគ្មានទេពកោសល្យ ក្នុងការធ្វើក្ដួលអោយបានល្អ ។ នេះជាលំដាប់ច្បាប់ក្នុងប្រវត្តិវិទ្យាដែលជាហេតុផលនៃវិវត្តន៍ ។

បើយើងពិចារណាទៅលើកំណត់និយមវិញ, យើងឃើញថា៖ ព្រឹត្តិការណ៍នេះកើតឡើងដោយគេកំណត់ ទុកមកជាស្រេច, ព្រោះព្រឹត្តការណ៍នេះគេចង់បង្ហាញហេតុផលនៃវិវត្តន៍ប្រទេសដោយប្រផ្នូលមួយ ។ ព្រោះថាដងក្ដួលពុំសមអាចបាក់បានឡើយព្រោះដងនោះធ្វើអំពីទង្វាយ៉ាងជាប់ ។ មុននឹងយកមកបាំងគ្រូគបានជ្រើសរើសក្ដួលយ៉ាងជាប់ក្នុងចំណោមក្ដួលប្រចាំថ្ងៃដែលមានចំនួនជាងដប់ ។ រីឯអ្នកបាំងក្ដួលទៀតសោតក៏ជាមនុស្សដែលប្រកបពិធីការ នៅផ្នែកស្លុតគីតវាំងបានសិរីងរើសយ៉ាងហ្មត់ចត់ជាទីបំផុត ។ ដូច្នេះយើងឃើញថាកំណត់និយមក៏ពិតជាមានស្ថិតនៅក្នុងវិវត្តន៍ប្រវត្តិវិទ្យាដែរ ។

ត្រង់ចំណុចទី២នេះបានគេពោលថាវាសនានិយម (fatalisme) ក៏មាននៅក្នុងវិវត្តន៍ប្រវត្តិវិទ្យាដែរ តើយោបល់នេះពិតដែរឬទេ ?



www.elibraryofcambodia.org

ហើយយើងយក ឧទាហរណ៍ ពីរឿងគ្រួសដែលមកពីចារណ៍ា ក៏យើងអាចឃើញបានដែរថា នោះមិនមានប្រផ្នួលក្តី, គ្មានប្រផ្នួលក្តី, មានថែវផ្សក្តី, គ្មានថែវផ្សក្តី ក៏វិវត្តន៍ប្រទេសខ្មែរត្រូវតែដើរមកដល់ដំណាក់ការនេះ ដោយខានពុំបាន ។ ពិសេសប្រទេសណាក៏ដូចជា ទៀតសពុំរួចពីរឿងរ៉ាវទាំងឡាយដែលយើងជាខ្មែរទាំងអស់គ្នាធ្លាប់បានទទួលមកហើយម្ដង និងទទួលនៅពេលខាងមុខទៀតដោយខានពុំបានឡើយ ។

ឧទាហរណ៍ជាក់ស្ដែងបញ្ជាក់ថា វិវត្តន៍ប្រវត្តិប្រទេសខ្មែរមានលក្ខណៈពិសេសនិយម គឺបង្ហាញអោយឃើញជាក់ច្បាស់នៅត្រង់ "ក្បួនកុទ្ធទំលាយ-ផ្ទួនទំលាយ" ដែលបានខាងមុខមកពីកមវនធុលបន្តិចនោះ ។

សេចក្ដីដូចបានអធិប្បាយមកហើយនេះ បានបញ្ជាក់ថាទ្រឹស្ដីដែលពោលថា វិវត្តន៍ប្រវត្តិវិទ្យា មានលក្ខណៈជាកំណត់និយមផង និងពិសេសនិយមផងនេះ សមហេតុសមផល . ត្រឹមទាំងប្រកបដោយសច្ចៈភាពណាស់ ។

185- អ្វីទៅហៅថាគោលដៅភាពនៃវិវត្តន៍ ?

(Qu'est ce que la finalité du devenir?)

គឺជាលទ្ធផលចុងក្រោយបង្អស់នៃវិវត្តន៍ប្រវត្តិវិទ្យា និងជាលទ្ធផលកំណត់ដោយហេតុប្រកបដោយកុសលផង អកុសលផង ។

186- គោលដៅភាពនៃវិវត្តន៍ប្រវត្តិវិទ្យា បានត្រូវអ្នកសាសនានិយមណាយកចិត្តទុកដាក់ជាងគេ? ហេតុអ្វី?



www.elibraryofcambodia.org

ព្រះសង្ឃកាតូលិកឈ្មោះ អូគុយស្តាំង (St. Augustin) បានយកចិត្តទុកដាក់ជាងគេ ។ ព្រោះលោកចង់បញ្ជាក់ថា "ព្រះអាទិទេពជាអ្នកញ៉ាំងអោយ វិវត្តន៍ទាំងអស់បានសម្រេច ដោយដាច់ណាត់, ហើយប្រកបដោយគោលដៅជាក់លាក់, នោះបើវិវត្តន៍នោះ មានលក្ខណៈជាប្រវត្តិសាស្ត្រ, ឬក្នុងធម្មជាតិនៃជីវិតមនុស្សសត្វ" ។ លោកអូគុយស្តាំងបានពោលថា៖ «វិវត្តន៍ទាំងអស់បានដល់គោលដៅរបស់ខ្លួនអាស្រ័យព្រះជាម្ចាស់ ។ ព្រះអង្គជាអ្នកសាងនូវវិវត្តន៍ទាំងអស់ក្នុងបុរីរបស់ព្រះអង្គ (Cité de Dieu)» ។

187. អ្នកប្រាជ្ញខ្លះបានពោលថា ៖ "វិវត្តន៍កើតមកពីវឌ្ឍនភាពនៃបញ្ញារបស់មនុស្ស, តើអ្នកយល់យ៉ាងដូចម្តេចចំពោះមតិខាងលើនេះ ?

វិវត្តន៍នៅក្នុងប្រវត្តិវិទ្យា ខុសគ្នានឹងវិវត្តន៍នៅក្នុងធម្មជាតិ ។ ប្រវត្តិវិទ្យាបានបង្ហាញវិវត្តន៍របស់ខ្លួន ដោយការណ៍ប្រវត្តិផ្សេងៗ ឬព្រឹត្តការណ៍បញ្ជាក់នូវគោលដៅភាពទាំងឡាយ ។ ចំណែកវិវត្តន៍នៅក្នុងធម្មជាតិជាវិវត្តន៍ប្រកបដោយប្រព័ន្ធគំនិត (Système d' idées) ដើម្បីពន្យល់អំពីភាពរស់ទាំងឡាយ ដែលគេប្រទះឃើញនៅក្នុងការសិក្សាបរមត្ថវិជ្ជា(métaphysique) របស់លោកអូគុស្តកុង (Auguste Comte) ។ យើងឃើញថាទ្រឹស្តីដែល បង្ហាញនិយមន័យដូចខាងលើ, ជាគំនិតផ្ទុយស្រឡះពីទ្រឹស្តីលោក (Auguste Comte) ដែល



www.elibraryofcambodia.org

បានពោលថា ៖ «វិវត្តន៍កើតមកអំពីពុទ្ធិនៃអាទិទេព» ពោលគឺ លោកអូគុស្តកុងតបានយល់ថា វិវត្តន៍សុទ្ធតែមានគោលដៅជាក់លាក់, ហើយចំណាំទៀតថាវិវត្តន៍នេះសុទ្ធតែកំណត់ដោយហេតុ, ថាវិវត្តន៍ប្រកបដោយវឌ្ឍនភាពក៏ប៉ុន្តែពុំមែនជាវឌ្ឍនភាព នៃបញ្ញាមនុស្សឡើយ ។

ប៉ុន្តែទ្រឹស្ដីដែលពោល បញ្ជាក់ថាវិវត្តន៍ កើតមកពីវឌ្ឍនភាព នៃបញ្ញាមនុស្សបាន ស្របទៅនឹងគំនិតអ្នកប្រាជ្ញខ្លះដូចជា លោកកង់ (Kant) និងលោកកុងដរសេ (Condorcet) ជាដើម ។ លោកទាំងពីរយល់ថាវិវត្តន៍នេះកើតមកពីវឌ្ឍនភាព ដែលជាធាតុក្នុងមនុស្ស ។ មិនតែប៉ុណ្ណោះ លោកអ្នកប្រាជ្ញ ទាំងពីរនេះបានបញ្ជាក់ថែមទៀតថា ៖ « គឺជាវឌ្ឍនភាព នៃបញ្ញាមនុស្ស » ។

បើយើងពិចារណាមើលឲ្យដិតដល់ទៅ ។ យើងឃើញថាគំនិត លោកកង់ (Kant) ក្ដី, លោកកុងដរសេ (Condorcet)ក្ដី, សុទ្ធតែផ្អែកទាំងស្រុងទៅលើការពិចារណា ដែលយករូបមន្ត វិទ្យាសាស្ត្រ, មានរូបវិទ្យាជាដើមមកធ្វើជាមូលដ្ឋាន ។ គំនិត លោកទាំងពីរនេះបានបដិសេធ, មិនជឿជាក់ទៅលើពិធីសាសន៍ ដែលបានស្រង់សម្ដីតែពីក្នុងគម្ពីររបស់សង្ឃ ។ ជាគំនិត ដែលអោយតម្លៃតែពីឧត្តភាពក្នុងរូបវិទ្យាប៉ុណ្ណោះ ។ ឯចំណែក ទ្រឹស្ដីរបស់លោកអូគុស្តកុងត៍ ដែលយល់ថា "វិវត្តន៍ទាំងអស់ សុទ្ធតែមានគោលដៅកំណត់ដោយហេតុ , ហើយវាចេញពី គម្ពីរគល់នៃព្រះពិធីសាសន៍គឺបរមត្ថវិជ្ជានោះ យល់ថាមុនអ្វី



www.elibraryofcambodia.org

ទាំងអស់ គឺលាំងទេពស្ថិតនៅផ្សាមមកហើយជាប្រធាននៃកម្មនិងផលទាំងអស់របស់ធម្មជាតិក្នុងការធ្វើអោយរីកចំរើន ឬបំផ្លាញបោលអ្វីទាំងអស់នៅក្នុងលោកនិងបរលោក ដើម្បីបង្កើតសារជាថ្មីឡើងវិញ ។

យើងយល់ថា , មតិដែលមានលក្ខណៈបដិបក្ខនឹងគ្នារវាងអ្នកប្រាជ្ញទាំងពីរនេះ, បញ្ជាក់ពីការខ្វះសមត្ថភាពនៃបញ្ញាមនុស្សក្នុងការស្រាវជ្រាវរក "ពុទ្ធិសច្ចៈ" ស្ដីពីវិវឌ្ឍន៍នេះឯង ។ ដូច្នេះយើងជឿថាមានតែទ្រឹស្ដីនៃព្រះសមណគោតមប៉ុណ្ណោះទេដែលអាចឆ្លើយអោយត្រូវបាន គឺថា "វិវត្តន៍នៃអ្វីទាំងអស់ដែលកើតឡើងពីបច្ច័យទាំងឡាយ ដែលជាគ្រឿងទាក់ទងគ្នាតជាប់រវាងធាតុនិងអំពើនេះម្យ៉ាង ។ ម្យ៉ាងទៀតជាបច្ច័យដែលទាក់ទងរវាងផលនិងកម្មនេះ ។ បើថាបច្ច័យកើតពីធាតុនិងអំពើជារបស់អនត្ត រាលគឺមិនទៀងព្រោះវានឹងនាំទៅរកការវិនាសវិញ ។ ហើយកំណត់និយមស្ថិតនៅត្រង់ផលនៅរកការលាយសូន្យនេះឯង ។ តែបើជាបច្ច័យកើតពីកម្មនិងអំពើវិញ, គេឃើញថាកម្លាំងទាំងឡាយនោះអន្ទោលតាមគ្នាឡើងតជាប់ , តែមានកំណត់និយមដែលគឺ ស្ថិតនៅត្រង់ការរលាយបន្តនៃផលនិងកម្មស្មើគ្នា ។ រួមសេចក្ដីមកយើងយល់ថាទោះជាវិវត្តន៍នេះ , កើតមកពីអាទិទេពកំណត់ក្ដី, ឬ កើតមកពីកំលាំងបញ្ញាមនុស្សក្ដី ក៏សុទ្ធតែមានបច្ច័យទាក់ទងរវាងគ្នាទាំងអស់, ទើបសំរេចជារូបរាងបាន ។ ដូច្នេះព្រះពុទ្ធទ្រង់បានបញ្ជាក់ន័យរបស់ទ្រឹស្ដីនេះ បានជាក់លាក់ពិតប្រាកដណាស់ ។



www.elibraryofcambodia.org

188- ដើម្បីត្រួតពិនិត្យលើវិវត្តន៍នៃប្រវត្តិវិទ្យា តើអ្នកប្រាជ្ញឈ្មោះអ្វី បានចង្អុលការសិក្សាប្រវត្តិវិទ្យាតាមបែបវិភាគ?

ដើម្បីត្រួតពិនិត្យលើវិវត្តន៍នៃប្រវត្តិវិទ្យាអោយច្បាស់លាស់ លោកហេហ្គែល (Hegel) ធ្វើវិភាគការសិក្សាប្រវត្តិវិទ្យាជាបីយ៉ាងគឺ :

១ - ត្រូវសិក្សាប្រវត្តិវិទ្យាតាមច្បាប់ដើម, ដែលជាប្រវត្តិវិទ្យានៃសាក្សីផ្ទាល់ ។

២ - ត្រូវសិក្សាប្រវត្តិវិទ្យាតាមបែបពិចារណា , ដែលរិះគន់ធ្វើអោយអតីតកាលវិលទៅក្នុងបច្ចុប្បន្នជានិច្ច ។

៣ - ត្រូវសិក្សាប្រវត្តិវិទ្យាតាមបែបទស្សនវិជ្ជា ដែលឋិតនៅក្នុងអតីតកាលនិងក្នុងសកល, ព្រោះជាប្រវត្តិវិទ្យាជាវិវត្តន៍មនុស្ស ដែលលោកហេហ្គែល ចាត់ទុកថាជាសំណុំនៃបាតុកម្ម, នៃការរីកចំរើននៃគំនិតដែលឋិតនៅបច្ចុប្បន្នកាលមួយគ្មានទីបញ្ចប់។

189- តាមពិតវិវត្តន៍នៃប្រវត្តិវិទ្យា ដែលបានដល់គោលដៅកំពូលរបស់ខ្លួនៈ ហើយអាចវិលមករកភាពដើមវិញទេ ?

ប្រវត្តិវិទ្យាក្រោយដែលវិវត្តន៍ទៅបានរាប់ពាន់ឆ្នាំ ក៏វិលត្រឡប់មកដូចដើមវិញ ។ ឧទាហរណ៍ខ្មែរសម័យអង្គរបានវិវត្តន៍ទៅដល់កំពូលនៃការរៀនសូត្រ និងរីកចំរើនគ្រប់វិស័យមានអរិយធម៌រុងរោចន៍ ។ មកដល់សម័យបាត់បែកលង្វែក និងសម័យបច្ចុប្បន្នខ្មែរក៏វិលត្រឡប់មករកភាពដូចដើមវិញ គឺ ការធ្លាក់ចុះខុនដាបស្ទើរតែគ្រប់វិស័យ ដោយ[illegible] នៃសង្គ្រាម ។



www.elibraryofcambodia.org

190- តើអ្នកប្រាជ្ញឈ្មោះអ្វី ? មានសញ្ជាតិជាអ្វី? ដែលបានសង្កេតឃើញថាអរិយធម៌ជាច្រើនដែលបានកើតមានជីវិតនៅលើភិភពលោកយើងនេះមក បានត្រូវរលាយរលត់ទៅវិញស្ទើរតែទាំងអស់ ?

អ្នកប្រាជ្ញឈ្មោះ តូនប៊ី (Toynbee) មានសញ្ជាតិជាអង់គ្លេស បានសង្កេតឃើញយ៉ាងដូច្នេះក្រោយទាំងបានបញ្ជាក់ថែមទៀតថា :

«នៅក្នុងសំណុំនៃវិវត្តន៍មនុស្សសម័យបុរាណ ៦៥០ គេឃើញនៅសល់សង្គមអរិយធម៌តែ ២១ប៉ុណ្ណោះ ។ ហើយអរិយធម៌ទាំង ២១ ដែលនៅសល់នោះ ក្នុងរយៈកាល ៦០០០ ឆ្នាំក៏កន្សល់ទុកតែអរិយធម៌ ៦ ដែលមានជីវិតរស់រហូតមកដល់បច្ចុប្បន្នកាលនេះ ។

191- តើយើងយល់ថាអរិយធម៌ក្នុងលោកទាំងមូល សុទ្ធតែបង្ហាញវឌ្ឍនភាព ឬវិវត្តន៍វិលចុះវិលឡើងទាំងអស់ដូចគ្នាឬយ៉ាងដូចម្ដេច ? ចូរពន្យល់ ។

គង់ប្រវត្តិសាស្ត្របានបង្ហាញភាពតាប់អោន និងរុងរឿងរបស់ខ្លួនតាមរយៈស្ថាប័នសង្គមផ្សេងៗមានសិល្បៈ - ទស្សនវិជ្ជាសីលវិជ្ជា - ច្បាប់ចរិវត្តន៍ ។ល។ ដែលយើងនិយមនាំគ្នាហៅឈ្មោះថាពន្លឺនៃអរិយធម៌ ។ ពន្លឺនេះជួនកាលក៏ភ្លឺហើយរលត់ទៅវិញក៏មាន ឬ ក៏ភ្លឺហើយភ្លឺទៀតក៏មាន ឬ ម្យ៉ាងទៀតរលត់ហើយរលត់ទៀត ក៏មានដែរ ។



www.elibraryofcambodia.org

ឧទាហរណ៍៖ ប្រទេសបារាំងសម័យណាប៉ូឡេអុង.បូណាប៉ាត (NAPOLEON - BONAPATE) ពន្លឺអរិយធម៌បានបញ្ចេញរស្មីត្រចះត្រចង់ ។ លុះដល់មកសម័យសង្គ្រាមលោកលើកទី ២ ពន្លឺនោះក៏រលត់រស្មីទៅវិញ ដោយសារអាល្លឺម៉ង់ចូលកាន់កាប់ក្រុងប៉ារីសទាំងមូល ។ មកដល់សម័យបច្ចុប្បន្នបារាំង ងើបមុខចេញពីភាពអាប់អោន, ហេតុបានឈ្មោះថាប្រទេសមហាអំណាចមួយក្នុងលោក ។ បានសេចក្ដីថា ពន្លឺអរិយធម៌ ក្រោយពីរលត់ហើយក៏ភ្លឺ, ក្រោយពីភ្លឺមកក៏រលត់វិញ ។

ប៉ុន្តែបើយើងក្រឡេកមើលប្រទេសចាមវិញ, ក្រោយពីបានពន្លឺត្រចះត្រចង់នៅសតវត្សទី១៣ ហេតុបានចូលកាន់កាប់ក្រុង «អង្គរ» របស់ខ្មែរអស់មួយរយៈកាលនោះ, ឥឡូវនេះ ចាមបានបាត់រស្មីហើយ ពោលគឺចាមបានរលត់ទៅបាត់ ដោយគ្មានថ្ងៃ នឹង បញ្ចេញពន្លឺឡើងវិញបានឡើយ ព្រោះថា «ចាម» បានបាត់បង់ប្រទេសរបស់ខ្លួនទាំងមូលពីផែនទី ពិភពលោកទៅហើយ ។

ដូច្នេះ ទ្រឹស្ដីដែលពោលថាវិវត្តន៍ប្រវត្តិវិទ្យាបានវិលចុះឡើងគ្មានឈប់នោះ ( les théories cycliques du devenir historique) ពុំសូវត្រូវទាំងអស់ទេ ។

ឧទាហរណ៍ : ទ្រឹស្ដីរបស់លោកសូរ៉ូគីន (la théorie des fluctuations selon Sorokin) ដែលបានពោលថា ៖
«ដរាបណាអរិយធម៌របស់មនុស្សបានជីវិតនៅលើលោកនេះ, ដរាបនោះ នឹងមាន បំលាស់ប្ដូរមិនកំណត់ដែលវិលវល់ជុំវិញគំរូសង្គមនិងប្រពៃណីវប្បធម៌បីយ៉ាងគឺ » ៖



www.elibraryofcambodia.org

១ - គំរូគំនិតនិងបញ្ញា (tybe idéationnel) ដែលប្រកបសន្តិភាពដោយកុសល (Bien) មួយខ្ពស់ផុតពីឥន្ទ្រីយ និងវិចារណញ្ញាណ, ហើយដែលមានចិត្តនិងជំនឿជាធំ ។

២ - គំរូឥន្ទ្រីយារម្មណ៍និយម (type sensualiste) ដែលសំអាងទៅលើគំនិតថា, គជភាពពិតប្រាកដតែឥន្ទ្រីយារម្មណ៍ ប្រកបដោយគំនិតពិសោធនិយមនិងត្រេកត្រអាលនិយម (esprit empirempiristeste et hédonistique)

៣ - គំរូកណ្ដាល គឺគំរូគំនិតនិយម (typeidéaliste) ដែលឋិតនៅកណ្ដាលគំរូពីរខាងលើ ។

*

* *



www.elibraryofcambodia.org

# សង្គមវិទ្យា

(la sociologie)

192- នរណាបង្កើតសង្គមវិទ្យាមុនគេ?

លោកអូគុស្តកុង (Auguste Comte) ពាក់កណ្ដាលសតវត្សទី១៩ បានបង្កើតសង្គមវិទ្យាមុនគេ ។

193- ដូច្នេះលោកអូគុស្តកុង អោយនិយមន័យទៅលើពាក្យសង្គមវិទ្យាថាយ៉ាងដូចម្តេច ?

លោកអូគុស្តកុង បានអោយនិយមន័យទៅលើសង្គមវិទ្យាថា៖ "ស្យង់វិជ្ជមាននៃបាតុភូតសង្គម" (science positive des phénomènes Sociaux) ។

194- តាមពិតសង្គមវិទ្យាគឺអ្វី ?

តាមពិតសង្គមវិទ្យា គឺការសិក្សាទូទៅពីសង្គមមនុស្ស ។

195- ដើម្បីសិក្សាសង្គមវិទ្យាអោយបានច្បាស់លាស់ តើមានវិជ្ជាអ្វីខ្លះ ដែលអ្នកប្រាជ្ញសម័យថ្មីកំពុងតែនាំគ្នាសិក្សាពីសង្គមមនុស្ស ?

អ្នកប្រាជ្ញសម័យថ្មីបានសិក្សាសង្គមមនុស្សទាំងមូល តាមវិធីសាស្ត្រផ្សេងៗគ្នា ។ បច្ចុប្បន្ននេះ ជាមួយនឹងការសិក្សាពីមនុស្សវិទ្យា, គេបានរកឃើញវិជ្ជាពីរទៀត ដែលអ្នកប្រាជ្ញសម័យថ្មីកំពុងយកចិត្តទុកដាក់ជាងគេ គឺ រេឌ្ឋវិទ្យា (ethnologie) និងរេឌ្ឋសាស្ត្រ (ethnographie) ។



www.elibraryofcambodia.org

196- អ្វីទៅហៅថា "ការណ៍សង្គម" (fait social) ?

ការណ៍សង្គម គឺជាលទ្ធផលនៃការរួមរស់ជាក្រុមរបស់មនុស្ស ឧទាហរណ៍ស្ថាប័នផ្សេងៗ (institution) ទំនៀម (mœurs) និងជំនឿរួម (croyances collectives) ។

197- អ្នកសង្គមវិទ្យាឈ្មោះ ស៊ក ដាវី (Georges-Davy) បានពោលថា "មនុស្សគឺជាសត្វដែលរចនារស់នៅក្នុងសង្គមផង និងជាសត្វដែលប្រកបដោយសភាវគតិនិយាមផង" ។ ចូរវិភាគញែកគំនិតរបស់អ្នកប្រាជ្ញខាងលើនេះតាមបែបសង្គមវិទ្យា?

ដើម្បីវិភាគញែកគតិរបស់លោកស៊ក-ដាវី, គប្បីយើងយល់ន័យរបស់ពាក្យថា "សភាវៈនិយាម" សិន ។ សភាវនិយាម (Instinct de la règle) គឺ សភាវៈដែលមនុស្សគ្រប់រូបបានទទួលមកពី សង្គមដែលខ្លួនរស់នៅ ។ សភាវៈនោះបានបង្ហាប់បញ្ចូលមនុស្សអោយប្រតិបត្តិតាមស្ថាប័ន , ប្រពៃណី, ទំនៀមទំលាប់របស់សង្គមនោះ ។ មនុស្សដែលបានទទួលឥទ្ធិពលសង្គម ហើយកែងខាងជាមួយនឹងសភាវគតិកំណើត (instinct natif) របស់ខ្លួនឲ្យសភាវៈម្យ៉ាងដែលគេហៅថា "សភាវគតិនិយាម" នេះឯងជាចាំបាច់ ។

អ្នកសង្គមវិទ្យាជាច្រើនបាននាំគ្នាពិគ្រោះព្រមទាំងផ្តល់យោ-បល់គ្នាថា , ភេទជីវិតនៅក្នុងបានកើតឡើងពីសភាវគតិដែលគេ



www.elibraryofcambodia.org

ហៅថា " សភាវគតិសង្គម " (instinct social) ពិតមែន ឬទេ ?

តែចំពោះការឆ្លើយនឹងរឿងនេះ កុំភ្លេចនូវចំណោទស្រាយដាវិន មានផលពេលទាំងឡាយនោះ ។ គេបានសង្កេតឃើញថាដំបូង មនុស្សទាំងឡាយតែងរស់នៅដាច់ឡែកពីគ្នា ឬក៏រស់នៅជាក្រុមតូចៗមានរបៀបតាមទីកន្លែងនីមួយៗក្នុងពិភពលោក (les hommes vivent a l'état de hordes) ។ មនុស្សទាំងនោះពុំមានការអប់រំតាមបែបសង្គមកិច្ចដែលប្រកបដោយវេទនាសម្ពន្ធគ្រឹមគ្រាន់ឡើយ ។ លោក " ឡេវីស្ត្រូស " (Lévi Strauss) ពោលថា : " មនុស្សលោកមានលក្ខណៈមួយបែបដែលការណ៍សង្គមផ្សេងៗ , គឺវិន្ទុកលវិប្បធម៌ដែលប្រកបដោយនិយាមត្រឹមត្រូវ , ជាទំនៀម ឬ បែបបទដែលជាគ្រឿងបញ្ចូលលក្ខណៈពិតរបស់ខ្លួន ។

គំនិតរបស់លោកឡេវីស្ត្រូស បានឆ្លើយស្របនឹងគំនិតលោកសិកជាវិត្រង់ត្រង់ទី២ ។ ចំណែកលោកប៊ែរសុង (Bergson) បានពោលថា : " មនុស្សពុំមែនជាសត្វដែលមានសភាវគតិសម្រាប់តែក្រោមតាមគេនោះឡើយ ។ តែមនុស្សជាសត្វដែលមានបញ្ញា ។ ហើយរនាំងដែលបាំងសំពុះបញ្ញាយ៉ាងខ្សោយរបស់គេនិងពិធានាការគំនិតនោះ គឺ ជាច្បាប់ទំលាប់ ឬការណ៍នៃសង្គមទាំងឡាយដែលគេហៅថា " កាតព្វកិច្ច " (obligation) ដែលបង្ខិតបង្ខំគេអោយអនុវត្តតាមយ៉ាងម៉ាច់



www.elibraryofcambodia.org

ណាត់ ។ ដូច្នេះមនុស្សក្នុងក្រុងនីមួយៗមានសភាវគតិសង្គម ដោយឡែកពីគ្នា ខុសនឹងសត្វដែលមានអាកប្បកិរិយាយ៉ាងទៀងទាត់ដូចគ្នាទាំងអស់ ។ ឧទាហរណ៍ ៖ សត្វឃ្មុំគ្រប់សំបុកសុទ្ធតែមានអាកប្បកិរិយាដូចគ្នាទាំងអស់ រីឯមនុស្សនៅក្នុងសង្គមផ្សេងគ្នាមានអាកប្បកិរិយាក៏ផ្សេងគ្នាដែរ ។

វិនិច្ឆ័យយ៉ាងនេះ បានអោយលោកប៊ែរសុនសន្និដ្ឋានថា ៖ ដោយសារបានទទួលឥទ្ធិពលមួយពីសង្គមរបស់ខ្លួននេះហើយ បានជាមនុស្សខុសនឹងសត្វ ។ ហើយវត្ថុដែលធ្វើមនុស្សអោយខុសនឹងសត្វនោះ គឺ "ភារកិច្ច" (obligation) នៃសង្គមនោះឯង ។

ដូច្នេះយើងឃើញថា សង្គមមានឥទ្ធិពលទៅលើមនុស្សយ៉ាងខ្លាំង ។ សង្គមកែទំរង់បញ្ញានៃសភាវគតិកំណើតរបស់មនុស្ស ហើយមានច្បាប់សំរាប់បង្ខិតបង្ខំមនុស្សអោយគោរពតាមបទបញ្ជារបស់ខ្លួនពុំអាចប្រកែកបាន ។ ដោយសង្គមមានឥទ្ធិពលយ៉ាងខ្លាំងទៅលើមនុស្ស ដូច្នេះហើយបានជាលោករូសូ (J.J.Rousseau) ពោលថា ៖ "មនុស្សកើតមកសុទ្ធតែល្អទាំងអស់ ប៉ុន្តែសង្គមទៅវិញទេ ដែលធ្វើអោយមនុស្សពុករលួយ" ។

198- អ្វីទៅហៅថាសង្គមចិត្តវិទ្យា ?

សង្គមចិត្តវិទ្យា គឺការសិក្សាស្រាវជ្រាវពីអាកប្បកិរិយារបស់បុគ្គលម្នាក់ដែលរស់នៅក្នុងសង្គម (Etude du comportement de l'individu vivant dans une société) ។



www.elibraryofcambodia.org

de synthèse et l'Ethnographie une science d'analyse)

**204-** តើការណ៍សង្គមមានលក្ខណៈសំខាន់អ្វីខ្លះ ដែលគួរកត់សំគាល់ ?

ការណ៍សង្គមមានលក្ខណៈសំខាន់ពីរ ដែលគួរកត់សំគាល់គឺ:

១- លក្ខណៈរួម (fait collectif)

២- លក្ខណៈបង្ខាប់បង្ខំ (fait coercifif)

**205-** តើការណ៍សង្គមណាខ្លះដែលមានលក្ខណៈរួម ? ចូរលើកឧទាហរណ៍មកបង្ហាញ ?

ការណ៍សង្គមដែលមានលក្ខណៈរួមគឺ ការណ៍ផ្សេងៗរបស់សង្គម, ដែលមនុស្សជានរួមគ្នាអនុវត្ត ដោយគិតទទួលការបន្តតបន្តពីច្បាប់ទំលាប់អ្វីមួយហើយ ។ ឧទាហរណ៍ : អាពាហ៍ពិពាហ៍ - ភាសា - ទំនៀមទំលាប់ ។ល។

**206-** តើការណ៍សង្គមណាខ្លះ ដែលមានលក្ខណៈបង្ខាប់បង្ខំ ?

ការណ៍សង្គមដែលមានលក្ខណៈបង្ខាប់បង្ខំ គឺការណ៍ប្រកបដោយរបៀប និងច្បាប់របស់សង្គមនោះហើយ ការណ៍សង្គមនេះតែងមានសភាពជាវិធានវិនិច្ឆ័យផង (Sanction) ។ ឧទាហរណ៍ : វិន័យ និងច្បាប់របស់សង្គមនិមួយៗ ជាការបង្ខិតបង្ខំរបស់សង្គម ។

**207-** អ្វីទៅហៅថាសង្គមវិទ្យាប្រធានវិស័យ ?



www.elibraryofcambodia.org

(Qu' est-ce que la sociologie subjective ?)

ដែលហៅថាសង្គមវិទ្យាប្រធានវិស័យ គឺសង្គមវិទ្យាដែលគេបានស្រង់រូបមន្តរបស់វាពីប្រធានទាំងឡាយ ពោលគឺបុគ្គលដែលធ្លាប់បានស្គាល់ និង ធ្លាប់បានរស់នៅក្នុងសង្គមនោះ ។

## 208- អ្វីទៅហៅថាសង្គមវិទ្យាយល់ ?

(qu' est-ce que la socilogie compréhensive?)

ដែលហៅថាសង្គមវិទ្យាយល់ គឺសង្គមវិទ្យា ដែលប្រកបដោយការណ៍របស់ខ្លួនមានលក្ខណៈរូបី ។ ម្យ៉ាងទៀតព្រឹត្តិការណ៍ទាំងអស់នៃសង្គមវិទ្យាយល់ ពុំបានចំពន្យល់ការណ៍របស់ខ្លួនទេ, តែញ៉ាំងអោយគេយល់ការណ៍របស់ខ្លួនវិញ ។ ឧទាហរណ៍ : គ្រួសារដែលរស់នៅលើកោះមួយនៅនូវែល-គីនេ (Nouvelle-Guinée) សុទ្ធតែយកបងប្អូនឯងជាប្តីប្រពន្ធទាំងអស់ ។ ហេតុអ្វី ? គេអាចយល់បានដោយពុំបាច់ឆ្ងល់ថា ក្រុមសង្គមដ៏តូចនេះ គ្មានសិទ្ធិកលអោយជនណាមួយចូលទៅដល់សង្គមរបស់គេឡើយ ។ ពួកគេរស់នៅតាមបែបមនុស្សបុរេប្រវត្តិ ។

កាលណាគេធ្វើការរាវពង្សាវតារ (généalogie) ពីដើមកំណើតនៃមនុស្សទាំងនោះ, គេនឹងបានឃើញច្បាស់ដោយពុំមានឆ្ងល់ឡើយ ។

## 209- ហេតុអ្វីបានជាគេពោលថា សង្គមវិទ្យា និងប្រវត្តិ-វិទ្យាមានកម្មវត្ថុខុសគ្នា ?



www.elibraryofcambodia.org

បានជាគេពោលថា សង្គមវិទ្យានិងប្រវត្តិវិទ្យាមានកម្មវត្ថុខុសគ្នា ព្រោះប្រវត្តិវិទ្យាសិក្សាពីអ្វីដែលមានលក្ខណៈជាបុគ្គល ពីព្រឹត្តិការណ៍ពិសេសមួយ ។ ឯចំណែកសង្គមវិទ្យាវិញ ពីអ្វីដែលមានលក្ខណៈទូទៅ ពីច្បាប់សកល ។

## 210- តើសង្គមវិទ្យាមានមុខងារអ្វីខ្លះ ?

មុខងាររបស់សង្គមវិទ្យាមានច្រើនណាស់ ព្រោះជាវិជ្ជាដែលសិក្សាពីសង្គមមនុស្ស ។ ផ្ទុយពីព្រឹត្តិការណ៍ទាំងឡាយរបស់មនុស្ស ដែលប្រកបដោយការណ៍ពិសេស ត្រូវចូលជាកម្មវិធីនិងវត្ថុសិក្សានៃសង្គមវិទ្យាទាំងអស់ ។ ក្រៅពីនេះ នៅមានការណ៍ផ្សេងៗដែលជាភារៈរបស់សង្គមវិទ្យាដែរ គឺការចង្អុលប្រាប់ពីឫសគល់និងវិវត្តន៍នៃសង្គមមនុស្ស ។ រូបមន្តនៃសង្គមប្រៀបធៀបបានត្រូវអ្នកឯកទេសខាងអត្ថវិទ្យា និងអត្ថសាស្ត្រ (Ethnologie et Ethnographie) កំរិតអរិយធម៌ ឬក៏ហិនខាយនិងស្ថានក្រុបដល់សង្គមមនុស្ស ពីអតីតកាលរហូតដល់បច្ចុប្បន្នកាល ។

ឧទាហរណ៍ ៖ សង្គមវិទ្យាបានប្រាប់យើងអោយមើលឃើញបញ្ហា ឬបញ្ហាមនុស្ស ពីសម័យបុរេប្រវត្តិ អាស្រ័យការសិក្សាសង្គមវិទ្យានៅលើកោះមួយនៃប្រទេសនូវែលហ្គីណេ (Nouvelle Guinée) ។

## 211- អ្វីទៅហៅថា ចិត្តវិទ្យា ?

ចិត្តវិទ្យាគឺ « ស្បែងនៃចិត្ត » ពោល គឺវិទ្យាដែលសិក្សាពីចិត្ត ។



www.elibraryofcambodia.org

212- តើការសិក្សាពីចិត្តវិទ្យា ត្រូវពឹងផ្អែកទៅលើវិជ្ជាណាខ្លះ ដើម្បីញុំាងការសិក្សាអោយមានប្រាកដនិយម? ហេតុអ្វី ?

គេត្រូវពឹងផ្អែកទៅលើបរមត្ថវិជ្ជា ( Métaphysique ) ជាចាំបាច់ ដើម្បីរកប្រាកដនិយមក្នុងចិត្តវិទ្យា ។ ព្រោះថា, បរមត្ថវិជ្ជាមានភារៈវែកញែកសញ្ញាណចិត្ត និង សញ្ញាណវិញ្ញាណក្ខន្ធ ដើម្បីកាយរកប្រភពកំណើតនិងវាសនានៃចិត្ត ។

213- អ្នកប្រាជ្ញឈ្មោះអ្វីបានចែកចិត្តវិទ្យាជាពីរបែប? តើអ្វីខ្លះ?

អ្នកប្រាជ្ញឈ្មោះវ៉ុល ( Wolf ) នៅសតវត្សទី ១៨ បានចែកចិត្តវិទ្យាជាពីរបែបគឺ ÷

១ - ចិត្តវិទ្យាវិចារណញ្ញាណ (Psychologie rationnelle)

២ - ចិត្តវិទ្យាពិសោធ (Psychologie empirique)

214- អ្វីទៅហៅថាចិត្តវិទ្យាវិចារណញ្ញាណ ?

ដែលហៅថាចិត្តវិទ្យាវិចារណញ្ញាណ គឺចិត្តវិទ្យាដែលផ្តល់រូបមន្តរបស់ខ្លួនពីការវិនិច្ឆ័យនៃវិចារណញ្ញាណ ( Jugement de la raison) ជាចិត្តវិទ្យាដែលបដិសេធកំហើញដែលបានមកពីប្រភពផ្សេងៗដូចជាផ្តល់ដោយពិសោធន៍, ឬផ្តល់ដោយគន្លឹកសមាធិទេកម្មប្រមូលផ្សេងៗ ។ល។

215- អ្វីទៅហៅថាចិត្តវិទ្យាពិសោធ ?

ដែលហៅថាចិត្តវិទ្យាពិសោធគឺចិត្តវិទ្យាដែលយក "ការណ៍របស់ចិត្ត" មកធ្វើវិភាគព្រមទាំងពិនិត្យហេតុផ្ទាល់របស់ចិត្ត ។



www.elibraryofcambodia.org

216- តើអ្នកប្រាជ្ញឈ្មោះអ្វីខ្លះ ដែលមានគំនិតយកចិត្តមកធ្វើវិភាគ ?

អ្នកប្រាជ្ញដែលយល់ថាមិនត្រូវគេអាចកំចាត់នៃចិត្ត ត្រូវតែយកចិត្តនោះឯង មកធ្វើវិភាគតាមមធ្យោបាយផ្សេងៗទៀត នោះគឺលោកម៉ែនដឺប៊ីរ៉ង់ (Maine de Biran) លោកប៊ែរសុន (Bergson) លោកជែម (James) លោកក្លូដលេវីស្ត្រូស (Claude Levi Strauss) ។ល។

217- ការសិក្សាពីចិត្ត ដោយប្រើវិធីពិនិត្យលើអាកប្បកិរិយា (comportement) របស់មនុស្សឬសត្វគេអោយឈ្មោះថាចិត្តវិទ្យាអ្វី ? ហើយវិធីពិនិត្យនោះមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ការសិក្សាពីចិត្តដោយត្រិះរិះ និងពិនិត្យទៅលើអាកប្បកិរិយារបស់មនុស្សឬសត្វ គេហៅថា «ចិត្តវិទ្យាអាកប្បកិរិយា» (Psychologie du comportement) ។ វិធីពិនិត្យនោះមានពីរយ៉ាងគឺ :

១- ពិនិត្យទៅលើប្រធានរបស់ការណ៍ចិត្តដែលគេហៅថាវិធី «ប្រធានវិស័យ» (méthode Subjective) ។

២- ពិនិត្យទៅលើវត្ថុរបស់ការណ៍ចិត្ត ដែលគេហៅថា វិធី «វត្ថុវិស័យ» (méthode objective)

218- អ្វីទៅហៅថាការណ៍ចិត្ត ? ( fait psychique )

ការណ៍ចិត្ត គឺអ្វីដែលកើតអោយយើងដឹង សភាពខាងក្នុងនៃចិត្តដូចជាសេចក្តីករុណា( sentiment ), ការរំភើប(émotion)



www.elibraryofcambodia.org

លំនប់ (passion) ។ល។ ដែលគេហៅថា "ញាណរបស់ចិត្ត" ។ គេអាចហៅថា «ការណ៍នៃអាកប្បកិរិយា» ក៏បាន ព្រោះថាបើគ្មានអាកប្បកិរិយាទេ គេមើលការណ៍ចិត្តពុំឃើញឡើយ ។ ជួនកាលគេអោយនិយមន័យ «ការណ៍ចិត្ត» ថា: «ជាសំណុំប្រតិកម្មភាវៈរស់ (être vivant)»

219- ការបំបែកការណ៍របស់ចិត្ត មកពិនិត្យកើតទៅជាវិទ្យាមួយ, តើវិទ្យានោះឈ្មោះអ្វី ?

ការបំបែកការណ៍របស់ចិត្តមកពិនិត្យ និងពិចារណារកហេតុនិងផល គេហៅថា "ចិត្តវិភាគវិទ្យា" (Psychanalyse) ។

220- ហេតុអ្វី ក៏មនុស្សអាចយកការណ៍របស់ចិត្តមកធ្វើវិភាគរកហេតុផលឃើញ ?

បានជាមនុស្សអាចយកការណ៍របស់ចិត្តមកធ្វើវិភាគ ព្រោះមនុស្សមានតម្រិះនិងវិចារណញាណ ។

221- តើវិធីពិនិត្យនិងពិសោធចិត្តវិទ្យាមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

វិធីពិនិត្យ និងពិសោធចិត្តវិទ្យាមានបីយ៉ាងគឺ:

១- វិធីប្រធានវិស័យ ឬចិត្តវិទ្យា "ឧត្តមបុរិសៈ"
(la méthode subjective ou la psychologie en «1ère personne»)

២- វិធីវត្ថុវិស័យឬចិត្តវិទ្យា "បឋមបុរិសៈ"
(la méthode objective ou la psychologie en «3ème personne»)

៣- វិធីអន្តរប្រធានវិស័យឬចិត្តវិទ្យា "មជ្ឈិមបុរិសៈ"



www.elibraryofcambodia.org

(la méthode inter-subjective ou pychologie en «2e personne»)

222- អ្វីហៅថា "វិធីប្រធានវិស័យ" ក្នុងចិត្តវិទ្យា ?

ដែលហៅថាវិធីប្រធានវិស័យក្នុងចិត្តវិទ្យា គឺការធ្វើវិភាគរកហេតុផលរបស់ចិត្តដោយយកចិត្តរបស់ខ្លួនឯងមកធ្វើជាប្រធានក្នុងការពិចារណា ។

223- អ្វីទៅហៅថា "វិធីវត្ថុវិស័យឬចិត្តវិទ្យាបឋមបុរិស:"?

ដែលហៅថា "វិធីវត្ថុវិស័យ ឬចិត្តវិទ្យា បឋមបុរិស:" គឺការពិចារណារករហេតុផលនៃចិត្តដោយយក "វត្ថុផ្សេងៗ" ជាគ្រឿងពិចារណា ។ វត្ថុជាគ្រឿងពិចារណានោះគឺ: ឧទាហរណ៍: ឯកសារ អក្សរសិល្ប៍, ការដោះស្រាយរបស់ជីវិតដែលមានលក្ខណ: ជាសំដីឬអក្សររបស់អ្នកប្រាជ្ញកវីឬអ្នកនិពន្ធឬជាចំលើយចំពោះសំណួរផ្សេងៗ ដែលជាវត្ថុសំរាប់ចំក្តីការណ៍របស់ចិត្ត ។

224- អ្វីទៅហៅថា "អន្តរប្រធានវិស័យឬចិត្តវិទ្យា បញ្ចមបុរិស:" ?

ដែលហៅថា "អន្តរប្រធានវិស័យ, ឬចិត្តវិទ្យាបញ្ចមបុរិស:" គឺការពិចារណារករហេតុផលនៃចិត្តអ្នកដទៃ ដោយវិធីទាក់ទងជាមួយអ្នកដទៃដូចជា ស្នេហា, មិត្តភាព, សមានចិត្ត ។ល។ ហើយនៅពេលនោះគេស្រាវយកការណ៍ នៃចិត្តជនដទៃនោះមកពិចារណាវែកញែក ។

* * *



www.elibraryofcambodia.org

# ១០– ទំនោរនៃធម្មជាតិមនុស្ស

(tendance de la nature humaine)

**225- អ្វីទៅហៅថាទំនោរ ?**

ទំនោរ គឺការទោរទន់ទៅរកឧត្តមគតិណាមួយប្រកបដោយបំណងនិងចិត្តស្រើបស្រាល ។ ឧទាហរណ៍ ការចាប់អារម្មណ៍របស់បុគ្គលម្នាក់ទៅចំពោះសម្ភារៈ, កាមតណ្ហា, វីរភាពក្លាហានណាមួយ ស្ទើរជានិមិត្តរូបនៃចំណូលចិត្ត, ជំនក់អារម្មណ៍ ។ បើកាលណាអារម្មណ៍នោះឯងបានជាប់ពាក់ខ្លាំងឥតកំរិត ទើបកើតមានរូបភាពតែគំនិតច្បាស់លាស់ ដែលបញ្ជាក់ថានេះហើយ "ជាទំនោរ" ។ ទំនោរនេះបង្ហាញរូបច្បាស់កាលណាមានប្រតិកិរិយាខាងក្រៅផ្សាយចេញមកដោយទប់ពុំបាន ។

**226- តាមពិតទំនោរនៃមនុស្សចែកជាប៉ុន្មានកងធំៗ គឺអ្វីខ្លះ?**

តាមពិតទំនោរនៃមនុស្សចែកជាប្រាំកងធំៗគឺ :

១ - ទំនោរសរីរាង្គ (tendance organique)

២ - ទំនោរអន្តរបុគ្គល (tendance inter-individuelle)

៣ - ទំនោរសង្គម (tendance sociale)

៤ - ទំនោរឧត្តមគតិ (tendance idéale)

៥ - ទំនោរផ្ទាល់ខ្លួន (tendance personnelle)

**227- អ្វីទៅហៅថា ទំនោរសរីរាង្គ ?**

ដែលហៅថាទំនោរសរីរាង្គ គឺ ទំនោរទាំងឡាយ ដែលកើតឡើងពីសរីរាង្គរបស់មនុស្សម្នាក់ៗ ។



www.elibraryofcambodia.org

228- តើទំនោរសរីរាង្គរបស់មនុស្ស ខុសនិងទំនោរសរីរាង្គរបស់សត្វដូចម្ដេចខ្លះ ?

ទំនោរសរីរាង្គរបស់សត្វ និងមនុស្ស ខុសគ្នាត្រង់សរីរាង្គមនុស្សខុសនិងសរីរាង្គសត្វ. ហើយម្យ៉ាងទៀតទំនោររបស់មនុស្សមានលាយឥទ្ធិពលរបស់សង្គម ។

229- តើការស្រេកឃ្លានអាហារ សំរាប់តាំការជីវិតអាចផ្ដល់នូវទំនោរជាក់លាក់សំរាប់មនុស្សនិងសត្វឬទេ ? ចូរពន្យល់ ។

ការស្រេកឃ្លានរបស់មនុស្ស ឬ សត្វទៅរកអាហារ ជាទំនោរជាក់លាក់ ប៉ុន្តែមានលក្ខណៈខុសគ្នា ។ ទំនោរមនុស្សទទួលឥទ្ធិពលសង្គម ដែលគេឃើញថាមានលក្ខណៈសំខាន់បីគឺ ៖

១- លក្ខណៈសង្គមកម្ម (socialisation)

២- លក្ខណៈស្មុគស្មាញ (complication)

៣- លក្ខណៈចិត្តកម្ម (spiritualisation)

រីឯទំនោរសត្វគឺ គ្រឿងអារម្មណ៍ឃ្លាន និងទំលាប់សុទ្ធសាធ ។

230- អ្វីទៅហៅថាទំនោរ អន្តរបុគ្គល ?

(tendance inter-individuelle)

ដែលហៅថាទំនោរអន្តរបុគ្គល គឺទំនោរដែលកើតឡើងពីទំនាក់ទំនងរវាងវិញ្ញាណរបស់បុគ្គលម្នាក់ៗ ទៅនិងវិញ្ញាណរបស់ជនដទៃ ។



www.elibraryofcambodia.org

**231-** ហេតុអ្វីក៏មនុស្សមានទំនោរដែលគេហៅថា «អត្តបុគ្គល» នេះ?

មនុស្សមានទំនោរអត្តបុគ្គល ព្រោះមនុស្សមានទំនោរដែលមានលក្ខណៈផ្សេងៗកប់នៅក្នុងសរីរាង្គរបស់ខ្លួន ។

**232-** តើទំនោរមានលក្ខណៈផ្សេងៗ ដែលញុំាងអោយមនុស្សមានទំនោរហៅថា «អត្តបុគ្គល» នោះគឺអ្វីខ្លះ?

ទំនោរផ្សេងៗ ទាំងឡាយ ដែលញុំាងអោយមនុស្សមានទំនោរអត្តបុគ្គលគឺ :

១- សភាវក្រុមនិងសមានចិត្តឆ្លង ។
(instinct grégaire et sympathie-contagion)

២- សភាវគតិកំណើត ដែលមនុស្សបានទទួលពីតាយរបស់ខ្លួន ។ (instinct maternel)

៣- សមានចិត្តចូលគ្នារបស់មនុស្ស ។ (sympathie communion)

៤- ទំនោរបរត្ថភាព (tendance altruiste)

៥- ទំនោរអត្តត្ថភាព(tendance égoïste)

**233-** អ្វីទៅហៅថាទំនោរសង្គម ?
(Tendance sociale)

ដែលហៅថាទំនោរសង្គម គឺទំនោរដែលកើតមកពីកំលាំងអនុស្សាវរីយ៍របស់មនុស្ស ពីកំលាំងដែលកើតមានឡើងក្រោយពេលដែលមនុស្សនោះ ; បានរួមរស់ជាមួយគ្រួសារនិងមាតុប្រទេសរបស់ខ្លួន អស់ពេលដ៏យូរ ។



www.elibraryofcambodia.org

234- អ្វីទៅហៅថាទំនោរឧត្តមគតិ ?

(Tendance idéale)

ដែលហៅថាទំនោរឧត្តមគតិ គឺទំនោរដែលកើតឡើងក្នុងចិត្តរបស់មនុស្ស ក្រោយពីមានដំណក់ទៅលើគំនិតផ្សេងៗរបស់អ្នកដទៃ ។

235- តើគំនិតអ្វីខ្លះ ដែលញ៉ាំងមនុស្សអោយមានទំនោរឧត្តមគតិ ?

គំនិតដែលញ៉ាំងមនុស្សអោយមានទំនោរឧត្តមគតិគឺ :

១- គំនិតសញ្ចេតនាក្នុងសាសនា ។
(sentiment religieux)

២- គំនិតសីលសញ្ចេតនា ។
(sentiment moral)

៣- គំនិតសញ្ចេតនាសិល្បៈ ។
(sentiment esthétique)

៤- គំនិតសញ្ចេតនាបញ្ញា ។
(sentiment intellectuel)

236- អ្វីទៅហៅថាទំនោរផ្ទាល់ខ្លួន ?

(Tendance personnelle)

ដែលហៅថាទំនោរផ្ទាល់ខ្លួន គឺទំនោរដែលមានលក្ខណៈជាបុគ្គលនិយម (individualisme) ឬអត្តទត្ថបុគ្គលនិយម ។

237- តើកំលាំងអ្វីខ្លះ ដែលញ៉ាំងមនុស្សអោយមានទំនោរផ្ទាល់ខ្លួន ?



www.elibraryofcambodia.org

កំលាំងដែលញុំាងមនុស្សអោយមានទំនោរផ្ទាល់ខ្លួនគឺ :

១- កំលាំងដែលកើតពីសេចក្ដីត្រូវការលើសេចក្ដីថ្លៃថ្នូរផ្ទាល់ខ្លួន
(dignité personnelle)

២- កំលាំងដែលកើតពីតំរូវការឯករាជ្យ ។
(besoin de l'indépendance)

៣- កំលាំងដែលកើតពីអំណាចគ្រប់គ្រងត្រួតត្រា ។
(besoin de domination)

៤- កំលាំងដែលកើតពីអស្មិមានះ ។
(Amour propre)

238- **តើទំនោរសង្គមមានប្រយោជន៍យ៉ាងណាខ្លះ ចំពោះសង្គមជាតិ ?**

ចំពោះសង្គមជាតិទំនោរសង្គមផ្ដល់ប្រយោជន៍ដូចតទៅនេះ:

១- ជំរុញពលរដ្ឋអោយស្រលាញ់ស្រុកកំណើតរបស់ខ្លួន ។

២- បង្កើតគំនិតស្រលាញ់ប្រពៃណី និងជាតិរបស់ខ្លួន ។

៣- ជំរុញអ្នកស្នេហាមាតុប្រទេស អោយធ្វើពលិកម្មយ៉ាងធំ ដើម្បីបំរើនិងការពារមាតុប្រទេស ។

៤- ទំនោរសង្គមអប់រំពលរដ្ឋ អោយមានឧត្តមគតិជាតិច្បាស់លាស់ ។

៥- បង្កើតមនោគមវិជ្ជាជាតិ ដែលជាកត្តាបញ្ជាក់នូវមូលដ្ឋាននៃការអប់រំជាតិ ។

៦- ញុំាងការអប់រំអោយស្របទៅតាមគោលអប់រំជាតិពិត ដើម្បីបណ្ដុះសម្បជញ្ញៈជាតិ ។

*

* *



www.elibraryofcambodia.org

# ១១- ឆន្ទៈ

(La volonte)

239- អ្វីទៅហៅថាឆន្ទៈ ?

(Qu'est.ce que la volonté ?)

ឆន្ទៈគឺកំលាំងចិត្តដែលជំរុញអោយមនុស្សយើង ធ្វើសកម្មភាពផ្សេងៗ ប្រកបដោយការត្រិះរិះពិចារណា ។

240- អ្វីទៅហៅថា "អំពើរបស់ឆន្ទៈ ?"

ដែលហៅថាអំពើរបស់ឆន្ទៈគឺ "ចេតនារម្មណ៍" ដែលកើតឡើងពីការណ៍របស់ចិត្ត ។

241- តើគេអាចយកឆន្ទៈមកធ្វើវិភាគបានឬទេ ?

បើគេអាចទាញចិត្តមកធ្វើវិភាគបាន គេក៏អាចទាញយកឆន្ទៈមកធ្វើវិភាគបានដែរ ។ ព្រោះថា "ឆន្ទៈ" ជាកំលាំងនៃ "ចិត្ត" ។

242- ដើម្បីធ្វើវិភាគទៅលើឆន្ទៈ តើគេត្រូវប្រើមធ្យោបាយអ្វីខ្លះ ?

ដើម្បីធ្វើវិភាគទៅលើឆន្ទៈ គេត្រូវប្រើមធ្យោបាយផ្សេងៗ ដូចតទៅនេះ :

១- ត្រូវពិនិត្យអោយបានច្បាស់ថា នូវអ្វី ដែលគេប្រុងធ្វើ ។ ហើយៈនាពេលនោះ គេត្រូវការជាចាំបាច់នូវមុខងារត្រៀមត្រៀបរបស់ឥន្ទ្រិយ ។

២- ត្រូវប្រមូលយកហេតុការណ៍ផ្សេងៗ ប្រមូលហេតុទាំងឡាយមកថ្លឹងប្រៀបធៀបមើល, តើបានផលល្អឬអាក្រក់ ?



www.elibraryofcambodia.org

៣- ត្រូវហ៊ានសំរេចកិច្ចការទាំងឡាយដោយកុំញញើក
ញញើម ។

៤- ទីបំផុតត្រូវហ៊ានប្រតិបត្តិ (exécution) សេចក្តីសំរេចនោះ ។

**243-អ្វីទៅហៅថា "ធម្មជាតិ" នៃឆន្ទៈ ?**

(Qu'est-ce que la nature de la volonté?)

តាមទ្រឹស្តីបញ្ញានិយម (théorie intellectualiste) "ឆន្ទៈជាបញ្ញា" ។ ឧទាហរណ៍ : គំនិតរបស់លោក ស្ពីណូសា (spinoza) ។

បើតាមទ្រឹស្តីពិសោធនិយម (théorie empiriste) ឆន្ទៈជាចំណង់ ។ ឧទាហរណ៍ : គំនិតរបស់លោក កុងឌីយ៉ាក់ (conillac) ។

បើតាមទ្រឹស្តីបរមត្ថវិជ្ជា (théorie métaphysique) ឆន្ទៈជាសេរីភាពផ្ទាល់ (libre arbitre) សំដៅយក "អំណាចនៃចិត្តដែលបានសំរេចរួចហើយ" ។

**244-តើគេបានរកឃើញប្រភពរបស់ឆន្ទៈថាកើតមកពីអ្វី ?**

ឆន្ទៈត្រូវអ្នកប្រាជ្ញចិត្តវិទ្យាល្បីៗ ជាច្រើនក្នុងពិភពលោក នាំគ្នាអោយយោបល់ខុសគ្នាទាំងអស់ ។ លោកអ្នកប្រាជ្ញខ្លះពោលថា : "ឆន្ទៈ" កើតពី "សេរីភាពផ្ទាល់" ព្រោះថា "ឆន្ទៈ" មានសេរីភាពអាចប្រព្រឹត្តទៅដោយគ្មានអ្វីបង្ខិតបង្ខំ រារាំងឬជ្រៀតជ្រែកឡើយ ។ ចំណែកលោកអ្នកប្រាជ្ញដែលជឿទៅលើ "កំណត់និយម" (déterminisme) បានពោលថា ឆន្ទៈ



www.elibraryofcambodia.org

កើតពីភាវៈសរីរាង្គ ចំណុះវិជ្ជា ការអប់រំ ឬពោលអោយខ្លីថា
កើតពី "កត្តាសរីរៈបញ្ញា - ចិត្តនិងសង្គម" ។
តែបើតាមទ្រឹស្ដីសាសនានិយមគេពោលថា :
"ឆន្ទៈកើតមកពីអាត្មាដែលជាម្ចាស់នៃអំពើរបស់មនុស្ស" ។

## 245- បើឆន្ទៈឋិតនៅក្នុងចិត្តរបស់មនុស្ស តើគេអាចបណ្ដុះឆន្ទៈបានឬទេ ? ដោយវិធីណាខ្លះ ?

ដោយឆន្ទៈឋិតនៅក្នុងចិត្តរបស់មនុស្ស, បានជាគេយល់ថា «បើគេបណ្ដុះ ឬ កាត់ចិត្តបាន, គេក៏អាចបណ្ដុះ ឬ កាត់ឆន្ទៈបានដែរ» ។ ក៏ប៉ុន្តែដើម្បីបណ្ដុះឆន្ទៈ, គេត្រូវពឹងផ្អែកទៅលើកត្តាផ្សេងៗដូចជា ៖

១- កត្តាសរីរាង្គ (facteur organique) ដែលគេតែងនិយមនិយាយថា «បើកាយមានសុខភាពល្អ បណ្ដាលមកពីគ្មានជម្ងឺនិងមានអាហារបរិបូណ៌, មានសំរាកគ្រប់គ្រាន់, នោះខួរក្បាលដែលជាគ្រឿងត្រួតត្រានៃឆន្ទៈ ក៏អាចមានលំនឹងហើយស្អាតល្អ» ។

២- កត្តាបញ្ញា (facteur intellectuel)

ដើម្បីអោយមានឆន្ទៈល្អ, យើងត្រូវចេះបណ្ដុះបញ្ញា ។ ការបណ្ដុះបញ្ញាអាស្រ័យសុខភាពនិងការអប់រំ ដូច្នេះមនុស្សជាយនៃអ្នកដឹកនាំជាកត្តាសំខាន់របស់បញ្ញា សំរាប់បណ្ដុះឆន្ទៈ ។ ឧទាហរណ៍ : ការអានសៀវភៅបណ្ដាលអោយរីកបញ្ញា ។ ហើយការរីកបញ្ញាបណ្ដាលអោយកើតឆន្ទៈព្រោះសម្បូរណ៍ឧត្ដមគតិ ។

៣- កត្តាសញ្ចេតនា (facteur du sentiment)



www.elibraryofcambodia.org

សេចក្តីនេះជាកំលាំងខ្លាំងបំផុត សំរាប់បង្កើតឆន្ទៈ ។ ការរក្សាសេចក្តីនេះអោយរឹងប៉ឹងក្រៃទាំងប្រកបដោយគុណសម្បត្តិ ជាលំហាត់យ៉ាងទៀងទាត់របស់មនុស្ស ។ ហើយការបង្ក្រាប់បង់នូវគុណវិបត្តិទាំងឡាយរបស់ចិត្តជាការទ្រទ្រង់ឆន្ទៈអោយមានលំនឹង ។

៤-កត្តាឧត្តមគតិសង្គម (facteur de l'idéal social)

ដោយយើងបានឃើញថា : «មនុស្សជាសត្វដែលរស់នៅក្នុងសង្គម» ហើយយើងស្គាល់ពីឥទ្ធិពលសង្គមដែលកែងសង្កត់មកលើមនុស្ស ។ ដូច្នេះហើយបង្កើតឆន្ទៈជាកុសលបាន អាស្រ័យយើងចេះពត់ឆន្ទៈ អោយមានទំនោរសង្គមនោះផងដែរ ។ បើពុំដូច្នោះយើងនឹងត្រូវសង្គមរារាំងមិនអោយឆន្ទៈនោះ ប្រព្រឹត្តទៅបានឡើយ ។

ឧទាហរណ៍ : លោករូស្សូ (J. J. Rousseau) បានបណ្តុះឆន្ទៈផ្ទុយពីឧត្តមគតិសង្គម ។ ឆន្ទៈលោករូស្សូកើតមានថែន ពីពុំដែលប្រើបានតែចំពោះលើរូបរូស្សូម្នាក់ឯងប៉ុណ្ណោះ ។ ពេលគឺលោករូស្សូ បង្កើតឆន្ទៈអោយរើរមុនកាលសម័យនៃសង្គមដែលគាត់រស់ ។ ទំរាំគេយល់ថា «ឆន្ទៈលោករូស្សូត្រូវនឹងឧត្តមគតិសង្គមបានវិញ, ផ្នូរលោករូស្សូដែលកប់លើកោះដើមស្រល់» (îles des peupliers) ចង់រលួយទៅជាផេះអស់ ។ នេះហើយ ឆន្ទៈដែលពុំស្របទៅនឹងឧត្តមគតិសង្គម។

*

* *

www.elibraryofcambodia.org

# ១២- តំលៃ-ករណីយកិច្ចនិងកុសល

(Valeur, Devoir et Bien)

**246-** អ្វីទៅហៅថាតំលៃ ?

(Qu'est-ce que la valeur ?)

តំលៃគឺអ្វីដែលគេនិយមចង់បានគ្រប់គ្នា ។

**247-** តើសំរាប់មនុស្ស តំលៃស្ថិតនៅលើអ្វី ? ហើយមានប៉ុន្មានយ៉ាង?

សំរាប់មនុស្ស តំលៃស្ថិតនៅលើរូបនិងជីវិត ពោលគឺបើមានរូបឥតជីវិតក៏ឥតតំលៃ, បើមានជីវិតឥតរូប ក៏ឥតតំលៃ ។ តែផ្នត់គំនិតគេយល់ថា: តំលៃរបស់មនុស្សស្ថិតនៅលើកាយនិងចិត្តទៅវិញ ។ អាស្រ័យហេតុនេះហើយទើបយើងឃើញកើតមានតំលៃពីរយ៉ាងផ្សេងគ្នាគឺ :

១- តំលៃសម្ភារៈ ឬតំលៃសេដ្ឋកិច្ច

(Valeur matérielle ou économique)

២- តំលៃគំនិត ឬសីលតំលៃ ។

(Valeur spirituelle ou morale)

**248-** អ្វីទៅហៅថាតំលៃសម្ភារៈ ឬតំលៃសេដ្ឋកិច្ច ?

ដែលគេហៅថាតំលៃសម្ភារៈ ឬតំលៃសេដ្ឋកិច្ច គឺតំលៃដែលមនុស្សសំគាល់ទៅលើគ្រឿងប្រដាប់ប្រើប្រាស់ ដែលមានលក្ខណៈជាសម្ភារៈ ឧទាហរណ៍ផ្ទះ ថយន្ត វិទ្យុ ប្រាក់ ។ល។ ហើយសម្ភារៈទាំងនេះមានតំលៃជាភោគទ្រព្យ ជាសម្បត្តិរបស់សង្គមមនុស្សដែលហៅថាសេដ្ឋកិច្ច ។



www.elibraryofcambodia.org

## 249- អ្វីទៅហៅថាតំលៃគំនិត ?

ដែលហៅថាតំលៃគំនិតគឺតំលៃឧត្តមគតិរបស់មនុស្សសំរាប់ញ៉ាំងអោយកើតសេចក្ដីសុខ សន្តិភាព វឌ្ឍនភាពនិងសុខមាលភាពដល់សង្គមមនុស្ស ។ ឧទាហរណ៍ : ស្នាដៃរបស់លោកអាល់ប៊ែរកាមុស (Albert CAMUS) មានតំលៃខាងផ្លូវគំនិតក្នុងការត្រួសត្រាយរកសច្ចៈភាព ដែលមាននៅក្នុងគុណសម្បត្តិមនុស្សជាតិ ។ ដូច្នេះស្នាដៃនេះត្រូវគេបានទទួលរង្វាន់ណូបែល (Prix NOBEL) ។

## 250- អ្វីទៅហៅថាសីលតំលៃ ?

ដែលហៅថាសីលតំលៃ គឺតំលៃដែលកើតមកពីអំពើល្អរបស់មនុស្សក្នុងការគិតនិងអនុវត្តន៍ ។ តែសីលតំលៃត្រូវមានលក្ខណៈសំខាន់ត្រឹមត្រូវខ្លះផងដែរ ដូចជា :

១- តំលៃដែលចេញពីចំណង់នៃបុគ្គលម្នាក់ៗ ។

ឧទាហរណ៍ : យើងចង់បានសន្តិភាពសេរីភាពនិងសុភមង្គល ហើយអ្នកដទៃក៏ចង់បានវត្ថុទាំងបីយ៉ាងនេះដែរ ទើបយើងសន្និដ្ឋានថា វត្ថុនោះមានតំលៃសីលធម៌ បើយើងចង់បានវត្ថុទាំងបី ហើយអ្នកដទៃត្រឡប់ជាពុំចង់បាន យើងពុំអាចសន្និដ្ឋានបានថានេះ "ជាសីលតំលៃបានឡើយ" ។

២- តំលៃដែលមានកំណើតធម្មជាតិ ដោយមនុស្សពុំអាចជៀសវាងនិងចោលពុំបាន ។

ឧទាហរណ៍ : មាតាបិតាបានបង្កើតនិងចិញ្ចឹមបីបាច់កូន ។ កូនត្រូវគោរពនិងចិញ្ចឹមលោកវិញ ។ នេះជាតំលៃទី២ ដែលមានលក្ខណៈជាសីលតំលៃ ។



www.elibraryofcambodia.org

៣-កំរៃទាំងឡាយណាដែលមានគូបដិបក្ខ ។

ឧទាហរណ៍ ៖ អ្នកដំណើរដើរទៅប្រទះខ្លាបាក់ជើងកណ្ដាលព្រៃ, ក៏មានចិត្តជួយសង្គ្រោះរកថ្នាំបិតជើងនិងជួយព្យាបាលរហូតបានជាសះស្បើយ ។ ដល់ខ្លាជាជើង ខ្លាស៊ីគាត់និងកូនប្រពន្ធអ្នកដំណើរនោះ ។ ការពិចារណារបស់អ្នកដំណើរត្រូវមានគឺ (គឺត្រូវជួយឬសំលាប់ខ្លា?) ។ ព្រោះថា«ជួយក៏ជាកំរៃ», «សំលាប់ក៏ជាកំរៃ» ។ ហើយកំរៃដែលមានគូបដិបក្ខនេះហើយថា «លក្ខណៈទី៣របស់សីលកំរៃ» ។

៤-ថាកំរៃដែលមានលក្ខណៈត្រឹមត្រូវចំពោះខ្លួនឯងផង ចំពោះជនដទៃ និង សង្គមលោកទាំងមូលផង ។

ឧទាហរណ៍ ៖ គ្រាប់បែកបរមាណូ មានកំរៃសំរាប់បញ្ឈប់សង្គ្រាមលោកលើកទីពីរ តែឥតកំរៃសំរាប់អ្នករងគ្រោះគឺជនជាតិជប៉ុន ។ តែការរកឃើញរូបមន្តនៃគ្រាប់បែកនេះគ្រប់ប្រទេសធំៗអាច បញ្ឈប់សំទុះប្រើប្រាស់គ្រាប់បែកនេះនៅពេលក្រោយបាន ។ ព្រោះកំរៃរបស់វានៅត្រង់មនុស្សខ្លាចពុំហ៊ានយកមកប្រើប្រាស់សំរាប់ការធ្វើសង្គ្រាម ។ សីលកំរៃនេះប្រកបដោយកុសលនិងអកុសលផង, តែមានលក្ខណៈប្រាកដនិយមសំរាប់បញ្ជាក់នូវលក្ខណៈទី៤ គឺ«សីលកំរៃ»។

## 251-អ្វីទៅហៅថាករណីយកិច្ច ?

ករណីយកិច្ចគឺ «លក្ខណៈនៃអ្វីដែលតំរូវឲ្យករលើគំណត់ចិត្តដោយសេរីរបស់មនុស្ស» ឬជាភាពចាំបាច់នៃអំពើដោយសេរី



www.elibraryofcambodia.org

នៅក្រោមបញ្ញាដាច់អហំការរបស់វិចារណញ្ញាណ, «គង់» (KANT) ។ ឬបើពោលដោយខ្លី លោកគង់បញ្ជាក់ថា «ករណីយកិច្ចជាបញ្ញាដាច់អហំការមួយ» ។
(un impératif catégorique)

## 252- ករណីយកិច្ចមានលក្ខណៈសំខាន់អ្វីខ្លះ ?

ករណីយកិច្ចមានលក្ខណៈសំខាន់ដូចតទៅ ៖

១- ជាបញ្ញា ឬសេចក្ដីបង្គាប់មួយ ។

២- ជាអតិរេកភាពនៃតំលៃ (transcendance de la valeur)

៣- ជាភាតព្វកិច្ច ដែលមិនសំរេចតាមបំណងអ្នកត្រូវក្រិត្ត គោរពគុណតំលៃភក្ដាយ ។

៤- ជាបញ្ញាដែលខាងគតិលោកធម៌ក្នុងជីវិត ។

៥- ជាគំនិតសកល ។

៦- ជាគំនិតនៃលក្ខណៈអោយក្លាយជាន ។

## 253- គេបានពោលថាករណីយកិច្ចមានលក្ខណៈជាបញ្ញាដាច់អហំការ, តើការបង្ហាញនូវលក្ខណៈទាំងនេះអាចញ៉ាំងយើងអោយពិចារណាទៅលើមុខវិជ្ជាប៉ុន្មានយ៉ាង ?

«ករណីយកិច្ចមានលក្ខណៈជាបញ្ញាដាច់អហំការ» នេះជាគោលការណ៍ទ្រឹស្ដីរបស់លោកគង់ (KANT) ។ ដើម្បីខ្លះឃើញបញ្ហានេះលំអិត, យើងអាចផ្ញើការពិចារណាទៅលើមុខវិជ្ជាផ្សេងៗនៃការសិក្សាគឺ :



www.elibraryofcambodia.org

១ - ទេវវិទ្យា (théologie)

២ - សង្គមវិទ្យា (sociologie)

៣ - ទ្រឹស្ដីវិចារណញ្ញាណនិយម (Rationalisme) ។ល។

254 - តាមទេវនិយម តើគេយល់ឃើញថាករណីយកិច្ចជាបញ្ជា មានបែបផែនយ៉ាងដូចម្ដេចខ្លះ ? ចូរលើកឧទាហរណ៍មកពន្យល់ ។

អ្នកទេវនិយមបានប្រកាសថា «ករណីយកិច្ចជាបញ្ជារបស់ព្រះអាទិទេព» ពោលគឺគេយល់ថាអាទិទេពជាអ្នកបង្គាប់បញ្ជា, ជាអ្នកសាងព្រហ្មលិខិត និងវាសនាមនុស្ស ។ អំណាចទាំងឡាយដែលញុាំងអោយយើងបានដល់គោលដៅ, ឬកុំដល់គោលដៅ អាស្រ័យកំលាំងទេពនោះឯង ។ ហេតុដូច្នេះហើយបានជាករណីយកិច្ច ដែលបានកើតចេញមកពីព្រះអាទិទេព ត្រឹតមានបែបជាកាតព្វកិច្ចវិញ ។ លក្ខណៈករណីយកិច្ច ទោះបីប្រកបដោយ «កុសល» ក្ដី «អកុសល» ក្ដីក៏សុទ្ធតែមានមូលដ្ឋានត្រឹមត្រូវ ។ ឧទាហរណ៍ : អាទិទេពបានបង្កើត មូអ៊ីស (Moïse) មក ដើម្បីអោយជួយរំដោះជនជាតិអេប្រឺ (Hébreux) អំពីទាសភាព (esclavage) ពោលគឺត្រូវចង់រំដោះជាតិអេប្រឺ (ជ្វីហ្វ) ពីអនានិគមអេស៊ីប (អារ៉ាប) ផង និងដើម្បីនាំជនជាតិដែលជាទាសករទាំងនេះ អោយបានយល់នូវផ្លូវបរមសុខផង (គឺព្រះបន្ទូលទាំងដប់) ។

យើងបានឃើញថា ករណីយកិច្ចរបស់ មូអ៊ីស (Moïse) មានពីរយ៉ាងគឺ :



www.elibraryofcambodia.org

១- រំដោះជនជាតិហេព្រឺពីអេស៊ីប (អារ៉ាប់)
២- នាំជនជាតិហេព្រឺអោយទៅរកព្រះបន្ទូលទាំងដប់នៅភ្នំស៊ីណាអ៊ី (Si Naï)

ដូច្នេះម៉ូអ៊ីស មានករណីកិច្ចត្រូវបំពេញបញ្ហាទ្វេភាគទាំងនេះ ដោយខានពុំបាន, ហើយបញ្ហា ឬករណីយកិច្ចរបស់ម៉ូអ៊ីស ជាបញ្ហាដាច់អហំការ, ព្រោះថាទោះបីម៉ូអ៊ីសបានត្រូវព្រហ្មលិខិតនាំអោយទៅបានជាកូនចិញ្ចឹមរបស់បុត្រស្រីស្តេច ហ្វារ៉ាអុង (PHARAON) ក្តី, ទោះបីម៉ូអ៊ីសបានធ្វើជាវិសូករប្រកបដោយអំណាចដ៏លើសលប់ក្តី ក៏ម៉ូអ៊ីសពុំបានបំភ្លេចឬវៀសវាងពីករណីយកិច្ចជា បញ្ហាដាច់អហំការនេះឡើយ ។

យើងឃើញថា ករណីកិច្ចត្រាស់ម៉ូអ៊ីសអោយដោះបង់ចោលអំណាចហេតុគន្លាក់ខ្លួនជា អ្នកទោសដាច់ត្រូវកាត់ក្តីអោយអាស្រូវ ។ តើម៉ូអ៊ីសវៀសវាងបានឬទេ ? យើងឃើញថាទោះបីម៉ូអ៊ីសនឹងវៀសវាងគេចវេះយ៉ាងណាក៏ដោយ ក៏វៀសពុំរួចពីករណីយកិច្ច ដែលមានលក្ខណៈដាច់អហំការរបស់ព្រះអាទិទេពបានឡើយ ។ ទីបំផុតយើងឃើញថា ម៉ូអ៊ីសរួចពាកទុក្ខទោសទាំងអស់ហេតុបានទៅជាមគ្គុទ្ទេសក៍ ដ៏ល្អិតក្នុងការនាំជនជាតិហេព្រឺ គឺថ្មីៗទៅរកព្រះបន្ទូលទាំងដប់របស់ព្រះអាទិទេព ។ នេះហើយជាករណីយកិច្ចដែលមានលក្ខណៈដាច់អហំការ របស់ព្រះអាទិទេព ។

255- តាមរបបសង្គមនិយម, តើករណីយកិច្ចដាច់បញ្ញានោះ មានលក្ខណៈយ៉ាងដូចម្តេច? ចូរលើកឧទាហរណ៍មកពន្យល់ ។



www.elibraryofcambodia.org

តាមរបបសង្គមនិយម ករណីយកិច្ចក៏មានថែមចំពោះបញ្ញាដែរ រីឯចំពោះបញ្ញារបស់សង្គម ។ អ្នកប្រាជ្ញឈ្មោះ ឌូរ៉ឹម (Durkheim) យល់ថា៖

"សីលញាណរបស់មនុស្សមានឥទ្ធិពលសង្គម , ហើយសីលញាណនេះឯងជាអ្នកបញ្ជានៅក្នុងខ្លួនយើង"

តាមគំនិតខាងលើនេះ , យើងឃើញថា ឥទ្ធិពលសង្គមប្រាប់សីលញាណមនុស្សអោយគោរពនិងធ្វើតាមនូវឧត្តមគតិមួយ គឺ "ឧត្តមគតិសង្គម" ។ ឧទាហរណ៍ ៖ ដើម្បីអោយបានទៅជាចៅក្រមមួយរូបពេញលក្ខណៈច្បាប់ , ជនទាំងឡាយត្រូវតែដើរតាមបញ្ជា ដែលមានលក្ខណៈជាច្បាប់របស់សង្គមខ្លួនពោលគឺ៖ ដូចជានៅប្រទេសខ្មែរ អ្នកត្រូវមានលក្ខណៈដូចតទៅនេះ ៖

១- ត្រូវជននោះបានសញ្ញាប័ត្រមធ្យមសិក្សាប័ត្រភាគទី ២ ។

២- ត្រូវសិក្សានៅមហាវិទ្យាល័យច្បាប់ចំនួនបួនឆ្នាំ ។

៣- ត្រូវមានបរិញ្ញាប័ត្រច្បាប់ ។

៤- ត្រូវបានរដ្ឋទទួលស្គាល់អោយធ្វើជា "រដ្ឋអាជ្ញា" ហើយបំពេញការក្នុងសាលាកាត់ក្តីជាច្រើនឆ្នាំ ឬយ៉ាងហោចណាស់ត្រូវបានសញ្ញាប័ត្រជាន់ខ្ពស់ខាងវេត្តបាល ។

៥- ត្រូវបានសេចក្តីយល់ព្រមបញ្ជាក់ដោយក្រឹត្យក្រុមពិគណៈរដ្ឋមន្ត្រី ។

ដូច្នេះមនុស្សទាំងឡាយ ទោះបីខ្លួនចេះស្រាវជ្រាវយ៉ាងណាក្តី បើពុំបានបំពេញលក្ខខណ្ឌដូចខាងលើនេះទេ , ពុំអាចទៅជាចៅក្រមពេញលក្ខណៈច្បាប់បានឡើយ ។ យើងឃើញថាសង្គមញាំងជនដែលចង់ធ្វើជាចៅក្រម អោយបំពេញករណីយកិច្ច



www.elibraryofcambodia.org

តាមបញ្ញារបស់ខ្លួនយ៉ាងដាច់ខាត ។ នេះជាករណីយកិច្ច ជាបញ្ជាដាច់អហំការរបស់សង្គមទៅលើបុគ្គល ។

256- គេបានពោលថា: ករណីយកិច្ច ដែលជាបញ្ជាដាច់អហំការបានប្រភពមកពីវិចារណញ្ញាណផងដែរ តើអ្នកយល់យ៉ាងដូចម្ដេច ចូរលើកឧទាហរណ៍មកពន្យល់?

ចំពោះបីករណីយកិច្ចដែលមានលក្ខណៈជាបញ្ជា កើតចេញមកពីប្រភពផ្សេងៗ តាមការយល់ឃើញរបស់អ្នកប្រាជ្ញខ្លះក៏ដោយ ក៏នៅមានអ្នកប្រាជ្ញខ្លះយល់ថា "បើករណីយកិច្ច ជាអំពើដែលមានមនុស្សជាអ្នកប្រព្រឹត្តទៅ ករណីយកិច្ចនេះចង់ទោះមានប្រភពមកពីណាក៏ដោយក៏ជៀស"ចិត្តរបស់មនុស្ស" មិនរួចដែរ ។ អ្នកប្រាជ្ញឈ្មោះ កង់ (Kant) ក៏នៅជឿថែរថា "ថ្វីបើករណីយកិច្ចជាបញ្ជាកើតមកពីអាទិទេព" ឬក៏ពិភពសង្គមក្ដី ក៏ករណីយកិច្ចនេះកើតចេញពីចិត្តរបស់មនុស្ស គឺ "វិចារណញ្ញាណ" នេះឯង ។ លោកអ្នកប្រាជ្ញនេះ យល់ថា "សីលវិជ្ជា" គឺជាងអ្វីទាំងអស់ ចំពោះមនុស្ស ។ លោកពុំព្រមទទួលស្គាល់ភាពថា "សីលវិជ្ជាធ្លាក់ពីវិតវិញមកដល់ទៅទទួលស្ដាប់បង្គាប់គោលការណ៍មួយ ក្រៅពីមនុស្សខ្លួនឯងទៀត" ទោះជាគោលការណ៍នោះជាព្រះអាទិទេពអតិរេក (Dieu-transcendant) ឬជាវត្ថុមួយដែលមានអំណាចក៏ដោយ ។ លោកកង់ (Kant) បន្ថែមទៀតថា:

"វិចារណញ្ញាណ មានច្បាប់របស់ខ្លួនច្បាស់លាស់ណាស់ ឥតឲ្យបង្គាប់បញ្ជាដល់មនុស្ស" ។ ដូច្នេះយើងឃើញថា



www.elibraryofcambodia.org

# ១៣. សីលញ្ញាណ

(La conscience morale)

258- អ្វីទៅហៅថាសីលញ្ញាណ ?

ដើម្បីអោយនិយមន័យរបស់ពាក្យ "សីលញ្ញាណ" បាន, ជាបឋមយើងត្រូវស្គាល់ន័យនៃពាក្យ "សីល" និង "ញាណ" ជាមុនសិន ។

អ្វីទៅហៅថា "សីល" (morale)? ( តាមបែបទស្សនវិជ្ជា "សីល" គឺ ក្បួនដែលសិក្សាអំពីនិយាមទាំងឡាយ សំរាប់ដឹកនាំមនុស្សអោយធ្វើ "កុសល" ហើយនិងជៀសវាង "អកុសល" )

(Science qui traite des règles à suivre pour faire le bien , éviter le mal .)

ចុះអ្វីទៅហៅថា "ញាណ" (conscience)? (តាមបែបទស្សនវិជ្ជា "ញាណ" គឺជាសញ្ចេតនា ដែលកប់នៅក្នុងចិត្តរបស់មនុស្សហើយដែលតែងញុំាងមនុស្សអោយចេះវិនិច្ឆ័យអ្វីជា "កុសល" ឬ "អកុសល" ) ។

(Sentiment intérieur qui nous fait juger ce qui est bien et ce qui est mal.)

សរុប : "សីលញ្ញាណ" គឺ "សញ្ចេតនានៃចិត្ត ដែលប្រកបដោយនិយាម (règles) ញុំាងមនុស្សអោយដោះស្រាយបញ្ហា "កុសល" និង "អកុសល" ។

259- អ្វីទៅហៅថា "ចិត្តញាណ" ?

(Qu' est-ce que la conscience psychologique?)



www.elibraryofcambodia.org

លោកអ្នកប្រាជ្ញ ឈ្មោះ ឡាឡង់ (La Lande) បានឲ្យនិយមន័យថាៈជា « អន្តរញ្ញាណ (intuition) ដែលនាំចិត្តអោយដឹងភាពនិងអំពើរបស់ខ្លួន ; ដូច្នេះចិត្តញាណ មិនគឺអ្វីក្រៅពី "អ្វីដែលនាំអោយចិត្តស្គាល់សច្ចៈភាពពិតប្រាកដ នៃសកម្មភាពរបស់មនុស្ស" ។

260- តើ«សីលញ្ញាណ» និង"ចិត្តញាណ" ខុសគ្នាយ៉ាងដូចម្តេចខ្លះ? ចូរពន្យល់ ។

«សីលញ្ញាណ» និង "ចិត្តញាណ" វត្ថុទាំងពីរនេះ ជាសភាពនៃចិត្តដែលនាំអោយដឹងដូចគ្នា, គឺជាអំណោយដែលមានគុណសម្បត្តិខាងប្រាប់«សច្ចៈភាព»ដូចគ្នា។ តែប៉ុន្តែវត្ថុទាំងពីរមានលក្ខណៈខុសគ្នាត្រង់សកម្មភាពរបស់ខ្លួនពោលគឺ:

«សីលញ្ញាណ» ដឹងហើយញុំាងមនុស្សអោយធ្វើករណីយកិច្ចទាំងពួង ។ ជាសម្លេងនៃចិត្ត ។

ឯចំណែក«ចិត្តញាណ»វិញ គ្រាន់តែជាកន្សែងការដឹងប៉ុណ្ណោះ, ហើយពុំបង្គាប់មនុស្សអោយធ្វើអំពើឡើយ ។ ហេតុដូច្នេះហើយបានជាអ្នកនិយមមួយពោលថា:
«បើ"ចិត្តញាណ"ជាអ្នកទស្សនា "សីលញ្ញាណ" ជាអ្នកវិនិច្ឆ័យ» ។

(si la conscience psychologique est spectateur la conscience morale est juge)

261- គេបានពោលថា: «ការធ្វើវិភាគទៅលើសីលញ្ញាណ»



www.elibraryofcambodia.org

បានបង្ហាញអោយឃើញនូវ «គំនិតទស្សនវិជ្ជាថ្មីៗ ដែលជាសកម្មភាពរបស់ចិត្ត» ។ តើគំនិតទស្សនវិជ្ជានោះជាអ្វីខ្លះ ? តើគេអាចចាប់យកមកពិចារណារកហេតុផលនិងអំពើរបស់វាបានឬទេ ?

ការវិភាគទៅលើ «សីលញ្ញាណ» បានអោយគេឃើញនូវគំនិតទស្សនវិជ្ជាពីរគឺ :

១- សីលវិនិច្ឆ័យ (jugements moraux)

២- សីលសវេទនា (sentiments moraux)

ក្រោយដែលគេបានរកឃើញនូវគំនិតទាំងពីរនេះហើយគេក៏ចាប់ពិនិត្យ និងពិចារណាលើធាតុពិត និងលើអំពើរបស់វាទៀត ។ គេបានដឹងថា «សីលវិនិច្ឆ័យ» (jugements moraux) ជាធាតុបញ្ញាញាណ (éléments intellectuels) ដែលស្ថិតនៅក្នុងចិត្តរបស់មនុស្ស ។ គឺជានិយមក្នុងចិត្តអោយពិចារណា ហើយអោយកំណត់លើសកម្មភាពទាំងឡាយណាដែលប្រកបដោយកុសលឬអកុសល ។ ការពិចារណាខុសត្រូវអាក្រក់ល្អ សរុបទៅលើប្រការផ្សេងៗដូចជាការវិនិច្ឆ័យលើករណីកិច្ច លើសិទ្ធិមនុស្ស លើយុត្តិធម៌ដែលគួរលើច្បាប់ ។ ជួនកាលសីលវិនិច្ឆ័យត្រូវពិចារណាលើការណ៍ចិត្តផ្សេងៗថែមទៀតផងដូចជា «ទំនួលខុសត្រូវ» (Responsabilité) នៃបុគ្គល ។ល។

ឯចំណែក «សីលសវេទនា» វិញគេច្រើនជឿថាវាជា «ធាតុវេទនា» (éléments affectifs) ដែលនៅជាមួយ



www.elibraryofcambodia.org

ការវិនិច្ឆ័យគឺការគោរពកំពើជាកុសល ហើយស្អប់ខ្ពើមអំពើ «អកុសល» ។ល។

262- ដោយសីលញ្ញាណ ញ៉ាំងចិត្តអោយធ្វើការពិចារណា និងអោយកំណៃទៅលើប្រធានផ្សេងៗរបស់មនុស្ស បានជាអ្នកប្រាជ្ញខ្សែទស្សនវិជ្ជាភាគច្រើនចូលចិត្តចង់ដឹង, ចង់ស្គាល់, ព្រមទាំងចង់ឃើញ ដើមកំណើតនៃសីលញ្ញាណនេះ ។ តើសីលញ្ញាណកើតមកពីណាចូរពន្យល់ ។

ដើម្បីពិចារណាពីសីលញ្ញាណ អ្នកប្រាជ្ញជាច្រើនបានអោយគំនិត ឬ ទស្សនៈផ្សេងៗគ្នា :

១- លោក រូសូ ថា «សីលញ្ញាណ» ជា «សំលេងអមតៈនៃព្រះភាទិទេព» ។ មិនតែប៉ុណ្ណោះ លោកបានបញ្ជាក់ថែមទៀតថា «សីលញ្ញាណជាទៅក្រមនិច្ចដែលមិតនៅក្នុងចិត្តរបស់មនុស្ស, ហើយទៅក្រមនោះសោតកុំមានការភ័ន្តច្រឡំនៅក្នុងការពិចារណាឬវិនិច្ឆ័យទាំងឡាយឡើយ ។

២- អ្នកប្រាជ្ញឈ្មោះ រេត (Red) បានយល់ថា : «សីលញ្ញាណ ជាសភាវញ្ញាណភ្លាមៗ (sentiment immédiat) ដែលស្ថិតនៅក្នុងខ្លួននៃមនុស្សភាគតិច» ។

៣- ចំពោះពួក រ៉ូម៉ង់ទិច ពោលថា : «សីលញ្ញាណ ជាសក្តិមួយពិសេស (faculté speciale) ដែលមានលក្ខណៈខុសពីវិចារណញ្ញាណ» ។

www.elibraryofcambodia.org

263- តើគំនិតនៃអ្នកប្រាជ្ញទាំងបីមើលឃើញ " សីលញ្ញាណ" ថាមានប្រភពមកពីណា, ហើយកើតពីអ្វី ?

ដោយយោលទៅតាមអំណាចគំនិតរបស់អ្នកប្រាជ្ញខ្លះ យើងហៅថា «សីលញ្ញាណ» ដំបូងកើតមកពី «ចិត្ត» ប៉ុន្តែកើតមកពីសរីរាង្គនៃគ្រាប់ចិត្តទៀត ។ បន្ទាប់មកនៅក្នុងចិត្តចំនួន ១២១ របស់មនុស្ស, សីលញ្ញាណកើតមកពីស្ដេចចិត្ត ក្នុងចំណោម «សោភណចិត្ត» ចំនួន ៩១ ។ ជាស្ដេចចិត្តដែលប្រកបដោយគន្លឹះស្មើស្មុំរឿង ហេតុទាល់តែលោក «រូស្សូ» យល់ថាជា «សភាវគតិចិត្ត» ដែលឋិតនៅក្នុងចិត្តរបស់មនុស្ស (១) ។

264- តើទ្រឹស្តីទស្សនវិជ្ជាណាខ្លះ ដែលសាកល្បងយក "សីលញ្ញាណ" មកពិចារណា? តើទ្រឹស្តីនិមួយៗយល់ថា " សីលញ្ញាណមានលក្ខណៈយ៉ាងដូចម្តេចខ្លះ ?

ទ្រឹស្តីដែលយក «សីលញ្ញាណ» មកពិចារណាគឺ :

១- ទ្រឹស្តី សីលឥន្ទ្រិយ ឬមតិមានពីកំណើត ។

(théorie de sens moral ou thèse innéiste)

២- ទ្រឹស្តី ពិសោធនិយម ។

(théorie empiriste)

---

(១) : ចិត្តរបស់មនុស្សយើងមានចំនួន ១២១ គឺ: អសោភណចិត្ត៣០ និងសោភណចិត្ត ៩១ ។ ឯចំណែក «សីលញ្ញាណ» កើតនៅក្នុងសោភណចិត្ត ៩ នេះឯង, ហើយ «សីលញ្ញាណ» ជាស្ដេចនៃសោភណចិត្ត ។



www.elibraryofcambodia.org

៣. ទ្រឹស្តីវិចារណញ្ញាណនិយម ៖

(théorie rationaliste)

ទ្រឹស្តីទី ១ យល់ថា «សីលញ្ញាណ» មានកំណើតមកមនុស្សមក ។

ឧទាហរណ៍ ៖ មនុស្សកើតមកមានខួរក្បាល, ដូច្នេះមនុស្សកើតមកត្រូវយក «សីលញ្ញាណ» មកផង ។

ទ្រឹស្តីទី ២ យល់ថា «សីលញ្ញាណ» កើតមកពី «កិរិយាធម៌» របស់មនុស្ស ក្រោយដែលខ្លួនបានហាត់ហ្វឹកហ្វឺនក្នុងជីវិតមកអស់កាលយូរ ។ ពោលគឺគេយល់ថា «សីលញ្ញាណ» កើតមកពី «វិវត្តន៍នៃពូជមនុស្ស» (លោកស្ពេនស៊ែរ) (Spencer), ក្រោយមកទៀតគេជឿថាកើតមកពីការអប់រំនៃសង្គមមនុស្ស (លោកឌូរ៉ែម) ។

ទ្រឹស្តីទី៣ យល់ថា «សីលញ្ញាណ» កើតមកពី «ខួរក្បាលមនុស្សដែលមានវិចារណញ្ញាណ» ដែលគេចាត់ទុកថាជាបុព្វសិទ្ធិកំណើតនៃមនុស្ស (une prérogative congénitale de l' homme) ។

ហេតុដូច្នេះហើយបានជាអ្នកនិយមតាមទ្រឹស្តីទី៣នេះ អោយឈ្មោះ «សីលញ្ញាណ» ថា ៖ ជា «វិចារណញ្ញាណអនុវត្ត» (Raison pratique) ។



www.elibraryofcambodia.org

# ១៤.ទំនួលខុសត្រូវនិងវិបាកវិនិច្ឆ័យ

(La Responsabilité et la sanction)

265- អ្វីទៅហៅថា ទំនួលខុសត្រូវ?

( Qu'est-ce que la Responsabilité?)

ដែលហៅថាទំនួលខុសត្រូវគឺ ការធានាថានឹងរ៉ាប់រងលើអំពើទាំងឡាយដែលខ្លួនបានប្រព្រឹត្ត មានការទទួលសារភាព ។ ហើយនឹងទទួលវិបាកវិនិច្ឆ័យផងដែរ ។

266- អ្វីទៅហៅថា ទំនួលខុសត្រូវខាងផ្នែកសង្គម?

(Qu'est-ce que la Responsabilité sociale?)

ដែលហៅថាទំនួលខុសត្រូវផ្នែកសង្គម គឺទំនួលខុសត្រូវចុះសារភាពចំពោះមុខច្បាប់នៃសង្គមនោះ ។

ឧទាហរណ៍ : ជនទាំងឡាយដែលប្រព្រឹត្តល្មើសនឹងច្បាប់សង្គម ត្រូវតុលាការជាអ្នកកាត់ទោស ។ តែមុននឹងផ្តន្ទាទោស ឬកាត់ទោសជននោះ ច្បាប់ត្រូវការជាចាំបាច់នូវទំនួលខុសត្រូវ គឺការឆ្លើយសារភាព[illegible] ។ ម្យ៉ាង ច្បាប់ត្រូវការ ទំនួលខុសត្រូវនៃជនជាប់ចោទសំរាប់ធ្វើជាអំណាងរបស់ខ្លួន ទើបគេឃើញមានការ ធ្វើទារុណកម្មដើម្បីបង្ខំជនដែលល្មើស ឬជនជាប់ចោទអោយសារភាពជាមុនសិន ។

267- អ្វីទៅហៅថាទំនួលខុសត្រូវខាងផ្នែកសីលវិជ្ជា?

ទំនួលខុសត្រូវខាងផ្នែកសីលវិជ្ជា គឺការទទួលសារភាពទាំងឡាយ ដែលពុំបង្ខិតបង្ខំ ក្រោយទាំងជាសារភាពឬទំនួលខុសត្រូវ ដែលសាមីជនបានញាណគ្រប់គ្រាន់ផង ។ ឧទាហរណ៍ :



www.elibraryofcambodia.org

មនុស្សឆ្កួតពុំមានទំនួលខុសត្រូវខាងផ្លូវសង្គម និង សីលវិជ្ជា ឡើយ ។ ដូច្នេះ មនុស្សឆ្កួតគ្មានកំហុសចំពោះមុខតុលាការ ទេ ។

**268-តើទំនួលខុសត្រូវផ្នែកសង្គម បានត្រូវច្បាប់ចែកជា ប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?**

ទំនួលខុសត្រូវផ្នែកសង្គម ត្រូវច្បាប់ចែកជាពីរផ្នែកទៀត គឺ ៖

១. ផ្នែកព្រហ្មទណ្ឌ (responsabilité pénale)

២. ផ្នែករដ្ឋប្បវេណី (responsabilité civile) ។

ឧទាហរណ៍ ៖ ចោរសំលាប់គេត្រូវទទួលទោសឧក្រិដ្ឋ ព្រោះ ជាទំនួលខុសត្រូវធ្ងន់គឺ ផ្នែកព្រហ្មទណ្ឌ ។

ឧទាហរណ៍ ៖ ក្នុងវិវាទ ម្ចាស់ផ្ទះត្រូវទទួលទោសផ្នែករដ្ឋប្បវេណី គឺទោសស្រាល ។ គឺការបង្ខាប់អោយម្ចាស់វត្ថុ សងជំងឺចិត្តអ្នករងគ្រោះដោយបង់ជាប្រាក់ ។

**269-តើទំនួលខុសត្រូវផ្នែកសង្គម និង ផ្នែកសីលវិជ្ជាមាន ទំនាក់ទំនងគ្នាយ៉ាងដូចម្តេចខ្លះ ចូរលើកឧទាហរណ៍ និងពន្យល់ ?**

មនុស្សជាសត្វដែលអាចរស់នៅក្នុងសង្គមបាន ដូច្នេះតួនាទីរបស់សង្គមគឺធ្វើឲ្យមនុស្សអោយ ប្រព្រឹត្តនូវកាយបញ្ញា ជាចំណែករបស់ខ្លួន ។ កាលណាមនុស្សទាំងឡាយណា ដែលចង់សុខចិត្តរស់នៅក្រោមអំណាច នៃសង្គមណាមួយ ហើយ មនុស្សទាំងឡាយនោះត្រូវច្បាប់សង្គមបញ្ជា អោយ



www.elibraryofcambodia.org

មានទំនួលខុសត្រូវក្នុងក្របខ័ណ្ឌច្បាប់និងអំណាចរបស់ខ្លួន ។ ទំនួលខុសត្រូវនេះបានត្រូវសង្គមចែកចេញជាពីរផ្នែកគឺ :

១- ផ្នែកព្រហ្មទណ្ឌ និង

២- ផ្នែករដ្ឋប្បវេណី ។

ក៏ប៉ុន្តែ ដោយទំនួលខុសត្រូវរបស់សង្គមត្រូវមានមនុស្សជាប្រធានក្នុងកត្តាវត្ថុរបស់ខ្លួន , ហើយមនុស្សនេះឯងជាសត្វដែលបរិភោគ "ចរោសស្មុគស្មាញ" ទើបគេរកឃើញថា ដើម្បីអោយមានយុត្តិធម៌ក្នុងការវិនិច្ឆ័យ, ចៅក្រមមិនត្រូវគិតតែពីបញ្ហាសង្គមទេ, តែត្រូវគិតអំពីបញ្ហាសីលធម៌ផងដែរ ។ តើទំនាក់ទំនងទាំងពីរនេះមានលក្ខណៈយ៉ាងដូចម្ដេចខ្លះ?

ឧទាហរណ៍ : សង្គមបានដាក់ទោសមនុស្សម្នាក់អោយជាប់គុកមួយឆ្នាំព្រមទាំងបង្ខំអោយធ្វើការដាច់ពិន់ ។ មូលហេតុមកពីមនុស្សនោះបានសំលាប់ប្រពន្ធរបស់ខ្លួន ។ នៅពេលកាត់ទោស, ចៅក្រមភាគច្រើនពិនិត្យតែលើការកាត់ទោសនេះ ព្រោះចៅក្រមខ្លួនឯងក៏ជាមនុស្ស, ចំណែកអ្នកមានទោសក៏ជាមនុស្ស ។ ចៅក្រមក៏មានប្រពន្ធ, អ្នកទោសក៏មានប្រពន្ធ ។ បើដូច្នោះត្រូវដាក់គុកមួយឆ្នាំ ហើយបង្ខំអោយធ្វើការដាច់ពិន់ ដោយទោសសំលាប់ប្រពន្ធដែលមានសហាយ ។ លុះដល់ពេលប្រពន្ធចៅក្រមមានសហាយវិញ, បើចៅក្រមសំលាប់គេ ចៅក្រមខ្លួនឯង ក៏ត្រូវគេយកមកកាត់ទោសដូចគ្នានឹងខ្លួនកាត់ទោសជនដទៃដែរ ។ ចៅក្រមនៅតែងមានបញ្ហាសីលធម៌ នៅក្នុងអារម្មណ៍របស់ខ្លួនជានិច្ច ដោយពិចារណាទៅលើកុសល និងអកុសល ។ ម្យ៉ាងទៀតចៅក្រមអាចយកទំនួលខុសត្រូវ



www.elibraryofcambodia.org

ផ្នែកសីលវិជ្ជា ពាក់ជួនក្រុមប្រឹក្សាតុលាការពិចារណា ដើម្បីជួយសំរាលទោសអ្នកជាប់ចោទ, ដូចជាបញ្ហា «ចេតនា» និង «អចេតនា» ។ល។ ចៅក្រមបានប្រើច្បាប់ទំនួលខុសត្រូវសង្គមមកជាទំនួលខុសត្រូវសីលវិជ្ជា ដើម្បីចាត់ទុកអំពើនេះថាជាទោសកម្មធម្មតាហើយ ដែលអ្នកមានពិរុទ្ធត្រូវទទួលទោសតែត្រឹមបទមធ្យមប៉ុណ្ណោះ ។ ជួនកាលគេអាចជួយអ្នកទោសអោយបានរួចខ្លួនផង គឺមានអោយសំអាងទៅលើ «បញ្ហាញាណ» គឺគេតែងបង្គាប់អ្នកជាប់ពិរុទ្ធ អោយទៅទាក់ទងនឹងពេទ្យវិកលចរិត ព្រោះច្បាប់បានទទួលស្គាល់ថា មនុស្សឆ្កួតជាមនុស្សបាត់ញាណ, ជាជនគ្មានទំនួលខុសត្រូវខាងសីលវិជ្ជា, ហើយនិងជាមនុស្សឥតទោស ។ ដូច្នេះយើងឃើញថា ទំនួលខុសត្រូវខាងផ្នែកសង្គម មានទំនាក់ទំនងយ៉ាងជាក់លក្ខណ ជាមួយនិងទំនួលខុសត្រូវខាងសីលវិជ្ជា ពុំអាចកាត់ដាច់ពីគ្នាបានឡើយ ។

## 270- អ្វីទៅហៅថា ទំនួលខុសត្រូវក្នុងទ្រឹស្តីវិចារណញាណនិយម?

ដែលហៅថា ទំនួលខុសត្រូវក្នុងទ្រឹស្តីវិចារណញាណនិយម គឺទំនួលខុសត្រូវដែលចេញមកពីការពិចារណានៃសាមីជនម្នាក់ៗ ។ គេនឹងត្រូវមានទំនួលខុសត្រូវបានលុះត្រាតែគេមានញាណត្រឹមត្រូវ, ពុំមែនជាមនុស្សឡប់សតិ, ឬមនុស្សឆ្កួត ។ គេជាមនុស្សមានសេរីភាព គឺពុំមែនបង្ខិតបង្ខំដោយអំណាចពលនរណាម្នាក់ឬច្បាប់ណាមួយ ។ ឆន្ទៈរបស់គេជាឆន្ទៈដែល



www.elibraryofcambodia.org

ប្រកបដោយកុសលចិត្ត ហើយក៏គ្មាននរណាម្នាក់មកការពារចំណុះណាក៏រានចិត្តរបស់គេបានឡើយ ។

ឧទាហរណ៍ : លោករូស្សូបានរត់ភៀសខ្លួនទៅប្រទេសស្វីស ក្រោយដែលបានសរសេរទំនៀមប្រទេស និងសង្គមរបស់បារាំងនៅក្នុង "សៀវភៅ" របស់លោកមួយឈ្មោះ "អេមីល" (Emile) ។ ហេតុអ្វីក៏លោករូស្សូរត់? លោករូស្សូរត់ព្រោះគេបានតាមចាប់ខ្លួនគាត់ពីបទសរសេរ អោយខូចរបៀបរៀបរយសង្គមរបស់គេ ។

លោករូស្សូរត់ព្រោះខ្លាចមានទំនួលខុសត្រូវចំពោះសង្គម។ ប្រាំឆ្នាំក្រោយមក រូស្សូក៏ត្រឡប់មកប្រទេសបារាំងវិញ ។ ហេតុអ្វីក៏រូស្សូត្រឡប់មកប្រទេសបារាំងវិញ ? គាត់ត្រឡប់មកប្រទេសបារាំងវិញ ព្រោះគេលែងតាមចាប់ខ្លួនគាត់, គេបានទុកជាមោឃៈ នូវដីកាចាប់ខ្លួនគាត់, ម្យ៉ាងទៀតគាត់ត្រូវត្រឡប់ចូលមកប្រទេសបារាំងវិញ ព្រោះគាត់មានទំនួលខុសត្រូវខាងវិចារណញ្ញាណ ។ ព្រោះរូស្សូមានវិប្បដិសារី រូស្សូដើរទៅលក់នូវច្បាប់ទុកអោយរដ្ឋចិញ្ចឹម, ហេតុនេះហើយបានជាគាត់សរសេរវចនានុក្រមតន្ត្រី (Dictionnaire de musique) មួយចំណែកអោយរដ្ឋនោះវិញ ។ យើងឃើញថា រូស្សូមានទំនួលខុសត្រូវផ្នែកវិចារណញ្ញាណ ព្រោះគាត់មានសេរីភាព, គាត់រួចចាកពីសំណប់ចិត្តនៃសង្គមហើយត្រឡប់ជាមានភក្តីភាពសង្គមវិញ ។

271-តើទំនួលខុសត្រូវ ផ្នែកប្រពៃណីនិយមមានលក្ខណៈយ៉ាងដូចម្តេច? ចូរពន្យល់ ។



www.elibraryofcambodia.org

តាមប្រៃតណ៍និយម ជនណាក៏ដោយដែលបានប្រព្រឹត្តនូវអំពើអ្វីមួយ សុទ្ធតែត្រូវមានបង្គាប់ពីចិត្តរបស់ខ្លួនដែលបានពិចារណារួចហើយ ។ អ្នកប្រាជ្ញប្រៃតណ៍និយមទៀតថាបើគ្មានសេចក្តីសម្រេចចិត្តទេ បុគ្គលពុំអាចអនុវត្តនូវអំពើអ្វីមួយបានឡើយ ព្រោះមានការបង្ខិតបង្ខំ គ្មានក្តី ។ ពួកអ្នកប្រាជ្ញទាំងនោះយល់ថា "ចិត្ត" ជាកត្តាចំបងសំរាប់ការអនុវត្តអំពើទាំងឡាយនៃមនុស្ស ។

គេរៀបថា "មនុស្សមានក្នុងចិត្តមួយ" ដែលអ្នកប្រៃតណ៍និយមហៅថា "សេរីភាពជ្រើស" (libre arbitre) ញ៉ាំងអោយគេសំរេចកិច្ចការនានាបាន ។ ដូច្នេះទំនួលខុសត្រូវដែលអ្នកប្រៃតណ៍និយម បានរកឃើញនោះ គឺទំនួលខុសត្រូវបណ្តាលមកពីចិត្តដែលជារបស់មនុស្សដែលប្រកបដោយ "មូលហេតុ" នេះឯង ។

## 272-អ្វីទៅហៅថា "វិបាកវិនិច្ឆ័យ" ?

Qu'est-ce qu'une sanction?

វិបាកវិនិច្ឆ័យគឺជាវិបាក ដែលកើតឡើងពីការប្រព្រឹត្តភាពមិនស្របច្បាប់ជាមិនខាន និងតែងតែមានន័យជាពិន័យ ។ តាមវិបសស័ណ្ឋា វិបាកវិនិច្ឆ័យជាផលទាំងឡាយអ្នកសំរាប់ផលទាំងឡាយដែលគេធ្វើអំពើ ។

## 273 - តើវិបាកវិនិច្ឆ័យរបស់មនុស្ស ត្រូវគេចែកជាប៉ុន្មានផ្នែក, គឺអ្វីខ្លះ ?



www.elibraryofcambodia.org

វិបាកនិច្ឆ័យរបស់មនុស្ស តាមអ្នកសង្គមវិទ្យា (Sociologue) បានចែកជាពីរផ្នែក :

១- ផ្នែកសីលវិជ្ជាដែលគេហៅថា "វិបាកនិច្ឆ័យសីលវិជ្ជា" (la sanction morale)

២- ផ្នែកសង្គមដែលគេហៅថា "វិបាកនិច្ឆ័យសង្គម" (la sanction sociale)

## 274 - អ្វីទៅហៅថាវិបាកនិច្ឆ័យសីលវិជ្ជា ?

ដែលហៅថាវិបាកនិច្ឆ័យសីលវិជ្ជា គឺវិបាកនិច្ឆ័យដែលមានលក្ខណៈដូចជាទំនួលខុសត្រូវនៃបុគ្គលម្នាក់ៗ ។ ជាសតិសម្បជញ្ញៈ របស់បុគ្គលមួយផ្នែកដែលនៅយកចិត្តទៅលើគុណសម្បត្តិនៃកុសល ។ គេមានវិបាកនិច្ឆ័យខាងសីលវិជ្ជាកាលណាគេសប្បាយរីករាយ ក្រោយដែលបានបំពេញករណីកិច្ចមួយ បានផលល្អប្រសើរសមតាមបំណង ឬគេមានវិប្បដិសារីកាលណាគេបានធ្វើនូវកំហុសអ្វីមួយត្រលប់បានគំនិតកើតជាកុសល ។

## 275 - អ្វីទៅហៅថា វិបាកនិច្ឆ័យសង្គម ?

ដែលហៅថាវិបាកនិច្ឆ័យសង្គម គឺវិបាកនិច្ឆ័យដែលមានលក្ខណៈដូចជា "ទំនួលខុសត្រូវវត្ថុវិស័យ" (la responsabilité objective) ។ ក្នុងន័យនេះវិបាកនិច្ឆ័យមានសភាពជាករណីយកិច្ច ឬជាកាតព្វកិច្ចរបស់បុគ្គលនីមួយៗ ចំពោះទំនួលខុសត្រូវសង្គម។ លទ្ធផលនៃវិបាកនិច្ឆ័យសង្គមគឺ



www.elibraryofcambodia.org

ផ្តល់ជារង្វាន់ ឬធ្វើទោសបុគ្គលនីមួយៗ ដែលបានចូលខ្លួនទៅនៅក្រោមការត្រួតត្រានៃច្បាប់សង្គម ។

ទាហានដែលចេញទៅសមរភូមិ ត្រូវទទួលវិបាកវិនិច្ឆ័យសង្គមដូចតទៅគឺ :

១ - គុណូបការជាគ្រឿងឥស្សរិយយស (Médaille) ចំពោះទាហានណាដែលបានទទួលជ័យជំនះក្នុងសង្គ្រាម ។

២ - ត្រូវជាប់គុក ឬត្រូវទោសប្រហារជីវិតចំពោះទាហានណាដែលរត់ចោលកងទ័ព ។ ល ។

## 276 - តើវិបាកវិនិច្ឆ័យ ត្រូវអ្នកប្រាជ្ញទាំងឡាយ សំគាល់ឃើញថាមានទ្រឹស្តីប៉ុន្មានបែប? តើទ្រឹស្តីនោះមានលក្ខណៈយ៉ាងដូចម្តេចខ្លះ ?

តាមការពិនិត្យរបស់អ្នកប្រាជ្ញសង្គមវិទ្យាវិបាកវិនិច្ឆ័យចេញមកពីសង្គមមនុស្សច្រើនជាងអ្វីទាំងអស់ ។ គេបានពិនិត្យឃើញថាមានទ្រឹស្តីវិបាកវិនិច្ឆ័យ ពីរបែបរបស់សង្គមមនុស្ស :

១ - សង្គមប្រពៃណីនិយម

២ - សង្គមវិវត្តន៍និតិសាស្ត្រ ។

១ - នៅក្នុងសង្គមប្រពៃណីនិយម គេច្រើនជឿថា "វិបាកវិនិច្ឆ័យ" ត្រូវផ្អែកទាំងស្រុងទៅលើ "សេរីភាព" គឺចេតនារម្មណ៍នៃអ្នកធ្វើអំពើ ។ ក៏ការវិនិច្ឆ័យតាមបែបសង្គមប្រពៃណីច្រើនផ្អែកទៅលើជំនឿនៃសង្គម "ដែលបញ្ចូលទ្រឹស្តី" របស់ខ្លួនពីផ្នែក "បរមត្ថវិជ្ជា" ។

ឧទាហរណ៍ : សង្គមអង់គ្លេសពីអតីតកាលបានធ្វើទណ្ឌកម្មទៅ



www.elibraryofcambodia.org

លើ "ស្រីខ្ទប់" ដោយចាប់យកទៅចងភ្ជាប់នឹងគុកទាំងរស់ ។ បុព្វហេតុ "ដោយគេមានជំនឿថា" ដើម្បីបញ្ឈប់អំពើអកុសលរបស់ស្រីខ្ទប់នេះ, គេត្រូវតែកប់ទាំងរស់ ។ បន្ទាប់មកគេត្រូវយកឈើយ៉ាងស្រួចទៅដោតចំកណ្ដាលដើមទ្រូងសាកសពនោះទៀត ។

ការដាក់ទោសដែលមានលក្ខណៈប្រតិកម្មនិយមនេះ ជាមធ្យោបាយយ៉ាងសក្តិសិទ្ធសំរាប់សង្គមអង់គ្លេស ។ នាសម័យនោះ អ្នកសង្គមវិទ្យាយល់ថាជាស្រីស្ដីមួយ ដែលសំរាប់បំភ័យកុំអោយ អ្នករៀនវេទមន្តអាក្រក់ (Magie noire) ដែលរេះធ្វើអំពើ (le maléfice) ដើម្បីសាងបាបកម្មរបស់ខ្លួនទៅលើអ្នកដទៃ-តទៅទៀត ។ ម្យ៉ាងទៀត វិបាកវិនិច្ឆ័យនេះ ចង់បង្ហាញអ្នកចង់សាងនូវក្រិដ្ឋកម្ម អោយរារែក ឬ ចង់ចប់សំធុះអកុសលកម្មទាំងនោះដោយអំពើចំពៃលកនេះ ។ ជាការមប់តាមវិបាកប្រតិកម្មនិយម ដែលគេជឿថា "ត្រូវតែធ្វើអាក្រក់ចំពោះមនុស្សអាក្រក់" (Rendre le mal pour le mal) ។

២ - ការប្រែប្រួលសង្គមវិវត្តន៍នីតិសាស្ត្រ វិបាកវិនិច្ឆ័យពេលទៅក្រោយវិវត្តន៍នីតិសាស្ត្រ គឺការរីកចំរើនរបស់ច្បាប់សង្គម ។ គេបានយកមនុស្សទៅកាត់ក (ឧទាហរណ៍: ស្ដេចបារាំងឈ្មោះ លូទី ១៦ ត្រូវរាស្ត្រដាក់ទណ្ឌកម្ម ដោយកាត់កនឹងម៉ាស៊ីន (Guillotine) ។ ប្រទេសអង់គ្លេសសម័យកណ្ដាល គេសំឡាប់មនុស្ស ដោយចងក្បាលកមុខទស្សនិកជនរាប់ម៉ឺននាក់ ។ ប្រទេសវៀតណាមសម័យខុត្តង្គ វិបាកវិនិច្ឆ័យត្រូវធ្វើឡើង



www.elibraryofcambodia.org

ដោយបណ្ដោយអ្នកជាប់ក៏រូ " ភាយសាស្ត្រាស " ដាក់ឈ្នាង ស្រែកអោយប្រជានុរាស្ត្របានស៊ីងត្រប់គ្នា ។ ក្នុងសម័យ ព្រះបាទរាមាជើងព្រៃ ទណ្ឌកម្មបានត្រូវគេធ្វើទៅលើមនុស្ស ដែលមានទោសស្រាល ជាមួយគ្នា: (ឧទាហរណ៍ : ឧកញ៉ាអភ្ញ៉ន ហ៊ានក្បត់នឹងរាជសារព្រះបាទរាមាជើងព្រៃ ដោយរៃរកសារនោះចោល ហើយបង្គាប់អោយគេយក ទៅទៅសំលាប់ ។ ក្រោយមកត្រូវស្ដេចបញ្ជាអោយចាប់ គ្រួសារអ្នកផ្ទូនមួយក្ដាំទៅសំលាប់ដោយកប់ត្រឹមក ហើយ កាប់រឹងនោះ ។ យើងឃើញថាវិធីកាត់ក្ដីនេះ ផ្អែក ទាំងស្រុងទៅលើច្បាប់របស់សង្គមនីមួយ ៗ ដែលពុំគួរទាល់ទូ ឥតដាច់ ។ ទៅសម័យសង្គមចាស់ចេក គេដាក់ទណ្ឌកម្មមនុស្ស ដែលជាប់ក៏រូដោយបង្ហាប់ទៅនឹងកៅអីអគ្គិសនី ។ ការ ធ្វើទណ្ឌកម្មទៅលើមនុស្ស ដែលច្បាប់សង្គមកំណត់ដូចខាងលើ ត្រូវអ្នកអក្សរសាស្ត្រម៉ាណ្យា ដែលគេហៅថា " មនុស្សធម៌ " សរសេរផ្ដាសាព្រមទាំងរិះគន់ទៀតពីការខ្វះសមត្ថភាព ក្នុង ការអប់រំមនុស្សអោយសាងកុសលនិងជៀសវាងឧក្រិដ្ឋកម្ម ។

* * *



www.elibraryofcambodia.org

# ១៥. ជីវិតផ្ទាល់ខ្លួន : គុណធម៌

(Vie personnelle : vertu)

## 277-អ្វីទៅហៅថា „ជីវិតផ្ទាល់ខ្លួន" ?

ដែលហៅថា «ជីវិតផ្ទាល់ខ្លួន» គឺគុណធម៌របស់បុគ្គលម្នាក់ៗចំពោះសង្គមដែលខ្លួនរស់នៅ ។ គុណធម៌នេះយ៉ាងតំរូវសំរាប់តែមនុស្សទាំងឡាយណា ដែលមានសតិភ្ញាក់ចា ប្រកបដោយកុសល ។

## 278-តើសង្គមមនុស្ស បានទទួលស្គាល់គុណធម៌ដែលជាអំពើរបស់មនុស្សដែរឬទេ? ឬក៏សង្គមមនុស្សបាននាំឆ្ងាយពីគុណធម៌ ប្រៀបដូចជាការរឹតបំពាននៃសេរីភាពរបស់មនុស្ស?

សង្គមមនុស្សបានជួយអោយកំលាំងទៅមនុស្ស. ក្រោមទាំងជួយធ្វើអោយបានសំរេចនូវ «ឧត្តមគតិ» ខ្លះរបស់មនុស្ស ។ សីលវិជ្ជាដែលយើងស្គាល់ថា ជាផ្នែកមួយនៃគុណធម៌របស់មនុស្សនោះ, បានញ៉ាំងមនុស្សអោយទទួលស្គាល់កុសលដោយភាពងាយស្រួល ។ មិនតែប៉ុណ្ណោះសោតសីលវិជ្ជាធ្វើមនុស្សក្នុងសង្គមអោយមានលក្ខណៈជាមនុស្សពិតប្រាកដ ។ គឺជួយនូវស្ថិរភាពនៃសីលវិជ្ជានិង ឧត្តមគតិបានទាំងស្រុងនូវអោយមនុស្សសំរេចបំណងធំៗរបស់ខ្លួន នៅក្នុងសង្គមនេះហើយ, បានជាមនុស្សស្គាល់កំលាំងកិច្ចរបស់ខ្លួន ក្រោមទាំងហ៊ានតតាំងចំពោះបញ្ហាផ្សេងៗ ។



www.elibraryofcambodia.org

ឧទាហរណ៍ ៖

១- មនុស្សសម័យបច្ចុប្បន្នបានតស៊ូដើម្បីរើសគូស្រករ ដោយខ្លួនឯង ។

២- មនុស្សអាចរើសមុខរបររបស់ខ្លួន ក្នុងសង្គម . ដោយពុំគោរពតាមរបៀបច្បាប់និងប្រពៃណីខ្លះដែលគេរៀបអោយមនុស្សទទួលអនុវត្តតាំងពីសម័យចាស់ ។

ឧទាហរណ៍ ៖ ក្នុងជាតិគ្រូព្រាហ្មណ៍ដែលមាននាទីគ្រូព្រះរាជវង្សស្តេច, ទទួលភារៈប្រោះព្រហ្មពិធីផ្សេងៗក្នុងរាជាធិបតេយ្យព្រហ្មញ្ញសាសនា, ត្រូវមានកូនប្រុសមួយប្រុសរបស់ខ្លួនអោយបន្តវេនតទៅទៀត ។ តែគេឃើញថាជិតកន្លះសតវត្សមកហើយនៅប្រទេសខ្មែរ កូនប្រុសបាគូបានជ្រើសរើសការងារដោយខ្លួនឯង, ហើយហ៊ានលុបចោលទំនៀមប្រពៃណីរបស់ខ្លួនដោយកាត់ផ្នួងសក់របស់គ្នាចោល ។ កូនចៅបាគូបានជ្រើសរើសការកាយកិច្ច ផ្តាច់ប្រពៃណីរបស់ខ្លួនដោយឥតញញើតញញើម ។ នេះជាភស្តុតាងបញ្ជាក់អោយឃើញថា មនុស្សបានកម្រើកបុគ្គលិកលក្ខណៈរបស់ខ្លួន គឺវត្តមានផ្លាស់ប្តូរ និងវឌ្ឍនភាព ។ មនុស្ស បច្ចុប្បន្នកាន់តែវិវត្តពីលក្ខណៈធម្មជាតិមកជាលក្ខណៈសកល ដូចជាហ៊ានទទួលខុសត្រូវលើការរើសតំណាងរបស់ខ្លួននៅក្នុងសង្គមដើម្បីត្រួតត្រា ។ល។

## 279- អ្វីទៅហៅថាគុណធម៌ពិត ?

គុណធម៌ពិត គឺសីលធម៌របស់បុគ្គលដែលមានមនោសញ្ចេតនារស់ ។



www.elibraryofcambodia.org

280- អ្វីទៅហៅថាសញ្ញាណនៃគុណធម៌ ?

(Qu'est-ce qu'une notion de la vertu?)

ដែលហៅថា "សញ្ញាណនៃគុណធម៌" គឺការប្រាប់ភាពពិតនៃគុណធម៌ , គឺការបង្ហាញប្រាប់ពីលក្ខណៈពិតនៃគុណធម៌ ឬក៏ថា "លក្ខណៈសច្ចៈរបស់គុណធម៌" ក៏បាន ។

281- អ្វីទៅហៅថាកំលាំងគុណធម៌ ?

ដែលហៅថា "កំលាំងគុណធម៌" គឺកំលាំងនៃចិត្តមនុស្សដែលញុំាងអោយសាងកុសល ។

លោកឡឺសែន (Le Senne) យល់ថា "គុណធម៌" គឺ "សេចក្ដីក្លាហានក្នុងការស្វែងរកកុសល" ។

ឯចំណែកលោករ៉ឺនូវៀ (Renouvier) យល់ថា "គុណធម៌គឺជាកំលាំងដែលមាន ការពិចារណា, ការជំនះគន្លង , សេរីភាព ភាពជាម្ចាស់នៃខ្លួនឯង" , ដំណើរនាំ ឬចំណាត់ចំណែងដោយខ្លួនឯង" (direction de soi)។ លោកដេការត (Descartes) យល់ថាគុណធម៌គឺ "ចិត្តបុណ្យ" (générosité) ។

នៅទីនេះ "គុណធម៌" គឺ "សេចក្ដីខ្ជាប់ខ្ជួន" (constance) "សេចក្ដីព្យាយាម" (persévérance) ឬជា "ទំលាប់នៃកុសល" ។ ខ្លះទៀតបានអោយនិយមន័យថា :

"គុណធម៌គឺជាឆន្ទៈច្បាស់លាស់ទៅក្នុងសីលចរិយា , ជាសំណាំចិត្តក្រោយដែលកើតមកពីការប្រឹងប្រែង ។

282- តើគុណធម៌មានលក្ខណៈដូចគ្នាឬទេ ? ហើយចែកចេញជាប៉ុន្មានបែប ?



www.elibraryofcambodia.org

គុណធម៌របស់មនុស្សមានច្រើនបែប - ច្រើនយ៉ាងណាស់ ហើយមានលក្ខណៈពុំដូចគ្នាទាំងអស់ទេ ។ ហេតុដូច្នេះហើយ បានជាគេភាគចែក "គុណធម៌" ជាពីរពួកផ្សេងគ្នាគឺ :

១ - គុណធម៌សាមញ្ញ

២ - គុណធម៌កំណើត

283- អ្វីទៅហៅថា "គុណធម៌" សាមញ្ញ ?

ដែលហៅថា "គុណធម៌សាមញ្ញ" គឺគុណធម៌ដែលបានមក ពីការប៉ុនប៉ង - និងការហ្វឹក ។

ឧទាហរណ៍: — ការទៀងពេល (ponctualité)

— ការចេះប្រមាណមិនអោយហួស (sobriété)

— ភក្តីភាព (loyauté)

— ភាពខ្ជាប់ខ្ជួន (constance)

— ការគួរសម (politesse) ។

284- អ្វីទៅហៅថា "គុណធម៌" កំណើត ?

ដែលហៅថា "គុណធម៌កំណើត" គឺ "គុណធម៌" ដែល មនុស្សបានទទួលមកតាំងពីក្នុងពោះមាតារបស់ខ្លួនមក ។

ឧទាហរណ៍ : — ចិត្តល្អ (la bonté)

— ភាពមិនរឹងរូស (docilité)

— ចិត្តសន្តោស - មេត្តា ។ល។

285- ចុះចំណែកលោក "អារិស្តូត" (Aristote(1)) បាន យល់ថាគួរចែក "គុណធម៌" ជាប៉ុន្មានក្រុម ?

លោកអារីស្តូត បានចែក "គុណធម៌" ជាពីរក្រុមធំៗ



www.elibraryofcambodia.org

១. គុណធម៌បញ្ញា (vertu intellectuelle) ។

២. សីលគុណធម៌ (vertu morale) ។

286- ដូច្នេះ តាមទស្សនលោក អារីស្តូត តើអ្វីទៅហៅថា គុណធម៌បញ្ញា ?

លោកអារីស្តូត, បានអោយនិយមន័យទៅលើពាក្យ "គុណធម៌បញ្ញា" ថា :

" ជាគុណធម៌ដែលធ្វើអោយបញ្ញាវិះគិត កាន់តែល្អឡើងរើយៗ សាងពុទ្ធិខាងលក្ខៈ "

ឧទាហរណ៍ : — សិល្បៈ (Art)

— ស្យន់ (Science)

— ការប្រុងប្រយ័ត្ន (La prudence)

— គតិបណ្ឌិត (la Sagesse)

— បញ្ញា (L' intelligence)

— ។ល។

287- អ្វីទៅហៅថា "សីលគុណធម៌" ?

លោកអារីស្តូតពោលថា :

«សីលគុណធម៌» គឺជាគុណធម៌ដែលមាននៅក្នុងទំលាប់ ដែលចេះគ្រប់សង្កត់លើសំទុះជំរុញវិចារណញ្ញាណ និងក្នុងទំលាប់ប្រព្រឹត្តអោយសមរម្យត្រឹមត្រូវ ទោះជានៅក្នុងស្ថានភាពណាក៏ដោយ ។

---

(១) អារីស្តូត (Aristote) ជាសាវ័ករបស់លោកប្លាតុង (Platon) ហើយត្រូវជា "សិស្សចៅ" របស់ "សូក្រាត" (Socrate) ។



www.elibraryofcambodia.org

ឧទាហរណ៍ : — សេចក្ដីក្លាហាន (Le courage)

— ការបេះប្រមាណ (La tempérance)

— យុត្តិធម៌ (La justice)

— គតិបណ្ឌិត (La sagesse)

— ។ល។

**288- តើក្នុងជំនឿសាសនា, គេអាចរកឃើញគុណធម៌អ្វីខ្លះទៀតក្រៅពីទស្សនៈលោកអារីស្តូត ?**

នៅក្នុងជំនឿផ្នែកគ្រិស្តសាសនា ព្រះសង្ឃព្រះនាម សាំងតូម៉ា (Saint Thomas) ក្រៅអំពីបានគាំទ្រទស្សនៈលោកអារីស្តូតមក, លោកបានបន្ថែមគុណធម៌ផ្សេងៗ ដូចតទៅនេះ:

១ - ជំនឿចំពោះព្រះគ្រិស្ត (La foi)

២ - ការសង្ឃឹម (L'espérance)

៣ - សប្បុរសធម៌ (La charité) ។

គុណធម៌ទាំងបីនេះ លោក "សាំងតូម៉ា" បានអោយឈ្មោះវិសមួយគឺ "គុណធម៌ទេវកម្មវត្ថុ" ។

នៅក្នុងជំនឿផ្នែកសាសនាមហាម៉ែត គុណធម៌គឺការលះបង់ចិត្តក្នុងការធ្វើ "អត្តពលី" (Sacrifice) គោលគឺការបូជាជីវិតថ្វាយព្រះអាឡាហ៍ ។

នៅក្នុងជំនឿផ្នែកព្រហ្មញ្ញសាសនា ក្រៅពីគុណធម៌សាមញ្ញធម្មតា គេបានសង្កេតឃើញការហាមធ្វើពិធីបូជា និងធ្វើតបៈធម៌ ហើយការគោរពស្មារតីទៅលើអាទិទេពអង្គណាមួយ ។ នៅក្នុងជំនឿផ្នែកព្រះពុទ្ធសាសនាគេបានឃើញ "គុណធម៌" គោលគឺព្រះបារមីទាំង៣០ដែលព្រះអង្គបានកសាងគ្រប់ៗជាតិ ។



www.elibraryofcambodia.org

ឧទាហរណ៍ : ( ទានបារមី - ទានឧបបារមី - ទានបរមត្ថ-
បារមី សីលបារមី - សីលឧបបារមី - សីលបរមត្ថបារមី - ។ល។

289- ក្រៅពីទ្រឹស្តីដែលហៅថា « គុណធម៌ » នេះ តើនៅមានគុណសម្បត្តិអ្វីទៀត ដែលអ្នកប្រាជ្ញបានអោយតំលៃថាប្រសើរជាង « គុណធម៌ »?

ក្រៅពីទ្រឹស្តីហៅថា « គុណធម៌ » នៅមានគំហើញរបស់មនុស្សជាច្រើនទៀតដែលអ្នកប្រាជ្ញយល់ថាមានតំលៃជាងគុណធម៌គឺ : ឧទាហរណ៍ :

-សុក្រឹតភាព ( perfection ) ឬភាពល្អឥតខ្ចោះ ។

-គុណូបការ ( mérite ) ឬ „ សីលតំលៃ „ ។ល។

290- អ្វីទៅហៅថាមនុស្សថ្លៃ? (Personnes de valeurs )

ដែលហៅថា „ មនុស្សថ្លៃ „ គឺមនុស្សទាំងឡាយណាដែលមានគុណធម៌ ឬគុណូបការៈសំខាន់ ឬខ្ពស់ដាច់គេ ។ ឧទាហរណ៍ : ទង្វើណាដែលផ្តល់អក្សរសាស្ត្របានអោយថា ទង្វើ ចំពោះគេ "មនុស្សថ្លៃ" ដូចជាលោក កាមុស, សាត្រ ដែលណាដាច់ ដ៏ សារ៉ាំងវិញ្ញូ ។ល។

តែចំពោះមនុស្សថ្លៃ គេបានចែកជាបីផ្នែកធំៗ ដើម្បីស្រួលចំណាំគឺ :

១- បណ្ឌិត (le sage)

២- វីរបុរស (le héros)

៣- សន្តបុគ្គល (le saint)

291- អ្វីទៅហៅថា "បណ្ឌិត" ( le sage )



www.elibraryofcambodia.org

បណ្ឌិតគឺ មនុស្សដែលមាន ចំណង់ទាញ (inspiration) ប្រកបដោយបញ្ញានិយម (intellectualisme) ។ មានរបៀបជីវិត (style de vie) ប្រកបដោយលំនឹង (équilibre) ។ មានឥរិយាបថធម្មជាតិ ស្របនឹងវិវត្តន៍ធម្មជាតិ ។ មានឥរិយាបថចំពោះទ្រើយភាព (attitude envers la sensibilité) មិនសូវកើតញាប់ញ័រហួសហេតុ ។ មានឥរិយាបថចំពោះអ្នកដទៃ ប្រកបដោយលក្ខណៈជាបុគ្គលនិយម (individualisme) ។ មិនគិតប្រយោជន៍ផ្ទាល់ខ្លួនហើយប្រកាន់ជឿថា គុណធម៌ជាគ្រឹះផ្ទាល់ខ្លួនរបស់បណ្ឌិត ។

292-អ្វីទៅហៅថា "វីរបុរស" ? (le héros)

វីរបុរស គឺមនុស្សដែលមានចំណង់ទាញប្រកបដោយសន្ទុះសភាវគតិ (élan instinctif) ។ មានរបៀបរស់នៅប្រកបដោយភាពក្លៀវក្លាហួសជនដទៃ ។ មានឥរិយាបថធម្មជាតិជាម្ចាស់លើធម្មជាតិ ។ មានឥរិយាបថចំពោះទ្រើយភាពប្រកបដោយលង់ងប់ (passion) មានឥរិយាបថចំពោះអ្នកដទៃជាបុគ្គលនិយមហួសហេតុ (ultra-individualisme) ហើយជាមនុស្សប្រកបដោយចិត្តបុណ្យ (générosité) ។

293-អ្វីទៅហៅថា "សន្តបុគ្គល" ?

សន្តបុគ្គលគឺមនុស្ស ដែលមានចំណង់ទាញប្រកបដោយជំនឿទៅលើសាសនា ។ មានរបៀបរស់នៅជាដរាបដែលស្វែងរកឥតឈប់ឈរនូវសុក្រិតភាព ។ មានឥរិយាបថធម្មជាតិជាអតិរេក (transcendance) ហើយយល់កិច្ចការទាំងអស់ដែលនៅក្រៅធម្មជាតិ ។ មានឥរិយាបថចំពោះទ្រើយភាពខុស



www.elibraryofcambodia.org

ផនផែន ពោលគឺវិរត្តិកបៈ (ascétisme) គេបរមសុខក្រៅលោក ។ ចំពោះពួកជេន, គេថាមនុស្សប្រកបដោយគំនិតអស្ចារ្យស្ម័យនឹងថាបុគ្គល ដែលមានបារម្គជាតិដ្ឋនៅលើសុគតិគត ។ សន្តុបុគ្គលច្រើនជាមនុស្សស្អប់លោកិយ ធុញនឹងលោកិយហើយដៀថា មានតែបរលោកទេ ដែលមានមុត្តិធម៌ពិត និងមានសុភមង្គលពិត ។

* * *



www.elibraryofcambodia.org

# ១៦. សិទ្ធិ និង ច្បាប់

## 294-អ្វីទៅហៅថា «ច្បាប់» ?

(Qu'est-ce que le droit ?)

អ្នកប្រាជ្ញឈ្មោះ ឡិបនិច (Leibniz) ពោលថា៖ «ច្បាប់គឺជាស័ព្ទអំណាចមួយ» ។ តែចំពោះអ្នកប្រាជ្ញខ្លះទៀតថា៖ "ច្បាប់ជាកំលាំង" ឧទាហរណ៍ : "ព្រះមហាទិទេពជាអ្នកបង្កើតលោក ព្រោះអង្គជាអ្នកផ្តល់នូវប្រយោជន៍និងអំណាចដែលជាកំលាំងចំពោះមនុស្សសព្វទាំងឡាយ, អ្នកណាទើបបុគ្គលមានអំណាចបំផុតជាងគេទាំងអស់, បុគ្គលក្រោយមានសិទ្ធិជំនួសគេដែរ" ។ លោកយ៉ាក់ខិនលោកហេហ្គែល ( Hegel ) ក៏អោយការគិត-និច្ឆ័យចំពោះនិយមន័យរបស់ "ច្បាប់" ថាជាកំលាំងដែរ ឧទាហរណ៍ : "ច្បាប់មិនមែនអ្វីក្រៅពីការលោភលន់របស់វិញ្ញាណនៃសង្គម ដែលមានច្បាប់ ជាអ្នកបកស្រាយផង" ។ លោកសូក្រាតយល់ថា :

"ច្បាប់ គឺអ្វីដែលមនុស្សកំណត់ទុកដំរូវមាតិទេពក្នុងការរកយុត្តិធម៌" តែចំពោះលោកសូក្រាត (Socrate) ច្បាប់របស់មនុស្សជាពិសេស "ច្បាប់វិជ្ជមាន" (lois positives) ដែលបង្កើតដោយមនុស្ស, សុទ្ធតែខ្វះគតិយុត្តិធម៌ទាំងអស់។ ចំពោះលោកសូក្រាត "ច្បាប់ដែលបង្កើតដោយសំពីទៅក្រុមជាកំលាំងដែលពោរពេញទៅដោយអយុត្តិធម៌ ហើយមានតែច្បាប់មាតិទេពប៉ុណ្ណោះទេដែលយុត្តិធម៌" ។

ប៉ុន្តែជាទូទៅគេច្រើនអោយនិយមន័យទៅលើ "ច្បាប់" ថា "និយាយជាគោលក្តីច្បាស់លាស់បំផុតរបស់មនុស្ស សំរាប់ការពារ



www.elibraryofcambodia.org

សិទ្ធិ និង សេរីភាព ដែលធម្មជាតិបានសំពិតសំអាងឡើង ដើម្បីជីវិតរស់នៅនៃសត្វលោកទូទៅ» ។

អ្នកប្រាជ្ញខ្លះទៀតអោយនិយមន័យទៅលើ "ច្បាប់" ថា៖ "អ្វីដែលហាមនិងការពារមនុស្ស" ហេតុនេះហើយបានជាគេឮមានពាក្យថា "រំលោភ ច្បាប់ធ្វើទោស ,គោរព ច្បាប់ជួយការពារ» (Violer la loi frappe, respecter la loi protège) ។ នៅក្នុងន័យនេះ យើងបានឮថា៖ "ច្បាប់មាននិម្មិតភាពជាវិជ្ជមានផង និង អវិជ្ជមានផង» (Aspect négatif et positif du droit)

295-អ្វីទៅហៅថា «ច្បាប់ធម្មជាតិ» ?

ដែលហៅថាច្បាប់ធម្មជាតិ គឺច្បាប់ដែលកើតមកតំណាលនឹងវិចារណញ្ញាណនៃមនុស្ស ។ គឺជាកេតនភណ្ឌដែលមនុស្សបានទទួលជាពិសេសពីធម្មជាតិ ។ ចំពោះអ្នកប្រាជ្ញឈ្មោះ ស៊ីសេរ៉ុង (Sicéron) យល់ថា : "ច្បាប់ធម្មជាតិជានិយាមឧត្តមបំផុត (Suprême) ដែលថាំតែនៅក្នុងធម្មជាតិ» ឯចំណែកលោកក្រូស្ស៊ីស (Crotius) ពោលថា៖ "ច្បាប់ធម្មជាតិជានិយាមមួយដែលមានគំនិតចេញមកពីវិចារណញ្ញាណត្រឹមត្រូវ, ជាអំពើដែលមានសីលលក្ខណៈឬអយុត្តិធម៌ផ្លាស់ប្តូរទៅតាមធម្មជាតិប្រកបដោយវិចារណញ្ញាណ» ។

296-តើអ្នកប្រាជ្ញឈ្មោះអ្វីដែលបានពោលថា៖ «ច្បាប់ជាផលនៃសង្គម» ? តាមគំនិតនេះ តើច្បាប់មានទំនាក់ទំនងទៅនឹងសង្គមមនុស្សយ៉ាងដូចម្តេចខ្លះ ?

លោក ឌួកហ៊ីម (Durkheim) ជាអ្នកសង្គមវិទ្យាដែលហ៊ានពោលថា "ច្បាប់ជាផលនៃសង្គម» ។ នៅក្នុងន័យនេះ



www.elibraryofcambodia.org

លោក ឌូគីត ថែមទៀតថា "ច្បាប់គឺជានិយាមរបស់សង្គម ដូចជាពិធីបុណ្យ ទំនៀមទំលាប់ប្រពៃណីជាដើម សុទ្ធសឹងតែមានលក្ខណៈដូចច្បាប់ដែរ ។ ប៉ុន្តែ លោកឌូគីត ក៏បានថ្លែងបញ្ជាក់ទៀតថា "សង្គមពិតប្រាកដតែងតែកំណត់ទៅដោយគុណវិបត្តិ និងសេចក្តីអាក្រក់" ។

ហេតុដូច្នេះហើយ បានជាយើងឃើញថា ច្បាប់ជួនជានិយាមសង្គមមួយដែលមិនស្របនឹងគោលការណ៍នៃយុត្តិធម៌ និងសេចក្តីអាក្រក់ ។ ឧទាហរណ៍ៈ "សូក្រាតត្រូវបានគេយកច្បាប់យុត្តិធម៌កាត់ទោស ព្រមទាំងបង្ខំឲ្យលេបថ្នាំពុលស៊ីក (ciguë) ។ ដោយសារច្បាប់ គឺជាផលរបស់សង្គមនេះហើយ បានជាច្បាប់បានចាត់ទុកនូវសីលធម៌របស់ខ្លួនបន្តិចម្តងៗ ។ ហេតុក្លាយទៅជាឧបករណ៍សំរាប់ស្បានការទំនុកចិត្តទៅលើសិទ្ធិមនុស្ស ។ ឧទាហរណ៍ៈ សង្គមអាល្លឺម៉ង់សម័យសង្គ្រាមលោកលើកទីពីរ បានបង្កើតច្បាប់សម្លាប់រង្គាលទៅលើជនជាតិជ្វីហ្វ (Juif) ។ ច្បាប់នេះជាផលរបស់សង្គមអាល្លឺម៉ង់សម័យនោះ បង្កើតដោយលោកហ៊ីត្លែរ (Hitler) ដើម្បីសងសឹកដូចស្របជាជាតិអាល្លឺម៉ង់ដែលស្អប់ជ្វីហ្វបានសម្លាប់ជនជាតិនេះអស់ការណ៍ ជាយូរណាស់មកហើយ ។

ច្បាប់របស់ប្រទេសមានលក្ខណៈសង្គមប្រវត្តិ, ផ្ទុយទៅវិញ មនុស្សធម៌, ហើយគេឃើញថាច្បាប់នេះត្រូវគោរពដោយអាល្លឺម៉ង់សម័យនោះទាំងស្រុងវាំងប្រទេស ។ ដែលជាហេតុសំរាប់យើងឃើញថា "ច្បាប់ជានិយាមរបស់សង្គម និងជាផលនៃសង្គមនីមួយៗ ដែលមានលក្ខណៈពេលវេលាទៅតាមវិវត្តន៍របស់សង្គមនិងស្ថានភាពនយោបាយសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ។

*

* *



www.elibraryofcambodia.org

# ១៧. គ្រួសារ

(La Famille)

297- អ្វីទៅហៅថា " គ្រួសារ "?

គ្រួសារ គឺមនុស្សមួយក្រុម ដែលបានរួមរស់នៅក្រោមដំបូលផ្ទះជាមួយគ្នា ។ ឧទាហរណ៍ៈ ប្ដី-ប្រពន្ធ-កូន ។ល។ ឬជាសមាជិកជាញាតិវង្ស ដែលមករួមរស់នៅក្នុងផ្ទះជាមួយគ្នា ។ ហេតុនេះបានអ្នកប្រាជ្ញខ្លះតែងសន្មតឲ្យហៅថា " គ្រួសារជាកោសិការស់ (Cellule vivante) នៃសង្គម ។

298- តើពីបុរាណកាល សម័យដែលមនុស្សមានពុទ្ធិ (La Connaissance) ពុំទាន់ផុះផុល, គេច្រើនស្គាល់អ្វីថាជាគ្រួសារ ?

ពីបុរាណកាល សម័យដែលមនុស្សមានពុទ្ធិពុំទាន់ផុះផុល គេច្រើនស្គាល់ថាជាគ្រួសារនូវ " បក្សសម្ព័ន្ធនៃតូតិម " (Clan totémique) គឺពួកមនុស្សមួយក្រុមដែលជឿថាគេមានខ្សែស្រឡាយមានកំណើតជាមួយគ្នា ។ គេបានលើកយកសត្វ រូបតំណាងខ្លួនគេនោះឡើងធ្វើជាទីគោរពបូជារួមគ្នា ។ ក៏ប៉ុន្តែ គេបានសង្កេតឃើញថា កំណើតរបស់តូតិមនោះក្នុងគ្រួសារនៃកុលសម្ព័ន្ធសម័យបុរាណ ឬ នៅលើដីជាច្រើនពាន់នៃពិភពលោកសម័យបច្ចុប្បន្ន មានសក្តិពលខ្លាំងជាងកំណើតសាច់ឈាមពិតរបស់គ្រួសារឈាមណាស់ ។ លោកហ្វ្រេស៊ើ (Frazer) បានបញ្ជាក់ក្នុងសៀវភៅរបស់គាត់ថា:

" កំណាត់ដែលបង្កើតឡើងដោយនិមិត្តរូបតូតិម (Totem)



www.elibraryofcambodia.org

មានឥទ្ធិពលខ្លាំងក្លាជាងចំណងសាច់សាលោហិត និងចំណងគ្រួសារ» ។ (Le lien créé par le totem est plus fort que le lien de sang ou de famille)

## 299- តើពាក្យថា "តូតឹម" (Totem) មានប្រភពពីណាមក?

ពាក្យ "តូតឹម" ជាពាក្យរបស់ពួកឥណ្ឌាក្រហមរស់នៅក្នុងទ្វីបអាមេរិកខាងជើង សំរាប់សំគាល់រូបតំណាងរបស់ខ្លួន ដែលសាងឡើងដោយឈើបញ្ឈរណាមួយ មានសភាពជាបដិមាសសសោរ ហើយមានរូបផ្សេងៗ ។ ពាក្យ "តូតឹម" ត្រូវអ្នកប្រាជ្ញខាងជនជាតិវិទ្យា (Ethnologue) ម្នាក់ជាតិអង់គ្លេសឈ្មោះ J. ឡុង (J-Long) យកមកប្រើមុនគេក្នុងសៀវភៅ នៅឆ្នាំ ១៧៩១ ។

## 300- ក្នុងសម័យបច្ចុប្បន្ននេះ, តើកុលសម្ព័ន្ធណាដែលបានរស់ក្នុងសភាព "តូតឹម" នៅឡើយ?

ក្នុងបច្ចុប្បន្នកាលនេះតូតឹមនៅមាននៅឡើយក្នុងពិភពលោក គឺកុលសម្ព័ន្ធនៅប្រទេសអូស្ត្រាលី, ពួកឥណ្ឌាក្រហមនៅទ្វីបអាមេរិកខាងជើង, កោះនៅប្រជុំទ្វីបប៉ូលីណេស៊ី, នៅប្រទេសឥណ្ឌាភាគខាងកើត, នៅក្នុងទ្វីបអាហ្វ្រិក និងទ្វីបអាស៊ីអាគ្នេយ៍ ។

## 301- តើនៅក្នុងលោក របបនាសម្ព័ន្ធនៃគ្រួសារនិមួយៗដូចគ្នាឬទេ?

នៅក្នុងសកលលោក គ្រួសារនិមួយៗមានរបបនាសម្ព័ន្ធមិនដូចគ្នាទេ ។ គ្រួសារខ្លះជឿថាម្ដាយជាអ្នកបង្កើតវង្សត្រកូល ។



www.elibraryofcambodia.org

ក្នុងគេហដ្ឋានខាងប្រពន្ធ ដូចជាព្រះអាទិទេពក្រុមទាំងបួន
ប្រគល់អំណាចគ្រួសារក្នុងគ្រួសារទៅអោយម្តាយគ្រប់គ្រង ។
បន្ទាប់មក គេសាងរូបម្តាយរបស់គេជាតំណាងរូបនៃព្រះអាទិទេព
ដែលគេហៅថា "ក្ងីម" ។

គ្រួសារប្រភេទនេះ គេហៅថាគ្រួសារបែបម្តាយ (famille matriarcale) ។

គ្រួសារប្រភេទនេះជឿថាឪពុកជា ជាអ្នកបន្តកេរ្តិ៍ត្រកូល ។ គេណែនាំសាងរូបឪពុកទុកជាភូមិ, ក្រោយមកទុកឪពុកជាធំនៅក្នុងគ្រួសារ ហើយដែលគេហៅថា ៖

"គ្រួសារបែបឪពុក" (famille paternelle) មាននៅក្នុងគ្រួសារដែលនិយមទុកឪពុកជាធំ គេឃើញមានគ្រួសាររ៉ូម៉ាំង (famille de type romain), គ្រួសារអាល្លឺម៉ង់ (famille germanique) ។ល។

302- អ្វីទៅហៅថា "អាពាហ៍ពិពាហ៍" ?

ដែលហៅថា "អាពាហ៍ពិពាហ៍" គឺការផ្សំផ្គុំយ៉ាងឧឡារិក, ជាផ្លូវការរវាងប្រុសម្នាក់និងស្រីម្នាក់ ដើម្បីបង្កើតគ្រួសារថ្មីមួយទៀត ។ គឺជាពិធីមួយក្នុងចំណោមពិធីសំខាន់ៗរបស់ច្បាប់សង្គមមនុស្ស ដើម្បីបញ្ជាក់ជាផ្លូវការពីទំនាក់ស្នេហារវាងប្រុសម្នាក់និងស្រីម្នាក់ ។

303- តើការប្រកាសជាឱឡារិកដោយពិធីមួយដើម្បីបញ្ជាក់ពីទំនាក់ស្នេហារវាងស្រីម្នាក់និងប្រុសម្នាក់ នៅក្នុងសង្គមមនុស្សត្រូវមានលក្ខខណ្ឌអ្វីខ្លះជាចាំបាច់ ?



www.elibraryofcambodia.org

ពិធីប្រកាសចំណងស្នេហា ជាផ្លូវការដែលគេនិយមហៅថា "អាពាហ៍ពិពាហ៍" នោះ ត្រូវទទួលថាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន ។ លុះត្រាតែសាមីខ្លួនប្រុសនិងស្រីមានបំពេញលក្ខខណ្ឌខ្លះដូចតទៅនេះ ៖

១ - លក្ខខណ្ឌសម្ភារៈ (conditions matérielles)

២ - លក្ខខណ្ឌវេទនា (conditions affectives)

៣ - លក្ខខណ្ឌសង្គម (conditions sociales)

៤ - លក្ខខណ្ឌសីលវិជ្ជា (conditions morales) ។

## 304- អ្វីទៅហៅថា « លក្ខខណ្ឌសម្ភារៈ » នៅក្នុងអាពាហ៍ពិពាហ៍ ?

ដែលហៅថា "លក្ខខណ្ឌសម្ភារៈ នៅក្នុងអាពាហ៍ពិពាហ៍គឺ:

១ - សាមីខ្លួនទាំងប្រុសស្រី ត្រូវមានសុខភាពគ្រប់គ្រាន់ ។

២ - ត្រូវមានរបរចិញ្ចឹមជីវិតដើម្បីសាងគ្រួសារដោយខ្លួនឯង ។

៣ - ត្រូវមានធនធាន ឬប្រាក់កាសគ្រប់គ្រាន់ដើម្បី ធ្វើជាថ្លៃដែលមានលក្ខណៈជាគុណធម៌សម្ភារៈសំរាប់ជូន ទៅខាងស្រី ( ចំណងដៃ , បណ្ណាការ និង គ្រឿងបញ្ចាំចិត្ត ) ។

៤ - សម្ភារៈគ្រាប់ទីតដោះ ។ នៅសង្គមបុរាណគេច្រើនដាក់គិតឱ្យកូនប្រុសទៅរករបស់ដែលមានតំលៃ ដើម្បីជាថ្នូរទឹកដោះដូនមាតាខាងកូនស្រីដែលត្រូវការ ឬ វង្សត្រកូលខ្លះដាក់ទុកថាជាការកក់ចិត្តគិតសំរាប់ជាតំលៃគ្រួសារគេ ។

ឧទាហរណ៍ ៖ កូនប្រុសខ្លះត្រូវមានសមត្ថភាព និងបញ្ញាវាងវៃ ដើម្បីនាំទ្រព្យសម្បត្តិជាច្រើន វិលនាំកម្លាយខាងស្រីបញ្ចា



www.elibraryofcambodia.org

អោយគេ ។ ដូចជាត្រូវជួយក្មេងក្រ ដែលកំព្រាអោយបាន ទាន់ពេលវេលា ។ ល ។

៥- ជួនកាល សម្ពាធៈអាចក្លាយទៅជាលទ្ធភាពផ្ទាល់របស់ សាមីខ្លួន ប្រុស ឬស្រីថែមទៀតផង ។

ឧទាហរណ៍ : ព្រះកាយត្រូវលើកទូលរបស់ ព្រះបាទជនក្មួយ ទើបបាននាងសិលាដាចហាសិ ។

នាងរីតាណាម៉ាត្រូវគេចាត់ថាជាក្ខនដ៏ខ្ពង់បាន ទើបអាចអភិសេកជាមួយនិងព្រះរាជបុត្រល្អបាន ។

សង្គមសម័យបច្ចុប្បន្ន, កូនប្រុសត្រូវមានសញ្ញាប័ត្រខ្ពង់ខ្ពស់, ទ្រព្យសម្បត្តិ ឬ គុណសម្បត្តិណាមួយដែលមានតំលៃជាសម្ពាធៈ ទើបអាចរៀបអាពាហ៍ពិពាហ៍និងកូនស្រីរបស់អភិជនណាម្នាក់បាន ។

## 305- អ្វីទៅហៅថាលក្ខខណ្ឌវេទនា ?

ដែលហៅថា « លក្ខខណ្ឌវេទនា » គឺលក្ខខណ្ឌមួយដែលសង្គមកំរូវអោយ សាមីខ្លួនប្រុស និង ស្រីមានសេចក្ដីស្នេហារវាងគ្នាទៅវិញទៅមកផង ។ គូស្វាមីភរិយាកុំត្រូវទទួលការតំរូវកំរិតផងក៏សំណាក់មាតាបិតារបស់ខ្លួនឡើយ ។ ហេតុដូច្នេះហើយបានជាក្នុងពិធីអាពាហ៍ពិពាហ៍ « មេឃុំ » ត្រូវសួរជានិច្ចរកចំពោះភ្ញៀវ គឺចិត្តរបស់គូស្វាមីភរិយាទាំងពីរជាមុនសិន ដើម្បីបញ្ជាក់ពីវេទនា ( affectivité ) ក្នុងសេចក្ដីស្នេហារបស់អ្នកទាំងពីរនេះ ។

ឧទាហរណ៍ : មេឃុំត្រូវសួរថា :



www.elibraryofcambodia.org

អោយទៀតសំរាប់តំកើងសោភ័ណ្ឌ ទៅលើកាយខ្លួនដោយ ផ្ទៃមនុស្សផង ។ ហើយសំណាង ចំពោះបរទេស ជួន កាលត្រូវបញ្ចាក់ជាទេសចរ និងជាចំនួនប្រាក់ថែមទៀតផង ។

### 308- អ្វីទៅហៅថា " ជាតិប្រមាណ " ? ( La Natalité)

ដែលហៅថា "ជាតិប្រមាណ" គឺការត្រួតពិនិត្យនូវស្ថិតិនៃកំណើតរបស់មនុស្ស នៅក្នុងខេត្ត - ប្រទេសនីមួយៗ ។ ជាតិប្រមាណជាវិធានការណ៍ របស់បញ្ហានយោបាយ និងសេដ្ឋកិច្ច ។ គេត្រូវការ ចង់ដឹងចំនួន មនុស្សកើត, មនុស្សដែលកំពុងរស់នៅដោយបញ្ជាក់នូវភេទរបស់មនុស្ស ទៅតាមលំដាប់អាយុដូចជាត្រូវថែងថា : មនុស្សចាស់ , មនុស្សពេញវ័យ , មនុស្សជំទង់ , កូនក្មេង ។ ល ។

ចំនួនមនុស្សស្លាប់ក៏ជាមុខងារនៃការស្រាវជ្រាវនៃ ជាតិប្រមាណដែរ ។ សង្គមមនុស្សត្រូវការ ចង់ដឹងចំនួនសមាជិករបស់ខ្លួនយ៉ាងក្រិតក្រៅបំផុត ដើម្បីរៀបចំផែនការសម្ព័ន្ធសង្គមនយោបាយ , សេដ្ឋកិច្ច និងអប់រំអោយស្របទៅតាមកាលសម័យនិងកាលៈទេសៈនៃសតវត្ស ។

*

* *



www.elibraryofcambodia.org

# ១៨. យុត្តិធម៌ និង ការគោរពបុគ្គល- សប្បុរសធម៌

(La Justice et le respect de la personne. La charité)

## 309- អ្វីទៅហៅថា « យុត្តិធម៌ » ?

យុត្តិធម៌គឺគុណធម៌ប្រកបដោយឧត្តមគតិសង្គម, ដាក់និងធ្វើ ត្រឹមត្រូវតែគោរពនូវអ្វីដែលបុរេចេញមកពីវិចារណញ្ញាណ មនុស្សជាតិ ។ ខ្លួនការ « យុត្តិធម៌ » មានគឺយល់ន័យថា :

« ការគោរពយ៉ាងទៀងទាត់នូវសិទ្ធិរបស់ជនម្នាក់ៗ ពោលគឺការបើកឱកាសឲ្យជនម្នាក់ៗ មានសិទ្ធិរបស់ខ្លួន » ។

## 310- តើយុត្តិធម៌អាចចែកជាប៉ុន្មានសណ្ឋាន ?

យុត្តិធម៌អាចចែកជាបីសណ្ឋានគឺ :

១- យុត្តិធម៌ក្នុងការដូរ

២- យុត្តិធម៌ក្នុងការចែក

៣- យុត្តិធម៌ក្នុងការបង្គាប់

## 311- អ្វីទៅហៅថា « យុត្តិធម៌ » ក្នុងការដូរ ?

ដែលហៅថា « យុត្តិធម៌ក្នុងការដូរ » គឺភាពត្រឹមត្រូវឥតលំអៀងក្នុងការដូរ ។ គេអាចពោលថាការដូរមានយុត្តិធម៌ជានិច្ចកាល កាលណាអ្នកដូរ យករបស់ពីរដែលមានតម្លៃស្មើគ្នាមកដូរ ។ គឺយុត្តិធម៌ស្ថិតនៅលើសមមូល ( équivalence ) នៃតម្លៃវត្ថុដែលដូរនោះឯង ។



www.elibraryofcambodia.org

312- អ្វីទៅហៅថា «យុត្តិធម៌ក្នុងការចែក» ?

ដែលហៅថា "យុត្តិធម៌ក្នុងការចែក" គឺយុត្តិធម៌ដែលមនុស្សទាំងឡាយទទួលស្គាល់ថា ត្រឹមត្រូវនៅពេលដែលខ្លួនបានទទួលរង្វាន់ជាថ្នូរនឹងកំលាំង - ស្នាដៃ - និងកំរិតការរបស់ខ្លួន ។ គឺជាចំណែកដែលគេបានទទួលអំពីដៃនៃមនុស្សយុត្តិធម៌ម្នាក់ ឬពីច្បាប់នៃសង្គមរបស់ខ្លួន ។

313 - អ្វីទៅហៅថា "យុត្តិធម៌ក្នុងការបង្ក្រាប" ?

ដែលហៅថា "យុត្តិធម៌ក្នុងការបង្ក្រាប" គឺជាយុត្តិធម៌ដែលមានលក្ខណៈជាសមភាពលេខនព្វន្ត ។ ជាការបង្ក្រាបមួយបែបដែលចាប់អ្នកមានកំហុស អោយទទួលកំហុស ឬ សងជំងឺចិត្តដល់ជនរងគ្រោះអោយស្មើនឹងទំងន់នៃកំហុសខ្លួន ។ លោក តាល្យុំង យល់ថា "បើជនណាធ្វើអោយខូចភ្នែកអ្នកដទៃត្រូវតែខូចភ្នែករបស់ខ្លួនមកវិញ, ឬបើជនណាធ្វើអោយគេបាក់ធ្មេញត្រូវតែគេបាក់ធ្មេញទៅគេវិញ " ហេតុដូច្នេះហើយបានជាគេតែងនិយាយពេលកាលពីយុត្តិធម៌ បង្ក្រាបរបស់លោកតាល្យុំងដែលតែងជាច្បាប់ថា : "យកភ្នែកទៅសងភ្នែក, យកធ្មេញទៅសងធ្មេញ" តែបច្ចុប្បន្នកាលនេះច្បាប់បានកំរិតអោយគេបញ្ជាយ ផ្សេងពីលោកតាល្យុំង គឺសងតែលុយខូចខាតដោយភាពផ្សេងៗគ្នាតែសមគួរនឹងកំរិតជាជនរងការខូចចិត្ត នៃអ្នករងគ្រោះនោះ ។

314 - តើហេតុមកដល់សព្វថ្ងៃនេះ យុត្តិធម៌ពិតកើតមាននៅក្នុងសង្គមមនុស្សឬទេ?



www.elibraryofcambodia.org

សព្វថ្ងៃនេះយុត្តិធម៌ពិតក៏ពុំកើតមាននៅក្នុងលោកទេ ។ ព្រោះគេពុំឃើញមានរបៀបច្បាស់នៃគំរូទាំងឡាយ ដែលជារូបមន្តនៃយុត្តិធម៌នេះសោះ ។

ឧទាហរណ៍: ទោះក្រមក្នុងវិធានច្បាប់យុត្តិធម៌ពិតប្រាកដយកការគិតឡើយ ។ លោកសូក្រាត មហាទស្សនៈវិទូក្រិកស្លាប់ដោយពិសថ្នាំពុល . ក៏មិនស្គាល់ដោយច្បាប់នៃប្រទេសក្រិកទេ ។ លោករូសូបានទុកស្នាដៃពិសេសរបស់លោកស្ដីពី “វិសមភាព” (l'inégalité) នៃសង្គមមនុស្សសម័យសតវត្សទី ១៨ ហើយដែលមានរូបភាពថា សមាជិកក្នុងសង្គមនោះជាមួយគេដែរ ។ មតិនេះយល់ឃើញថា, “មនុស្សមានវិសមភាពទាំង ពីកំណើតមកម៉្លេះព្រោះមនុស្ស ជាសត្វលោកដែលរស់នៅក្នុងធម្មជាតិ, ហើយធម្មជាតិនេះឯងជាប្រភពនៃ “វិសមភាព” ដែលគេហៅថា “វិសមភាពធម្មជាតិ (inégalité naturelle) ។ ឧទាហរណ៍ : វិសមភាពនៃកាយនិងសម្បទាដូចជាសុខភាព , បញ្ញានិង ឥរិយាបថរបស់មនុស្សដែលមានពីកំណើតមក ។ ក៏ប៉ុន្តែមតិនេះ បានយល់ច្រឡំថាច្បាប់ទាំងអស់សុទ្ធតែយុត្តិធម៌, គឺអ្វីដែលចេញ ពីច្បាប់សុទ្ធតែយុត្តិធម៌ទាំងអស់ ។ លោកប្លាតុង (Platon) សាវ័ករបស់សូក្រាតគោលអះអាងថា , មានតែច្បាប់របស់អាទិទេពប៉ុណ្ណោះទេដែលមានយុត្តិធម៌ពិតប្រាកដ, ហើយ យុត្តិធម៌ដែលជា “ពុទ្ធិសច្ចៈ” នោះស្ថិតនៅតែក្នុង “ឧត្ដមាទិទេព” ឯណោះទេ ។

ថ្វីត្បិតតែសង្គមទាំងឡាយក្នុងសកលលោក ចាំបាច់មានសណ្ដាប់នៃការរស់នៅរបស់មនុស្សអោយមានយុត្តិធម៌ក្ដី, ក៏



www.elibraryofcambodia.org

ប៉ុន្តែគេនៅតែសង្កេតឃើញថា « មនុស្សដែលជាអ្នកប្រព្រឹត្ត នូវអំពើទាំងឡាយ បានរំលោភលើកិច្ចសន្យារបស់ខ្លួន ព្រម ទាំងហ៊ានបំពានបំពានលើសេរីភាពនិងសិទ្ធិរបស់មនុស្សដែល ច្បាប់បានកំណត់អោយនោះផងដែល ។ សរុបសេចក្តីមក, « អយុត្តិធម៌ក្នុងសង្គមក្តី, ក្នុងបុគ្គលក្តី សុទ្ធតែកើតមកពីមនុស្ស ច្រើនណាស់អន្តរជាតិ, ព្រោះថាមនុស្សបរិភោគមនោសញ្ចេតនា ផង, បរិភោគមហិច្ឆតាផង ។

## 315-អ្វីហៅថា « សប្បុរសធម៌ » ?

ពាក្យដែលហៅថាសប្បុរសធម៌ គឺគុណធម៌ពិសេសរបស់មនុស្ស ទាំងឡាយ ណាដែលមានចិត្តល្អនឹងមនុស្សឯទៀត ។

ជនដែលមានចិត្តសប្បុរស, ជាជនដែលមានគុណៈប្រកប ដោយខន្តីចំពោះមនុស្សជាតិ, មានសន្តិភាពនិងចិត្តប្រណី មេត្តា ( persévérance ) ។

## 316-គេបានពោលថា " ការធ្វើទានជាអំពើប្រកបដោយ លក្ខណៈអយុត្តិធម៌ក្នុងសង្គម ។ តើអ្នកយល់យ៉ាងដូច ម្តេចចំពោះមតិនេះ ?

ច្បាប់សប្បុរសធម៌បានបង្ហាញនៅក្នុងសីលធម៌ថា អោយជន ទាំងឡាយធ្វើទាន ។ ទោះបីទាននោះតិច ឬច្រើនក្តី, ល្អ ឬ ពុំល្អដែលជាគាប់ប្រសើរក្តី ក៏គេនិយមអោយគំនិតទៅលើទឹក ចិត្តសប្បុរសធម៌នេះណាស់ ។

ការជួយសង្គ្រោះអ្នកក្រីក្រក់សត់ទុគ៌ត ដោយផ្តល់អោយ នូវគ្រឿងឧបភោគបរិភោគ, សំលៀកបំពាក់ ថ្នាំពេទ្យ និង



www.elibraryofcambodia.org

ទិសដៅ ដើម្បី ស្គាល់អាស្រ័យជាសក្តិភាពបញ្ជាក់អោយពេញ នូវគំនិតសប្បុរសធម៌, ព្រោះថាសិលវិជ្ជាក្តី, ច្បាប់សង្គមក្តី ពុំបានដាក់កំហុសទៅលើអំពើល្អ ដែលគេទាក់ទុកថា ជាឧត្តមគតិមនុស្សជាតិនេះសោះឡើយ ។

ក៏ប៉ុន្តែ, មានគំនិតមួយទៀត ដែលគេលើកអះអាងថា ស្គាល់គំនិតគិតរបស់មនុស្ស នោះទិទៀនចំពោះសប្បុរសធម៌នេះទៅវិញ ។ មតិនោះបានជឿថា, ការទទួលអោយស្គាល់អាស្រ័យក្តី, ការអត់អោន ដោយទានអនុស្រ័យ, ការសង្គ្រោះ (assistance) ការប្រណីមេត្តាក្តី សុទ្ធតែជាសញ្ញាគតានៃគំរូការរបស់យុត្តិធម៌ ។ គោលគឺពុំមែនជាយុត្តិធម៌របស់សង្គមលោកពិតប្រាកដទេ, តែជាគ្រឿងក្លែងបន្លំសំរាប់សាងការជិះជាន់គេទៅទៀត ។ គេបានសន្មតថា អ្វីដែលមិនយុត្តិធម៌ គឺអយុត្តិធម៌, បើអយុត្តិធម៌ហើយ សុទ្ធតែនុសនឹងច្បាប់មនុស្សជាតិទាំងអស់ ។ គេជឿថា ការធ្វើទានដែលជនណាម្នាក់ ធ្វើទៅលើស្មូមយាយចាស់មួយរូប, នឹងនាំអោយស្មូមយាយចាស់នោះ មានការអាម៉ាស់មុខជាទីបំផុត, ហើយអ្នកធ្វើទាន ជាមនុស្សកំណាចទៅវិញ, ព្រោះបានធ្វើគេអោយអាម៉ាស់មុខចំពោះសង្គមមនុស្ស ។

មនុស្សនោះបានបញ្ជាក់ថា ពួកអ្នកក្រីក្រជាបន្ទុករបស់សង្គម, ដូចនេះសង្គមត្រូវតែធ្វើច្បាប់សំរាប់ជួយពួកទាំងនោះអោយជិតដល់ ប្រៀបដូចមាតាដែលមានភារៈត្រូវតែចិញ្ចឹមកូនរបស់ខ្លួនយ៉ាងដូច្នេះដែរ ។ ការបណ្តោយអោយមនុស្សក្រជើរសុំទាន, ការពុំគិតបញ្ហារបស់មនុស្សទាំងឡាយដែល



www.elibraryofcambodia.org

ជាសមាជិកក្នុងសង្គមរបស់ខ្លួន ជាអំពើអយុត្តិធម៌ដែល «ច្បាប់ត្រៃ» របស់អាទិទេពផ្តន្ទាទោសអ្នកកាន់អំណាចនៅសង្គមនោះដោយពុំអាចប្រកែកបាន ។

ទស្សនៈដែលពោលមកខាងលើនេះ ជាច្បាប់របស់មនុស្សម្នាក់ៗ ដែលបានទទួលមរតកពីធម្មជាតិ នូវសិទ្ធិរបស់ខ្លួន-ហើយសិទ្ធិនេះត្រូវតែលើកខ្ពស់ជាងច្បាប់សង្គមណា ដែលទទួលស្គាល់ថា «មនុស្សទាំងអស់មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់» តែផ្ទុយទៅវិញ សង្គមនោះបានព្រានិយកត្តិយនិងសមាជិករបស់ខ្លួនចំពោះសេរីភាពនិងការរស់នៅរបស់បុគ្គលទៅវិញ ។

* * *



www.elibraryofcambodia.org

# ១៩. បញ្ហាសេដ្ឋកិច្ច

(Problème économique)

317 - អ្វីទៅហៅថា «សេដ្ឋកិច្ច» ?

ដែលហៅថា "សេដ្ឋកិច្ច" គឺសិល្បៈដ៏ប្រសើរក្នុងការចាត់ចែងចំណូលនិងចំណាយនៅក្នុងគ្រួសារ, ការចាយវាយនិងរកចូលមកវិញយ៉ាងប្រសព្វនៃថវិកា សម្បត្តិទ្រព្យ ឬបរិភោគភ័ណ្ឌរបស់បុគ្គលណាម្នាក់ ឬរដ្ឋ ប្រទេសណាមួយ ។

318 - តើសញ្ញាណនៃ "សេដ្ឋកិច្ច" នៅបច្ចិមប្រទេស គេយល់ថាកើតមកពីអ្វី ?

សញ្ញាណនៃសេដ្ឋកិច្ច នៅបច្ចិមប្រទេស, គេយល់ថាកើតមកពីគំនិតសាសនាគ្រិស្ត គឺគេបានជឿថា គណៈសង្ឃនៃសាសនាគ្រិស្ត បានអោយកំណើតបង្កើតនូវទ្រឹស្តីពីរយ៉ាងគឺ: ទ្រឹស្តីតំលៃត្រឹមត្រូវ (théorie du juste prix) និងទ្រឹស្តីពីការប្រាក់ត្រឹមត្រូវ (théorie du juste intérêt) ។

319 - អ្វីទៅហៅថា "សេដ្ឋកិច្ចនយោបាយ" ?

ដែលហៅថា សេដ្ឋកិច្ចនយោបាយ គឺសាស្ត្រដែលនិយាយពីពុទ្ធិនៃបាតុភូត (connaissance des phénomènes) ការរកចាយ, ចំរោះការនិងប្រើប្រាស់ទ្រព្យធម្មជាតិ ឬពុទ្ធិនៃបាតុភូត ដែលសិក្សាពីភោគភ័ណ្ឌសម្ភារៈ នៅក្នុងសង្គមមនុស្ស ។

320 - តើសេដ្ឋកិច្ចនយោបាយ មានកម្មវិធីសិក្សាយ៉ាងដូចម្តេចខ្លះ ?



www.elibraryofcambodia.org

សេដ្ឋកិច្ចនយោបាយមានកម្មវិធីសិក្សាដូចតទៅ ៖

១- តំរូវការនិងកត្តាទាំងឡាយនៃផលិតកម្ម ។

២- ការរៀបចំនូវផលិតកម្មតាមបែបសកល ។

៣- ការជំនួញ ឬ ទិញដូរ ភោគផល ។

៤- តំលៃផ្សេងៗនៃផលិតកម្ម ។

៥- អំពីដើមទុន ។

៦- ប្រាក់សំរាប់ចាយ ឬ រូបិយវត្ថុ ។

៧- របៀបចែកចាយនូវផលិតផល ។

៨- មុខនាទីនៃរដ្ឋាភិបាលក្នុងការផលិត, ចែកចាយនិងប្រើប្រាស់គ្រឿងឧបភោគ បរិភោគ ឬ ភោគផលទាំងនោះ ។

321- តាមទស្សនៈអ្នកសេដ្ឋកិច្ចសេរីនិយម (économiste-libéraliste) អ្វីទៅហៅថា " សេដ្ឋកិច្ចនយោបាយ " ?

ពួកអ្នកសេដ្ឋកិច្ចសេរីនិយម បានអោយនិយមន័យ ទៅលើ « សេដ្ឋកិច្ចនយោបាយ » ថា :

" ការសិក្សាអំពីច្បាប់ខាងការបង្កើតផល, ខាងចែកនិងប្រើប្រាស់ ភោគទ្រព្យផ្សេងៗ " នេះជានិយមន័យរបស់លោក សង់-បាប់ទីស-សៃ (Jean - Baptiste Say) (១៧៦៧ - ១៨៣២) អ្នកសេដ្ឋកិច្ចជាតិបារាំងម្នាក់ ។

322- ចុះចំពោះពួកសេដ្ឋកិច្ចសង្គមនិយម (économiste socialiste) វិញ. តើយល់យ៉ាងដូចម្តេចដែរ, ចំពោះពាក្យថា " សេដ្ឋកិច្ច នយោបាយ " ។



www.elibraryofcambodia.org

ចំពោះពួកអ្នកសេដ្ឋកិច្ចសង្គមនិយមយល់ថា "សេដ្ឋកិច្ចនយោបាយ គឺការសិក្សាអំពីសកម្មភាពមនុស្សក្នុងការផលិត សកម្មភាពនេះ ទាក់ទងជាមួយនឹងភោគទ្រព្យផ្សេងៗ" ។

## 305- តើអ្វីទៅហៅថា "សេដ្ឋកិច្ចមនុស្ស" ?

ដែលហៅថា "សេដ្ឋកិច្ចមនុស្ស" គឺ "សេដ្ឋកិច្ចនយោបាយ ដែលសិក្សាតែក្នុងវិស័យតែពីផលទាំងឡាយរបស់មនុស្ស" ។

ឧទាហរណ៍ :

(ទីលំនៅ - ជីវភាពគ្រួសារ - ល័ក្ខខ័ណ្ឌនៃការងារ សុភមង្គល ។ល។)

## 304- តើអ្វីទៅហៅថា "សេដ្ឋកិច្ចសង្គម" ?

ដែលហៅថា "សេដ្ឋកិច្ចសង្គម" គឺ "សំណុំកត្តាដែលទាក់ទងនឹងជីវភាពរស់កម្មករ - កសិករ ជាមួយនឹងការលើកស្ទួយជីវភាពនៃអ្នកទាំងអស់នេះ" ។ នៅដើមសតវត្សទី២០ "សេដ្ឋកិច្ចសង្គម" មានលក្ខណៈថា "សកម្មភាពនៃសេដ្ឋកិច្ច, សំណុំទ្រព្យដែលទាក់ទងនឹងការបង្កើនផល ការបែងចែកនិងការប្រើប្រាស់នៃភោគផលទាំងនោះ" ។

## 305- តើសេដ្ឋកិច្ចនយោបាយ មានទំនាក់ទំនងជាមួយនឹងសីលវិជ្ជាឬទេ ? ហេតុអ្វី ?

សេដ្ឋកិច្ចនយោបាយ មានទំនាក់ទំនងជាមួយនឹងសីលវិជ្ជា កាលណាសេដ្ឋកិច្ចនយោបាយនោះជាឧបករណ៍ សំរាប់បំពើទ្រឹស្តី ឬគោលបន្ទាត់នយោបាយនៃរដ្ឋណាមួយ ។ ពិតមែនហើយថា "សេដ្ឋកិច្ចនយោបាយគឺជាសម្រង់ដែលសិក្សាភ័ក្ត្រ



www.elibraryofcambodia.org

នៃចាតុក្ខរបស់ផលិតកម្ម - ការចែកចាយអោយប្រើប្រាស់នូវគ្រឿងឧបភោគ បរិភោគ, ក៏ប៉ុន្តែត្រូវតែនេះឯងមានចាតុក្ខផលិតកម្មទាក់ទងជានិច្ចទៅនឹងមនុស្ស នៅក្នុងសង្គមរបស់ខ្លួនដែលមានជីវភាពរស់នៅក្នុងសំណុំនោះដែរ ។

ដូចនេះសិលវិជ្ជា ពុំអាចនឹងគេចរួចពីការសង្កត់សង្កិននៃសេដ្ឋកិច្ចនយោបាយបានឡើយ, កាលណាស្បង់នេះជាឧបករណ៍ប្រើប្រាស់នៃលទ្ធិណាមួយ ។ អាស្រ័យហេតុនេះហើយ បានជាគេឃើញសេដ្ឋកិច្ចនយោបាយស្ថិតនៅក្រោមបញ្ជារបស់ "នយោបាយសេដ្ឋកិច្ច" ហើយដែលជាប្រភពកើតអោយមាន ស្បង់សេដ្ឋកិច្ចពីរប្រភេទសំរាប់បំរើនយោបាយសេដ្ឋកិច្ចពីរគឺ: សេដ្ឋកិច្ចសេរីនិយម(économie libéraliste) និងសេដ្ឋកិច្ចសង្គមនិយម (économie socialiste) នេះឯង ។

## 326- អ្វីទៅហៅថា " នយោបាយសេដ្ឋកិច្ច " ?

ដែលហៅថា "នយោបាយសេដ្ឋកិច្ច" (Politique économique) គឺនយោបាយដែលជួយដោះស្រាយបញ្ហារស់នៅរបស់មនុស្សក្នុងសង្គមណាមួយ, ដោយយកយន្ត, វិធានការនិងបច្ចេកទេសនៃសេដ្ឋកិច្ច មកកែតំរង់, មានយកច្បាប់នៃ "សេដ្ឋកិច្ចនយោបាយ" ជាដើម មកពិនិត្យសារឡើងវិញ ដើម្បីលើកស្ទួយកំរិតជីវភាពនៃប្រជាពលរដ្ឋ ។

## 327- អ្វីទៅហៅថា " សេរីនិយមសេដ្ឋកិច្ច " ?

ដែលហៅថា "សេរីនិយមសេដ្ឋកិច្ច" គឺសេដ្ឋកិច្ចដែលបើកសេរីភាពអោយឯកជនទិញដូរ និងលក់ទៅវិញ នូវភោគផល



www.elibraryofcambodia.org

ផ្សេងៗតាមអំពើចិត្ត , ហើយធ្វើឲ្យគ្មានអំណាច ចូលទៅត្រួតត្រា ជ្រែកក្នុងការប្រកបកិច្ចការតែលេចឯង ; លក់របស់ឯកជនទៀត ។ ជាទ្រឹស្ដីដែលបង្កើតដោយពួកមូលធន (Capitalistes) ។

328- អ្វីទៅហៅថា "សង្គមនិយមសេដ្ឋកិច្ច" ?

ដែលហៅថា "សង្គមនិយមសេដ្ឋកិច្ច" គឺសេដ្ឋកិច្ចដែលកើតឡើងដោយលោក "កាលម៉ាក់" (KARL-MARX) ជាតិអាល្លឺម៉ង់នៅអំឡុងសតវត្សទី ១៩ ។ ជាសេដ្ឋកិច្ចដែលបង្កើតប្រយោជន៍នៃសមូហភាពដល់មនុស្សទាំងអស់ (Intérêt collectif) ដោយប្រគល់អំណាចទៅឲ្យរដ្ឋកាន់កាប់សេដ្ឋកិច្ច ទូទៅជំនួសឯកជន - គោល គឺរដ្ឋជានាយទុន (Etat patron) ។

329- តើទ្រឹស្ដីសង្គមនិយមសំខាន់ៗ នៅក្នុងលោកមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ទ្រឹស្ដីសង្គមនិយមសំខាន់ៗ នៅក្នុងលោកមានបីយ៉ាងគឺ :

១- ទ្រឹស្ដីសង្គមនិយមហួសវិស័យ ឬទ្រឹស្ដីកុម្មុយនិស :
(socialisme utopique ou communisme)

២- ទ្រឹស្ដីសង្គមនិយមក្លាស៊ិចទាំងមូល :
(socialisme classique intégral)

៣- ទ្រឹស្ដីសង្គមនិយមក្លាស៊ិចគួរ
(socialisme classique mitigé) ។

330- អ្វីទៅហៅថា "សង្គមនិយមហួសវិស័យ ឬកុម្មុយនិស"?



www.elibraryofcambodia.org

ដែលហៅថា «សង្គមនិយមបូសវិស័យ ឬ កុំមុយនីស» គឺលទ្ធិ «រួមសំបាច់និយម» លទ្ធិដែលប្រគល់ការធានាគ្រប់បែបយ៉ាងទៅអោយរដ្ឋទាក់ទែង ព្រមទាំងទទួលស្គាល់ថា កម្មសិទ្ធិទាំងអស់ជារបស់រដ្ឋ» ។

331- អ្វីទៅហៅថា «សង្គមនិយមក្លាស៊ិចទាំងមូល» ?

ដែលហៅថា «សង្គមនិយមក្លាស៊ិចទាំងមូល» គឺជារបបមួយ ដែលទទួលអោយរដ្ឋធានាការរស់នៅរបស់ប្រជាជនទាំងមូលកែលម្អអោយរដ្ឋប្រគល់កម្មសិទ្ធិខ្លះ មកប្រជាជនវិញ គឺដូចជា : ម្ហូបអាហារ - សំលៀកបំពាក់. ផ្ទះសំរាប់នៅ ។ល។

332 - អ្វីទៅហៅ «សង្គមនិយមក្លាស៊ិចថ្មី» ?

ដែលហៅថា «ទ្រឹស្ដីសង្គមនិយមក្លាស៊ិចថ្មី» គឺ ទ្រឹស្ដីដែលទទួលអោយរដ្ឋធ្វើជាម្ចាស់លើលោហក្រាសធំៗ ទាំងអស់, ហើយស្នូចអោយរដ្ឋពិនិត្យមើលអោយបានជិតដល់លើជីវភាពនៃកម្មករ - កសិករ និងសំរួលជីវភាពរស់នៅនៃជនទាំងអស់នោះផង ។

333- គេបានឮដឹងថា «បញ្ហាសេដ្ឋកិច្ច» នៅក្នុងពិភពលោក បានចោទឡើងយ៉ាងខ្លាំងចំពោះប្រទេសទាំងអស់ ។ តើមូលហេតុនៃបញ្ហាសេដ្ឋកិច្ចនេះ កើតមកពីណា ? តើបណ្តាលអោយមានវិបាកអ្វីខ្លះ ?

បញ្ហាសេដ្ឋកិច្ចនៅក្នុងពិភពលោក, បានក្លាយទៅជាជម្ងឺសាហាវបំផុត ដែលគេពុំអាចនឹងរកឲ្យសង្ឃឹមព្យាបាលបានឡើយ ។ ជម្ងឺនេះ, បានក្លាយទៅជាវិបត្តិសង្គមនៃប្រទេស-



www.elibraryofcambodia.org

និមួយៗ ហើយដែលគេអាចនឹងដោះស្រាយទៅបាន លុះ ត្រាតែគេយកទៅដោះស្រាយនៅលើឆាកពិភពលោក ។ មូល ហេតុនៃបញ្ហាសេដ្ឋកិច្ចដ៏ធំបណ្ដាលមកពី «វឌ្ឍនភាពនៃតិច និច, និងការប្រើម៉ាស៊ីន» (la mécanisation) ពោលគឺ ផលិតផលដែលបានមកពីការប្រើម៉ាស៊ីន បានឡើងកំរិតហួស ពីសេចក្ដីត្រូវការនៃប្រជាជន, ហេតុបណ្ដាលអោយទៅជា សម្បូរពេកលើសលប់ហោល (la surproduction) ហើយ ពេលនោះ បញ្ហាផ្សារសំរាប់លក់ឧបភោគ, បរិភោគនិង គ្រឿងប្រើប្រាស់សព្វសារពើក៏បានកើតឡើង ។ ប្រទេស ខ្លះដែលធ្លាប់តែជាអ្នកទិញ, ក៏ស្រាប់តែក្លាយទៅជាអ្នកលក់ វិញ ។ បញ្ហាមួយទៀត គឺប្រទេសដែលធ្លាប់លក់ពុំព្រមសុខ ចិត្តនឹងចំណេញដល់ប្រទេសដែលធ្លាប់ទិញ ដែលក្លាយទៅ ជាអ្នកលក់នោះនោះ, ព្រោះប្រទេសនិមួយៗត្រូវការរក្សា វិបុលភាព (prospérité) និងរក្សាជញ្ជីងពាណិជ្ជកម្ម (balance commerciale) ជាតិខ្លួន ។ ការកំរោល ភោគផលបានធ្វើអោយប្រទេសខ្លះហ៊ានដេញថ្លៃ គឺលក់ ផលិតផលយ៉ាងថោកនៅក្នុងផ្សារតែមួយ, ហើយពេលនោះ ជំលោះក៏កើតមានឡើងរវាងប្រទេសមហាអំណាចផ្សេង ៗ បញ្ហាសេដ្ឋកិច្ចនេះ ជាប្រភពនៃបញ្ហានយោបាយ, ព្រោះ ថាប្រទេសដែលមានសេដ្ឋកិច្ចខ្លាំងក្លាបានស្វែងរកស្រាវគុណ ប្រយោជន៍ខាងផ្លូវសិលវិជ្ជា, ក្នុងគោលបំណងបង្ហាញកិត្យា នុភាពរបស់ខ្លួនដោយផ្ដល់ជាជំនួយផ្សេងៗ ដល់ប្រទេសជិត ខាងដែលជាប្រទេសក្រ ដែលអន់ខ្សោយខាងសេដ្ឋកិច្ច



www.elibraryofcambodia.org

(lutte des prestiges ou potlachs) ជាដើម ។ ក៏ប៉ុន្តែ ពេលនោះមកហើយ ដែលគេឃើញកើតមានបក្សសម្ពន្ធ ប្រយុទ្ធនឹងគ្នាយ៉ាងក្នុងពិភពលោក ។

334- តើការងារមានគុណសម្បត្តិអ្វីខ្លះ ? ចូរស្រង់យកទស្សនវិចាររបស់អ្នកប្រាជ្ញមកពន្យល់ ។

អ្នកប្រាជ្ញជាច្រើនបានលើកយកតំលៃនៃការងារ ។ អ្នកខ្លះបានពោលថា "ការងារជាប្រភពនៃសាមគ្គីធម៌» (លោក ម៉ូកវីយ) ។ ការងារជា«ចំណងសំរាប់ចងមនុស្សអោយរួបរួម ដោយស្មោះស្ម័គ្រជាមួយប្រុសប្រុសស្រាវខ្លួន» ។ អ្នកខ្លះទៀតបាន ពោលថា "ការងារផ្ដល់នូវសេចក្ដីថ្លៃថ្នូរ ហើយត្រូវតែរមែងជា ថ្នាក់ផ្ទៃសុភមង្គល ។ លោក «ស្ពិនស៊ែ» (Spencer) ពោលថា «ការងារជាសកម្មភាពស័ក្ដិសិទ្ធិដែលនាំអោយទឹក ឃើញនូវកំលាំងរបស់ខ្លួន» ។ លោក "ប៊េសុន" ថ្លែងថា : "ការងារជាកំណើតនៃប្រាជ្ញារបស់មនុស្ស សំរាប់បញ្ជាក អោយឃើញគុណៈ រូបិយវត្ថុ និងសេរីភាពពេញលេញ» ។

ចំណែកឯលោក «ដេកាត» (Descartes) វិញ «ការងារ ធ្វើអោយមនុស្សទៅជាម្ចាស់ និងជាអ្នកគ្រប់គ្រងធម្មជាតិ» ។ លោក "ម៉ុកស៊ែល" ពោលថា : «ការងារគឺជាការរំដោះ មនុស្សចេញពីធម្មជាតិដ៏វិញក្លូនអោយមានសេរីភាព» ។ ចំណែកឯលោក "ការ៉ល់ម៉ាក" ថ្លែងថា : "ការងារជាការរួម សម្ពន្ធបរិយាកាសទាំងឡាយដែលមនុស្សបង្កើត» ។ សរុប សេចក្ដីមក «ការងារជាភារកិច្ចរបស់មនុស្សទាំងអស់នៅ



www.elibraryofcambodia.org

កំរោងការ , ជាប្រភពនៃវិសមភាពនិងការកេងប្រវ័ញ្ចការងារ របស់មនុស្ស , គឺ ជាឧបាយកម្មជាតិដែលគេប្រើឲ្យមនុស្សអោយ បន្តការរស់នៅរបស់ខ្លួនតាមកម្មសិទ្ធិឯកជន ។ គឺជាដើម កិលេស ដែលបណ្តាលមនុស្សអោយក្លាយជាចោរ និង ព្រោះថាវិស្វ័យភាពនិងល្អកម្មសិទ្ធិនេះនឹងកើតការសំរេច ។ ត្រូវ ការចែករំលែកកិច្ចការមានកំរិតរបស់ល្អ " ។

335- អ្វីទៅហៅថា " កម្មសិទ្ធិឯកជន " ?

ដែលហៅថា " កម្មសិទ្ធិឯកជន " គឺកម្មសិទ្ធិដែលបុគ្គលម្នាក់ មានសិទ្ធិដាច់មុខក្នុងការប្រើប្រាស់ , ចាយវាយ , ឬទាញផល ប្រយោជន៍ផ្សេងៗពីវត្ថុទាំងឡាយណាដែលខ្លួនមាន ។

336- តើកម្មសិទ្ធិដែលមាន លក្ខណៈជាមូលធន , បានមក ដោយវិធីណាខ្លះ ?

កម្មសិទ្ធិមូលធន កើតបានមកពីវិធីសំខាន់បីយ៉ាងគឺ:

១- ដោយសារការកេងកាប់ គេរកទ្រព្យសម្បត្តិដែលអ្នកដទៃ យកមកធ្វើជាកម្មសិទ្ធិ , ដូចជាកម្មសិទ្ធិ លើដីធ្លី ឬ ស្រែ ភ្នំ ទន្លេ ព្រៃព្រឹក្សា ។ ល ។

២- ដោយសារការចំរើនកម្មសិទ្ធិដែលមានលក្ខណៈជា ការកេងប្រវ័ញ្ចតៗគ្នា ឬ ចាប់យកដោយប្រយោលពីកំលាំង របស់កម្មករ ។

៣- ដោយសារមរតក ដែលម្ចាស់កម្មសិទ្ធិ បានទទួលពីឪពុក ម្តាយ ឬ ជីដូន ជីតារបស់ខ្លួនមក ។

337- អ្វីទៅហៅថា " បញ្ហាសង្គមកិច្ច " ?



www.elibraryofcambodia.org

ដែលហៅថា "បញ្ហាសង្គមកិច្ច" គឺបញ្ហាដែលទាក់ទងទៅនិងជីវភាពរបស់មនុស្សទាំងឡាយដែលជាសមាជិកនៃសង្គមនោះ ។ បញ្ហានេះមានទិដ្ឋភាពសំខាន់ពីរយ៉ាងគឺ :

- ទិដ្ឋភាពសេដ្ឋកិច្ច, សំរាប់ធានាដល់ការចិញ្ចឹមជីវិតនៃសមាជិកសង្គម ។
- ទិដ្ឋភាពសីលវិជ្ជា, សំរាប់ការពារយុត្តិធម៌ និងសិទ្ធិនៃទង្វើរបស់សមាជិកសង្គម, ដែលត្រូវទាមទារអោយអ្នកដឹកនាំសង្គមនោះជួយសំរួលបញ្ហាសំនៅរបស់ខ្លួនផង ។

*

* *



www.elibraryofcambodia.org

# ២០ - បញ្ហានយោបាយ
# រដ្ឋ-ប្រជាជាតិ-មាតុប្រទេស

(Problème politique : l'Etat, la nation, la patrie)

338- អ្វីហៅថា " រដ្ឋ " ?

- គេបានអោយនិយមន័យរដ្ឋទៅតាមទំនោររបស់ ទស្សនគតិដែលខ្លួនបញ្ជាក់នូវភាពណាមួយ ដែលមានស្ថាប័ននិងដំណើរនយោបាយត្រឹមត្រូវ ។ ខ្លះថា "រដ្ឋជាសង្គមសរុបទាំងមូល" ។ ខ្លះទៀតពោលថា "រដ្ឋគឺអង្គការមួយ ដែលមានសមាសភាពដូចតទៅ :

អង្គការរណ៍ , អង្គការតុលាការ និង បក្សនយោបាយនៃអ្នកទាំងពីរក្រុមនោះ ។ ដើម្បីបញ្ជាក់ពីចេតនាសម្គាល់ ដែលមាននៅក្នុងសង្គមនៃភាពណាមួយក្រនោះ ខ្លះបានអោយនិយមន័យថា "រដ្ឋ គឺជាអង្គការប្រមូលផ្តុំនៅអង្គការប៉ូលិស អង្គការរដ្ឋបាល , អង្គការតុលាការ , និងអង្គការនយោបាយ ។ ខ្លះទៀតបានប្រៀបធៀបរដ្ឋទៅនឹងសង្គម ដោយពោលថា "រដ្ឋជាខួរក្បាលនៃសង្គម" ។ តាមពិត រដ្ឋគឺ "អាណាចក្រមួយដែលមានអ្នកដឹកនាំនិងពលរដ្ឋ ប្រកបដោយអង្គការបួនគឺ : អង្គការនយោបាយ , អង្គការសេដ្ឋកិច្ច , អង្គការរដ្ឋបាល និងអង្គការតុលាការ ។

339- តើរដ្ឋវិទូយោបាន "អនុគមន៍" ដ៏ចាំបាច់ប៉ុន្មាន ? គឺអ្វីខ្លះ ?



www.elibraryofcambodia.org

រដ្ឋនិមួយៗត្រូវមានអនុគមន៍ជាចាំបាច់បីគឺ :

អនុគមន៍សាសនា (fonctions religieuses)

បឋមអនុគមន៍ (fonction primaire)

ទុតិយានុគមន៍ (fonction secondaire) ។

អនុគមន៍សាសនា មានភារៈរៀបចំនិងបណ្តុះបណ្តាលអត្ថការសាសនាអោយស្របទៅតាមគន្លងរាស្ត្រភាគច្រើន ។

បឋមអនុគមន៍មានភារៈរៀបចំអំណាចបី នៅក្នុងការគ្រប់គ្រងអោយប្រកបដោយយុត្តិធម៌ ដោយបង្កើតជាអង្គការសំរាប់បំពេញអំណាចនោះ ។ អំណាចទាំងបីនោះគឺ :

អំណាចនីតិបញ្ញត្តិ (pouvoir législatif)

អំណាចនីតិប្រតិបត្តិ (pouvoir exécutif)

អំណាចតុលាការ (pouvoir judiciaire)

ទុតិយានុគមន៍ មានភារៈការពារ, ឧបត្ថម្ភ និង ទទួលបន្ទុកខាងអក្សរសាស្ត្រនិងសិល្បៈគីឡាធម៌ប្រជាជាតិ និងសេដ្ឋកិច្ចសន្តិសុខ - អនាម័យ ។ល។

## 340- អ្វីទៅហៅថា "សេរីភាព" ?

សេរីភាពគឺជាបេតិកភណ្ឌរបស់ធម្មជាតិ (នេះជាសំដីរបស់លោករូសូ) ។ លោករូសូពោលថា : "មនុស្សកើតមកមានសេរីភាពតែម្តង (l' homme est né libre)" ។ ហេតុដូច្នេះហើយបានជាលោករូសូពោលថា : (សូមកុំអោយរដ្ឋបំពាល់ដល់សេរីភាពធម្មជាតិរបស់មនុស្ស) ។

ឯចំណែកលោកម៉ុងតេស្គីយើពោលថា "សេរីភាព គឺជាលទ្ធផលនៃការគោរពបទបញ្ញា" មានសេចក្តីថា "ដើម្បីគោរពសេរីភាព



www.elibraryofcambodia.org

ផងម្នាក់ៗ  អោយបានត្រឹមត្រូវ  កុំអោយសិទ្ធិមនុស្សម្នាក់ទៅជាន់ឈ្លីសិទ្ធិមនុស្សម្នាក់ទៀតបាន  មនុស្សទាំងអស់ត្រូវប្រគល់អំណាចទៅលើខ្លួន  ដើម្បីរៀបចំអោយបានជាបក្សារួម ហើយដែលមានមនុស្សទាំងអស់នោះ  ជាអ្នកទទួលបញ្ជាវិញ ។

341- អ្វីហៅថា " លទ្ធិប្រជាធិបតេយ្យ " ?

(La Démocratie)

ដែលហៅថាលទ្ធិប្រជាធិបតេយ្យ  គឺលទ្ធិដែលរាស្ត្រជាម្ចាស់នៃអំណាច ។ ក្នុងឋានៈជាម្ចាស់នៃអំណាច  រាស្ត្រមានភារកិច្ចរើសអ្នកតំណាងរបស់ខ្លួន  ដើម្បីបង្កើតច្បាប់អនុវត្តដែលជាវគ្គមកកិច្ចទៅប្រកបដោយ :

សមភាព,  សេរីភាព,  ភាតរភាព,  វឌ្ឍនភាពនិងសុភមង្គល ។

342- អ្វីទៅហៅថា "លទ្ធិផ្តាច់ការ" ?

(Absolutisme ou totalitarisme)

ដែលហៅថា «លទ្ធិផ្តាច់ការ»  គឺលទ្ធិជារបបក័ត្តដែលរដ្ឋមានអំណាចផ្តាច់ការ ។ លទ្ធិផ្តាច់ការតំរូវអោយរាស្ត្រគោរពអ្នកដឹកនាំម្នាក់ដែលមានអំណាចខ្ពស់អាទិទេព,  ជារាជាធិបតេយ្យដែលអាចសំរេចនិងធ្វើអ្វីបានតាមចិត្ត ។ ជាលទ្ធិដែលគ្មានសេរីភាព,  សមភាពនិងភាតរភាព,  ប្រកាសអំណាចចេញមកពីឧត្តមៈនៃបុគ្គលម្នាក់ ឬ មួយក្រុម ។

343- អ្វីហៅថា "អនាធិបតេយ្យនិយម" ?

(Anarchisme)



www.elibraryofcambodia.org

ដែលហៅថា «មូលាធិបតេយ្យនិយម» គឺលទ្ធិមួយដែលទាមទារអោយមនុស្សទាំងអស់មានសេរីភាព សេរីខាងការចំណេញ ឬ ការបង្កើនទ្រព្យរបស់ខ្លួន ។ ជាលទ្ធិដែលបើកអោយក្រុមហ៊ុនសង្គមនីមួយៗ មានសិទ្ធិប្រកួតប្រជែងនឹងអាជ្ញាធររបស់រដ្ឋវិញបាន កាលណាអាជ្ញាធរនៃរដ្ឋនោះ ជាឧបករណ៍នៃលទ្ធិផ្តាច់ការ ។ ក្នុងមូលាធិបតេយ្យនិយម អោយគំនិតទៅលើធម្មជាតិ មនុស្សដែលគេជឿថាមានសភាវគតិខ្ពង់ខ្ពស់លើសលុបជាងអ្វីទាំងអស់ ។ ក្នុងមូលាធិបតេយ្យនិយមប្រឆាំងនឹងជាតិនិយមនិងលទ្ធិរបស់រដ្ឋ ដែលមានលក្ខណៈជាការបង្ខិតបង្ខំ ឬ វិធានវិនិច្ឆ័យ ។

## 344- អ្វីហៅថា "ទ្រឹស្តីទេវវិជ្ជា" ?

(théorie théologique)

ដែលហៅថាទ្រឹស្តីទេវវិជ្ជា គឺទ្រឹស្តីដែលនិយាយពីអំណាចទេពនៃព្រះជាម្ចាស់, ជាទស្សនៈដែលជឿថាអ្នកកាន់រដ្ឋនីមួយៗ បានទទួលបញ្ជាពីព្រះអាទិទេពអោយមកដឹកនាំមនុស្ស ។ ឧទាហរណ៍ — លោកមហាម័តបានជឿថា លោកជាទូតនៃព្រះជាម្ចាស់ ។ ព្រះអង្គបានបញ្ជាអោយលោកចុះពីឋានសួគ៌មកដើម្បីដឹកនាំមនុស្ស ។

អ្នកទ្រទ្រង់ដែលដឹកនាំដោយជំនឿនេះ តែងកាន់តាមលទ្ធិប្រជាធិបតេយ្យ ហើយសម្បូរដោយលទ្ធិផ្តាច់ការ ។

## 345- អ្វីទៅហៅថាតថនិយមនៅក្នុងរដ្ឋ ?

(Réaliste dans l' Etat)



www.elibraryofcambodia.org

កថនិយមក្នុងវត្ថុ គឺភាពសមហេតុសមផលនៃរចនាសម្ព័ន្ធវត្ថុ ដែលប្រកបដោយកថៈ (le réel) ក្នុងការសិក្សា, ក្នុងគរុវត្តន៍រវាងអ្នកសិក្សានិងប្រជារាស្ត្រ ។ ជាទ្រឹស្តីដែលវិនិច្ឆ័យរកគុណនិងទោស (វិបាក) ក្នុងការប្រើអំណាច, សេរីភាព, និងសិទ្ធិរបស់អ្នកដឹកនាំរដ្ឋនិងប្រជាពលរដ្ឋ ។ ជាទ្រឹស្តីដែលជួយសំរុះសំរួលការទាមទារផ្នែកនយោបាយ, សេដ្ឋកិច្ចនិងសីលធម៌រវាងរដ្ឋនិងប្រជារាស្ត្រ និងជារូបមន្តនៃកិច្ចព្រមព្រៀងគ្រប់យ៉ាងរវាងអ្នកទាំងពីរក្រុម ។

## 346- អ្វីទៅហៅថា "មនសិការជាតិ" ?

(conscience nationale)

មនសិការជាតិ គឺព្រលឹង ឬគោលការណ៍ចិត្តដែលបណ្តាលអោយភ្ញាក់រលឹកក្នុងការស្នេហាជាតិ ។ ជាព្រលឹងដែលកើតមកពីអនុស្សាវរីយ៍ ដែលជាប់រកតយ៉ាងជ្រៅតាំងពីអតីតកាលមក, មានការរួមសុខទុក្ខជាមួយគ្នាជាស្រេច ។ ម្យ៉ាងទៀត, ព្រលឹងនោះជានិមិត្តរូប នៃការព្រមព្រៀងគ្នាក្នុងអតីតកាល, បច្ចុប្បន្នកាលនិងអនាគតកាលដែលតែងបង្កើតនូវឆន្ទៈមួយ គឺស្រលាញ់ហើយរក្សាមរតករួម អោយស្ថិតនៅក្នុងគំនិតជានិច្ច ។

## 347- អ្វីទៅហៅថា « មាតុប្រទេស » ?

(La Patrie)

មាតុប្រទេស គឺដីភូមិកំណើតដែលមនុស្សទាំងឡាយធ្លាប់រស់នៅជាមួយគ្រួសាររបស់ខ្លួន ។ ស្នេហាមាតុប្រទេសគឺ



www.elibraryofcambodia.org

ស្នេហាជាតិ , គំនិត , មនុស្ស . ត្រូវកើតឡើងដោយខ្លួនឯងស្ទាប់ស្គាល់ថាជា
របស់ជាតិខ្លួន ។ គឺជាសវេទនាឯកជនប្រកបដោយ
សភាវគតិ, ជាសវេទនាប្រជាករ (Sentiment de masse)
ដែលជាប់ទាក់ទិននឹងស្រុកកំណើត , និងភាសា , និងប្រពៃណី
និងបរិយាកាសទូទៅ (ambiance générale) ។
ស្នេហាមាតុប្រទេស បណ្ដាលអោយគេភ្ញាក់ស្មារដោយស្រើប
ឬដោយគំហើង ហើយបូជាជីវិតជាពលិកម្ម ។

*

* *



www.elibraryofcambodia.org

# អត្ថាធិប្បាយ



www.elibraryofcambodia.org

ប្រធានទី ១.– តើទស្សនវិជ្ជាមានគុណប្រយោជន៍ សំរាប់បង្ហាញការពិចារណានៅក្នុងស្យង់, និងបង្ហាញនូវវិធីទាំងឡាយរបស់ស្យង់, យ៉ាងដូចម្តេចខ្លះ? ចូរពន្យល់ ។

(ក្រុងរ៉ែនសម័យប្រលងខែមិថុនា១៩៥២)

**តំរោងអត្ថាធិប្បាយ**

## ១. សេចក្តីផ្តើម –

ទស្សនវិជ្ជាខុសនិងស្យង់ត្រង់លក្ខណៈខ្លួនរបស់វិជ្ជានេះព្រោយទាំងសច្ចៈកុងពុទ្ធិ (réalité de la connaissance) ខ្លះខ្លាយនិងផ្តត់គំនិតទៅរកភាពប្រមាណ ។ ឯចំណែកស្យង់វិញ, វិជ្ជានេះក៏បានផ្តល់នូវគន្លឹះសំរាប់ត្រួតត្រាសច្ចៈផ្តល់ទស្សនវិទូមិនតិចដែរ ។ ដើម្បីបំបិនបំណងរបស់មនុស្សដែលកុំខេះខ្វែកនិងការចង់ចេះចង់ដឹងនោះ, គេឃើញវិជ្ជាទាំងពីរនេះ បានចេញមុខមកបំពេញតួនាទីរបស់មនុស្សជាតិវិជ្ជានានា ។ តាមពិតស្យង់និងទស្សនវិជ្ជាមានសម្ភារៈដែលជាឧបករណ៍របស់ខ្លួនជាមួយគ្នា គោលគឺវិចារណញ្ញាណ (la raison) ។ ទស្សនវិទូទាំងឡាយដែលស្រលាញ់សច្ចៈធម៌, បាននាំគ្នាជ្រើសរើសមាគ៌ាស្យង់ដើម្បីបណ្តុះពុទ្ធិរបស់ខ្លួន, ដែលជាហេតុបណ្តាលអោយស្យង់ក្លាយទៅជាយានមួយ នាំអោយបានដល់នូវពុទ្ធិសច្ចៈសំរាប់ការប្រព្រឹត្តទៅជាធម្មតានៃវិចារណញ្ញាណមនុស្សជាតិ ។

## ២. តួសេចក្តី

*១- ស្យង់និងតក្កវិជ្ជា :*

*ក- ស្យង់និងមុខងារទស្សនវិជ្ជានៃភាសា*



www.elibraryofcambodia.org

ត្រូវបញ្ជាក់ថា ទស្សនវិទូតែងត្រូវការភាសា សំរាប់ពិចារណាទៅលើអ្វីទាំងអស់ ។

— សង់ជាភាសាសំរាំង ។

— គណិតវិទ្យាបានមកពីរូបមន្តនៃភាសា ។

— ទស្សនវិទូ យករូបមន្តភាសា ដើម្បីពិចារណាទំនាក់ទំនងក្នុងធម្មជាតិ ។

— សង់បានបន្ទោសទៅទស្សនវិទូ ពីគំនៃនិរសាគន៍របស់គំនិតក្រៅសត្ថៈ ។

## ១- កំរិតការនៃវត្ថុវិស័យភាពរបស់គំនិត

— ត្រូវបញ្ជាក់ថា :

— សង់ជាពុទ្ធិក្រៅគំនិតពីកំណើតរបស់មនុស្ស

— លោកសារីស្កតលាវែករបស់ទស្សនវិទូបាតុង, ជឿថា គំនិតមនុស្សប្រកបដោយបញ្ញាស្អាប់ ប្រៀបដូចគុំទាន់ឈូស ។

— គំនិតមនុស្សវះភាសាគន៍ ឥតគំនៃលើអ្វីទាំងអស់ ។

— គំនិតបញ្ញាមនុស្សត្រូវការវត្ថុខាងក្រៅ ដើម្បីវិវត្តន៍នៃសត្ថៈ

— ផ្ទុះវត្ថុវិស័យភាពជារូបមន្តសំខាន់បំផុត សំរាប់គំនិតមនុស្ស ។

— លោកកុងសេត (M. GONSETH) ជឿថាទស្សនមនុស្សស្ថិតនៅចំកណ្តាលរឿងពីរ គឺនៅចន្លោះ “រូបអក្ខរញ្ញាណ” (forme intuitive) និង “យានវិចារណញ្ញាណ” (Idéal rationnel) ។



www.elibraryofcambodia.org

— ក្នុងគណិតវិទ្យា គំនូរការវិភាគវិស័យភាពរបស់មនុស្ស បាន
ចោទជាបញ្ហាសំរាប់មនុស្សនិទ្ទេសក្នុងការវិភាគ គំនែងនៃតក្ក
ភាពប្រមាណ និង លក្ខណៈនៃសច្ចៈ ។

## គ- គំហើញនៃគំនូរការបញ្ញា

ត្រូវគោលថា ៖

— ជំរាបនៃគំនិតមនុស្សឆ្ពោះទៅរកពិភពសប្បុរស, ពុំសូវប្រាកដ
ប្រែជាជាងគំនូរការពិសោធន៍ក្នុងសង្គមទៀយ ។

— សង្គមបានបញ្ចប់សន្និដ្ឋានដោយសំរាយភាពវិជ្ជាគតិ ។

— វិភាគវិស័យភាព បានស្វែងរកបញ្ហាដោយសន្និដ្ឋានបានរួប
មិនត្រឹមត្រូវខ្លះ ។

— ទ្រឹស្តីមិនស៊ីសង្វាក់នៃសង្គមនិរន្តរ៍ គឺជាបាតុភូតមួយត្រូវ
ត្រូវចាំបាច់ស្វែងរកលក្ខណៈរួបរួមគ្នាជាបញ្ហានិងវត្ថុប្រក់រួប ។

## ឃ- គំហើញនៃគំនូរការសិល្ប

ត្រូវគោលការណ៍ថា ៖

— គំនូរប្រាជ្ញពិតប្រាកដពុំបានសុខចិត្ត ទទួលស្គាល់ភាព
ស្រពិចស្រពិលក្នុងវត្ថុជាតិទៀយ ព្រោះវាទារអោយមាន
គ្រោះថ្នាក់ ។

— គំនូរការសម្បជាតិ ត្រូវពិនិត្យអោយឃើញលក្ខណៈច្បាស់
លាស់ សិទ្ធសិប្បវិនិច្ឆ័យ ឬ អនុវត្ត ។

— គំនូរការសំរបរបស់អ្នកប្រាជ្ញ ត្រូវរកឲ្យបានលក្ខណៈអោយ
ឃើញលើឡើងនាំមនុស្សអោយត្រូវការលើកលំពងទាំងឡាំង នៃ
ធម្មជាតិ ។

— គោលគំនិតទាំងអស់ត្រូវតែងវិជ្ជការលើចិត្តវិទ្យា នៃបញ្ហា
ទាំងស្រុង ។



www.elibraryofcambodia.org

## ២- ស្យង់ និង ទស្សនវិជ្ជា

### ក- ការពិចារណាទៅលើប្រវត្តិវិទ្យា

ត្រូវរំលឹកថា ៖

— ទស្សនវិជ្ជាបានឃ្លាតឆ្ងាយពីស្យង់ពិសោធន៍បន្តិចម្ដងៗ ។

— ផ្ទុកទស្សនវិជ្ជាក្រិច ពុំបានពិសោធរកលក្ខណៈតាមវិធីស្យង់ទេ តែបានពិសោធន៍តាមវិធីបែបទស្សនវិជ្ជា ។

— ត្រូវរំលឹកឧទាហរណ៍ពីវិញ្ញាណរបស់លោក “ជ៉ារម និកថា ពុំមែនជាពិតកម្មឃើញទេ តែចំពោះរោគការណ៍វិញ្ញាណសជា “សត្វមួយ” ទៅវិញ ។

— អ្នកចិត្តវិជ្ជាសម័យបច្ចុប្បន្ន បានរករឃើញលក្ខណៈនៃពិភពនៃពួកគេនៅលើកើតទស្សនៈបែបវិជ្ជាក្រិចបុរាណ ដែលរបៈពិចារណានិងមានចំណេះលើនៃវិស័យ ។

— ទស្សនវិទូ ត្រូវតែមានចំណេះចំពោះវិស័យណាមួយ ដែលខ្លួនសរសេរអំពីបុណ្ណោះ, ពីព្រោះបានធ្លាប់គោរពតាមច្បាប់ដែលគេបានធ្វើ ។

### ខ- ស្យង់ពុំមែនជាទស្សនវិជ្ជាទេ ៖

ត្រូវគោរពថា ៖

— អ្នកប្រាជ្ញខាងវិទ្យុ នៅពេលត្រូវការគ្រប់គ្រងលើជាក់ស្ដែងមួយសុទ្ធតែបានតាំងខ្លួនឲ្យទៅជា ទស្សនវិទូទាំងអស់សិន ។

— ស្យង់ពន្យល់បាតុភូតងាយ បាតុភូត ផ្សេងៗ នូវទ្រឹស្ដីនៃគំនិត ដែលមានទំនាក់ទំនងទៅនឹងបាតុភូត ។

— ទស្សនវិទូលោក “កុងសេត” (GONSETH) ដែលនិយាយពី “រូបអត្តសញ្ញាណគួរយកមកពិចារណា ។



www.elibraryofcambodia.org

— ទស្សនវិជ្ជាក៏ដូច «រូបអគ្គញ្ញាណ» ទាំងអស់នេះ, ដែរ បានលក្ខណៈស្រដៀងគ្នា ។

— ព្រោះបញ្ហាប៉ះពាល់ក្រឹត្យការណ៍ខ្លួនឯង, ហើយបានគោលដៅចាប់យកសច្ចៈក្រៅពិសោធន៍ ( réalité non empirique).

## គ- តំលៃទស្សនវិជ្ជានៃស្យង់

— ស្យង់មិនអាចជំនួសស្យង់ក៏ដូចតែតំលៃទស្សនវិជ្ជាដែរ ។

— ស្យង់និងទស្សនវិជ្ជាជួយគ្នាទៅវិញទៅមក ។

— ទស្សនវិទូពិនិត្យរូបរាងក្រៅនៃលោក - ហើយស្យង់ជាអ្នកពិនិត្យភាពខាងក្នុងនៃលោក ។

— សេចក្តីសន្និដ្ឋានរបស់ទស្សនវិទូដែលឡើងដល់ ប្រពៃក៏ល្អ ច្បាស់ តែអាចពិតតាំងដែលបានមកពីស្យង់សុទ្ធតែត្រូវទស្សនវិជ្ជាតំរូវមុនជានិច្ច ។

# ៣. សេចក្តីបញ្ចប់

ត្រូវសារុបសេចក្តីថា :

— ស្យង់ជាសកម្មភាពល្អិតល្អន់របស់គំនិតមនុស្ស ។ ទស្សនវិទូត្រូវប្រើបញ្ញាមើលជ្រៅជ្រះស្រឡះ, ស្យង់ត្រូវប្រើវិធីរបស់ខ្លួនដើម្បីបញ្ជាក់សច្ចៈ ។ ស្យង់តំរូវទស្សនវិជ្ជាអោយដល់គោលដៅជាក់លាក់ហើយកុំអោយឈប់ពាក់កណ្តាលផ្លូវ ។ តើតំលៃទាំងពីរនេះអាចចោលផលប្រយោជន៍ខ្លួនបានទេ? ទស្សនវិជ្ជាដែលទ្រទ្រង់គំនិតពិសោធន៍ផ្តល់លទ្ធផល នឹងនាំអោយអន្តរាយដល់ធនធានមនុស្សជាពិសេសបំផុត ។

*

* *



www.elibraryofcambodia.org

ប្រធានទី២ _ "គណិតវិទ្យា និងពិសោធន៍" តើវិជ្ជាទាំងនេះមានទំនាក់ទំនងរវាងគ្នាឬឆ្ងាយដាច់ពីគ្នា យ៉ាងដូចម្ដេចខ្លះ? ចូរពន្យល់ ។

(ម៉េត្រូប៉ូល - សម័យប្រលងខែវិច្ឆិកាឆ្នាំ ១៩៥៣ -
សំរាប់ថ្នាក់គណិតវិទ្យា)

គំរោងអត្ថាធិប្បាយ

១. សេចក្ដីផ្ដើម .- គេច្រើនពោលថា គណិតវិទ្យាខុសស្រឡះពីវិទ្យាសាស្ត្រពិសោធន៍ ។ គណិតវិទ្យារិះរកសច្ចៈរបស់ខ្លួនតែលើក្រដាស, លើក្ដារខៀន, ពុំបាច់យកវត្ថុមកពិសោធន៍និងសង្កេតទេ, តែច្រើនយកនិមិត្តរូបផ្សេងៗ មកពិចារណាទៅវិញ ។ ឯចំណែកវិទ្យាសាស្ត្រពិសោធន៍ ត្រូវរកសច្ចៈក្នុងមន្ទីរពិសោធន៍ដោយរើសយករូបវត្ថុដែលមានមកពិចារណា, យកសន្និដ្ឋានមកសំរេចនៅក្នុងប្រដាប់ពិសោធន៍ផ្សេងៗ ។ តើពិសោធន៍ជាមធ្យោបាយដែលមានសារៈសំខាន់ សំរាប់គណិតវិទ្យាឬទេ ?

២. តួសេចក្ដី

១- ដើមកំណើតពិសោធន៍នៃវិជ្ជាទាំងពីរ

— អនុវត្តន៍កើតមុនទ្រឹស្ដី ព្រោះដំបូងមនុស្សចាប់អនុវត្តព្រាវៗដោយគ្មានគោលដៅ ។ បន្ទាប់មកក៏ឃើញលទ្ធផលល្អអាក្រក់, ពេលនោះហើយ ទ្រឹស្ដី ក៏កើតមានឡើង ។



www.elibraryofcambodia.org

— ការប្រើថ្នាំពុល និងថ្នាំព្យាបាលរោគ តែងប្រើគ្នាតាំងពីសម័យបុរេប្រវត្តិ ។ លទ្ធផលគឺមនុស្សត្រូវស្លាប់ ឬបានសះស្បើយពីជំងឺ ។

— ហេតុមកដល់ជំនាន់លោក « ក្លូតប៊ែរណា » (Claude-Bernard) ទើបគេបានធ្វើពិសោធន៍សត្វត្រឹមត្រូវ ។ រីឯគណិតវិទ្យាក៏ដូចគ្នាដែរ, ត្រូវបានទទួលផលជាក្បួនខ្នាតត្រឹមត្រូវនៅសម័យលោក « ក្លូតប៊ែរណា » ។

## គ-ពិសោធន៍គណិតវិទ្យា

— ពិសោធន៍នេះគេពិសោធតាមបែបបុរាណពីដើមមក - គឺគេចាប់ផ្ដើមដោយសាកល្បងគ្មានគិតពីការលំបាកទេ ។

— ធរណីមាត្រ ( géométric ) គឺកើតឡើងប្រើប្រាស់ជាមួយការវាស់ដីរៀលប្រវែង និងទំហំ - គឺមុនដំបូងគេសាកវាស់ដីការនៅតាមមាត់ទន្លេ « នីល » ( le Nil ) ។ ដូច្នេះគណិតវិទ្យាកើតមកពីវាស់វែង ។

( arithmétique ) កើតមកពីការរាប់គិតលេខ ។

— គណិតវិទ្យា កើតមកពីពិសោធន៍រូបវិទ្យាដែលគេរស់នៅរាល់ថ្ងៃ ។

— គណិតវិទ្យាកើតមកពីការគិតគូរទាំងផ្លូវចិត្ត ។

## ខ ដើមកំណើតនៃក្បួនគណិតវិទ្យា

គណិតវិទ្យាកើតពីក្រុងក្រិច បុរាណដែលមានអ្នកប្រាជ្ញចង់ដឹងការណ៍បីទូទៅអ្វីៗ ដែលរស់នៅក្នុងលោក មានចម្ងល់ជាដំបូង ដើម ។



www.elibraryofcambodia.org

# ៣. សេចក្តីបញ្ចប់

ត្រូវគូសបញ្ជាក់ថា ៖

— ស្យង់ធម្មជាតិ ដែលវិវត្តទៅជាស្យង់កិរិយាអនុមាណរួម ។

— ស្យង់គណិតវិទ្យា ដែលក្លាយទៅជាកិរិយាធន៍វិចារណញ្ញាណនិងអនុមាណវិញ្ញូ ។

— ចំណេះពិតប្រាកដពុំស្ថិតនៅលើវិចារណា តែមួយនៃវិជ្ជាទាំងពីរទេ, តែវាស្ថិតនៅលើគំនិតសច្ចៈដែលជារួមផ្សំនៃកិរិយាធន៍និងវិចារណញ្ញាណរបស់មនុស្សចំពោះទំនាក់ទំនងនៃវិជ្ជាទាំងពីរនេះ ។

* * *



www.elibraryofcambodia.org

ប្រធានទី៣. – តើអ្នកយល់យ៉ាងដូចម្តេច ចំពោះការពិចារណារបស់លោកប៊ែរទ្រង់រ៉ូសែល ដែលយល់ថា "គណិតវិទ្យាអាចអោយនិយមន័យថា ជាវិជ្ជាដែលគេពុំដឹងថាគេចង់និយាយពីអ្វី? ហើយម្យ៉ាងទៀតគំនិតដែលនិយាយនោះតើមានសច្ចៈឬទេ ?

ចូរពន្យល់និងរិះគន់ផង។

តំរោងអត្ថាធិប្បាយ

១.សេចក្តីផ្តើម.– គេច្រើនពោលថា គណិតវិទ្យាជា "ល្បែងប្រាជ្ញ ឥតស្បៀង" ។ ហើយចំពោះលោកអូគុស្តុំ (A-Comte) គណិតវិទ្យាជាការសិក្សាតែមួយ ដែលផ្តល់នូវគំនិតត្រឹមត្រូវក្នុងចំណោមវិជ្ជា ទាំងឡាយ" ។ តែមានបណ្ឌិតមួយពោលមកតាមថា "គណិតវិទ្យាអាចអោយនិយមន័យថា ជាវិជ្ជាដែលគេពុំដឹងថា តើចង់និយាយពីអ្វី ? ហើយគំនិតនិយាយមកនោះតើមានសច្ចៈឬទេ ? "

២. តួសេចក្តី

១ គណិតវិទ្យាក្លាស៊ិច

ត្រូវពន្យល់ខ្លឹមសារ របស់គណិតវិទ្យា ដែលគេពោលថា គណិតវិទ្យាជាដំបូងនៃវិជ្ជាអនុមានវិញ្ញាណ (science déductive) ។

— ពីព្រោះវិជ្ជានេះទៀតជាវិជ្ជាដែលប្រើសំភាពពិតពិចារពិនិត្យក្នុងសំរាយបញ្ជាក់ (demonstration) ។

www.elibraryofcambodia.org

— ភាពស្មុគស្មាញកម្មវិធីអាចធ្វើឲ្យរំខានដល់ការពិសោធន៍ ។

— បុគ្គលម្នាក់ៗដូចជាគាត់ស្ទួនដែរក៏ចេះខ្លួនឯងត្រូវមានភាពពិតនៃវិចារណញាណខ្លួន ។

— និយមន័យបង្ហាញការចាំបាច់ដល់អ្នកគណិតវិទ្យាពីអរូបីអត្តនិយម ។

— អ្នកគណិតវិទ្យាត្រូវបានវិភាគផលនៃការវិនិច្ឆ័យ ដោយអត្តភាព ។

## ២- ការគិតពិចារណារបស់ រ៉ូសែល (Russel) មិនត្រូវតាមគណិតវិទ្យាទាំងអស់ទេ :

— អរូបីកម្មរបស់គណិតវិទ្យាបានធ្វើកុំឲ្យយើងដឹងថា តើគេនិយាយពួករបស់នោះត្រូវឬទេ ?

— ការពិចារណាបានរកឃើញគេយល់ថា រវាងវត្ថុបានផ្លាស់ប្តូរនិងនិក ចំនួនបានរះរាយងាយ ។

— ក្មេងបានរៀនវិជ្ជារបស់នាវិកវិទ្យា បានបង្កើតចំណេះដឹង និងសន្និដ្ឋានរបស់វាយ៉ាងពេញលេញ ។

## ៣- គណិតវិទ្យាដែលលោកគូរ៉េសយល់ឃើញ :

— គណិតវិទ្យានេះពិចារណាក្នុងអរូបីកម្មក្តី ក៏ទៅវិញការបង្កើតដំណើរការដែលគេហៅថា "ប្រតិបត្តិ" វិធីលក់វិធីថា អនុមានកញ្ញាណកើត "សម្មតិកម្ម អនុមានកញ្ញាណ" (hypothético-déductive) ។

— បើតាមលោក អាល់ប៊ែរ - ឡូតម៉ាន់ (Albert-Lautmann) "គណិតវិទ្យាជាសំណុំនៃសញ្ញាដែលគ្មានន័យហើយប្រើសញ្ញាមួយជំនួសសញ្ញាមួយទៀតដោយ[illegible]

www.elibraryofcambodia.org

— ក្នុងគណិតវិទ្យាគេពុំបាននឹងថាត្រូវឬខុសទេ, ទោះទៅក្នុងល្បែងរូបវិទ្យាដែលចេញមកពីពិសោធន៍ក៏ដោយ ក៏ភាពពិតហាក់ដូចជាពុំទាន់ច្បាស់នៅឡើយ ។

## ៣. សេចក្តីបញ្ចប់ :

ត្រូវបញ្ចប់ក្នុងសេចក្តីបញ្ចប់ថា ៖

— លោកគូរ៉ែលក៏ថាវិញ្ញាណនៃវាល ពុំមែនប្រាកដនៅក្នុងគណិតវិទ្យាទាំងអស់ទេ ។ ការដែលវិស្វករលទ្ធ:ក្នុងល្បែងផ្គុំរណ៏ពិសោធន៍មានលទ្ធ:នៅត្រឹមពុំទាន់ទៀងទាត់ ។ ឧទាហរណ៍ គណិតវិទ្យាបានវាស់គំរិតកំលាំងយ៉ាងពពកឡើយ ក្នុងយានអាកាសយ៉ាងត្រឹមត្រូវ, ល្បែងបានចេញពីពិសោធន៍ដោយបង្ហាញលទ្ធផលយ៉ាងជាក់ច្បាស់ណាស់ តែទីបំផុតយានអាកាសជាច្រើន បានបំផ្លាញអវកាសយានិកទាំងស្រុងអោយខ្លាច ។ តែទោះជាយ៉ាងណាក៏ដោយ ក៏យើងឃើញថា មតិលោកគូរ៉ែលបានផ្តល់អោយឃើញរូបភាពពិតនៃគណិតវិទ្យាដែលកើតពីស្បែងគំនិតរបស់មនុស្ស ។

* * *



www.elibraryofcambodia.org

ប្រធានទី៤ - «ហេតុអ្វីបានជាក្នុងករណីខ្លះគេអាចពោលថា៖ គណិតវិទ្យាមានសារៈសំខាន់ហួសហេតុស្ទើរតែរៀនស្វាង ពុំបាន?»

ចូរពន្យល់និងវែកញែកទស្សនខាងលើនេះ។

(ប្រឡងខែតុលាឆ្នាំ ១៩៩១ - វិញ្ញាសាសំរាប់ថ្នាក់គណិតវិទ្យា)

**គំរោងអត្ថាធិប្បាយ**

## ១. សេចក្ដីផ្ដើម —

កំរិតការរូបវិទ្យាប្រឆាំងផ្ទុយនឹងកំរិតការគណិតវិទ្យា។ រូបវិទ្យាមានលក្ខណៈល្អត្រឹមត្រូវ៖ ឧទាហរណ៍ កំសៀវទឹកដាំពុះបើបិតគ្របជិតនឹងផ្ទុះ, ផ្ទុយទៅវិញបើគេពុំបិតគ្របជិតទេកំសៀវត្រូវតែបើកគ្របទៅវិញ។ ស្ទើរបង្ហាញភាពពិតជារូបី។ រីឯគណិតវិទ្យាផ្ទុយនឹងរូបវិទ្យាត្រង់គណិតវិទ្យាបង្ហាញពុំបានច្បាស់លាស់ទេ៖ ឧទាហរណ៍ មុំតិររបស់ត្រីកោណពុំអាចស្មើនឹងមុំកែងពីរបានទេ។ តើលក្ខណៈត្រង់ណាដែលគេពោលថា គណិតវិទ្យាមានសារៈសំខាន់ហួសហេតុស្ទើររៀនស្វាងពុំបាន?

## ២. តួសេចក្ដី

### ១- ប្រវត្តិនៃគណិតវិទ្យា

ក- កំរិតការជាចាំបាច់

— ដើម្បីអាចយកលោកអោយស្គាល់ ជាកំណាត់ខទស្សនគណិតវិទ្យា។



www.elibraryofcambodia.org

— គណិតវិទ្យា ដែលគេសាគការីស្នូកយកចិត្តទុកដាក់ពីក្រឹត្យ លក្ខណៈពិតប្រាកដរបស់វាផង សំរាយបញ្ហាគណនាទំនាក់ទំនង ដើម្បីណាក៏ត្រឹមត្រូវ ។

## ១- អាទិបទនៃគណិតវិទ្យាក្នុងកាលសម័យ

— គេបាននិយាយថ្មីៗ ដែលគណិតវិទ្យាបង្កើតនោះមាន ប៉ុស្តុយឡា (postulats) ។ ឧទាហរណ៍ : ប៉ុស្តុយឡា អឺគ្លីត ។

មកដល់សតវត្សរ៍ ១៩ ទើបមានអ្នកប្រាជ្ញផ្នែកគណិតវិទ្យា រុស្ស៊ីឈ្មោះឡូបាតឆេវស្គី (Lobatchevski) ; អ្នកប្រាជ្ញ អាល្លឺម៉ង់ឈ្មោះរីម៉ាន (Riemann) និងអ្នកប្រាជ្ញហុងគ្រី ឈ្មោះបុល្យ៉ៃ (Bolyaï) គេរកឃើញប្រព័ន្ធគិតហើយបដិសេធ ប៉ុស្តុយឡាអឺគ្លីតចោល ។

## ២- ចំលើយនៃគណិតវិទ្យា

### ក- គេអាចនិយាយពីតំរូវការនៃគណិតវិទ្យាបាន

— តំរូវការគណិតវិទ្យា បានត្រូវគេសំគាល់ឃើញថាស្រង់ ប្រព័ន្ធពិសោធន៍ផ្ទះផ្សេង ។ និយមន័យគណិតវិទ្យានិងនិយមន័យ របស់វិទ្យាសុទ្ធតែចេញមកពីពិសោធន៍បញ្ហាទាំងអស់ ។ អាវិស្នូក យកចំណុចត្រង់នេះថា គណិតវិទ្យាមានសារៈសំខាន់ណាស់ ស្ទើរទៀតសាវាងកុំបាន ព្រោះបានពិចារណាត្រឹមត្រូវ ។

— តែអ្នកប្រាជ្ញបច្ចុប្បន្នដូចជាលោក "ហ៊ីលប៊ែរ" (Hilbert) និងពួកអ្នកប្រាជ្ញសាលាវីយែន (Vienne) គេពោលថា «គណិតវិទ្យា» ពុំសូវមានសារៈសំខាន់ឡើយ ។



www.elibraryofcambodia.org

## ២- គណិតវិទ្យាមានព្រំដែនត្រឹមត្រូវ

— គណិតវិទ្យា មានព្រំដែនរបស់ខ្លួនត្រង់មតិមួយដែលពោលថា : " សារៈសំខាន់របស់គណិតវិទ្យាបានក្លាយទៅជាសារៈសំខាន់នៃគោលការណ៍ ដែលភ្ជាប់ជាស់និងគោលការណ៍នៃអនុមានវិញ្ញាណ " ។

— សារៈសំខាន់ក្នុងរូបវិទ្យា មានប្រៀបជាងសារៈសំខាន់ក្នុងគណិតវិទ្យា ត្រង់តំលៃ និងលទ្ធផលដែលសំរាំងចេញពីពិសោធន៍ ។

## ៣. សេចក្ដីបញ្ចប់

— យើងឃើញថា មតិដែលពោលអះអាងមកនេះ ក៏មានយោបល់ត្រឹមត្រូវប្រកបដោយភាពសមរម្យណាស់ដែរ ។ ព្រោះថា គណិតវិទ្យាបានបង្ហាញនូវភាពជាក់លាក់គួរអោយចាប់អារម្មណ៍ ។ គណិតវិទ្យា បង្កើតរូបមន្តនានាដែលមានគោលបំណងស្វែងរកភាពប្រាកដនិយម ។ តែលុះដល់ស្ញង់វិត្តដល់កំរិតទាំងនេះដែរ គណិតវិទ្យាក៏ស្ថិតនៅក្រោមវិត មានតំលៃសំរាប់តែក្នុងករណីពិសេសមួយចំនួន , ព្រោះថា ប្រភពមេរៀនជាយតិតនៃគណិតវិទ្យាសុទ្ធ , តំលៃទាំងឡាយនៃគណិតវិទ្យាបានមកពីគំនិតបញ្ញារបស់មនុស្សផងដែរ ។

* * *


www.elibraryofcambodia.org

ប្រធានទី៥ ៖– « ហេតុអ្វីក៏គណិតវិទ្យា ត្រូវគេនាំគ្នាចាត់ទុកថា ជាឧបករណ៍សំខាន់មួយ ក្នុងចំណោមវិជ្ជាទាំងឡាយ ? » ចូរលើកឧទាហរណ៍ និងវែកញែកតាមបែបទស្សនវិជ្ជា ។

(ក្រុងមេត្រូប៉ូលីតាន់-សម័យប្រឡងខែឧសភា ឆ្នាំ១៩៥៩
ថ្នាក់គណិតវិទ្យា)

## គំរោងអត្ថាធិប្បាយ

**១. សេចក្ដីផ្ដើម ៖–** លោកកង់(Kant) សរសេរថា « នៅក្នុងទ្រឹស្ដីពិសេសនៃធម្មជាតិ, ពាក្យថាវិជ្ជាពិតប្រាកដពុំមានឡើយ តែគេឃើញមានតែបរិមាណគណិតវិទ្យាប៉ុណ្ណោះ » ។ ៤០ ឆ្នាំក្រោយមក លោកអូគុស្តកុង បានសរសេរក្នុងមេរៀនទស្សនវិជ្ជារបស់លោកថា « នៅសម័យបច្ចុប្បន្ននេះ, វិជ្ជាគណិតវិទ្យាពុំសូវមានប្រយោជន៍ ដោយសារពុទ្ធិសច្ចៈ និងតំលៃរបស់ខ្លួន ក្លាយទៅជាឧបករណ៍សំរាប់មនុស្សស្រាវជ្រាវរកច្បាប់នៃបាតុភូតធម្មជាតិ » ។

វិវត្តន៍នៃវិជ្ជា នៅសម័យនៃលោកអ្នកប្រាជ្ញទាំងពីរ បានផ្ដល់លទ្ធផលដល់ « តារាវិទ្យា » តែម្យ៉ាងប៉ុណ្ណោះ ។ មកដល់សព្វថ្ងៃនេះ ទស្សនៈនេះបានត្រូវគេយកមកអនុវត្តក្នុងវិជ្ជាមនុស្ស វិជ្ជាធម្មជាតិ, ជាពិសេសក្នុងវិជ្ជាចិត្តវិទ្យា និងសេដ្ឋកិច្ចនយោបាយ ។

យើងបានឃើញថា គណិតវិទ្យាបានជួយវិស័យទាំងឡាយ ស្ទើរតែក៏និងមនុស្សរកសន្និដ្ឋានពុំត្រូវ ។



www.elibraryofcambodia.org

## ២. គួរសេចក្តី.

### ១. គណិតវិទ្យាជាឧបករណ៍សំខាន់ នៅត្រង់វត្ថុជាធម្មជាតិនៃស្បៀង ។

- ស្បៀងបច្ចេកទេស នៅត្រង់ឧបករណ៍ ពិសោធន៍ក្នុងធម្មជាតិរបស់ខ្លួនគ្រប់ផ្នែក - ឧទាហរណ៍ : ម្ហូប ការកែច្នៃ ស៊ីតក្នុងសំបកពោត . សីតាផ្ទាត្រូតជាតិដែលចក្ខុមើលឃើញ ។ សក្ការគណៈដែលក្រោតការច្នៃ ហើយដោយទឹកក្តៅ ផល. ត្រូវទទួលសំណុំការណ៍ ដែលរបៀបពិនិត្យ ឃើញនិងច្បាប់ស្អាត ។

— គណិតវិទ្យាមានអរូបីកម្មខ្ពស់ តែអរូបីកម្មនោះអាចធ្វើសំរាយបញ្ជាក់បានដោយ តែមានសម្ពិតកម្ម , អាចត្រូវ , ប្រជុំស្តុប ឲ្យវត្ថុនេះនៅឡើង ។

— កំរិតរបស់គណិតវិទ្យាក្នុងការស្វែងរកអរូបីផ្លូវសំរាប់ប្រជុំគ្នា និងយថាទ័យផ្សេងៗ ។

### ២. គណិតវិទ្យាជាឧបករណ៍សំខាន់ នៅត្រង់ធម្មជាតិពិតរបស់ខ្លួន ។

#### ក- ឧបករណ៍សំខាន់ត្រង់វត្ថុគណិតវិទ្យា :

— គណិតវិទ្យាមានវត្ថុធាតុរបស់ខ្លួនជាបរិមាណអរូបី ។

— គណិតវិទ្យាមាន បរិមាណដែលអាចវាស់និង រាប់បាន ដែរ ។ បរិមាណទាំងនេះជាគោលការរបស់ស្បៀងពិសោធន៍ ។

↳ ហេតុនេះហើយលោក « គុងឌីយ៉ាក »ពោលថា :



www.elibraryofcambodia.org

« ស្ទើរជាភាសារបស់បញ្ញា ជាពិសេសស្ទើរជាប្រវត្តិធាតុ
នៃគណិតវិទ្យា »

ខ- ឧបករណ៍សំខាន់នៅត្រង់វិធីជា «សម្មតិកម្មអនុមានវិញក» ÷

— លោក «ហាដាម៉ារ» (HADAMARD) ពោលថា «គណិតវិទ្យា ជាស្ទើរទូទៅនៃលំនាំជាតិ ដែលគេអាចពិចារណាពេញភ័ក្ត»

— លោក «ពួងកាំរ៉េ» ពោលថា : «ដោយលក្ខណៈសម្មតិកម្មអនុមានវិញក មានក្នុងគណិតវិទ្យានេះហើយ ទើបគេមានស្រាវជ្រាវកលក្ខណៈពេញភ័ក្តជាតិទាំងអស់នៅលើលោកនិងក្រៅលោក» ។

— លោកអាញស្តែង (EINSTEIN) ពោលថា : «គណិតវិទ្យាជាស្ពានសំរាប់រូបវិទ្យា ក្នុងការរាវរកគោលការណ៍បន្តិកម្ម» ។

## ៣. សេចក្តីបញ្ចប់

លោក ឡេអុង - ប្រុនស្វិច (Léon Brunschvigg) ពោលថា :
«ចំណេះរបស់មនុស្សដែលជាវត្ថុធាតុនៃគតិសោភ័ណ មានលក្ខណៈក្នុងវិចារណញ្ញាណ និងវិស័យភាព» ។

គំនិតលោកអ្នកប្រាជ្ញនេះយល់ថា វត្ថុវិស័យភាពកើតពីការពិនិត្យ ។ ឯចំណែកវិចារណញ្ញាណកើតពីត្រង់ត្រាយនៃគណិតវិទ្យាដែលគេការពេញទៅដោយគតិសោភ័ណ ។


www.elibraryofcambodia.org

— ពិសោធន៍ផ្តល់វត្ថុធាតុគ្រប់យ៉ាង ដល់គណិតវិទ្យា និង ចំណែកគណិតវិទ្យាបានខំស្មានអោយរកឃើញក្នុងស្ប៉ី ។

— គណិតវិទ្យាផ្តល់រូបមន្តពិតទៅស្ប៉ី ដើម្បីដោះស្រាយ បញ្ហាការចិត់ចាំងក្នុងឧទ្ធាតិផែសមនុស្សពុំបានដឹង ។

* * *



www.elibraryofcambodia.org

ប្រធានទី៦ — "តើគេអាចសន្និដ្ឋានថា" ការណ៍ទាំងឡាយ សុទ្ធតែត្រូវគេពិនិត្យឃើញតាមរយៈនៃកញ្ចក់ទ្រឹស្តីឬ? ចូរពន្យល់តាមវិធីទស្សនវិជ្ជានូវមតិខាងលើនេះ ។

(ក្រុងម៉ុងប៉េលិយេ - ខែឧសភា ឆ្នាំ ១៩៥៨
វិញ្ញាសាសំរាប់ថ្នាក់វិទ្យាសាស្ត្រពិសោធន៍)

គំរោងគំនិត

## ១. សេចក្តីផ្តើម — ត្រូវបញ្ជាក់គំនិតដូចតទៅ :

— មនុស្សស្គាល់ធម្មជាតិ ដោយសារឥន្ទ្រិយទាំងឡាយរបស់ខ្លួន ។

— មនុស្សមានវិញ្ញាណសំរាប់ពិចារណា ទៅលើវត្ថុធាតុធម្មជាតិ ។ គុណសម្បត្តិឥន្ទ្រិយតែម្យ៉ាងពុំអាចជំរុញការដឹង ស្គាល់របស់មនុស្សអោយសំរេចបំណងរបស់ខ្លួនទាំងអស់ទេ ។

— ដូចនេះមនុស្សមានគុណសម្បត្តិបន្ទាប់បន្សំ (qualités secondaires) ទាំងឡាយដែលទៀតរើសបៀថាជំនួយ ។ អាស្រ័យហេតុនេះហើយបានជាយកិច្ចមួយបានគេលើកឡើងថា : "មនុស្សដឹងការណ៍ទាំងឡាយនៃធម្មជាតិដោយទ្រឹស្តី" ។

## ២. សេចក្តីអធិប្បាយ

១- គេពុំអាចដឹងនិងស្គាល់ "ការណ៍ស្បង់" (fait scientifique) ដោយកញ្ចក់ទ្រឹស្តីឡើយ ។



www.elibraryofcambodia.org

— អ្នកពិសោធន៍ទាំងឡាយដូចជាលោក «ម៉ាហ្សង់ឌី» (MAGENDIE) ជាអ្នកធ្លាប់បានអះអាងថាការពិនិត្យក្នុងការណ៍របស់ធម្មជាតិតែងប្រទះឃើញលទ្ធផលនៃច្បាប់នៅក្នុងនោះ ។

— ប៉ុន្តែច្បាប់ត្រូវបញ្ជាក់នូវការណ៍ដែលកើត គឺបានមកពីការពិពណ៌នានិងវិភាគដ៏ល្អិតល្អន់ផង ។

— ពាក្យថាទ្រឹស្ដីដ៏ប៉ុនប៉ងបានមកពីសម្មតិកម្មធំៗ (grandes hypothèses) ប៉ុណ្ណោះ ។

— ម្យ៉ាងទៀតស្វែងរកសច្ចៈ, ច្បាប់កុំអាចរំលងចោលទ្រឹស្ដីបានឡើយ ។

ក៏ប៉ុន្តែបើមានតែទ្រឹស្ដីគ្មានការពិចារណា, ក៏រកសច្ចៈពុំឃើញដែរ ។ ព្រោះដូចជាលោកវីវែល «WHEWELL» ធ្លាប់ពោលមកហើយថា ៖ "ទ្រឹស្ដីគឺសេចក្ដីពិនិត្យយ៉ាងហ្មត់ចត់ ព្រមទាំងពិចារណា ដោយយ៉ាងល្អិតល្អន់" ។

— អ្នកប្រាជ្ញម្នាក់ពោលអះអាងថា «ខ្ញុំរកសច្ចៈឃើញដោយចំណេះផ្ទាល់របស់ខ្ញុំពុំមែនដោយទ្រឹស្ដីទេ» (c'est à l'aide de mon savoir el non de théorie que j'ai découvert le vrai!)

២. ការណ៍កំណើតរបស់ធម្មជាតិ ដែលមនុស្សបានស្គាល់ក៏អាស្រ័យដោយទ្រឹស្ដី :

(Le fait brul lui-même est perçu quelque chose de théorique)



www.elibraryofcambodia.org

— អ្នកប្រាជ្ញអាចស្គាល់ផង និងរកឃើញនូវគុណធម៌របស់ខ្លួន ក៏អាស្រ័យដោយស្រីស្តី ឬតាមតែការណ៍ដែលអ្នកប្រាជ្ញបុរាណ បានត្រួសត្រាយខ្លះមករហើយ ។

— អ្នកប្រាជ្ញថ្មីរកការណ៍ពុំឃើញទេ, បើគ្មានអ្នកនាំគំនិតដោយ គោលគុណធម៌នេះ ព្រោះថាវិជ្ជាវិស័យភាពនៃធម្មជាតិក៏គង់មាន អាស្រ័យប្រភពវិស័យភាព ទេញមកបង្ហាញខ្លួនដោយគិត, ដោយពិចារណា ។

— គេត្រូវការភាសាដើម្បីបញ្ជាក់គំនិតអ្វីមួយ ដែលជាសម្មតិកម្មពង្សល់ ។ ឧទាហរណ៍ៈ លោក«ភ្តូឡេមេ» (Ptolémée) ពោលថា«ព្រះអាទិត្យរះហើយលិចទៅវិញ នៅជុំវិញផែនដី» នេះជាភាសាដែលបង្ហាញអោយមនុស្សដឹងថា «ព្រះអាទិត្យធ្វើដំណើរ» ។ ដូច្នេះស្រីស្តីចេញជាភាសានូវការណ៍សំខាន់របស់គំហើញផ្សេងៗ ក្រោយទាំងចំណោះបេះដើមទាំងឡាយ ។

— ភាសាជាចក្ខុទេសក៍ គឺជានិមិត្តកម្មវិចារណញាណ ។

— ដោយស្រីស្តីលោកគ្រូរតឡក់អាចប្រែលថា "ក្រុមផ្កាស ស្រាយទៅជាក្រុមសង្ខ" បានឡើយ ។

## ៣. សេចក្តីបញ្ចប់

ស្រីស្តីពិតមែនតែអញ្ចឹង ក៏ប៉ុន្តែគេអាចចាត់ទុកថា ជាក្នុងនេះសា សំរាប់បង្ហាញការណ៍ទាំងឡាយបាន ។ សព្វៈទាំងឡាយដែលបានលទ្ធផលគាប់ប្រសើរ ក៏ដោយស្រ័យស្រីស្តីឆ្លាប់រកឃើញ ហើយបញ្ជាក់ថា មានតក្កភាពឬភាពត្រាកដនិយមកំពុងមកផងដែរ ។ ដូច្នេះស្រីស្តីពុំគ្រាន់តែជាការលន្ទកដោយប្រើបានប៉ុណ្ណោះទេ, តែជាគំនិតដែលស្ទង់ពិសោធន៍ត្រូវតាប់យកមកធ្វើជារូបមន្តនៃការពិចារណា ។

* * *



www.elibraryofcambodia.org

ប្រធានទី៧.– «តើច្បាប់ដែលសិក្សាពីសីលវិជ្ជាខុសពីច្បាប់

នៅក្នុងធម្មជាតិយ៉ាងដូចម្ដេចខ្លះ?»

ចូរពន្យល់តាមបែបទស្សនវិជ្ជា ។

( ក្រុងបៃរណុលស៊ើ - ខែឧសភា ឆ្នាំ ១៩៥០

វិញ្ញាសាសំរាប់ថ្នាក់គណិតវិទ្យា )

## គំរោងអត្ថាធិប្បាយ

### ១. សេចក្ដីផ្ដើម.–

ច្បាប់ដែលសិក្សាពីសីលវិជ្ជា បានគឺង ផ្លូវការពិចារណាលើនៃវិចារណញ្ញាណ បកស្រាយមូលដ្ឋានដើម្បី ស្វែងរកលក្ខណៈដូចជាចិត្តវិទ្យាជាស្នូលនៃចិត្ត, ជាវិភាគពីគំនិត ដើម្បីបង្ហាញភក្ដីភាពនៃចិត្ត ។ ចំណែកឯច្បាប់ធម្មជាតិ, ជាពិសោធន៍ដែលប្រាប់គំហើញក្នុងធម្មជាតិ ។ ច្បាប់ទាំងពីរនេះ ទាក់ទងជានិច្ចទៅនឹងវិចារណញ្ញាណរបស់មនុស្ស ។ តើត្រង់ លក្ខណៈណាខ្លះដែលបង្ហាញថាច្បាប់ទាំងពីរនេះខុសគ្នា ?

### ២. តួសេចក្ដី

១- ច្បាប់ធម្មជាតិនិងច្បាប់សីលវិជ្ជា :

ក- ច្បាប់ធម្មជាតិមាន គម្ពីរក្បួនរបស់ខ្លួន គឺធម្មជាតិដែលមាន ជីវិត, ជាឧបករណ៍នៃពិសោធន៍និងសកម្មភាពនៃធម្មជាតិ

— មនុស្សមិនគ្រាន់តែជាសត្វលោកនេះ ប្រកបដោយជីវិត ប៉ុណ្ណោះទេ, តែជាគំនិតដែលប្រកបដោយវិចារណញ្ញាណ និងបនសិការសីលវិជ្ជា ហើយនៅក្នុងន័យនេះ ចិត្តវិទ្យាបាន ក្លាយទៅជាវិបកជាងមួយនៃច្បាប់ធម្មជាតិ ។



www.elibraryofcambodia.org

– រូបវិទ្យាស្ថិតនៅក្នុងចំណោមនៃស្យង់ធម្មជាតិ ។

– ស្យង់ធម្មជាតិបានអោយវត្ថុធាតុដើមទៅមុខវិជ្ជាដូចតទៅ: តារាវិទ្យា , សិលាវិទ្យា , រូបវិទ្យា , គីមី .

– គោត្រសំនៃវិជ្ជាទាំងឡាយដែលគេប្រើ ឃើញក្នុងស្យង់ធម្មជាតិដែរគឺ: កាយវិទ្យា , ជីវវិទ្យា ។ល។

## ១- សច្ចៈដែលបានមកពីស្យង់ធម្មជាតិ បានប្រែភាពទៅជាស្យង់សីលវិទ្យា :

– ប្រវត្តិសាស្ត្រសិក្សាពីមនុស្ស និង សង្គមរបស់មនុស្សតាំងពីសម័យបុរេប្រវត្តិ – ។ កាលណាប្រវត្តិវិទ្យាក្លាយទៅជាសង្គមវិទ្យា ពេលនោះហើយដែលគេសង្កេតឃើញលក្ខណៈនៃស្យង់សីលវិទ្យា ។

## ២- តើស្យង់ទាំងពីរខុសគ្នាត្រង់លក្ខណៈណាខ្លះ ?

– ស្យង់ទាំងពីរខុសគ្នាត្រង់លក្ខណៈខ្លះដូចជា ៖

– ស្យង់ធម្មជាតិមាន កំណត់និយមកំណើតរបស់ខ្លួនគេ ឯកការទោល ។

ឧទាហរណ៍: សត្វដង្កូវបានក្លាយទៅជាមេអំបៅតែពុំមានការប្ដូរនៅក្នុងសីលធម៌សោះឡើយ ។ ខុសគ្នានឹងមនុស្សដែលវិវត្តពីល្ងង់ខ្លៅទៅជាមានបញ្ញាដោយការសិក្សា, ការអប់រំ, ពោលគឺកំណត់និយមសម្ភារៈ (le déterminisme matérialiste)

– ស្យង់សីលវិជ្ជា មានសីលធម៌ដែលពិសេសរបស់ខ្លួនត្រង់វិវត្តន៍នៃវិចារណញ្ញាណដែលជាឧបករណ៍នៃគុណគុះ ។ មនុស្សខុសនឹងសត្វត្រង់វិវត្តន៍បញ្ញា ។



www.elibraryofcambodia.org

## ៣- សេចក្តីបញ្ចប់

— ស្យង់ធម្មជាតិ ដែលខុសនិងស្យង់សិល្បវិទ្យាត្រង់លក្ខណៈ សិល្បៈដែលខ្វះ ដោយកំណត់និយមមានឯកភាពខុសគ្នាពីធម្មជាតិមកក្តី ក៏គេសង្កេតឃើញថាមានលក្ខណៈស្របគ្នាដោយភាគច្រើនត្រង់លក្ខណ៍ទាំងឡាយ ដែលទាក់ទងនឹងវិចារណញ្ញាណ ។ ព្រោះថាគំហើញទាំងឡាយ ដោយពិភពលោកក្តី ស្យង់ដែលប្រើសម្ភារៈ ខុសនិងគំហើញ ដែលចេញពីវិភាគវិចារណញ្ញាណសុទ្ធសាធ ។

* * *



www.elibraryofcambodia.org

ប្រធានទី៤.— "តើគេអាចបញ្ចូលវិជ្ជាឯកទេសនៃស្យង់ទៅ ក្នុងវប្បធម៌ទូទៅ របស់មនុស្សបានឬទេ ? ហេតុអ្វី ? ចូរពន្យល់និងវិភាគ ។

( ប្រឡងវិញ - វិច្ឆិកា ឆ្នាំ ១៩៥០ .
វិញ្ញាសាសំរាប់ថ្នាក់ស្យង់ពិសោធន៍ )

តំរោងអត្ថាធិប្បាយ

## ១- សេចក្តីផ្តើម

— ពេលវេលាបាននាំមកអោយមនុស្សនូវចំណេះដែលខាងសភាពផ្សេងៗគ្នា ។ ចំណេះទាំងអស់ បានវិវត្តទៅរកការបែកចេញពីគ្នា ដែលមនុស្សពុំអាចប្រមូលយកមកទុកដាក់ជាសាធារណ សំរាប់ចំណេះផ្ទាល់របស់ខ្លួនម្នាក់ឯងបានឡើយ ។ គឺជាវិវត្តន៍ស្យង់ បានជ្រើសរើសនូវផ្លូវឯកទេសរបស់ខ្លួន (Spécialisation de la science) ។ លោកអូគុស្តកុង (A. Comte) ពោលថា : "គំហើញនៃទ្រឹស្តីបែកខ្ញែកជាលទ្ធផលពីសតវត្សក្រោយនេះ បាននាំមកនូវការចំរើនខាងការស្រាវជ្រាវក្នុងស្យង់ ព្រមទាំងបណ្តាលអោយមនុស្សឈប់មានកង្វល់ក្នុងកិច្ចការប្រចាំថ្ងៃរបស់ខ្លួន" ។ ឯកទេសក្នុងស្យង់រីកចំរើន រហូតនាំអោយ មតិខ្លះយល់ថា ជាចំណែកមួយនៃវប្បធម៌ទូទៅរបស់មនុស្ស ។ តើឯកទេសស្យង់នៃវប្បធម៌ទូទៅរបស់មនុស្សខុសគ្នាយ៉ាងដូចម្តេចខ្លះ ?

www.elibraryofcambodia.org

## ២- គួរសេចក្តី

### ១ - ឯកទេសក្នុងស្នងប្រឆាំងនឹងវប្បធម៌ទូទៅ :

ក - ការចំណេះទាំងឡាយរបស់វិទ្យាសាស្ត្រនៃចំណិត សុទ្ធតែជាកត្តាមួយនៃវប្បធម៌ ។ ប៉ុន្តែវប្បធម៌ដែលបានមកពីគំហើញ ជាឯកទេសហួសហេតុ នូវការលូតលាស់ទៅជាប្រឆាំងនឹងវប្បធម៌ពិតរបស់មនុស្សទៅវិញ ។

— វប្បធម៌ពិតគឺជាចំណោះមនុស្ស គឺការបណ្តុះបណ្តាលបញ្ញា ។

— អ្នកប្រាជ្ញឯកទេស ដែលគិតតែពីមុខងារឯកទេសរបស់ខ្លួនតែកក្រឡប់ ទៅជាល្ងង់ខ្លៅទៅវិញ ។ ព្រោះខ្លួនពុំបានស្គាល់វិជ្ជាដទៃទៀត របស់នូវការខ្វះនូវចំណេះ ទាំងឡាយដទៃដែលកំពុងវិវត្តទៅគ្មានទីបញ្ចប់ ។

— គំនិតឯកទេសបានធ្វើអោយខ្វះសតិអ្នកសិក្សា , ព្រោះជាគំនិតឯកត្តាតែម្នាក់ឯង ។

### ២ - ឯកទេសក្នុងស្នងប្រឆាំងនឹងវប្បធម៌មនុស្សជាតិ :

— ដើម្បីអោយបានគំនិតមនុស្សជាតិ គេត្រូវសាងមូលវត្ថុគតិ ដែលមានប្រយោជន៍ចំពោះមនុស្សទូទៅ ។

— ឯកទេសស្ងួតបណ្តុះគំនិតថ្មី ក៏ពិតមែនហើយតែ , វាបាននាំចិត្តមនុស្ស អោយរឹងរូសហៅ , ហើយក្រហឹន រកាំរកាច , មានអំនួតក្រអឺតប្រឆាំងនឹងគ្នាក្នុងសង្គមមនុស្ស ដោយការឆ្លើងឆ្លៃ ។

(la spécialisation scientifique risque d'enduroir le coeur et de rendre impoli)



www.elibraryofcambodia.org

— ក្នុងវិស័យគំនិត, ការភ័តជំពឹងខាងវៃឆ្លៀតវិចារថ្មី បានធ្វើ
អោយមានការប្រែប្រួលប្រែបល់ក្នុងទស្សនៈ ដែលរកគ្នាប់គិតនិង
ពិចារណាបួរហើយ ។

— វិជ្ជាឯកទេសក្នុងស្រែ នាំអោយមនុស្សល្ងង់ខ្លៅទៅវិញ
ព្រោះនាំមនុស្សអោយដើរតែក្នុងផ្លូវរបស់ខ្លួន ។

— អ្នកប្រាជ្ញផលិតគ្រឿងប្រហារខ្ទះសីលធម៌និងមនុស្សធម៌ ។

— អ្នកប្រាជ្ញឯកទេសល្បងក្នុងផ្លូវល្អ ជួយជីវិតមនុស្សក្នុង
វិស័យវេជ្ជវិទ្យា និងផលិតកម្មចំណីអាហារមកឱយខ្លួន ។

## ២ - មធ្យោបាយរួមនៃស្ទង់ឯកទេសខ្លះជាមួយវប្បធម៌មនុស្ស :

— ឯកទេសក្នុងស្រុង ជាជំនួយក្នុងវិស័យវប្បធម៌ ។

— កម្មវិធីសិក្សាសម័យបច្ចុប្បន្នខ្លះថ្វីបើយល់ថាវិជ្ជាឯកទេស
ជំរើសផ្លូវផ្សេងតែម្នាក់ឯងក៏ដោយ, ក៏ហាក់ដូចជានៅអោយ
គំលាតទៅលើគុណវិជ្ជារេះ ។

និក្ខេបបទ (thèse) នៃនិស្សិតនៅពេលចេញពីមហាវិទ្យា
ល័យ មានលក្ខណៈឯកទេសទាំងស្រុង ។

— វិជ្ជាឯកទេសបក្តីគំនិតថ្មី ចំពោះវិចារណញាណមនុស្ស
ដូចជាសំដីរបស់អ្នកប្រាជ្ញម្នាក់ពោលថា :

«សុវចិត្តអោយវប្បធម៌ខ្វែងគ្នា, ដើម្បីកុំអោយវិនាសដី »
(Il faut croiser les cultures pour ne pas ruiner
le sol)

— ចំពោះក្នុងវិស័យឯកទេសខ្លះបានធ្វើ អ្នកប្រាជ្ញជាច្រើន
ខាងស្ទង់ដូចជាលោក «រ៉ូសែល» (Russel) លោកបានថា



www.elibraryofcambodia.org

ទីវហេត» (whitehead). លោក «ហ៊ុយស៊ែល» (Husserl) លោក «ពៀស» (Peirce) ។ល។

ដោយពិចារណាតាមបែបទស្សនវិជ្ជា ពេលគឺបាននាំគ្នាសិក្សាពីទស្សនវិជ្ជាទៅវិញ ។

— អត្ថន័យមួយបានសិរយោគគំនិតឯកទេសនៃស្សង់ ចំពោះទ្រឹស្ដីមនុស្សថា : «ត្រូវទុកឲ្យឯកទេសកោយបន្តការស្រាវជ្រាវរបស់ខ្លួនចុះ កុំអោយបែកខ្ញែកឃ្លាតចាកពីគោលនៃបុរសមិមនុស្ស» ។

(Le spécialiste peut avoir son violon d' Ingres)

— ស្ត្រីមានវិជ្ជាឯកទេស របស់ខ្លួនក្នុងការថែទាំផ្ទះសំបែងនិងគ្រួសារ ។ គ្រួសារនិងសិល្បៈនៃគ្រួសារក្នុងការស្វែងរកសុភមង្គលក្រៅ ស្ត្រីទាំងឡាយបាត់ទុកជាវិជ្ជា ឯកទេសរបស់ខ្លួន ។

## ៣- សេចក្ដីបញ្ចប់

— គំហើញឯកទេសមានសារៈសំខាន់ កាលណាសិទ្ធិមនុស្សត្រូវគេគោរព ។ ស្សង់បង្កើតគ្រាប់បែកអ៊ីដ្រូសែន (Bombe H) មានសំណាចបញ្ចប់ការឈ្លានពានរបស់សត្រូវ ដែលឥតគោរពច្បាប់សកល ។

— គួររំលឹកសំដីលោក «ប៊ែរក្សុន» (Bergson) ដែលពោលថា «រូបកាយដែលលាតសន្ធឹងធំទៅ តែងតែទាមទារព្រលឹងពិសេសមួយ !» ពេលគឺមនុស្សត្រូវការអ្វីដែលពុំមែនធម្មតា ដើម្បីសង្គ្រោះ ។



www.elibraryofcambodia.org

— លោក «អាឡាំង» (Alain) ពោលថា «វប្បធម៌ត្រូវការសេចក្ដីលំបាក, តែលំបាកនោះត្រូវមានផ្លែផ្កាជាកុសល» ។

— ដូច្នេះ វប្បធម៌តែងត្រូវការឯករទេសក្នុងសង្គំជាតិខ្មែរក្នុងលក្ខណៈជា «ឥត្ថភាពពិសេស»
(mystique du dépassement) ។

* * *



www.elibraryofcambodia.org

ប្រធានទី៩.– "ចូរពិចារណាការលើគំនិត របស់ទស្សនវិទូសម័យបច្ចុប្បន្នម្នាក់ដែលពោលថា៖ តក្កវិជ្ជា គឺជាសីលវិជ្ជានៃគំនិតដូចជាសីលវិជ្ជាជាតក្កវិជ្ជានៃអំពើ" ចូររិះគន់តាមបែបទស្សនវិជ្ជានូវទស្សនវាទលើនេះ ។

(ក្រុងទួលូស - ខែឧសភា ឆ្នាំ ១៩៥០ - វិញ្ញាសា សំរាប់ថ្នាក់ទស្សនវិជ្ជា)

## គំរោងអត្ថាធិប្បាយ

### ១- សេចក្តីផ្តើម

— សរញ្ញកនាំនៃមុខងាររបស់មនុស្ស ឬ ទស្សនគតិរបៀបបាន និងកំណាចនៃវិចារ ។

— ដាការគម្ពីរនៃវែលទស្សនវិទូបានបញ្ចូលនេះទស្សនទាំងពីរ នេះទៅក្នុងន័យស្របគ្នាមួយ ។

— សេចក្តីស្នេហារបស់លើគំនិតជា វង់តាបានរំលឹកពីករណី សីលវិជ្ជាដែលនៅក្នុងនោះមានតក្កភាព ។

— ផ្ទុយទៅវិញ តក្កភាពនិងវិចារនៃកត្រូវមកសីលវិជ្ជាផ្ទេរ ទុកជាដាំកោលការណ៍ប្រកបដោយអំពើ ។

តើវិជ្ជាទាំងពីរនេះមានទំនាក់ទំនងនឹងគ្នាយ៉ាងដូចម្តេចខ្លះ ?

### ២- តួសេចក្តី

១- តក្កវិជ្ជានិងសីលវិជ្ជា ពុំអាចបែកចេញពីគ្នាបានឡើយ៖

ក- ព្រោះវិជ្ជាទាំងពីរមានគម្ពីរវត្ថុរបស់ខ្លួនមួយស្របគ្នាគឺ៖



www.elibraryofcambodia.org

— មិនច្រឡំការអ្វីដែលកំណត់រួចហើយ (déterminisme) តែច្រឡំការអ្វីដែលកន្លងហើយយ៉ាងច្បាស់, និងច្រឡំការអ្វីដែលបង្ហាប់ដោយច្បាប់សកល ។

— សន្ធានបុរាណត្រូវតែល្អនៃវិជ្ជានេះ ទៅតាមសំណុំជាមួយគ្នា : ឧទាហរណ៍ ; តក្កភាព - សច្ចៈភាព - សីលវិជ្ជាកុសល, ករណីយកិច្ច ។ល។

— អ្នកប្រាជ្ញតក្កវិទ្យា ពុំហ៊ាននិយាយពីអរូបីដោយគុណភាពរបស់អ្វីដែលប្រែប្រួលដោយ តក្កភាពក្នុងខ្លួន (ឧទាហរណ៍ៈ ប្រែបានកើតរួត, ផ្លាស់ប្តូរលក្ខណៈ, ហើយនៅខាងសទៅវិញ) ។

— តក្កវិជ្ជា វិជ្ជការលើសញ្ញាណពិតប្រាកដដើម្បីបញ្ជាក់សច្ចៈ តើអាចជៀសវាង សីលវិជ្ជាបាន ឬទេ?

## ខ- ថ្វីបើមានសភាពស្របគ្នាក៏ដោយ ក៏យើងឃើញថា "តក្កវិជ្ជា ពុំមែនជា "សីលវិជ្ជានៃគំនិត" ហើយ "សីលវិជ្ជាពុំមែនជាតក្កវិជ្ជានៃអំពើ" ទេ ។

— គំនិតគឺជា ឧបករណ៍ដែលមានសារៈសំខាន់នៃវិស័យសីលវិជ្ជា ព្រោះថា គំនិតដែលយើងគិតពិចារណារាល់ថ្ងៃបានបង្កើតនូវបរិយាកាសមួយក្រោមទាំងបង្កើតនូវសំរេច និងសំរាប់ដាស់សតិយើងអោយធ្វើអំពើល្អមួយ ។

— ដូចនេះសីលធម៌ពុំមែនកើតមកពីតក្កភាពទេ ។

— ហើយតក្កភាពក៏ពុំអាចបង្កើតអំពើបានដែរ ។

— ចិត្តបង្កើតអំពើ ព្រោះថាបើចិត្តពុំបង្កើតសកម្មភាពរបស់ខ្លួនទេ, គ្មានអ្វីធ្វើអំពើបានឡើយ ។



www.elibraryofcambodia.org

«អ្នកត្រូវធ្វើជានិច្ច របៀបណាដែលគោលគំនិតនៃឆន្ទៈរបស់អ្នកមានតំលៃដូចជាគោលការណ៍ នៃនីតិសកល» (Agis toujours de telle sorte que la maxime de ta volonté puisse valoir en même temps comme principe d'une législation universelle).

**២-សេចក្ដីបញ្ចប់**— ត្រូវបញ្ជាក់សេចក្ដីខ្លះដើម្បីបញ្ចប់ដូចជា៖

— ការរស់នៅរបស់មនុស្ស ត្រូវចេះសំរបខ្លួនទៅតាមសង្គមមនុស្ស ។ ត្រូវចេះសាងកុសលផង និងពិចារណាក្នុងអំពើនោះផង ។ បើពុំដូច្នោះទេ សុភមង្គលក្នុងលោកនិយមិនប្រាកដជាកើតឡើយ ។

— «យើងមិនអាចចូលប្រយុទ្ធក្នុងសមរភូមិ ដោយកាន់ផ្កាកុលាបមួយនៅដៃទេ» នេះជាសំដីណាកគង់ ។ (Nous ne voudrions pas traverser la bataille une rose à la main) ។

— «ព្រះនឹងជួយជនណាដែលបានជួយខ្លួនឯង» ។

www.elibraryofcambodia.org

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេនជា eBook ដោយ ហ៊ីង ធារ៉ា
ខែឧសភា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្មៅ យុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

www.elibraryofcambodia.org